CIMB BANK ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី

របាយការណ៍ប្រចាំឆ្នាំ ២០១២

កម្លាំងរួមផ្សំនឹងថ្វីដៃដ៏ចំណាន

ដៃមួយគូរបស់យើងអាចបង្កើតអោយមានជាវត្ថុដ៏អស្ចារ្យជាច្រើន។ ដៃដែលមានទេពកោសល្យជាមួយឧបករណ៍ត្ន្ត្រី អាចបង្កើតជាបទភ្លេងយ៉ាងពិរោះរណ្តំ។ ចំណែកឯដៃដ៏ចំណានរបស់វិចិត្រករជាមួយជក់ និងទឹកថ្នាំពណ៌អាចគូសវាសចេញជាផ្ទាំងគំនូរដ៏ស្រស់ស្អាតពោរពេញទៅដោយភាពទាក់ទាញ។ ជាមួយនឹងកម្លាំងដៃ និងភាពប៉ិនប្រសប់ ថ្មដ៏រឹងមាំមួយដុំអាចក្លាយជាចម្លាក់មួយផ្ទាំងប្រកបដោយក្បួរក្បាច់រចនាយ៉ាងប្រណីត។ ដៃទាំងទ្វេ រវាំងារបាំ អាចរៀបរាប់ប្រាប់រឿងមួយដ៏លម្អិត។ ដូចគ្នានឹងដៃដ៏ចំណាន និងប៉ិនប្រសប់របស់សិល្បករទាំងនេះ ការខិតខំប្រឹងប្រែង ការប្តេជ្ញាចិត្ត និងជំនាញរបស់បុគ្គលិកធនាគារ ស៊ីអាយអ៊ីមប៊ីក៏អាចបំពេញនូវតម្រូវការទីផ្សារនានារបស់អតិថិជនខ្លួនផងដែរ។

ការខិតខំប្រឹងប្រែងបំពេញការងារយ៉ាងសកម្ម នាំមកនូវការរីកចម្រើន ហើយការរីកចម្រើននេះផងដែរអាចទទួលបានដោយមានការគាំទ្រពីការកំណត់ប្រចាំនៅក្នុងផ្នែកច្បាប់ និងបទប្បញ្ញត្តិ។ ផលិតផលក្នុងស្រុកសរុប ៧,៣ %(គិតត្រឹមខែកក្កដា ឆ្នាំ២០១២) ប្រទេសកម្ពុជាមានការរីកចម្រើនលើគ្រប់វិស័យ។ នេះជាឱកាសដ៏ល្អប្រសើរបំផុតក្នុងការធ្វើជំនួញនៅប្រទេសកម្ពុជា។

ចាប់តាំងពីធនាគារ ស៊ីអាយអ៊ីមប៊ី ចាប់ផ្តើមដំណើរការនៅក្នុងប្រទេសកម្ពុជារយៈពេល២ឆ្នាំកន្លងមកនេះ យើងទទួលបាននូវបទពិសោធន៍ជាច្រើន និងបានសម្របទៅតាមកាលៈទេសៈនានា។ បទពិសោធន៍ និងចំណេះដឹងក្នុងស្រុក រួមផ្សំជាមួយនឹងសមត្ថភាពក្នុងតំបន់របស់យើង បានធ្វើអោយយើងមានជំហរកាន់តែរឹងមាំក្នុងការបម្រើសេវាកម្មជូនអតិថិជនរបស់យើង។ ជាមួយ ៣ក្យស្លោករបស់យើងថា 'អាស៊ានសម្រាប់អ្នក (ASEAN For You)' យើងបានធ្វើការណែនាំជូននូវផលិតផល និងសេវាកម្មថ្មីល្អៗ ដែលក្នុងចំណោមនោះមាន Regional ATM Link ដែលជាសេវាកម្មបណ្តាញអេធីអឹមក្នុងតំបន់ សម្រាប់ភ្ជាប់អតិថិជនរបស់យើងឱ្យធ្វើប្រតិបត្តិការបានគ្រប់ពេលវេលាតាមតម្រូវការមិនថានៅក្នុងប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី សឹង្គបូរី ឬប្រទេសថៃ។ 'ASEAN For You' ក៏ឆ្លុះបញ្ចាំងអំពីទំនុកចិត្តរបស់យើងនៅក្នុងការធ្វើប្រតិបត្តិការឆ្លងប្រទេស និងការពង្រីកវិសាលភាពរបស់យើងនៅក្នុងតំបន់ផងដែរ។

មាតិកា

៤	សារតារបស់ធនាគារ
៥	តម្លៃស្នូលរបស់ស្ថាប័ន
៦	សារពីប្រធានក្រុមប្រឹក្សាភិបាល
៨	ការពិនិត្យមើលសមិទ្ធផលដោយអគ្គនាយក
១០	សារពីប្រធាននាយកប្រតិបត្តិនៃក្រុមហ៊ុនមេ
១២	ការពិនិត្យមើលធុរកិច្ច
២០	ស៊ីអាយអ៊ីមប៊ី កម្ពុជា នៅក្នុងសារព័ត៌មាន
២២	ព្រឹត្តិការណ៍សំខាន់ៗ
២៨	សេចក្តីថ្លែងការណ៍អំពីអភិបាលកិច្ចរបស់ធនាគារ
៣៧	របាយការណ៍របស់គណៈកម្មាធិការសវនកម្ម
៣៩	សេចក្តីថ្លែងការណ៍អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
៤៣	រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនមេ
៤៤	រចនាសម្ព័ន្ធរបស់ធនាគារ
៤៥	របាយការណ៍ព័ត៌មានរបស់ធនាគារ
៤៦	ប្រវត្តិរូបសង្ខេបរបស់ក្រុមប្រឹក្សាភិបាល
៥១	ប្រវត្តិរូបសង្ខេបរបស់លេខាធិការធនាគាររួម
៥២	ប្រវត្តិរូបសង្ខេបរបស់គណៈកម្មាធិការគ្រប់គ្រង
៥៧	បណ្តាញសាខា
៥៨	របាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្ម
១០៤	បណ្តាញសាខារបស់ក្រុមហ៊ុនមេ

សាវតា
របស់ធនាគារ

អំពីធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចាប់ផ្តើមប្រតិបត្តិការនៅក្នុងទីផ្សារប្រទេសកម្ពុជានៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយបានបើកសាខាធនាគារពាណិជ្ជទីមួយ នៅចំកណ្តាលរាជធានីភ្នំពេញ។ រហូតមកដល់បច្ចុប្បន្ននេះ ធនាគារមានសាខាចំនួន១១កន្លែង និងម៉ាស៊ីនអេធីអិមចំនួន១៧កន្លែង នៅក្នុងខេត្ត ក្រុងសំខាន់ៗចំនួនប្រាំ នៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានរាជធានីភ្នំពេញ ក្រុងសៀមរាប ព្រះសីហនុ បាត់ដំបង និងកំពង់ចាម។ បច្ចុប្បន្ននេះ យើងកំពុងបម្រើសេវាកម្មជូនដល់អតិថិជនជាក្រុមហ៊ុន និងឯកត្តបុគ្គលជាង ៤០០០នាក់។ នៅក្នុងឆ្នាំ២០១២ យើងបានណែនាំជូនទីផ្សារកម្ពុជានូវផលិតផលថ្មីៗ ដែលក្នុងនោះរួមមាន សេវាកម្ម Regional ATM Link ។ ធនាគារ ស៊ីអាយអិមប៊ី ក៏បានពង្រីកអាជីវកម្មតាមរយៈអនុភាពស្លាកសញ្ញា CIMB Preferred សម្រាប់ទីផ្សារអតិថិជនជាន់ខ្ពស់នៅក្នុងប្រទេសកម្ពុជាផងដែរ។

បច្ចុប្បន្ន ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី មាននិយោជិតជាជនជាតិខ្មែរជាង ១០០នាក់ដែលមានបទពិសោធន៍ និងជំនាញផ្សេងៗគ្នាទាំងក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ក៏ដូចជាវិស័យផ្សេងៗទៀតផងដែរ។ ជាស្ថាប័នដែលយកចិត្តទុកដាក់ដល់សង្គមក្នុងប្រទេសកម្ពុជា ធនាគារស៊ីអាយអិមប៊ី ភីអិលស៊ី បានចូលរួមចំណែកជួយសង្គមតាមរយៈគម្រោងសហគមន៍ និងអប់រំជូនដល់សហគមន៍ដែលខ្លួនបម្រើការជូន។

ធនាគារ ស៊ីអាយអិមប៊ី នៅក្នុងប្រទេសកម្ពុជា បានប្តេជ្ញាចិត្ត ថានឹងកសាងអនាគតហិរញ្ញវត្ថុឱ្យរឹងមាំ និងយូរអង្វែងសម្រាប់អតិថិជនរបស់ខ្លួន ហើយនឹងបន្តព្យាយាមបង្កើតឱកាស និងគុណតម្លៃតាមរយៈផលិតផល និងសេវាកម្មថ្មីៗមានអត្ថ-ប្រយោជន៍ខ្ពស់។ ធនាគារ ស៊ីអាយអិមប៊ី មានមោទនភាពក្នុងការដែលខ្លួនមិនត្រឹមតែជាអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាដៃគូអាជីវកម្មដ៏ល្អមួយរបស់អតិថិជននៅក្នុងប្រទេសកម្ពុជា។

អំពី ស៊ីអាយអិមប៊ី ហ្គ្រុប

ស៊ីអាយអិមប៊ី ហ្គ្រុប គឺជាស្ថាប័នសេវាកម្មហិរញ្ញវត្ថុធំជាងគេទីពីរនៅប្រទេសម៉ាឡេស៊ី និងជាធនាគារសាកលនាំមុខគេមួយក្នុងតំបន់អាស៊ាន។ ស៊ីអាយអិមប៊ី ហ្គ្រុប ធ្វើការផ្តល់ជូននូវសេវាកម្មធនាគារពាណិជ្ជ ធនាគារវិនិយោគ និងធនាគារអ៊ីស្លាម ក៏ដូចជាផលិតផល និងសេវាកម្មគ្រប់គ្រងទ្រព្យសកម្ម និងធានារ៉ាប់រង។ ស៊ីអាយអិមប៊ី ហ្គ្រុប មានទីស្នាក់ការធំនៅទីក្រុងកូឡាឡាំពួរ ហើយបច្ចុប្បន្ននេះមានវត្តមាននៅប្រទេសចំនួន៩ ក្នុងចំណោមប្រទេសទាំង១០ ក្នុងតំបន់អាស៊ាន (ប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី សិង្ហបូរី ថៃ ហ្វីលីពីន កម្ពុជា ប្រ៊ុយណេ វៀតណាម និងមីយ៉ានម៉ា)។ ក្រៅពីតំបន់អាស៊ាន ស៊ីអាយអិមប៊ី ហ្គ្រុប ក៏មានវត្តមាននៅក្នុងទីផ្សារប្រទេសចិន ហុងកុង បារ៉ែន ឥណ្ឌា ស្រីលង្កា អូស្ត្រាលី តៃវ៉ាន់ កូរ៉េ សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស។

ស៊ីអាយអិមប៊ី ហ្គ្រុប មានបណ្តាញសាខាធំជាងគេនៅក្នុងតំបន់អាស៊ានជាមួយសាខាជាង ១.១០០ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១២។ ធនាគារវិនិយោគរបស់ស៊ីអាយអិមប៊ី ហ្គ្រុប ក៏បានក្លាយជាធនាគារវិនិយោគក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកដែលធំជាងគេ បន្ទាប់ពីការប្រកាសទិញធនាគារវិនិយោគរបស់ RBS's Asia Pacific និងប្រតិបត្តិការភាគហ៊ុនជាច្រើនទៀត តាមរយៈសាច់ប្រាក់។

ស៊ីអាយអិមប៊ី ហ្គ្រុប ដំណើរការអាជីវកម្មរបស់ខ្លួនតាមរយៈ អង្គភាពចម្បងបី គឺធនាគារ ស៊ីអាយអិមប៊ី (CIMB Bank) ធនាគារវិនិយោគ ស៊ីអាយអិមប៊ី (CIMB Investment Bank) និងធនាគារ ស៊ីអាយអិមប៊ី អ៊ីស្លាមមិក (CIMB Islamic)។ ស៊ីអាយអិមប៊ី ហ្គ្រុប មានភាគហ៊ុនចំនួន ៩៧,៥% នៅក្នុងធនាគារ ស៊ីអាយអិមប៊ី នៀហ្គា (CIMB Niaga) នៅប្រទេសឥណ្ឌូនេស៊ី និងមានភាគហ៊ុន ៩៣,៧% នៅក្នុងធនាគារ ស៊ីអាយអិមប៊ីថៃ (CIMB Thai) នៅក្នុងប្រទេសថៃផងដែរ។

ស៊ីអាយអិមប៊ី ហ្គ្រុប ត្រូវបានចុះផ្សាយនៅលើទីផ្សារភាគហ៊ុនប៊ូរសាម៉ាឡេស៊ី (Bursa Malaysia) តាមរយៈស៊ីអាយអិមប៊ី ហ្គ្រុបហូលឌីងប៊ីហាដ (CIMB Group Holding Berhad)។ ធនាគារនេះ មានតម្លៃក្រុមហ៊ុននៅលើទីផ្សារភាគហ៊ុនប្រហែល ៥៥,៧៥ ពាន់លានរីងហ្គីតម៉ាឡេស៊ី គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១២។ ស៊ីអាយអិមប៊ី ហ្គ្រុប មាននិយោជិតជាង ៤៣.០០០នាក់ នៅក្នុងបណ្តាប្រទេសទាំង១៨។

តម្លៃស្នូល
របស់ស្ថាប័ន

ការផ្តោតការយកចិត្តទុកដាក់លើអតិថិជន

វត្តមានរបស់យើង គឺដើម្បីបម្រើអតិថិជនព្រមទាំងផ្តល់ជូនសេវាកម្ម និង
ផលិតផលតាមការយល់ដឹង និងផ្តល់តម្លៃរបស់អតិថិជន។

សមិទ្ធកម្មខ្ពស់

យើងខិតខំបំពេញការងារយ៉ាងសកម្ម និងជាមួយយុទ្ធសាស្ត្រជាក់លាក់
សម្រាប់អតិថិជន បុគ្គលិក និងភាគីពាក់ព័ន្ធទាំងអស់។

ការផ្តល់លទ្ធភាពដល់បុគ្គលិក

យើងផ្តល់អំណាច និងតម្រង់ទិសដល់បុគ្គលិកអោយមានគំនិតច្នៃប្រឌិត និង
ផ្តល់គុណតម្លៃដល់ស្ថាប័ន ក៏ដូចជាសហគមន៍ដែលគាត់បម្រើការជូន។

កម្លាំងនៃភាពចម្រុះគ្នា

យើងមានការគោរពចំពោះវប្បធម៌ផ្សេងៗគ្នា និងផ្តល់គុណតម្លៃលើទស្សនវិស័យ
ផ្សេងៗ ហើយយើងយល់ឃើញថាភាពចម្រុះគ្នា គឺជាប្រភពនៃកម្លាំង។

សុចរិតភាព

យើងបំពេញរាល់ការងារជាមួយភាពស្មោះត្រង់ ការគោរព និងវិជ្ជាជីវៈ
ច្បាស់លាស់ ពីព្រោះសុចរិតភាព គឺជាគុណតម្លៃស្នូលរបស់ ស៊ីអាយអ៊ីមប៊ី ហ្ស្រុប។

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលតែងតែមានកិត្តិនាមល្បីល្បាញ ដោយសារកេរ្តិ៍ដំណែលវប្បធម៌ដ៏សម្បូរបែបរបស់ខ្លួន។ នៅប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសកម្ពុជាបានកសាងខ្លួនឱ្យទៅជាប្រទេសដ៏សំខាន់មួយ ដែលមានភាពលេចធ្លោទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ចនៅក្នុងតំបន់។

សារពី
ប្រធានក្រុមប្រឹក្សាភិបាល

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលតែងតែមានកិត្តិនាមល្បីល្បាញដោយសារកេរ្តិ៍ដំណែលវប្បធម៌ដ៏សម្បូរបែបរបស់ខ្លួន។ នៅប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសកម្ពុជាបានកសាងខ្លួនឱ្យទៅជាប្រទេសដ៏សំខាន់មួយ ដែលមានភាពលេចធ្លោទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ចនៅក្នុងតំបន់ ។ ជាក់ស្តែងប្រទេសកម្ពុជាបានធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំកំពូលអាស៊ានលើកទី២០ និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី៧ យ៉ាងជោគជ័យនៅក្នុងឆ្នាំ ២០១២ កន្លងទៅនេះ។ ស្ថិរភាពនយោបាយ និងគោលនយោបាយបើកចំហរចំពោះការវិនិយោគ បានបង្កើតបរិយាកាសវិនិយោគទុនដ៏គួរឲ្យទាក់ទាញមួយនៅក្នុងប្រទេសកម្ពុជា។ ប្រទេសកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ជាមួយនឹងកំណើនផលិតផលក្នុងស្រុកសរុបចំនួន ៧,៣% នៅឆ្នាំ ២០១២។ យើងឃើញថា ប្រភពនៃកំណើនសេដ្ឋកិច្ចនេះកើតចេញពីកត្តាជាច្រើន។ ឧស្សាហកម្មទេសចរណ៍ នៅតែបន្តរីកចម្រើនជាមួយនឹងការអញ្ជើញមកទស្សនារបស់ភ្ញៀវទេសចរបរទេសជាង ២លាននាក់ក្នុងមួយឆ្នាំចាប់តាំងពីឆ្នាំ២០០៧ ហើយការនាំចេញកៅស៊ូបានកើនឡើងប្រមាណជា ១២% ដោយសារតម្រូវការផ្នែកកៅស៊ូនៅតែមានជាបន្តបន្ទាប់ ជាពិសេសតម្រូវការពីប្រទេសចិន ប្រទេសម៉ាឡេស៊ី និងប្រទេសវៀតណាម នាឆ្នាំ២០១២ នេះ។ ធនាគារ ស៊ីអាយអ៊ីមប៊ី បាននិងកំពុងធ្វើការវិនិយោគនៅប្រទេសកម្ពុជា ដោយសារយើងពិនិត្យឃើញថា វិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានឹងបន្តលូតលាស់តទៅមុខទៀត ហើយជឿជាក់ថាប្រតិបត្តិការ និងសេវាកម្មរបស់យើងមានភាពសក្តិសមបំផុត ក្នុងការគាំទ្រទាំងពាណិជ្ជកម្មដែលមានមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា ក៏ដូចជាពាណិជ្ជកម្មដែលភ្ជាប់ទំនាក់ទំនងជាមួយបណ្តាប្រទេសក្នុងតំបន់ និងពាណិជ្ជកម្មនានាក្នុងតំបន់ដែលស្វែងរកឱកាសវិនិយោគនៅក្នុងប្រទេសកម្ពុជា។

ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី ទើបតែចាប់ផ្តើមដំណើរការប្រតិបត្តិការធនាគាររបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជាបានរយៈពេល២ឆ្នាំប៉ុណ្ណោះ។ ចាប់តាំងពីចាប់ផ្តើមដំណើរការមក ធនាគារបានបង្កើតសាខាចំនួន១១ ដែលក្នុងនោះសាខាថ្មីចំនួន៤ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១២។ ធនាគារ ក៏មានការិយាល័យសម្រាប់បម្រើសេវាកម្មធនាគារសម្រាប់អតិថិជនជាន់ខ្ពស់ (Preferred Center) ចំនួន ៤កន្លែង ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM) ចំនួន១៧ ម៉ាស៊ីនដាក់ប្រាក់ស្វ័យប្រវត្តិ (CDM) ចំនួន១១ និងម៉ាស៊ីនដាក់មូលប្បទានបត្រ (CDT) ចំនួន១១ នៅតាមបណ្តាទីក្រុងសំខាន់ៗចំនួន៥ ទូទាំងប្រទេសផងដែរ ដែលរួមមានរាជធានីភ្នំពេញ ក្រុងសៀមរាប ក្រុងព្រះសីហនុ ក្រុងបាត់ដំបង និងក្រុងកំពង់ចាម។ ក្រៅពី សាខាថ្មីទាំង៤ នេះ លទ្ធផលនៃការធ្វើប្រតិបត្តិការសំខាន់ៗផ្សេងទៀតដែលសម្រេចបាននៅក្នុងឆ្នាំ២០១២ មានដូចជាកំណើនទ្រព្យសកម្មរបស់ធនាគារពី ៨៩,៥លានដុល្លារអាមេរិក ទៅ ១៦៥,៦លានដុល្លារអាមេរិក ដែលជាលទ្ធផលនៃកំណើនតណទានពី ៤២,៤លានដុល្លារអាមេរិក ទៅ ៨៤,៦លានដុល្លារអាមេរិក និងកំណើនប្រាក់បញ្ញើរបស់អតិថិជនពី ៤៩,៦លានដុល្លារអាមេរិក ទៅ ៩៨,៤លានដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំកន្លងទៅ។ ការពង្រីកខ្លួនយ៉ាងឆាប់រហ័សនេះ គឺជាការបង្ហាញឱ្យឃើញកាន់តែច្បាស់អំពីការតាំងចិត្តយ៉ាងមុតមាំក្នុងការធ្វើឱ្យវត្តមានរបស់ធនាគារស៊ីអាយអ៊ីមប៊ី ភីអិលស៊ី មានភាពរឹងមាំ ដើម្បីអាចឲ្យធនាគារយើងផ្តល់ជូននូវសេវាកម្មប្រកបដោយគុណភាព និងប្រសិទ្ធភាពនៅលើទីផ្សារកម្ពុជា ។ កន្លងមកធនាគារស៊ីអាយអ៊ីមប៊ី ភីអិលស៊ី បាននាំមកនូវផលិតផល និងសេវាកម្មប្រកបដោយការច្នៃប្រឌិតថ្មីៗជាច្រើន ដើម្បីបំពេញតាមតម្រូវការរបស់អតិថិជនជាក្រុមហ៊ុន ក៏ដូចជា អតិថិជនជាឯកត្តបុគ្គលរបស់ធនាគារ ដែលរួមមាន ការវិនិយោគរូបិយប័ណ្ណទ្វេ (Dual Currency Investment)បណ្តាញម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិក្នុងតំបន់ (Regional ATM Link) និងសេវាកម្មធនាគារសម្រាប់អតិថិជនជាន់ខ្ពស់ (Preferred Banking)។ ជាមួយនឹងបុគ្គលិកធនាគារដែលទទួលបានការបណ្តុះបណ្តាលកម្រិតខ្ពស់ប្រមាណជាង ១០០នាក់ ធនាគារមានមោទនភាពក្នុងការប្រកាសថាការបម្រើសេវាកម្មអតិថិជនជាអាទិភាពទីមួយរបស់យើង។ ម្យ៉ាងវិញទៀត អស់រយៈពេលជាង២ឆ្នាំ ក្នុងការធ្វើប្រតិបត្តិការជាធនាគារពាណិជ្ជ ធនាគារបានធ្វើឱ្យអតិថិជនគ្រឹះរបស់ខ្លួន មានការកើនឡើងរហូតដល់ ៧.៣៥៨នាក់។

ទន្ទឹមនឹងនេះ ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី បានផ្តល់នូវភាពងាយស្រួលដល់អតិថិជនក្នុងការទទួលបានការបម្រើសេវាកម្មរបស់ធនាគារនៅគ្រប់ទីកន្លែងនៅក្នុងតំបន់ដែលពួកគេទៅដល់ ស្របតាមពាក្យស្លោកមួយរបស់ធនាគារ 'អាស៊ានសម្រាប់អ្នក (ASEAN For You)'។ អតិថិជនរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី អាចចូលទៅកាន់បណ្តាញសាខានានារបស់យើងដែលមានចំនួនជាង ១.១០០ នៅតាមបណ្តាប្រទេសអាស៊ាន។ ក្នុងនាមជាធនាគារអាស៊ាន យើងយល់ច្បាស់អំពីតម្រូវការរបស់អតិថិជន ហើយយើងបានប្រើប្រាស់ជាប្រយោជន៍នូវអ្វីដែលមានភាពដូចគ្នា និងភាពដោយឡែកពីគ្នានៃប្រព័ន្ធអាស៊ានរបស់ធនាគារ ដើម្បីផ្តល់ជូនអតិថិជននូវអត្ថប្រយោជន៍ថ្នាក់តំបន់។

ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី ក៏មានមោទនភាពផងដែរក្នុងការចូលរួមចំណែកក្នុងសង្គមមួយដ៏ល្អ ហើយធនាគារនឹងបន្តចូលរួមជាវិភាគទានដល់គម្រោងនានាលើផ្នែកអប់រំ និងគម្រោងសហគមន៍ ជាច្រើនបន្ថែមទៀត។ ជាក់ស្តែងនៅឆ្នាំ២០១២ បុគ្គលិករបស់យើងបានស្ម័គ្រចិត្តធ្វើការបរិច្ចាគឈាម និងរៀបចំឱ្យមានការជួបជុំគ្នាជាច្រើន ដើម្បីចែករំលែកចំណេះដឹងដល់កុមារៗសិស្សសាលានៅតាមសហគមន៍ជនបទនានា។ ធនាគារក៏បានបន្តការឧបត្ថម្ភគាំទ្ររបស់ខ្លួនចំពោះសកម្មភាពនានារបស់កាកបាទក្រហមកម្ពុជាផងដែរ។

តាងនាមឲ្យក្រុមប្រឹក្សាភិបាល និងក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាលរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី ខ្ញុំសូមឆ្លៀតឱកាសនេះសម្តែងនូវការកោតសសើរយ៉ាងជ្រាលជ្រៅចំពោះធនាគារជាតិនៃកម្ពុជា និងបណ្តានិយ័តករនានា ព្រមទាំងអតិថិជនទាំងអស់របស់ធនាគារ ក្រុមការងារបង្កើតគោលការណ៍ និងបុគ្គលពាក់ព័ន្ធដទៃទៀតចំពោះការបន្តកិច្ចគាំទ្រដល់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី ក្នុងអំឡុងពេលពេញមួយឆ្នាំនេះ។ ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណចំពោះគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី សម្រាប់ការធ្វើប្រតិបត្តិការដ៏ជោគជ័យដែលបានសម្រេចឡើងនៅក្នុងឆ្នាំ២០១២។ ខ្ញុំមានមោទនភាពជាខ្លាំងដែលធនាគារយើងមានក្រុមការងារប្រកបដោយវិជ្ជាជីវៈ និងមានការលះបង់ខ្ពស់ ចំពោះការងារដែលទាំងនេះជាកត្តាជម្រុញឲ្យអនាគតរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី កាន់តែភ្លឺចិញ្ចែងចិញ្ចាច និងឈានទៅមុខជានិច្ច។

DATO' SHAARANI IBRAHIM
ប្រធានក្រុមប្រឹក្សាភិបាល

ការពិនិត្យមើលសមិទ្ធិផលដោយ

អគ្គនាយក

បរិយាកាសនៃប្រតិបត្តិការឆ្នាំ២០១២

អត្រាកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានកើនឡើងប្រមាណ ៧% នៅក្នុងឆ្នាំ ២០១២ ដែល បង្ហាញអំពីលទ្ធផលគួរឲ្យរីករាយ បើប្រៀបធៀបទៅនឹងតួលេខកើនឡើងក្នុងឆ្នាំ២០១១ ដែលមានចំនួនត្រឹមតែ ៦,១% ប៉ុណ្ណោះ។ រីឯសន្ទស្សន៍អតិផរណានៅរក្សាបានត្រឹមអត្រា ៥% ដដែល។ ការវិនិយោគផ្ទាល់ពីបរទេស (FDI) ត្រូវបានរំពឹងទុកថានឹងបន្តកើនឡើងរហូតដល់ ០,៧៥ពាន់លានដុល្លារអាមេរិករួមជាមួយ នឹងទុនបម្រុងបរទេសដែលកើនឡើងដល់ ៣,៨៦ពាន់លានដុល្លារអាមេរិក ដែលឆ្លុះបញ្ចាំងឱ្យឃើញនូវការកើនឡើងនៃប្រាក់បញ្ញើធនាគារសរុបចំនួន ២៤% និងឥណទានធនាគារសរុបចំនួន ៣០% បើប្រៀបធៀបនឹងឆ្នាំកន្លងទៅ។

សូចនាករសេដ្ឋកិច្ច	២០០៨	២០០៩	២០១០	២០១១	២០១២*	២០១៣
ផលិតផលក្នុងស្រុកសរុប (គិតជាពាន់លានដុល្លារអាមេរិក)	១១,៣	១០,៩	១១,៦	១៣,០	១៤,៣	១៥,៨
សន្ទស្សន៍អតិផរណា	២៥,០%	-0,៧%	៤,0%	៥,0%	៥,២%	៣,៦%
ការនាំចេញ (គិតជាពាន់លានដុល្លារអាមេរិក)	៤,៧១%	៤,៣0%	៥,២0%	៤,៨៧%	៥,៨៦%	៦,៨៦%
ការនាំចូល (គិតជាពាន់លានដុល្លារអាមេរិក)	៦,៥១%	៥,៨៨%	៦,៨0%	៦,៦0%	៧,៨៨%	៨,៩៤%
ការវិនិយោគផ្ទាល់ពីបរទេស (គិតជាពាន់លានដុល្លារអាមេរិក)	0,៨0%	0,៥២%	0,៦0%	0,៦៨%	0,៧៥%	0,៨២%
ប្រាក់បញ្ញើធនាគារ (គិតជាពាន់លានដុល្លារអាមេរិក)	២,៥%	៣,៣%	៤,៣%	៥,២%	៦,៤%	N/A
ឥណទានធនាគារ (គិតជាពាន់លានដុល្លារអាមេរិក)	២,៤%	២,៥%	៣,២%	៤,២%	៥,៥%	N/A
ការវិនិយោគផ្ទាល់ពីបរទេស (គិតជាពាន់លានដុល្លារអាមេរិក)	២,១៦%	២,៣៧%	២,៦៥%	៣,0៣%	៣,៤៦%	៣,៨៧%

ប្រភព: អង្គការមូលនិធិរូបិយប័ណ្ណពិភពលោក ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី

**ការប៉ាន់ស្មាន*

កំណើនសេដ្ឋកិច្ចនេះ គឺជាលទ្ធផលនៃការរីកចម្រើនដ៏ខ្លាំងក្លាក្នុងវិស័យកសិកម្ម ដែលបានចូលរួមចំណែកចំនួន ៣0% នៃផលិតផលក្នុងស្រុកសរុប (GDP) ការនាំចេញដ៏ច្រើនសម្បើមនៃវិស័យវាយនភ័ណ្ឌ ការបន្តកើនឡើងក្នុងការវិនិយោគលើវិស័យសំណង់ និងកំណើនឧស្សាហកម្មទេសចរណ៍។ ជាពិសេស ការនាំចេញផ្នែកវាយនភ័ណ្ឌបានកើនឡើងដល់ ៤,៧ពាន់លានដុល្លារអាមេរិកដែលមានការកើនឡើងចំនួន ១0% បើប្រៀបធៀបនឹងឆ្នាំកន្លងទៅ។ ការវិនិយោគលើវិស័យសំណង់បានកើនឡើងចំនួន ៧៤% ក្នុងរយៈពេល ០៨ខែ ដំបូងនៃឆ្នាំនេះ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។ ចំនួនភ្ញៀវទេសចរ ក៏បង្ហាញឱ្យឃើញអំពីការកើនឡើងគួរកត់សម្គាល់ផងដែរ គឺមានចំនួន ២៤% ក្នុងរយៈពេល ០៩ខែ ដំបូងនៃឆ្នាំ២០១២ បើប្រៀបធៀបនឹងឆ្នាំមុន ហើយត្រូវបានគេធ្វើការប៉ាន់ស្មានថា នឹងមានចំនួនកើនឡើងរហូត លើសពី ៣លាននាក់ក្នុងរយៈពេលពេញមួយឆ្នាំនេះ។

ការទទួលយកសេវាកម្ម និងផលិតផលនានារបស់ធនាគារពីសំណាក់អតិថិជនកំពុងមានការកើនឡើង ដែលនេះឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈកំណើនយ៉ាងឆាប់រហ័សនៃប្រាក់បញ្ញើ និងប្រាក់កម្ចី ដែលជាមធ្យមមានការកើនឡើងលើសពី ៣0% ជារៀងរាល់ឆ្នាំក្នុងរយៈពេល ០៥ឆ្នាំ ចុងក្រោយនេះនៅក្នុងវិស័យធនាគារ។ ទ្រព្យសកម្មសរុបរបស់ធនាគារធៀបនឹងផលិតផលក្នុងស្រុកសរុបមានចំនួនខ្ពស់ជាង ៧0%។ លើសពីនេះ អតិថិជនកម្ពុជាមិនមានការស្វាគ៌ាស្ទើរក្នុងការទទួលយកនូវផលិតផល និងសេវាកម្មថ្មីៗរបស់ធនាគារនោះទេ ដូចដែលឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈការរីកសាយភាយ និងការប្រើប្រាស់យ៉ាងឆាប់រហ័សនូវសេវាកម្មស្វ័យប្រវត្តិនានាពីសំណាក់អតិថិជន។ នាពេលថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធរាយការណ៍តាមប្រព័ន្ធអេឡិចត្រូនិកដែលជួយឲ្យការរាយការណ៍ធ្វើឡើងទាន់ពេលវេលា និងធ្វើឲ្យព័ត៌មានផ្សេងៗអំពីលទ្ធខណ្ឌសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានភាពត្រឹមត្រូវ និងប្រសើរឡើង។ ក្រេឌីត ប្យូរ៉ូកម្ពុជា ដែលទើបតែដំណើរការនាពេលថ្មីៗនេះ (សម្ពោធនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២) នឹងដើរតួនាទីរឹតតែសំខាន់ក្នុងការជួយរក្សាការពារ និងកាត់បន្ថយហានិភ័យឥណទាន ព្រមទាំងគាំទ្រដល់ការរីកលូតលាស់នៃប្រព័ន្ធធនាគារ។ នៅពេលដែលវិស័យធនាគារបន្តរីកចម្រើនជាលំដាប់ វាជាការបង្ហាញឱ្យឃើញអំពីការរីកចម្រើនជាលំដាប់នៃវិស័យឯកជនផងដែរ។ ការរីកចម្រើនទាំងនេះក៏បង្ហាញអំពីសមត្ថភាព ក្នុងការគ្រប់គ្រងត្រួតពិនិត្យលើហានិភ័យហិរញ្ញវត្ថុ និងបញ្ហាប្រឈមនានាដែលមានន័យថាធនាគារកណ្តាល មានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការរីកលូតលាស់ និងធានានូវការប្រកួតប្រជែងដោយត្រឹមត្រូវ និងយុត្តិធម៌ នៅក្នុងវិស័យធនាគារដែលកំពុងមានការរីកចម្រើនយ៉ាងគំហុក។ នាពេលថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានបង្កើនអត្រាប្រាក់បម្រុងកាតព្វកិច្ចពី ១២% ទៅ ១២,៥% ដែលជាការសរបញ្ជាក់នូវការបោះជំហានទៅមុខមួយជំហានទៀតក្នុងការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ និងជាវិធានការប្រុងប្រយ័ត្នមួយ សម្រាប់ដោះស្រាយបញ្ហានៃការកើនឡើងយ៉ាងខ្លាំងក្នុងការផ្តល់កម្ចី ក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ។

នៅទសវត្សកន្លងមកនេះ ប្រទេសកម្ពុជាបានវិវឌ្ឍខ្លួនយ៉ាងឆាប់រហ័សទៅជាទីផ្សារដ៏ទាក់ទាញបំផុតមួយនៅអាស៊ីអាគ្នេយ៍។

គិតត្រឹមចុងឆ្នាំនេះ ប្រទេសកម្ពុជាមានធនាគារពាណិជ្ជ និងធនាគារឯកទេសចំនួន ៣៩ ហើយរួមផ្សំជាមួយនឹងការកើនឡើងនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងទៀត បានធ្វើឲ្យមានការប្រកួតប្រជែងកាន់តែខ្លាំងឡើងនៅលើទីផ្សារ។ ទោះជាយ៉ាងនេះក៏ដោយ ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី នៅតែអាចរីកលូតលាស់ បានស្ទើរតែទ្វេដងនៅក្នុងឆ្នាំ២០១២ បើប្រៀបធៀបជាមួយឆ្នាំមូលដ្ឋានរបស់យើងនៅឆ្នាំ២០១១ ដែលក្នុងនោះតណាទានដុលបានកើនឡើងចំនួន១០០% ក្នុងខណៈដែលប្រាក់បញ្ញើបានកើនឡើងចំនួន ៩៨%។

លទ្ធផលប្រតិបត្តិរបស់ធនាគារនៅឆ្នាំ២០១២

ធនាគារសម្រេចបានការរីកចម្រើនដ៏ខ្លាំងក្លា ដែលធ្វើឲ្យប្រាក់ចំណូលរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី មានការកើនឡើង ២៥៧% ស្មើនឹងចំនួន ៤,៥លានដុល្លារអាមេរិក បើប្រៀបធៀបទៅនឹងឆ្នាំកន្លងទៅ។ ទាំងនេះគឺជាលទ្ធផលនៃកំណើនតណាទានសរុបចំនួន ១០០% រហូតដល់ ៨៤,៦លានដុល្លារអាមេរិក ដោយមានការគាំទ្រពីកំណើនប្រាក់បញ្ញើរបស់អតិថិជនចំនួន ៩៨% រហូតដល់ ៩៨,៤លានដុល្លារអាមេរិក។ ការខាតមុនបង់ពន្ធមានចំនួន ២លានដុល្លារអាមេរិក ដែលមានលក្ខណៈប្រសើរជាងឆ្នាំមុនដែលមានតែ ៣៨% ហើយយើងមានមោទនភាពណាស់ដែលធនាគារអាចសម្រេចបាននូវផែនការអាជីវកម្មបឋម ក្នុងរយៈពេល១ឆ្នាំមុនផងដែរ។ លទ្ធផលនៃកំណត់ត្រានេះ សម្រេចបានតាមរយៈការផ្តោតជាសំខាន់ទៅលើផ្នែកគន្លឹះដូចខាងក្រោម៖

- ការគ្រប់គ្រងគុណភាពតណទានដោយរក្សាបានអនុបាតតណទានមិនដំណើរការឲ្យនៅកម្រិតសូន្យ
- ធ្វើការបែងចែកសមតុល្យតណទានរបស់ធនាគារទៅផ្នែកផ្សេងៗនៃសេដ្ឋកិច្ចបានល្អ
- រៀបចំស្ថានភាពតារាងតុល្យការរបស់យើងបានល្អ
- គ្រប់គ្រងការចំណាយលើប្រតិបត្តិការបានល្អ និងកាត់បន្ថយអនុបាតចំណាយធៀបនឹងចំណូលពី ៣២៣% មកនៅត្រឹម ១៣៥%។



លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារក៏មានភាពប្រសើរឡើងផងដែរ ជាមួយនឹងការបម្រើសេវាកម្មធនាគារ សម្រាប់អតិថិជនជាន់ខ្ពស់ (Preferred Banking) របស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី នៅលើទីផ្សារកម្ពុជា។ នេះគឺជាលទ្ធផលនៃអត្ថប្រយោជន៍បន្ថែមផ្សេងៗដែលផ្តល់ជូនអតិថិជនសក្តានុពល តាមរយៈបណ្តាញអាស៊ានរបស់ធនាគារស៊ីអាយអ៊ីមប៊ីហ្គ្រុប។ បច្ចុប្បន្ននេះ យើងមានគណនីសម្រាប់អតិថិជនជាន់ខ្ពស់ (Preferred) ចំនួន ៨០០ ជាមួយនឹងទ្រព្យសកម្ម (Assets Under Management) ចំនួន ៣១លានដុល្លារអាមេរិក។ ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី គឺជាធនាគារទីមួយ ដែលបម្រើសេវាកម្ម វិនិយោគរូបិយប័ណ្ណទ្វេ (Dual Currency Investment) ដើម្បីជួយសម្រួលដល់អតិថិជន ដែលត្រូវការប្រើប្រាស់រូបិយប័ណ្ណបរទេស។ ក្រៅពីគណនីរូបិយប័ណ្ណបរទេស យើងក៏បម្រើជូនអតិថិជននូវផលិតផលគណនីបញ្ញើមាស (Gold Deposits) ដើម្បីជួយសម្រួលដល់អតិថិជនក្នុងការបែងចែកប្រាក់បញ្ញើ និងការវិនិយោគរបស់ពួកគាត់ផងដែរ។ល។

នៅពាក់កណ្តាលឆ្នាំ២០១២ យើងបានបង្កើនការវិនិយោគលើប្រព័ន្ធធនាគារស្នូលរបស់យើង ដើម្បីដាក់បញ្ចូលនូវផលិតផលហិរញ្ញវត្ថុមួយ គឺហិរញ្ញប្បទានពាណិជ្ជកម្ម (Trade Finance) ដែលប្រព័ន្ធនេះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការពង្រឹងសមត្ថភាពបម្រើសេវាកម្មអតិថិជន ក៏ដូចជាបង្កើតតម្លៃបន្ថែមជូនអតិថិជនរបស់ធនាគារផងដែរ។ នៅឆមាសទី២ នៃឆ្នាំ២០១២ យើងបានចាប់ផ្តើមការសេវាកម្មម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិក្នុងតំបន់របស់យើង ដែលជាអត្ថប្រយោជន៍ថ្នាក់តំបន់មួយទៀតសម្រាប់អតិថិជនដែលមានស្រាប់ និងអតិថិជនសក្តានុពលរបស់ធនាគារ ក្នុងការប្រើប្រាស់បណ្តាញម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិក្នុងតំបន់ ដែលមានចំនួនច្រើនជាង ៤.៨០០ នៅក្នុងបណ្តាញថ្នាក់តំបន់ទាំងមូលរបស់ធនាគារស៊ីអាយអ៊ីមប៊ី ដោយពុំមានគិតកម្រៃសេវាកម្មឡើយ។

ដើម្បីបន្ថែមការគាំទ្រដល់ការរីកចម្រើននៃអាជីវកម្មរបស់យើង ធនាគារបានបើកសាខាថ្មីចំនួន ៤ ទៀត នៅរាជធានីភ្នំពេញ ក្រុងបាត់ដំបង និងក្រុងកំពង់ចាម ដែលធ្វើឲ្យបណ្តាញសាខារបស់យើងមានចំនួនសរុប ១១សាខា នៅចុងឆ្នាំ២០១២ ហើយយើងក៏បានជ្រើសរើសបុគ្គលិកកម្ពុជាដែលមានទេពកោសល្យចំនួន ៥៤នាក់បន្ថែមទៀតផងដែរ។ ជាមួយគ្នានេះដែរ ធនាគារបានផ្តល់នូវកម្មវិធីវគ្គបណ្តុះបណ្តាល និងអភិវឌ្ឍន៍ដល់បុគ្គលិកចំនួន ១១៦នាក់ ដែលក្នុងនោះមានបុគ្គលិកឆ្នើមចំនួន ២២នាក់ ត្រូវបានបញ្ជូនទៅចូលរួមក្នុងកម្មវិធីវគ្គបណ្តុះបណ្តាល និងអភិវឌ្ឍន៍ប្រចាំតំបន់នៅប្រទេសសិង្ហបុរី និងម៉ាឡេស៊ីក្នុងឆ្នាំ២០១២។

ទស្សនវិស័យសម្រាប់ឆ្នាំ២០១៣

ផលិតផលក្នុងស្រុកសរុប (GDP) ត្រូវបានព្យាករណ៍ថានឹងមានការកើនឡើង ៧% ជាមួយអត្រាអតិផរណារក្សានៅក្នុងចន្លោះ៣%។ ការនាំចេញនឹងនៅតែជាប្រភពកំណើនដ៏សំខាន់ បើទោះបីជា តម្រូវការការនាំចូលផលិតផលវាយនភ័ណ្ឌទៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបត្រូវបានរំពឹងទុកថានឹងមានការថយចុះក៏ដោយ។ គេក៏បានធ្វើការព្យាករណ៍ទុកថា គ្រប់វិស័យទាំងអស់នឹងរក្សានូវការរីកលូតលាស់ លើសពី ១០% បើប្រៀបធៀបទៅនឹងឆ្នាំមុន។ វិស័យផលិតកម្មថ្មីៗដែលទើបនឹងកកើតឡើង ដែលរួមមាន ផ្នែកគ្រឿងបន្លាស់យានយន្ត និងការតម្លើងម៉ាស៊ីនអេឡិចត្រូនិកធុនតូច ភ្ជាប់ជាមួយនឹងការពង្រឹងដែលបានរំពឹងទុកសម្រាប់ការវិនិយោគផ្នែកសំណង់ ដែលបានមកពីការវិនិយោគផ្ទាល់ពីបរទេសចូលមកក្នុងប្រទេស ក៏រួមចំណែកក្នុងការព្យាករណ៍អំពីកំណើននេះផងដែរ។

អត្រាប្តូរប្រាក់ដុល្លារអាមេរិក/ខ្មែររៀលនឹងត្រូវរក្សាក្នុងកម្រិតប្រែប្រួលបន្តិច ឬ ដក ១ ភាគរយ។ វិស័យធនាគារត្រូវបានរំពឹងទុកថានឹងបន្តពង្រីកខ្លួន បើទោះជាដុល្លារូបនីយកម្មមានកម្រិតខ្ពស់ក៏ដោយ។ ធនាគារ ថ្មីៗនឹងបន្តចូលមកកាន់ទីផ្សារធនាគារកម្ពុជានៅឆ្នាំ២០១៣ ត្បិតថាទីផ្សារកម្ពុជានៅមានលក្ខណៈទូលំទូលាយ ដោយសារប្រជាជនមួយចំនួនធំមិនទាន់មានគណនីធនាគារនៅឡើយ។ ធនាគារដែលផ្តល់តណទាន និងទទួលប្រាក់បញ្ញើ ក៏ទទួលបានកម្លាំងចលករផងដែរ បន្ទាប់ពីការធ្លាក់ចុះនៅឆ្នាំ២០០៩-២០១០ ដែលបង្ហាញឱ្យឃើញអំពីការរីកចម្រើនជាមធ្យម ៤០% សម្រាប់ឆ្នាំ ២០១១ និង ២០១២។ ចំណុចនេះ សរបញ្ជាក់ឱ្យឃើញថាវិស័យធនាគារនឹងមានការកើនឡើងនៅក្នុងសន្ទុះប្រហាក់ប្រហែលគ្នា សម្រាប់ឆ្នាំ២០១៣ ស្របពេលគ្នានឹងការរីកចម្រើននៃផលិតផលក្នុងស្រុកសរុបផងដែរ។

ឆ្នាំ២០១៣ នេះ នឹងជាឆ្នាំទី៣ នៃប្រតិបត្តិការរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ យើងនឹងផ្តោតសំខាន់លើ "ការអនុវត្តឱ្យបានត្រឹមត្រូវ" ("doing it right") តាមអាទិភាពជាយុទ្ធសាស្ត្រដូចខាងក្រោម៖

- បន្តពង្រីកមូលដ្ឋានអតិថិជនរបស់យើងតាមរយៈការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដែលយើងបានកសាងអស់រយៈពេលពីរឆ្នាំកន្លងមកនេះ និងស្វែងរកតំបន់ពាណិជ្ជកម្មយុទ្ធសាស្ត្រ ប្រកបដោយសក្តានុពល ដើម្បីបន្តបង្កើតបណ្តាញរបស់យើងក្នុងគោលដៅបង្កភាពងាយស្រួលដល់អតិថិជន
- បន្តបង្កើតរចនាសម្ព័ន្ធលក់របស់យើង ដោយផ្តោតសំខាន់លើការកសាងទំនាក់ទំនងជាជាងជម្រុញ អតិថិជនដែលមានស្រាប់ និងមានសក្តានុពលរបស់យើងទទួលយកសេវាកម្ម ឬ ផលិតផលរបស់ធនាគារ។
- ពង្រឹងស្តង់ដារសេវាកម្មអតិថិជនរបស់យើង ផ្អែកលើវិញ្ញាបនប័ត្រ ISO សម្រាប់ "សេវាកម្មអតិថិជន" ដែលធនាគារទទួលបាន
- បន្តកសាងជាស្ថាប័នបណ្តុះបណ្តាល តាមរយៈកម្មវិធីបណ្តុះបណ្តាលផ្ទៃក្នុងរបស់យើងជាមួយនឹងស្ថាប័នលំដាប់ពិភពលោកនៅក្នុងតំបន់ និងផ្តោតសំខាន់លើការកសាងក្រុមការងារកម្ពុជាដ៏រឹងមាំមួយ
- ធ្វើឲ្យប្រសើរឡើងជាលំដាប់លើការកម្រិតគុណភាពសវនកម្ម និងការប្រតិបត្តិតាមច្បាប់ និងបទប្បញ្ញត្តិ
- ណែនាំសេវាកម្ម និងផលិតផលគ្រប់គ្រងទ្រព្យសម្បត្តិបន្ថែមទៀតដែលសក្តិសមសម្រាប់ទីផ្សារកម្ពុជា។

ជាចុងក្រោយ ខ្ញុំសូមសម្តែងនូវការកោតសរសើរដ៏ជ្រាលជ្រៅបំផុតចំពោះអតិថិជនស្មោះស្ម័គ្ររបស់ធនាគារយើង ក្រុមប្រឹក្សាភិបាលធនាគារ គណៈគ្រប់គ្រងធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី និងបុគ្គលិករបស់ធនាគារសម្រាប់ការគាំទ្រ និងការតាំងចិត្តខិតខំប្រឹងប្រែងរបស់ពួកគាត់ក្នុងការបំពេញការងាររពេញមួយឆ្នាំកន្លងមកនេះ។ ខ្ញុំក៏សូមសម្តែងនូវការគោរព និងកោតសរសើរដ៏ជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងធនាគារជាតិនៃកម្ពុជា សម្រាប់ការគាំទ្រចំពោះធនាគារយើងជាបន្តបន្ទាប់។

YEW WAN KUP
អគ្គនាយក

សារពី
ប្រធាននាយកប្រតិបត្តិនៃក្រុមហ៊ុនមេ

ធនាគារស៊ី អាយអិមប៊ី កម្ពុជា បានទទួលភាពជោគជ័យនៅក្នុងឆ្នាំ២០១២ និងជាធនាគារមួយដែលមានការរីកចម្រើនឆាប់រហ័ស ជាងគេមួយនៅក្នុងប្រទេសកម្ពុជា។ ដោយបានពង្រីកខ្លួនយ៉ាងឆាប់រហ័សពីធនាគារដ៏តូចមួយ ពេលនេះយើងបានបើកសាខាថ្មីចំនួនបួន បន្ថែមជាមួយនឹងការដាក់បម្រើជូននូវម៉ាស៊ីនអេធីអឹមចំនួន៧គ្រឿងទៀតនៅក្នុងរាជធានីភ្នំពេញ ក្រុងកំពង់ចាម និងបាត់ដំបង។

តាងនាមឱ្យ ស៊ីអាយអិមប៊ី ហ្គ្រុប ខ្ញុំសូមធ្វើការអបអរចំពោះគណៈគ្រប់គ្រង និងបុគ្គលិកធនាគារ ស៊ីអាយអិមប៊ី កម្ពុជា ដែលបានបញ្ចប់ឆ្នាំមួយទៀតប្រកបដោយភាពជោគជ័យ។ ឆ្នាំ២០១២ គឺជាឆ្នាំប្រតិបត្តិការទី២ ហើយយើងមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងជាមួយវឌ្ឍនភាពដ៏ល្អប្រសើរនេះ។ ទោះបីជាធនាគារមិនទាន់ឈានទៅដល់ចំណុចទទួលបានប្រាក់ដើមមកវិញនៅឡើយ ដោយសារការចំណាយលើការរៀបចំដំណើរការដំបូងក៏ដោយ ក៏យើងបានឃើញសក្តានុពលនៃលទ្ធផលជាវិជ្ជមាននាពេលអនាគតដ៏ខ្លីខាងមុខនេះ ដោយផ្អែកលើសមិទ្ធកម្មការងារនៅក្នុងឆ្នាំមុន និងទស្សនវិស័យរយៈពេលវែងនៃសេដ្ឋកិច្ចកម្ពុជា។

នៅក្នុងឆ្នាំ២០១២ យើងគឺជាធនាគារដំបូងគេនៅក្នុងប្រទេសកម្ពុជាដែលធ្វើការផ្តល់ជូននូវផលិតផលដែលអាចទទួលបានកម្រៃមកវិញ ដូចជាគណនីរូបិយប័ណ្ណទ្វេ។ យើងផ្តោតសំខាន់លើការបម្រើអតិថិជនក្នុងប្រទេសកម្ពុជាដោយធ្វើការផ្តល់ជូនបន្ថែមនូវផលិតផល និងសេវាកម្មធនាគារថ្មីៗ។ ក្នុងនាមជាធនាគារសាកលមួយក្នុងតំបន់អាស៊ាន យើងនឹងបន្តផ្តល់ជូនអតិថិជននៅក្នុងប្រទេសកម្ពុជានូវការតភ្ជាប់ទៅនឹងបណ្តាញធនាគារ ទីផ្សារក្នុងតំបន់ វិនិយោគិន និងធុរកិច្ចជាច្រើនទៀតរបស់យើង។

យើងខ្ញុំសូមធ្វើការគាំទ្រចំពោះការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាកាលពីឆ្នាំមុន ក្នុងការបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។ ផែនការនេះនឹងជួយអោយវិស័យហិរញ្ញវត្ថុកម្ពុជាអាចធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុក្នុងតំបន់ ហើយគាំទ្រដល់របៀបវារៈអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិក្នុងរយៈពេលវែងផងដែរ។ ផែនការនេះក៏មានលក្ខណៈស្របគ្នាជាមួយនឹងយុទ្ធសាស្ត្ររបស់ ស៊ីអាយអិមប៊ី ហ្គ្រុប ដែលដើរតួនាទីជាអ្នកជួយសម្របសម្រួលផ្នែកពាណិជ្ជកម្ម និងវិនិយោគនៅក្នុងតំបន់ ព្រមទាំងជាអ្នកផ្តល់សេវាកម្មធនាគារសកលដល់អតិថិជនរបស់យើងនៅក្នុងតំបន់អាស៊ានផងដែរ។

តាងនាមឱ្យ ស៊ីអាយអិមប៊ី ហ្គ្រុប ខ្ញុំសូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាលកម្ពុជា និងធនាគារជាតិនៃកម្ពុជា ព្រមទាំងអតិថិជន ក៏ដូចជាភាគីពាក់ព័ន្ធរបស់យើងទាំងអស់ចំពោះការគាំទ្រជាប្រចាំ និងការប្តេជ្ញាចិត្តរបស់គាត់ក្នុងអំឡុងឆ្នាំ២០១២ កន្លងមកនេះ។

យើងខ្ញុំនឹងផ្តល់នូវ 'អាស៊ានសម្រាប់អ្នក (ASEAN For You)' ដែលល្អប្រសើរបំផុតជូនអតិថិជនទាំងអស់របស់យើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

NAZIR RAZAK
ប្រធាននាយកប្រតិបត្តិនៃក្រុមហ៊ុនមេ

ជាមួយសេចក្តីសាទរ និងការតស៊ូព្យាយាម ធនាគារ ស៊ីអាយអិមប៊ី អាចបង្ហាញជូនសាជាថ្មីម្តងទៀតថា យើងជាធនាគារដែលមានការរីកចម្រើនរហ័សជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា។

កម្មវិធីបង្កើនភាពស្និទ្ធស្នាលរវាងបុគ្គលិក ស៊ីអាយអ៊ីមប៊ី នៅខេត្តសៀមរាប

នាយកប្រតិបត្តិ ស៊ីអាយអ៊ីមប៊ី ហ្គ្រុប ជាមួយអ្នកចូលរួមកិច្ចប្រជុំកំពូល អ្នកដឹកនាំវ័យក្មេងក្នុងតំបន់អាស៊ាន កាលពីខែកញ្ញា ឆ្នាំ២០១២ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ដែលក្នុងនោះមានសិស្សពូកែកម្ពុជាចំនួន ៤រូប បានចូលរួមផងដែរ

ការពិនិត្យមើល ធុរកិច្ច

១៤ សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម

១៥ សេវាកម្មហិរញ្ញវត្ថុបុគ្គល

១៦ រតនាគារ

១៧ អំពីនាយកដ្ឋានគាំទ្រនានា

នាយកដ្ឋានហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រ

នាយកដ្ឋានធនធានសាធារណៈ

នាយកដ្ឋានព័ត៌មានវិទ្យា និងប្រតិបត្តិការ

នាយកដ្ឋានគ្រប់គ្រងហានិភ័យ

នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង

ដូចថ្ងៃដែលជាងគំនូរដែលធ្វើការគូសវាស និងលាយពណ៌ដើម្បីធ្វើអោយផ្ទាំងគំនូរមួយផ្ទាំងមើលទៅរស់រវើកដូចមានជីវិត នៅឯធនាគារ ស៊ីអាយអិមប៊ី យើងបានរួមបញ្ចូលគ្នានូវជំនាញ និងចំណេះដឹងក្នុងតំបន់របស់យើងដើម្បីនាំយកផលិតផល និងសេវាកម្មថ្មីៗ និងមានប្រយោជន៍មកកាន់ទីផ្សារធនាគារនៅក្នុងប្រទេសកម្ពុជា។

សេវាកម្ម ហិរញ្ញវត្ថុពាណិជ្ជកម្ម

នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម របស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី ទទួលខុសត្រូវលើការបំពេញតម្រូវការរបស់សាជីវកម្ម និងក្រុមហ៊ុនពហុជាតិធំៗ ក៏ដូចជាអាជីវកម្មតូចៗផងដែរ។

ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី គឺជាបុត្រសម្ព័ន្ធនៃ ស៊ីអាយអ៊ីមប៊ី ហ្គ្រុប ដែលជាធនាគារសាកលធំជាងគេបំផុតទី ៥ នៅក្នុងតំបន់អាស៊ាន និងមានការិយាល័យនៅក្នុងប្រទេសចំនួន ៨ ក្នុងចំណោមប្រទេសទាំង ១០ របស់អាស៊ាន។ ក្រុមហ៊ុនមេមានបុគ្គលិកសរុបចំនួន ៤២.០០០ នាក់ និងបម្រើអតិថិជនទូទាំង ១៧ប្រទេសនៅលើសកលលោក។

ដោយមានបណ្តាញយ៉ាងទូលំទូលាយ និងជាធនាគារសាកលនៅក្នុងតំបន់អាស៊ាន ធនាគារ ស៊ីអាយអ៊ីមប៊ី មានសមត្ថភាពខ្ពស់ ក្នុងការសម្របសម្រួលពាណិជ្ជកម្មក្នុងតំបន់ និងលំហូរវិនិយោគផងដែរ។ វិសាលភាពរបស់ ស៊ីអាយអ៊ីមប៊ី ហ្គ្រុប បានអនុញ្ញាតឱ្យធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្រប់តំបន់ និងបានចែករំលែកបទដ្ឋានអន្តរជាតិល្អប្រសើរបំផុតលើគ្រប់វិស័យ នៃសេវាកម្មហិរញ្ញវត្ថុរបស់ខ្លួន។

ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី បានប្តេជ្ញាផ្តល់ជូនការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបទពិសោធន៍តំបន់ដល់អាជីវកម្មធុនធំ និងតូចនៅប្រទេសកម្ពុជា។ សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ជាផ្នែកយ៉ាងសំខាន់នៃធុរកិច្ចទូទៅរបស់ធនាគារដែលមានឥណទានចំនួន ៤៣% នៃឥណទានសរុប និងប្រាក់បញ្ញើចំនួន ៦១% នៃប្រាក់បញ្ញើសរុប។ សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម បានសម្រេចកំណើនឥណទានសរុប ១៤,៤៣ លានដុល្លារអាមេរិក និងប្រាក់បញ្ញើសរុប ២២,០៥ លានដុល្លារអាមេរិក បើប្រៀបធៀបនឹងលទ្ធផលក្នុងឆ្នាំកន្លងមក។

សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ធ្វើប្រតិបត្តិការស្របជាមួយនឹងនាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល និងមានបណ្តាញសាខាចំនួន ១១ ទូទាំងប្រទេសកម្ពុជា។

ភាពជោគជ័យសំខាន់ៗរបស់យើង

សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ដែលបានប្រតិបត្តិការចំនួន ៣ ឆ្នាំកន្លង បានបន្តវិនិយោគលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស ដើម្បីបម្រើអតិថិជនឱ្យកាន់តែប្រសើរ។

នៅចុងឆ្នាំ២០១២ សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មបានបង្កើនបុគ្គលិកអ្នកតំណាងដល់ ៨ នាក់ បើធៀបនឹងបុគ្គលិកចំនួន ៤ នាក់នៅឆ្នាំកន្លងមក។ បុគ្គលិករបស់យើងភាគច្រើនជាជនជាតិកម្ពុជា ដែលនេះជាគោលនយោបាយប្រកបដោយនិរន្តរភាពដ៏ចម្បងមួយរបស់ ស៊ីអាយអ៊ីមប៊ី ហ្គ្រុប ក្នុងការអភិវឌ្ឍន៍សមត្ថភាព និងភាពជាអ្នកដឹកនាំរបស់បុគ្គលិកក្នុងស្រុក ក្នុងគ្រប់ទីផ្សារសំខាន់ៗរបស់ខ្លួន។ ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី នឹងបន្តការអភិវឌ្ឍន៍បុគ្គលិកដែលមានទេពកោសល្យក្នុងស្រុកតាមរយៈការផ្លាស់ប្តូរជំនាញបច្ចេកទេស និងស្តង់ដារជាន់ខ្ពស់ នៃអភិបាលកិច្ចសហគ្រាស។ យើងខ្ញុំសូមថ្លែងអំណរគុណដល់ ស៊ីអាយអ៊ីមប៊ី ហ្គ្រុប ដែលបានផ្តល់ដំបូន្មានទាំងនេះ ព្រមទាំងលើវិស័យផ្សេងៗទៀតតាមរយៈការបញ្ជូនបុគ្គលិកជាន់ខ្ពស់ពីទូទាំងតំបន់អាស៊ាន ដើម្បីមកធ្វើការបណ្តុះបណ្តាល។ បុគ្គលិកក្នុងស្រុករបស់យើងបានទទួលបទពិសោធន៍ទាំងនោះ និងចំណេះដឹងធនាគារ យ៉ាងទូលំទូលាយ ហើយយើងបន្តអនុវត្តបទដ្ឋានអន្តរជាតិល្អប្រសើរបំផុត ដើម្បីឆ្លើយតបទៅនឹងបរិយាកាសក្នុងប្រទេស។

យើងសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះធនាគារជាតិនៃកម្ពុជាសម្រាប់កិច្ចគាំទ្រ និងសេចក្តីណែនាំនានាតាំងពីដើមរៀងមក។ ធនាគារជាតិនៃកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការបង្កើតធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី។ ដំណើរវិវត្តន៍នៃបទបញ្ញត្តិ និងការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា បានជួយឱ្យមានការរីកចម្រើនយ៉ាងខ្លាំងក្នុងវិស័យធនាគារនៅកម្ពុជា ហើយយើងនឹងបន្តទំនាក់ទំនងដ៏ល្អនេះជានិច្ចនិរន្តន៍។

លទ្ធផលសម្រាប់ឆ្នាំ២០១២

សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម សម្រេចបានលទ្ធផលល្អដោយមានកំណើនឥណទាន និងប្រាក់បញ្ញើយ៉ាងខ្លាំងក្លា។ នៅចុងឆ្នាំ ២០១២ ឥណទានរបស់សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មមានចំនួនដល់ទៅ ៣៧,២៩ លានដុល្លារអាមេរិក ហើយប្រាក់បញ្ញើមានចំនួនដល់ទៅ ៥៥,៤០ លានដុល្លារអាមេរិក។ យើងមានសេចក្តីសោមនស្សរីករាយជាខ្លាំង ចំពោះកំណើនខាងលើជាមួយនឹងគុណភាពទ្រព្យសកម្មរបស់យើង ដែលមានដំណើរការល្អចាប់តាំងពីពេលចាប់ផ្តើមបង្កើតធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី នេះ។



ផែនការសម្រាប់ឆ្នាំ២០១៣

ដោយមានការឈានឆ្ពោះទៅមុខ យើងមានមូលដ្ឋានដ៏រឹងមាំក្នុងឆ្នាំ២០១២ និងមានគោលបំណងពង្រីកប្រាក់ចំណូលរបស់យើងឱ្យបានកើនឡើងទ្វេដងក្នុងឆ្នាំ២០១៣នេះ។ ការរីកចម្រើនរបស់យើង គឺតាមរយៈកំណើនឥណទាន និងប្រាក់បញ្ញើ ដែលមានការគាំទ្រពីការរីកចម្រើននិងវិវត្តន៍ នៃសមត្ថភាពប្រព័ន្ធប្រតិបត្តិការ និងដំណើរការធនាគាររបស់យើង។ យើងនឹងបន្តពង្រីកកម្មវិធីបណ្តុះបណ្តាល ដើម្បីជម្រុញធនធានមនុស្ស ដែលជាធនធានសំខាន់បំផុតរបស់ធនាគារ។ យើងមានផែនការណែនាំ និងលើកកម្ពស់ផលិតផលដែលមានស្រាប់ តាមរយៈការផ្តល់សេវាកម្មកាន់តែប្រសើរដល់សហគមន៍អាជីវកម្មកម្ពុជា។

ផលិតផលក្នុងសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម

១. ឥណទានមានកាលកំណត់
២. ឥណទានវិបារូប្បណ៍
៣. លិខិតធានា
៤. លិខិតឥណទាន
៥. ផលិតផល និងសេវាកម្មហិរញ្ញប្បទានពាណិជ្ជកម្មផ្សេងៗ
៦. គណនីចរន្ត
៧. ប្រាក់បញ្ញើមានពេលកំណត់
៨. គណនីរូបិយប័ណ្ណបរទេស
៩. ការវិនិយោគលើរូបិយប័ណ្ណទ្វេ

សេវាកម្ម ហិរញ្ញវត្ថុបុគ្គល

ក្នុងអំឡុងពេល ១២ខែកន្លងទៅនេះ នាយកដ្ឋានសេវាកម្ម ហិរញ្ញវត្ថុបុគ្គល បានរីកចម្រើនទៅមុខជាបន្តបន្ទាប់ ដើម្បីសម្រេចបាននូវគោលដៅយូរអង្វែង ដើម្បីក្លាយជាធនាគារដែលមានឈ្មោះមួយនៅអាស៊ាន។ ក្រុមការងាររបស់យើងខ្ញុំបានប្រឹងប្រែងអស់កម្លាំងកាយចិត្ត ដើម្បីកសាងមូលដ្ឋានគ្រឹះ និងបាននាំមកនូវផលិតផលល្អៗ និងសេវាកម្មថ្មីៗ បន្ថែមទៀតជាច្រើន។ យើងខ្ញុំបានពង្រីកបណ្តាញសាខាចំនួនបួននៅក្នុងខែវិច្ឆិកា ហើយបានដាក់តម្លើងម៉ាស៊ីនដកប្រាក់ (ATM) បន្ថែម និងបានដាក់តម្លើងម៉ាស៊ីនដាក់ប្រាក់ និងម៉ាស៊ីនដាក់មូលប្បទានប័ត្រចំនួនបួនបន្ថែមទៀត ដើម្បីអតិថិជនកាន់តែមានភាពងាយស្រួល។

ធនាគារ ស៊ីអាយអិមបី ជាធនាគារឈានមុខគេមួយនៅក្នុងតំបន់អាស៊ាន។ អតិថិជនរបស់យើងនឹងរីករាយជាមួយបទពិសោធន៍សេវាកម្មធនាគារក្នុងតំបន់ ដែលមានដូចជា សេវាកម្មធនាគារសម្រាប់អតិថិជនជាន់ខ្ពស់ សេវាកម្ម Regional ATM Link ដែលអនុញ្ញាតិឱ្យអតិថិជន ធ្វើការដកប្រាក់ពីបណ្តាញម៉ាស៊ីនអេធីអិមរបស់យើងទាំងអស់នៅក្នុងតំបន់ និងសេវាកម្មជាច្រើនទៀត ដែលនឹងមកដល់ក្នុងពេលឆាប់ៗនេះ។ នៅក្នុងឆ្នាំ២០១២នេះ យើងក៏បានឧបត្ថម្ភអតិថិជនជាន់ខ្ពស់ចំនួនបីរូបឱ្យចូលរួមកម្មវិធីប្រកួតវាយកូនគោល CIMB Classic ដែលមានការចូលរួមពីសំណាក់កីឡាករឆ្នើមៗនៅលើពិភពលោករួមមាន កីឡាករ Tiger Woods ដែលប្រព្រឹត្តទៅនៅក្នុងប្រទេសម៉ាឡេស៊ី ដែលជាព្រឹត្តិការណ៍ប្រកួតរបស់ PGA Sanctioned តែមួយគត់នៅក្រៅសហរដ្ឋអាមេរិក។

នៅឆ្នាំ២០១២ ធនាគារ ស៊ីអាយអិមបី បានទទួលលទ្ធផលគួរឱ្យកត់សម្គាល់។ ក្នុងនោះរួមមានដូចជា៖

- ប្រាក់បញ្ញើកើនឡើង ១៨០% ស្មើនឹង ៤២ លានដុល្លាសហរដ្ឋអាមេរិកនាចុងឆ្នាំ២០១២
- ប្រាក់កម្ចីកើនឡើង ១៤០% ស្មើនឹង ៤៧ លានដុល្លាសហរដ្ឋអាមេរិកនាចុងឆ្នាំ២០១២
- បើកសាខាថ្មីចំនួនបួនបន្ថែមទៀត៖ ២សាខា នៅរាជធានីភ្នំពេញ ១សាខា នៅខេត្តបាត់ដំបង និង ១សាខាទៀត នៅខេត្តកំពង់ចាម
- ណែនាំជូនសេវាកម្ម Regional ATM Link ដែលអនុញ្ញាតិឱ្យអតិថិជនធ្វើការដកប្រាក់តាមម៉ាស៊ីនអេធីអិមរបស់ធនាគារ ស៊ីអាយអិមបីទាំងអស់នៅក្នុងប្រទេសកម្ពុជា ម៉ាឡេស៊ី សិង្ហបូរី ថៃ ឥណ្ឌូនេស៊ី ដោយមិនគិតថ្លៃ។
- ផ្តល់ជូននូវផលិតផលវិនិយោគ ដូចជា ការវិនិយោគរូបិយប័ណ្ណទ្វេ
- ដាក់បន្ថែមម៉ាស៊ីនអេធីអឹម ១០គ្រឿងទៀត នៅក្នុងសាខាចំនួនបួន និងក្រៅសាខាចំនួន ៦គ្រឿង
- ដាក់ឱ្យដំណើរការម៉ាស៊ីនដាក់ប្រាក់ និងដាក់មូលប្បទានប័ត្រចំនួន ៤កន្លែង
- ផ្តល់ជូនកញ្ចប់សេវាកម្ម CIMB@work
- ដាក់បញ្ចូលដៃគូពាណិជ្ជកម្មជាច្រើនទៀត សម្រាប់ផ្តល់អត្ថប្រយោជន៍ (Privilege Program) បន្ថែមជូនអតិថិជនជាន់ខ្ពស់ (CIMB Preferred)
- បន្តកំណែទម្រង់គោលការណ៍ និងបែបបទផ្សេងៗឱ្យកាន់តែប្រសើរឡើង
- បច្ចុប្បន្នធនាគារ ស៊ីអាយអិមបី យើងមានសាខាសរុបចំនួន ១១កន្លែង (៧សាខានៅក្នុងរាជធានីភ្នំពេញ និង៤ទៀត និងក្រៅសាខាចំនួន៦ នៅក្នុងក្រុង សៀមរាប ព្រះសីហនុ បាត់ដំបង និងកំពង់ចាម) ដែលក្នុងនោះ ៤សាខា មានផ្តល់ជូនសេវាកម្មធនាគារសម្រាប់អតិថិជនជាន់ខ្ពស់។ ហើយសម្រាប់សាខាទាំង១១ យើងខ្ញុំបានបំពាក់ជូននូវម៉ាស៊ីនដកប្រាក់ ម៉ាស៊ីនដាក់ប្រាក់ និងម៉ាស៊ីនដាក់មូលប្បទានប័ត្រ ដើម្បីឱ្យអតិថិជនអាចធ្វើប្រតិត្តិការធនាគារបាន ២៤ម៉ោងជាប្រចាំថ្ងៃ។

ផែនការរបស់យើងសម្រាប់ឆ្នាំ២០១៣

បន្តស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និងនាំយកនូវផលិតផលថ្មីៗ និងសេវាកម្មល្អៗជូនដល់អតិថិជន។

- ធ្វើការណែនាំជូននូវផលិតផលវិនិយោគ ដែលអាចទទួលចំណូលបានច្រើន
- ដាក់បន្ថែមម៉ាស៊ីនអេធីអិម ម៉ាស៊ីដាក់ប្រាក់ និងម៉ាស៊ីនដាក់មូលប្បទានប័ត្រ
- ណែនាំជូនបន្ថែមនូវផលិតផល និងសេវាកម្មធនាគារប្រចាំថ្ងៃ
- ផ្តល់ជូននូវកញ្ចប់អត្ថប្រយោជន៍បន្ថែមដល់អតិថិជន CIMB Preferred
- បន្ថែមជូនកញ្ចប់សេវាកម្មល្អសម្រាប់អតិថិជនដាក់ប្រាក់បញ្ញើ
- ណែនាំជូននូវផលិតផលប្រព័ន្ធទូទាត់ប្រាក់ក្នុងតំបន់
- បន្តពង្រីកសេវាកម្មធនាគារស្វ័យប្រវត្តិ

នាយកដ្ឋានរតនាគារ

នាយកដ្ឋានរតនាគារ ធ្វើការគាំទ្រដល់សកម្មភាពអាជីវកម្ម ចម្បងរបស់ធនាគារ ដើម្បីបង្កើនតម្លៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ដោយគ្រប់គ្រងមូលនិធិតាមមធ្យោបាយដ៏សមស្រប បំផុត។

នេះជាមូលដ្ឋានគ្រឹះ ដែលកំណត់ក្របខណ្ឌសម្រាប់ជម្រុញដល់មុខងាររបស់នាយកដ្ឋានរតនាគារ។ មុខងារចម្បងរបស់នាយកដ្ឋានៈ រួមមាន ការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម គ្រប់គ្រង និងចាត់ចែងប្រាក់បម្រុងរបស់ធនាគារ ស្វែងរកទុនបង្វិលវិនិយោគមូលនិធិ ដែលលើសការព្យាករណ៍លើចំណូលការប្រាក់សុទ្ធ (NII) និងវាស់វែងហានិភ័យអត្រាការប្រាក់ (IRR) ឬវេទយិតភាពនៃការប្រែប្រួលអត្រាការប្រាក់លើទីផ្សារ។

នាយកដ្ឋានរតនាគារនេះ ក៏ទទួលខុសត្រូវក្នុងការផ្តល់មូលនិធិសម្រាប់តារាងតុល្យការរបស់ធនាគារ តាមរយៈការអនុវត្តយុទ្ធសាស្ត្រប្រកបដោយគំនិតច្នៃប្រឌិតមួយចំនួន ដែលអនុវត្តជាមួយផ្នែកអាជីវកម្មនានា របស់ធនាគាររួមទាំងការគ្រប់គ្រងមូលនិធិទាំងឡាយឱ្យបានទាន់ពេលវេលា ដើម្បីគាំទ្រដល់ដំណើរការអាជីវកម្មធនាគារ។

ផ្នែកបម្រើសេវាកម្មអតិថិជនរបស់នាយកដ្ឋានរតនាគារនេះ ក៏គ្រប់គ្រងលើអាជីវកម្មប្តូររូបិយប័ណ្ណបរទេស និងផលិតផលវិនិយោគផ្សេងៗដែលផ្សារភ្ជាប់នឹងទីផ្សារ ហើយដែលរួមចំណែកយ៉ាងសំខាន់បំផុតដល់ចំណូលមិនមែនការប្រាក់របស់ធនាគារ។ នាយកដ្ឋានរតនាគារ ធ្វើការយ៉ាងជិតស្និទ្ធជាមួយផ្នែកអាជីវកម្មផ្សេងៗ ដើម្បីស្វែងរកឱកាសបង្កើតចំណូលតាមរយៈការលក់ផលិតផលរតនាគារ រួមបញ្ចូលជាមួយផលិតផលផ្សេងៗទៀតដល់អតិថិជន។

បន្ថែមលើនេះ ផ្អែកលើសមត្ថភាព និងការសហការរវាងបណ្តាប្រទេសក្នុងតំបន់ នាយកដ្ឋានរតនាគារអាចផ្តល់ដំណោះស្រាយប្រកបដោយភាពជំនាញជូនដល់អតិថិជនក្នុងតំបន់ចំពោះតម្រូវការផ្នែកអាជីកម្ម ការវិនិយោគ និងតម្រូវការគ្រប់គ្រងហិរញ្ញវត្ថុផងដែរ។ ផលិតផលពាក់ព័ន្ធនឹងអត្រាការប្រាក់ និងផលិតផលនិស្សន្ទវត្ថុ គឺជាផ្នែកកំពុងរីកចម្រើនមួយផ្សេងទៀតដែលធនាគារកំពុងផ្តោតលើ។ រតនាគារ គឺជាមុខងារដ៏សំខាន់មួយនៅក្នុងការិយាល័យកណ្តាល ដែលធ្វើឱ្យអ្នកគ្រប់គ្រងអាជីវកម្មអាចផ្តោតលើផ្នែកជំនាញសំខាន់របស់ខ្លួន នៅក្នុងផលប៉ះត្រូវរបស់ធនាគារ។

ក្រុមការងារនៃនាយកដ្ឋានរតនាគារ និង CIMB Preferred

នាយកដ្ឋានគាំទ្រនានា

នាយកដ្ឋានយុទ្ធសាស្ត្រ និងហិរញ្ញវត្ថុ

ភាពជោគជ័យ/សមិទ្ធផលសំខាន់ៗរបស់នាយកដ្ឋានយុទ្ធសាស្ត្រ និងហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១២

នាយកដ្ឋានយុទ្ធសាស្ត្រ និងហិរញ្ញវត្ថុ មានតួនាទីរៀបចំ និងអនុវត្តគោលការណ៍ និងនិតិវិធីគណនេយ្ય ដើម្បីឱ្យស្របតាមគំរូស្តង់ដារគណនេយ្យកម្ពុជា និងច្បាប់ដែលបានចែងដោយធនាគារជាតិនៃកម្ពុជា ហើយត្រូវគ្រប់គ្រងគម្រោងផ្តួចផ្តើមក៏ដូចជាធ្វើការវាស់វែងផ្នែកហិរញ្ញវត្ថុ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុផងដែរ។

ពាក់ព័ន្ធនឹងគណនេយ្យហិរញ្ញវត្ថុ ធនាគារធានាថារាល់ប្រតិបត្តិការគណនេយ្យរបស់ធនាគារ សុទ្ធតែប្រកបដោយសុក្រិតភាព ឥម្លាភាព និងការថែទាំយ៉ាងត្រឹមត្រូវ។ នាយកដ្ឋានក៏សូមធានាជូនថា នឹងប្រតិបត្តិតាមគ្រប់ពេលនូវរាល់របាយការណ៍ដែលតម្រូវដោយបទឬញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ក៏ដូចជាការប្រកាសពន្ធជូនអគ្គនាយកដ្ឋានពន្ធដារ និងរបាយការណ៍សម្រាប់ក្រុមហ៊ុនមេ និងថ្នាក់ដឹកនាំផងដែរ។

ការរៀបចំផែនការថវិកា និងផែនការអាជីវកម្មគឺជាកិច្ចការប្រចាំឆ្នាំ ដើម្បីធានានូវនិរន្តភាពរបស់អាជីវកម្ម ហើយការគ្រប់គ្រងថវិកាជាការងារប្រចាំថ្ងៃ ដើម្បីធានាថាយើងអាចសម្រេចបានគោលដៅអាជីវកម្ម។ ការគ្រប់គ្រងចំណាយ គឺជាកិច្ចការត្រូវបានយកចិត្តទុកដាក់បំផុត ដើម្បីធានាថារាល់ការចំណាយទៅឱ្យអ្នកផ្គត់ផ្គង់ ធ្វើឡើងដោយមានសុពលភាព និងមានការអនុញ្ញាតត្រឹមត្រូវ ហើយរាល់ការចំណាយទាំងអស់ គឺស្ថិតនៅក្នុងកញ្ចប់ថវិកា។

ការគ្រប់គ្រងចំណាយ ក៏ជាកត្តាស្នូលសម្រាប់សេវាកម្មហិរញ្ញវត្ថុបុគ្គលផងដែរ។ តុល្យភាពនៃចំណាយ និងអត្ថប្រយោជន៍ត្រូវបានរៀបចំឡើង និងអនុវត្ត ដើម្បីធានាប្រសិទ្ធភាព និងប្រសិទ្ធផលនៃការវិនិយោគលើគម្រោងនានារបស់ធនាគារ។

យើងក៏កំពុងធ្វើការពិនិត្យមើលទៅលើប្រតិបត្តិការ ផ្ទៃក្នុងរបស់ធនាគារ និងការបង្កើតគម្រោងថ្មីៗនៅគ្រប់ផ្នែក និងនាយកដ្ឋាន ទាំងអស់ដែរ។ កិច្ចការងារមួយក្នុងចំណោមនោះគឺការរៀបចំបទដ្ឋានសូចនាករនៃការវាយតម្លៃសមិទ្ធផលការងារ (KPI) ប្រចាំឆ្នាំផងដែរ។

ផែនការចម្បងរបស់នាយកដ្ឋានយុទ្ធសាស្ត្រ និងហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៣

ដើម្បីធានាថាគំនិតផ្តួចផ្តើមនេះ ដំណើរការទៅមុខបានល្អ យើងនឹងផ្តោតសំខាន់លើការពង្រឹងបន្ថែម លើវិស័យហិរញ្ញវត្ថុ អាជីវកម្មធនាគារ តាមរយៈការគាំទ្រលើកំណើនអាជីវកម្មនៃផលិតផលនិងសេវាកម្មរូបិយវត្ថុ ក៏ដូចជាការគ្រប់គ្រងឱ្យបានប្រសើរនូវគោលដំហររបស់អាជីវកម្មធនាគារ។ លើសពីនេះទៅទៀត ការពិនិត្យមើលលើតម្លៃផ្ទេរមូលនិធិ (FTP) និងការបែងចែកចំណាយក៏ស្ថិតនៅក្នុងផែនការអនុវត្តរបស់យើងផងដែរ ដើម្បីធ្វើអោយប្រសើរឡើងនូវការវាស់វែងសមិទ្ធផលការងាររបស់ផ្នែកអាជីវកម្មនីមួយៗ ក៏ដូចជារបស់ផលិតផល និងសេវាកម្មធនាគារផងដែរ។

ការផ្តោតទៅលើប្រសិទ្ធភាពនៃដំណើរការ និងប្រព័ន្ធផ្ទៃក្នុងរបស់ធនាគារ នឹងបន្តសម្រាប់ឆ្នាំក្រោយតទៅទៀត រួមជាមួយនឹងការធានាគុណភាពសេវាកម្មក្នុងនាមជាធនាគារដំបូងគេ ដែលមានសេវាកម្មទទួលស្គាល់ដោយ ISO។

ក្របខ័ណ្ឌពត៌មានទំនាក់ទំនងវិនិយោគិន នឹងត្រូវធ្វើការកំណត់សាជាថ្មី ហើយធ្វើការបែងចែកអោយបានទៀងទាត់ ដើម្បីធានានូវភាពដូចគ្នាក្នុងការប្រាស្រ័យទាក់ទងរវាងបុគ្គលិកគ្រប់រូបជាមួយនឹងអតិថិជន។

នាយកដ្ឋានធនធានសាជីវកម្ម

នាយកដ្ឋានធនធានសាជីវកម្ម គ្រប់គ្រងទាំងផ្នែកធនធានមនុស្ស និងផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិ និងរដ្ឋបាល។ នាយកដ្ឋាននេះទទួលខុសត្រូវមុខងារសំខាន់ៗក្នុងធនាគារ ដើម្បីទទួលបានបុគ្គលិក ដែលត្រូវតាមតម្រូវការ និងធានាថាបុគ្គលិកទាំងនេះនឹងត្រូវបានចាត់ចែងទៅតាមសាខា ឬការិយាល័យនីមួយៗ។

រាល់ប្រតិបត្តិការរបស់នាយកដ្ឋាននេះ ពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយច្បាប់របស់ប្រទេស ហេតុដូច្នេះហើយ ទើបរាល់បញ្ហាផ្នែកច្បាប់ផ្សេងៗ ត្រូវបានត្រួតពិនិត្យមើលយ៉ាងល្អិតល្អន់ ដើម្បីធានាឲ្យបាននូវវប្បធម៌នីតិកម្ម។

ក្នុងខណៈពេលដែលផ្នែកធនធានមនុស្ស ជាអ្នកគ្រប់គ្រងបុគ្គលិក និងផ្តល់ប្រឹក្សាដល់នាយកដ្ឋានពាណិជ្ជកម្មជាដៃគូ ផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិ និងរដ្ឋបាល ក៏ត្រូវធ្វើការដោះស្រាយលើការគ្រប់គ្រងទ្រព្យសម្បត្តិសុវត្ថិភាព និងមុខងាររដ្ឋបាលផ្សេងៗទៀតផងដែរ។

បុគ្គលិក និងគណៈគ្រប់គ្រង

បុគ្គលិក ជាធនធានយ៉ាងសំខាន់បំផុតនៅក្នុងធនាគារបស់យើង។ តាមរយៈកិច្ចសហការជាក្រុម ដែលបានបង្ហាញឱ្យឃើញនូវភាពលេចធ្លោរនៃក្រុមការងារ និងការប្តេជ្ញាចិត្ត ដើម្បីសម្រេចបានសមិទ្ធផលនៅអំឡុងឆ្នាំកន្លងទៅនេះ យើងក៏មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដែលមានក្រុមដ៏រឹងមាំ។ យើងនឹងបន្តជំរុញឱ្យមានបរិយាកាសវិជ្ជមាននេះ តាមរយៈការបន្ថែមតម្លៃលើបទពិសោធន៍ និងការបង្កើនឱកាសសម្រាប់និយោជិតឱ្យចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល ដែលអនុម័តពីក្រុមហ៊ុនមេរបស់យើងនៅប្រទេសម៉ាឡេស៊ី។ គណៈកម្មាធិការគ្រប់គ្រងត្រូវបានបង្កើតឡើងចេញពីបុគ្គលិក ដែលមានការខិតខំប្រឹងប្រែងខ្សាហ៍ព្យាយាមសហប្រតិបត្តិការគ្នា ក្នុងវិស័យធនាគារ។ ធនាគារ ស៊ីអាយអ៊ីមបុី ផ្តល់នូវក្តីសុបិន្តរួមដល់បុគ្គលិក ហើយជួយជម្រុញក្តីសុបិន្តនោះក្លាយជាការពិត។

បរិយាកាសការងារ

ធនាគារ ស៊ីអាយអ៊ីមបុី ប្រកាន់យកផ្នត់គំនិតថា ការរីកចម្រើនរបស់បុគ្គលិក គឺជាការរីកចម្រើនរបស់ធនាគារ។ យើងតែងតែបណ្តុះបណ្តាលសមត្ថភាព ទេពកោសល្យបុគ្គលិក និងតម្លើងឋានៈរបស់ពួកគេ ជៀសជាងជ្រើសរើសបុគ្គលិកពីខាងក្រៅ។ យើងផ្តល់បរិយាកាសសិក្សាយ៉ាងល្អ សម្រាប់បុគ្គលិក និងថ្នាក់ដឹកនាំទៅលើការអភិវឌ្ឍខ្លួនឯងការងារ និងសមត្ថភាពការងារ។ យើងផ្តល់ការសិក្សាទាំងក្នុង និងក្រៅក្រុមហ៊ុនជូនដល់បុគ្គលិក។ យើងក៏ផ្តល់នូវការសិក្សាភាពជាអ្នកដឹកនាំ និងអាជីពក្នុងតំបន់ផងដែរ។ លើសពីនេះ យើងក៏ផ្តល់ជូននូវកម្មវិធីសិក្សាថ្នាក់ឧត្តមការអនុវត្តការងារតាមរយៈការចាត់តាំង និងកម្មវិធីចល័តបុគ្គលិកជាសាកលផងដែរ។

ការខិតខំប្រឹងប្រែងរបស់យើងដើរតួនាទីយ៉ាងសំខាន់។ ជារៀងរាល់ឆ្នាំ ជាផ្នែកមួយនៃក្រុមការងារបុគ្គលិក និងគណៈគ្រប់គ្រងត្រូវបានពង្រឹង តាមរយៈការកសាងសមត្ថភាពផ្លូវកាយ និងផ្លូវចិត្ត។

នាយកដ្ឋានព័ត៌មានវិទ្យា និងប្រតិបត្តិការ

នាយកដ្ឋានព័ត៌មានវិទ្យា និងប្រតិបត្តិការ សហការជាមួយគ្នាយ៉ាងជិតស្និទ្ធដើម្បីផ្គត់ផ្គង់ និងគាំទ្រសេវាកម្មផ្សេងៗដល់ប្រតិបត្តិការរបស់សាខាធនាគារ និងនាយកដ្ឋានផ្សេងៗទាំងឡាយ។ នៅក្នុងយុគសម័យ ដែលពាណិជកម្មដឹកនាំដោយប្រព័ន្ធបច្ចេកវិទ្យានាពេលសព្វថ្ងៃ នាយកដ្ឋានទាំងពីរយកចិត្តទុកដាក់យ៉ាងខ្លាំងលើហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធ កម្មវិធីប្រើប្រាស់សេវាកម្មព័ត៌មានវិទ្យា និងសន្តិសុខព័ត៌មានវិទ្យា។

នាយកដ្ឋានព័ត៌មានវិទ្យា និងប្រតិបត្តិការកម្ពុជារួមជាមួយនឹង GIOD – GT (នាយកដ្ឋានព័ត៌មានវិទ្យារបស់ស៊ីអាយអ៊ីមបីហ្គ្រុប) គឺជា ស្ថាបត្យករ ស្ថានិក និងអ្នកចែកចាយបន្ទូនូវគម្រោងសមាហរណកម្មជាច្រើន ព្រមទាំងជាអ្នកផ្គត់ផ្គង់ការគាំទ្រជាប្រចាំដល់ផ្នែកអាជីវកម្មផ្សេងៗ។

នាយកដ្ឋានព័ត៌មានវិទ្យា និងប្រតិបត្តិការចូលរួមជួយសម្រួលដល់ការណែនាំអំពីសេវាកម្មអេឡិចត្រូនិចផ្សេងៗ ដូចជាម៉ាស៊ីនដកប្រាក់ និងដាក់ប្រាក់ដោយស្វ័យប្រវត្តិ និងថ្មីៗនេះទៀត បានភ្ជាប់បណ្តាញអេធីអឹមក្នុងប្រទេសរបស់ខ្លួន ទៅនឹងបណ្តាញអេធីអឹមរបស់ធនាគារ ស៊ីអាយអ៊ីមបី ប្រចាំតំបន់ដូចជា នៅប្រទេសម៉ាឡេស៊ី ឥណ្ឌូណេស៊ី សិង្ហបុរី និងថៃជាដើម។

គោលដំហររបស់នាយកដ្ឋាននេះ គឺបន្តជួយពង្រឹងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា ដើម្បីផ្គត់ផ្គង់ប្រតិបត្តិការរបស់ធនាគារ ហើយទន្ទឹមនឹងនោះដែរ នាយកដ្ឋានព័ត៌មានវិទ្យាបានរៀបចំនូវគម្រោងយុទ្ធសាស្ត្រផ្សេងៗក្នុងការពង្រីក និងពង្រឹងសន្តិសុខពត៌មានវិទ្យាបន្ថែមទៀត ដើម្បីគាំទ្រគម្រោងថ្មីៗនៅឆ្នាំខាងមុខ។ ដោយមានកិច្ចគាំទ្រពីសំណាក់ GIOD – GT នាយកដ្ឋានព័ត៌មានវិទ្យា និងប្រតិបត្តិការកម្ពុជា បានបន្តធ្វើការងារដើម្បីឈានទៅដល់គោលដំហរួមតែមួយរបស់ ស៊ីអាយអ៊ីមបី ហ្គ្រុប។

នាយកដ្ឋានគ្រប់គ្រងហានិភ័យ

ការគ្រប់គ្រងហានិភ័យ គឺជាកត្តាវិន័យដ៏សំខាន់មួយនៅក្នុងចំណុចស្នូលរបស់ស្ថាប័នហិរញ្ញវត្ថុទាំងអស់។ នៅធនាគារ ស៊ីអាយអ៊ីមបី ភីអិលស៊ី នាយកដ្ឋានគ្រប់គ្រងហានិភ័យបំពេញមុខងារដោយឯករាជ្យ និងធ្វើការងារដោយផ្ទាល់ជាមួយគណៈ-កម្មាធិការពាក់ព័ន្ធចំនួនពីរគឺ គណៈកម្មាធិការឥណទានកម្ពុជា និងគណៈកម្មាធិការហានិភ័យ។ គណៈកម្មាធិការហានិភ័យដែលកោះហៅប្រជុំជារៀងរាល់ខែ គឺជាគណៈកម្មាធិការមួយដែលទទួលសិទ្ធិអំណាចពីក្រុមប្រឹក្សាភិបាល ឱ្យធ្វើការគ្រប់គ្រង និងត្រួតពិនិត្យការអនុវត្តលើរាល់សកម្មភាពគ្រប់គ្រងហានិភ័យរបស់ធនាគារ។ ចំណែកឯគណៈកម្មាធិការឥណទានកម្ពុជាដែលទទួលបានសិទ្ធិអំណាចពីក្រុមប្រឹក្សាភិបាលឱ្យពិចារណា និងសម្រេចលើការស្នើសុំឥណទាន ត្រូវរៀបចំការប្រជុំពិភាក្សាជារៀងរាល់សប្តាហ៍។ សរុបមកនាយកដ្ឋានគ្រប់គ្រងហានិភ័យទទួលខុសត្រូវចំពោះរដ្ឋាបាលនៃមុខងារគ្រប់គ្រងហានិភ័យប្រចាំថ្ងៃ ព្រមទាំងតាមដាន និងត្រួតពិនិត្យលើទំហំហានិភ័យរបស់ធនាគារ។

ហានិភ័យឥណទាន

ហានិភ័យឥណទាន សំដៅដល់លទ្ធភាពនៃការខាតបង់ដោយសារអ្នកជាប់កាតព្វកិច្ច ឬភាគីក្នុងកិច្ចសន្យាខកខានមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យាដល់ធនាគារ។ ហានិភ័យទាំងនេះកើតឡើងពីការផ្តល់កម្ចី ការផ្តល់ហិរញ្ញប្បទានពាណិជ្ជកម្ម ព្រមទាំងការសន្យាផ្តល់កម្ចីដល់អតិថិជន សម្រាប់ប្រើប្រាស់ចំពោះភាគី

នាយកដ្ឋានព័ត៌មានវិទ្យា និងប្រតិបត្តិការ

ទីបី ដូចជាការធានាជាដើម។ នាយកដ្ឋានគ្រប់គ្រងហានិភ័យ ផ្តល់ការវាយតម្លៃឯកសារជ្យលើសំណើសុំឥណទានមុនពេលដាក់ជូនឱ្យគណៈកម្មាធិការឥណទានកម្ពុជា ធ្វើការពិចារណា និងសម្រេច។ ការស្នើសុំឥណទានដែលហួសពីសិទ្ធិអំណាចអនុម័ត របស់គណៈកម្មាធិការឥណទានកម្ពុជា ត្រូវបញ្ជូនទៅឱ្យក្រុម-ប្រឹក្សាភិបាលជាអ្នកសម្រេចចុងក្រោយ។

ហានិភ័យសន្ធនីយភាព

ហានិភ័យសន្ធនីយភាព កើតឡើងនៅពេលដែលលំហូរសាច់ប្រាក់ចេញចូលរបស់ធនាគារ មិនអាចបំពេញតាមតម្រូវការថវិកា ដែលធនាគារកំពុងមាន ឬមិនគ្រប់គ្រាន់សម្រាប់បំពេញកាតព្វកិច្ចប្រាក់បញ្ញើរបស់អតិថិជននៅពេលដល់កាលកំណត់។ ហានិភ័យ សន្ធនីយភាពជាចម្បង ត្រូវបានគេធ្វើការពិនិត្យតាមដាន និងគ្រប់គ្រងដោយផ្អែកលើមូលដ្ឋាននៃការព្យាករណ៍លំហូរសាច់ប្រាក់ ពោលគឺការព្យាករណ៍យ៉ាងទៀងទាត់អំពីលំហូរសាច់ប្រាក់សម្រាប់ពេលអនាគត តាមរយៈរបាយការណ៍ការិយបរិច្ឆេទទ្រព្យសកម្ម និងអកម្ម កាតព្វកិច្ចក្រៅតារាងតុល្យការនានា និងឧបករណ៍ជួញដូរ សម្រាប់កាត់បន្ថយហានិភ័យទៅតាមអំឡុងពេលផ្សេងៗគ្នា ទាំងក្រោមស្ថានភាពអាជីវកម្មធម្មតា និងវិបត្តិ។ នាយកដ្ឋានគ្រប់គ្រងហានិភ័យ ក៏មានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យ តាមដានដោយឯករាជ្យលើទម្រង់របស់ហានិភ័យសន្ធនីយភាព និងរៀបចំរបាយការណ៍ប្រចាំខែ ដាក់ជូនគណៈកម្មាធិការ ហានិភ័យ ដើម្បីឱ្យធនាគារធ្វើការគ្រប់គ្រងស្ថានភាពសន្ធនីយភាព របស់ខ្លួនសម្រាប់បំពេញតម្រូវការប្រតិបត្តិការប្រចាំថ្ងៃ និងតម្រូវការតាមផ្នែកច្បាប់ឱ្យបានត្រឹមត្រូវផងដែរ។

ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ រួមមាន ហានិភ័យលើការខាតបង់ដោយផ្ទាល់ ឬដោយប្រយោលដែលបណ្តាលមកពីកង្វះខាត ឬការបរាជ័យនៃដំណើរការខាងក្នុង បុគ្គលិក ប្រព័ន្ធអេឡិចត្រូនិច និងព្រឹត្តិការណ៍ផ្សេងៗខាងក្រៅ។ យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ ប្រតិបត្តិការរបស់ ស៊ីអាយអិមប៊ី ហ្ស្រុប គឺផ្តោតលើគម្រោងផែនការ ហានិភ័យដ៏រឹងមាំដែលជាគោលការណ៍ណែនាំ និងទស្សនវិស័យ ដ៏ល្អរួមទាំងជាប្រព័ន្ធអភិបាលកិច្ចដ៏ល្អប្រសើរមួយ ដើម្បីបណ្តុះ នូវវប្បធម៌គ្រប់គ្រងហានិភ័យមួយតាមរបៀបបុរេសកម្មគ្រប់ពេល ជានិច្ចក្នុងការគ្រប់គ្រងហានិភ័យប្រតិបត្តិការ។ នាយកដ្ឋាន គ្រប់គ្រងហានិភ័យប្រតិបត្តិការ តែងធ្វើការណែនាំយោបល់ដល់ ផ្នែកនានា ដើម្បីធានាថារាល់គម្រោងនីមួយៗ និងដំណើរកិច្ច ប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារ ត្រូវបានធ្វើឡើងដោយមាន គោលការណ៍ និងនីតិវិធីត្រឹមត្រូវគ្រប់គ្រាន់។ ផ្នែកនីមួយៗ នៅ ក្នុងធនាគារមានតួនាទីធានាថាគ្រប់បទប្បញ្ញត្តិ និងគោលការណ៍ ដែលកំពុងមាននៅក្នុងក្រុមហ៊ុនមេរបស់ធនាគារ និងធនាគារជាតិ នៃកម្ពុជាត្រូវបានអនុវត្តតាម។ រាល់ហេតុការទាំងឡាយណា ដែលទាក់ទងនឹងហានិភ័យប្រតិបត្តិការ ឬមិនបានប្រតិបត្តិតាម ច្បាប់ ត្រូវបានរាយការណ៍ជូននាយកដ្ឋានគ្រប់គ្រងហានិភ័យ ក្នុងរយៈពេល ២៤ ទៅ ៤៨ម៉ោង គិតចាប់ពីពេលដែលរកឃើញ ដើម្បីកំណត់បញ្ហា និងចាត់វិធានការឱ្យបានសមស្រប។ ធនាគារ និងក្រុមហ៊ុនមេតែងតែរៀបចំការបណ្តុះបណ្តាលយ៉ាងទៀងទាត់ អំពីគោលការណ៍ដែលអនុម័តដោយធនាគារ និងគោលការណ៍ ដែលបានកែសម្រួលតម្រូវទៅតាមទីផ្សារដល់បុគ្គលិក ដើម្បី យល់ដឹង ហើយគោលការណ៍ទាំងអស់នោះក៏ត្រូវបានធ្វើការ ត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នកម្មជាប្រចាំផងដែរ។

ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ សំដៅលើការប្រែប្រួលនៃតម្លៃផលប័ត្រដែល បណ្តាលមកពីបម្រែបម្រួលនៃកត្តាទីផ្សារ និងកត្តាផ្សេងៗទៀត ដែលមានផលប៉ះពាល់។ ហានិភ័យទីផ្សាររបស់ធនាគារ កើត ឡើងពីបម្រែបម្រួលនៃអត្រាប្តូរប្រាក់បរទេស និងអត្រាការប្រាក់ នៅក្នុងទីផ្សារ។ គោលការណ៍ហានិភ័យទីផ្សាររបស់ធនាគារ គឺ មិនរក្សាទុកនូវលំហរូចិយប័ណ្ណបរទេស ដើម្បីរក្សាហានិភ័យឱ្យ នៅកម្រិតទាបមួយ។ ដោយសារសកម្មភាពទូទៅរបស់ធនាគារ គឺធ្វើការផ្តល់កម្ចី និងទទួលប្រាក់បញ្ញើដែលមានការិយបរិច្ឆេទ ខុសៗពីគ្នា ដូច្នេះធនាគារមិនអាចជៀសផុតពីហានិភ័យអត្រា ការប្រាក់បានឡើយ។ ហានិភ័យអត្រាការប្រាក់ជាចម្បង គឺ កើតឡើងពីភាពខុសគ្នានៃការិយបរិច្ឆេទ និងការចាត់ចែងបំពេញ គំលាតនៃលំហូរសាច់ប្រាក់ចេញចូលនៅក្នុងធនាគារ។ ហានិភ័យ អត្រាការប្រាក់នាពេលបច្ចុប្បន្ន ត្រូវបានវាស់វែងដោយរបាយ-ការណ៍គំលាតរវេទយិតភាពអត្រាការប្រាក់។ នាយកដ្ឋានគ្រប់គ្រង ហានិភ័យ ទទួលខុសត្រូវលើការត្រួតពិនិត្យតាមដានទម្រង់ ហានិភ័យអត្រាការប្រាក់របស់ធនាគារដោយឯករាជ្យ។

នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង

នាយកដ្ឋានទីផ្សារ និងទំនាក់ទំនងដើរតួយ៉ាងសំខាន់ក្នុងការ គាំទ្រកម្មវិធីទំនាក់ទំនងរបស់ធនាគារ ដើម្បីលើកកម្ពស់សាវតា របស់ធនាគារ ស៊ីអាយអិមប៊ី នៅក្នុងប្រទេសកម្ពុជា និងពង្រឹង ស្លាកសញ្ញាឱ្យមានភាពស៊ីចង្វាក់គ្នា។ នាយកដ្ឋានទីផ្សារ និង ទំនាក់ទំនងរួមមាន ផ្នែកគ្រប់គ្រងលើស្លាកសញ្ញានៃធនាគារ ទីផ្សារ ទំនាក់ទំនងសាធារណៈ គ្រប់គ្រងលើប្រព័ន្ធផ្សព្វផ្សាយ ទំនាក់ទំនងផ្ទៃក្នុង គ្រប់គ្រង និងឧបត្ថម្ភព្រឹត្តិការណ៍ និងទំនួល ខុសត្រូវសាជីវកម្ម។

នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង ត្រូវត្រួតពិនិត្យលើការ ទំនាក់ទំនងផ្ទៃក្នុងរវាងនាយកដ្ឋានផ្សេងៗ និងសកម្មភាព ទំនាក់ទំនងខាងក្រៅ ដើម្បីពង្រឹងកេរ្តិ៍ឈ្មោះ និងជម្រុញការលក់ ផលិតផល និងសេវាកម្មរបស់ធនាគារ។ នាយកដ្ឋានទីផ្សារ និង ទំនាក់ទំនងក៏ទទួលខុសត្រូវលើអត្តសញ្ញាណសាជីវកម្មទាំងអស់ ឱ្យស្របតាមគោលការណ៍ណែនាំរបស់នាយកដ្ឋានទីផ្សារ និង ទំនាក់ទំនងរបស់ក្រុមហ៊ុនមេ ដើម្បីផ្តល់ជាសារត្រូវ និងស៊ីសង្វាក់ គ្នា។ នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង បានរៀបចំព្រឹត្តិការណ៍ ទំនួលខុសសាជីវកម្មមួយចំនួនដូចជា ការប្រណាំងកង់នៅ អង្គរវត្តដើម្បីជួយដល់ក្មេងៗដែលមិនមានឱកាសក្នុងការសិក្សា ការរត់ប្រណាំង៣ក់កណ្តាលម៉ារ៉ាតុននៅភ្នំពេញដើម្បីជួយដល់ សហគមន៍ជនពិការ ព្រមទាំងការឧបត្ថម្ភកម្មវិធីមនុស្សធម៌ដទៃ មួយចំនួនទៀត ការបរិច្ចាគឈាម និងគម្រោងជួយដល់ការសិក្សា របស់ក្មេងៗជាច្រើនទៀតនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះ នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង ក៏ត្រូវទទួលបន្ទុករៀបចំ ផែនការ និងអនុវត្តរាល់ព្រឹត្តិការណ៍របស់ធនាគារទាំងអស់ផងដែរ ដូចជា ការសម្ពោធសាខា និងរៀបចំកម្មវិធីទីផ្សារ សកម្មភាព បង្កើតបណ្តាញអតិថិជន និងរៀបចំបទសម្ភាសន៍តាមប្រព័ន្ធ ផ្សព្វផ្សាយផងដែរ។ នៅក្នុងឆ្នាំ២០១៣នេះ យើងនឹងបន្តកិច្ច ខិតខំពង្រឹងបន្ថែមនូវគុណតម្លៃ និងជំហរស្លាកសញ្ញារបស់ ធនាគារឱ្យមានភាពស៊ីចង្វាក់គ្នាទូទាំងប្រទេស។

ការណែនាំជូន
ផលិតផលថ្មី

ស៊ីអាយអិមប៊ី កម្ពុជា នៅក្នុងសារព័ត៌មាន

9

Business

CIMB bank to host AEC conference in Malaysia

Abe Becker

CIMB announced it will host the second CIMB ASEAN conference at The Mandarin Oriental Kuala Lumpur hotel on June 13 and 14, according to a press release on Sunday.

The conference, under the theme "ASEAN Integration: Mind the Gap", will cater to both equity and fixed income investors and will gather some of the region's most prominent businesses and investors to profile leading ASEAN companies to fund managers and to discuss current issues surrounding ASEAN's economic integration, the press release said.

"This conference is important for Cambodia because its imminent integration into the ASEAN economic community in 2015 will provide many business opportunities for Cambodians and Cambodian businesses in other members of the community such as Thailand, Vietnam and so on," said Nazir

សន្និសីទកាសែតសម្ពោធសាខាថ្មីចំនួន៤ នៅរាជធានីភ្នំពេញ ក្រុងបាត់ដំបង និងក្រុងកំពង់ចាម កាលពីខែវិច្ឆិកា ឆ្នាំ២០១២

ធនាគារ ស៊ីអាយអ៊ីមប៊ីថៃ រៀបចំទទួលអាហារពេលល្ងាចសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ពីប្រទេសកម្ពុជា កាលពីខែមីនា ឆ្នាំ២០១២

ការបរិច្ចាកឈាម

ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១២

បុគ្គលិកធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ចូលរួមក្នុងយុទ្ធនាការទិវាផ្តល់ឈាមជាតិ

ការណែនាំដល់យុវជន

ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១២

បុគ្គលិកធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ចែករំលែកចំណេះដឹង និងបទពិសោធន៍ដល់សិស្សានុសិស្សក្នុងខេត្តព្រៃវែង

កិច្ចប្រជុំសរុប

ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២

លោក Yew Wan Kup អគ្គនាយករបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី នៅក្នុងកិច្ចប្រជុំសរុបជាមួយបុគ្គលិកនៅរាជធានីភ្នំពេញដើម្បីចែករំលែកព័ត៌មានថ្មីៗ។ បុគ្គលិកក៏មានឱកាសផ្តល់មតិយោបល់នៅក្នុងកិច្ចប្រជុំផងដែរ។

ព្រឹត្តិការណ៍ជិះកង់របស់ក្រុម INNOVATION WORKING GROUP

ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១២

ក្រុមការងារធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី រៀបចំព្រឹត្តិការណ៍ជិះកង់ជាក្រុមដើម្បីបណ្តុះស្មារតីធ្វើការងារជាក្រុម និងលើកស្ទួយការរស់នៅប្រកបដោយសុខភាពល្អ។

កម្មវិធីបង្កើនភាពស្និទ្ធស្នាលរបស់គណៈគ្រប់គ្រង

ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២

គណៈគ្រប់គ្រងរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ជួបជុំគ្នានៅរមណីដ្ឋានគិរីរម្យក្នុងសិក្ខាសាលា 'Live & Breathe CIMB Core Value' ដែលផ្ទួចផ្តើមឡើងដោយលោក Yew Wan Kup អគ្គនាយករបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី (ឈរនៅជួរខាងក្រោយ ទី៣ រាប់ពីខាងស្តាំ) និងលោក ប៊ុន យ៉ីន អគ្គនាយករងធនាគារ និង នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជ (អង្គុយជួរទី២ អ្នកទី៣ រាប់ពីខាងឆ្វេង)

RE VALUES

សមាគម MALAYSIAN RETAILER CHAINS ASSOCIATION

ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ទទួលស្វាគមន៍សមាគម Malaysian Retailer Chains Association (MRCA) អំឡុងពេលសមាគមធ្វើដំណើរទស្សនកិច្ច
មកកាន់ប្រទេសកម្ពុជា។ MRCA ធ្វើការយ៉ាងសកម្មក្នុងការលើកស្ទួយ និងផ្តោះប្តូរគំនិតអាជីវកម្មលក់រាយថ្មីៗជាមួយដៃគូនៅក្រៅប្រទេស។

កិច្ចប្រជុំគណៈគ្រប់គ្រងប្រចាំឆ្នាំ

ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១២

គណៈគ្រប់គ្រងរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បង្ហាញ និងពិភាក្សាអំពីលទ្ធផលប្រចាំឆ្នាំ។

ការសម្ពោធសាខាថ្មីចំនួន ៤ នៅក្នុងប្រទេសកម្ពុជា

ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២

លោក Dato' Shaarani Ibrahim ប្រធានក្រុមប្រឹក្សាភិបាលធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី និងលោកបណ្ឌិត ម៉ី កល្យាណ ប្រធានធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី រួមជាមួយគណៈគ្រប់គ្រងនៅពេលសម្ពោធសាខាថ្មីចំនួន៤ កាលពីខែវិច្ឆិកា ឆ្នាំ២០១២ ដែលក្នុងនោះសាខាចំនួន២ នៅរាជធានីភ្នំពេញ ១នៅក្រុងបាត់ដំបង និង ១ទៀតនៅក្រុងកំពង់ចាម។

កម្មវិធីបង្កើនភាពស្និទ្ធស្នាលរវាងបុគ្គលិករបស់ធនាគារ ស៊ីអាយអិមប៊ី នៅខេត្តសៀមរាប

ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៣

ធនាគារ ស៊ីអាយអិមប៊ី ភីលអិលស៊ី រៀបចំកម្មវិធីបង្កើនភាពស្និទ្ធស្នាលនៅខេត្តសៀមរាបសម្រាប់បុគ្គលិក ដើម្បីបង្កើនបរិយាកាសល្អប្រសើរសម្រាប់ក្រុមការងារ។

សេចក្តីថ្លែងការណ៍ស្តីពី

អភិបាលកិច្ចធនាគារ

ក្រុមប្រឹក្សាភិបាលមានជំនឿថា អភិបាលកិច្ចធនាគារដ៏រឹងមាំមួយមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការផ្តល់នូវគុណតម្លៃប្រកបដោយនិរន្តរភាព ការលើកកម្ពស់សុចរិតភាពធុរកិច្ច និងក្នុងការរក្សាទំនុកចិត្តរបស់វិនិយោគិនចំពោះធនាគារឆ្ពោះទៅរកការសម្រេចបាននូវគោលដៅ និងទស្សនវិស័យរបស់ធនាគារ។

វប្បធម៌ និងរចនាសម្ព័ន្ធអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពគឺជាធាតុសំខាន់បំផុតក្នុងការកំណត់អំពីរបៀបរបបដែលធនាគារដំណើរការ ហើយថ្នាក់ដឹកនាំធនាគារតែងតែសង្កត់ធ្ងន់លើចំណុចនេះ ក្នុងការណែនាំដល់គ្រប់បុគ្គលិករបស់ខ្លួនទាំងអស់ជាបន្តបន្ទាប់។ ក្របខណ្ឌអភិបាលកិច្ចដែលធនាគារសម្រេចយក ត្រូវបានធ្វើឡើង ដោយផ្អែកលើគោលការណ៍នានា និងការអនុវត្តល្អបំផុត ដូចមានចែងក្នុងប្រកាសរបស់ធនាគារជាតិនៃកម្ពុជាស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងប្រកាសស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របសម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ និងការអនុវត្តល្អបំផុតជាលក្ខណៈអន្តរជាតិក្នុងអភិបាលកិច្ចធនាគារដែលពាក់ព័ន្ធ។

ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល និងតុល្យភាពនៃក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ននេះ ក្រុមប្រឹក្សាភិបាលមានសមាជិកចំនួន ០៦ រូប ដែលរួមមានអភិបាលប្រតិបត្តិចំនួន ០១ រូប និងអភិបាលមិនប្រតិបត្តិចំនួន ០៥ រូប ហើយក្នុងចំណោមអភិបាលទាំងនោះមានអភិបាលចំនួន ០៤ រូបជាអភិបាលឯករាជ្យ។ ក្រុមប្រឹក្សាភិបាលបានបញ្ជាក់ថាសមាសភាពក្រុមប្រឹក្សាភិបាលមានចំនួនអភិបាលឯករាជ្យគ្រប់គ្រាន់ ដែលអាចធ្វើការវិនិច្ឆ័យដោយឯករាជ្យបំផុតនៅក្នុងកិច្ចពិភាក្សានានារបស់ក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលក៏ត្រូវគោរពជំណើរការនៃការធ្វើសេចក្តីសម្រេចរួមផងដែរ។

ក្រុមប្រឹក្សាភិបាល ទទួលបានអត្ថប្រយោជន៍ពីការចូលរួមចំណែកនានារបស់អភិបាលមិនប្រតិបត្តិនីមួយៗ នៅក្នុងគ្រប់វិស័យទាំងអស់នៃធុរកិច្ចរបស់ធនាគារ។ បន្ថែមពីលើជំនាញ និងបទពិសោធន៍ផ្នែកអាជីវកម្មជាច្រើនឆ្នាំរបស់អភិបាលនីមួយៗ អភិបាលមិនប្រតិបត្តិក៏ធ្វើការវិនិច្ឆ័យដោយឯករាជ្យក្នុងកិច្ចពិភាក្សាស្តីពីបញ្ហាយុទ្ធសាស្ត្រ សវនកម្ម ប្រតិបត្តិការ និងហានិភ័យផងដែរ។

រចនាសម្ព័ន្ធ និងសមាសភាពរបស់ក្រុមប្រឹក្សាភិបាលត្រូវគោរពទៅតាមលក្ខខណ្ឌតម្រូវ ដែលមានចែងនៅក្នុងប្រកាសរបស់ធនាគារជាតិនៃកម្ពុជា។

សមាសភាពក្រុមប្រឹក្សាភិបាល



ដើម្បីធានាឱ្យបាននូវតុល្យភាពនៃអំណាច ការបង្កើននូវគណនេយ្យភាព និងសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចប្រកបដោយឯករាជភាពនោះ តួនាទីរបស់ប្រធានក្រុមប្រឹក្សាភិបាល និងតួនាទីរបស់អភិបាលប្រតិបត្តិ/អគ្គនាយក (ED/GM) ត្រូវបានបែងចែក និងដាក់ឱ្យនៅដាច់ដោយឡែកពីគ្នា ដោយមានការបែងចែកយ៉ាងច្បាស់លាស់អំពីការទទួលខុសត្រូវរវាងប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលប្រតិបត្តិ/អគ្គនាយក ដើម្បីជៀសវាងកុំឱ្យបុគ្គលណាម្នាក់ ឬក្រុមណាមួយអាចត្រួតត្រាលើជំណើរការនៃការធ្វើសេចក្តីសម្រេចបាន។

ប្រធានក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ត្រូវបានដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល ០១ រូប គឺលោក Dato' Shaarani Ibrahim។ លោក Dato' Shaarani Ibrahim ទទួលខុសត្រូវលើការដឹកនាំ និងគ្រប់គ្រងក្រុមប្រឹក្សាភិបាល ហើយធានាប្រសិទ្ធភាពនៃការបំពេញមុខងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។ ប្រធានក្រុមប្រឹក្សាភិបាលបំពេញតួនាទីផ្លូវការជាថ្នាក់ដឹកនាំ និងធ្វើជាអធិបតីក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលទាំងអស់ ដឹកនាំការពិភាក្សារវាងអភិបាល ព្រមទាំងតម្រង់ទិសក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យលើការគ្រប់គ្រងធនាគារ។ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវធ្វើការសម្របសម្រួលលំហូរព័ត៌មានរវាងគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល ព្រមទាំងពិភាក្សាយោបល់ជាមួយគណៈគ្រប់គ្រង ដើម្បីដាក់ចេញនូវរបៀបវារៈសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនីមួយៗ។

អភិបាលប្រតិបត្តិ/អគ្គនាយក

លោក Yew Wan Kup គឺជាអភិបាលប្រតិបត្តិ/អគ្គនាយករបស់ធនាគារ។ លោកទទួលខុសត្រូវរួមលើការអនុវត្តយុទ្ធសាស្ត្ររបស់ធនាគារ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល រៀបចំធុរកិច្ចរបស់ធនាគារ និងដឹកនាំប្រតិបត្តិការ ស្របតាមគោលដៅយុទ្ធសាស្ត្រ និងទិសដៅអាជីវកម្ម។ លោកគឺជាប្រធានគណៈកម្មាធិការគ្រប់គ្រង ហើយធ្វើការដឹកនាំគណៈកម្មាធិការគ្រប់គ្រងក្នុងការអនុវត្តយុទ្ធសាស្ត្រ និងទស្សនវិស័យរបស់ធនាគារ។ ក្នុងឋានៈជាអភិបាលប្រតិបត្តិ/អគ្គនាយក លោកទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាភិបាល លើប្រតិបត្តិការធុរកិច្ចប្រចាំថ្ងៃរបស់ធនាគារ។

ទំហំ និងសមាសភាពរបស់ក្រុមប្រឹក្សាភិបាល

ទំហំ និងសមាសភាពរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ ដោយពិនិត្យមើលទៅលើវិសាលភាពលក្ខណៈ ភាពខុសប្លែកគ្នា និងការពង្រីកធុរកិច្ចរបស់ធនាគារ។

ក្រុមប្រឹក្សាភិបាលយល់ឃើញ និងអះអាងថា សមាសភាពក្រុមប្រឹក្សាភិបាលនាពេលបច្ចុប្បន្នមានចំនួនគ្រប់គ្រាន់ សម្រាប់គ្រប់គ្រងអាជីវកម្មទាំងមូលរបស់ធនាគារ។ សមាជិកក្រុមប្រឹក្សាភិបាលបច្ចុប្បន្នបានពាំនាំយកនូវចំណេះដឹង បទពិសោធន៍ និងជំនាញដ៏មានតម្លៃមកកាន់ក្រុមប្រឹក្សាភិបាល ដើម្បីដឹកនាំធនាគារឆ្ពោះទៅរកការសម្រេចបាន នូវទស្សនវិស័យរបស់ក្រុមហ៊ុនមេ។

អភិបាលទាំងអស់របស់ធនាគារ សុទ្ធតែបានបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យគ្រប់គ្រាន់ ដើម្បីទទួលបានមុខតំណែងជាអភិបាល ដូចមានចែងក្នុងប្រកាសរបស់ធនគារជាតិនៃកម្ពុជា។ គ្រប់អភិបាលឯករាជ្យទាំងអស់របស់ធនាគារ បង្ហាញអំពីការវិនិច្ឆ័យដោយឯករាជ្យ និងអាចទទួលយកបាន ព្រមទាំងមិនចូលរួមប្រតិបត្តិធុរកិច្ចណា ដែលអាចមានផលប៉ះពាល់ដល់ការវិនិច្ឆ័យ និងការធ្វើសេចក្តីសម្រេចដោយឯករាជភាពរបស់ខ្លួនឡើយ។ ប្រវត្តិរូបសង្ខេបរបស់អភិបាលនីមួយៗ មានបង្ហាញនៅលើទំព័រទី ៤៨ ដល់ ៥០ នៃរបាយការណ៍ប្រចាំឆ្នាំនេះ។

ក្រមសីលធម៌របស់អភិបាល

ក្រុមប្រឹក្សាភិបាល គោរពតាមវិធាននៃក្រមសីលធម៌ ដែលមានចែងក្នុងប្រកាសរបស់ធនាគារជាតិនៃកម្ពុជា។

អភិបាលរបស់ធនាគារ ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌ដែលជាមគ្គុទេសក៍ សម្រាប់ការអនុវត្តនូវបទដ្ឋានក្រមសីលធម៌មួយដ៏ត្រឹមត្រូវ និងការអនុវត្តធុរកិច្ចប្រកបដោយភាពប្រុងប្រយ័ត្ន ក៏ដូចជាបទដ្ឋានអាកប្បកិរិយា ប្រកបដោយក្រមសីលធម៌សម្រាប់អភិបាលម្នាក់ៗ ដោយផ្អែកលើគោលការណ៍សុចរិតភាព ការទទួលខុសត្រូវ ភាពស្មោះត្រង់ និងការទទួលខុសត្រូវចំពោះសង្គម។

ការកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល គឺជាអង្គភាពមួយរបស់ធនាគារដែលធ្វើសេចក្តីសម្រេចចុងក្រោយបង្អស់ លើកលែងតែបញ្ហាណាដែលទាមទារឱ្យមានការអនុម័តយល់ព្រមពីភាគទុនិក។ ក្រុមប្រឹក្សាភិបាលដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រ និងទស្សនវិស័យរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវទាំងស្រុង លើការដឹកនាំ គ្រប់គ្រង ណែនាំ និងត្រួតពិនិត្យលើគ្រប់ប្រតិបត្តិការទាំងមូលរបស់ធនាគារ ហើយពង្រឹងបទដ្ឋាននៃគណនេយ្យភាពក្នុងគោលគំនិតជួយដល់គណៈគ្រប់គ្រង ដើម្បីអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវរួមលើការបង្កើតក្របខណ្ឌការងារ នៃអភិបាលកិច្ចល្អនៅក្នុងធនាគាររាប់បញ្ចូលទាំងដំណើរការ នៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាមច្បាប់។ សមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប ត្រូវនាំយកនូវការវិនិច្ឆ័យឯករាជ្យ ចំណេះដឹងផ្សេងៗគ្នា និងបទពិសោធន៍នានា ដើម្បីធ្វើការពិភាក្សាអំពីបញ្ហានានាទាក់ទងនឹងយុទ្ធសាស្ត្រ ប្រតិបត្តិការ ធនធាន និងការធ្វើធុរកិច្ច។

ក្រុមប្រឹក្សាភិបាល បានអនុម័តលើរបៀបវារៈនៃបញ្ហាមួយចំនួន ដែលត្រូវបានរៀបចំសម្រាប់សុំការអនុម័តពីក្រុមប្រឹក្សាភិបាល រាប់បញ្ចូលទាំង (ក្នុងចំណោមចំណុចផ្សេងៗទៀតជាច្រើន) ការពិនិត្យមើលឡើងវិញ និងការយល់ព្រមលើចំណុចដូចខាងក្រោម៖

- ផែនការយុទ្ធសាស្ត្រ/ធុរកិច្ច និងគម្រោងថវិកាប្រចាំឆ្នាំ។
- ការវិនិយោគថ្មីៗ ការផ្តាច់ខ្លួន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញក្រុមហ៊ុន ការរៀបចំរចនាសម្ព័ន្ធក្រុមហ៊ុនឡើងវិញ រាប់បញ្ចូលទាំងការបង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធ ការចូលហ៊ុន ឬ សម្ព័ន្ធយុទ្ធសាស្ត្រ ទាំងនៅក្នុង និងក្រៅប្រទេស។
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងភាគលាភបណ្តោះអាសន្ន ព្រមទាំងការផ្តល់យោបល់លើភាគលាភ ចុងក្រោយដែលត្រូវចែកជូនភាគទុនិកនៅមុនពេលផ្សព្វផ្សាយ និងប្រកាសផ្សាយជាសាធារណៈអំពីការបែងចែកភាគលាភ។
- ការតែងតាំងអភិបាល និងប្រធាននាយកប្រតិបត្តិថ្មី ព្រមទាំងការកំណត់ប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗរបស់ពួកគេ។

ការទទួលខុសត្រូវរួមសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាលមានដូចខាងក្រោម៖

- ផ្តល់នូវគោលដៅ និងគោលនយោបាយច្បាស់លាស់សម្រាប់ឱ្យមន្ត្រីប្រតិបត្តិជាន់ខ្ពស់អនុវត្ត។
- ធានាឱ្យមាននូវការត្រួតពិនិត្យគ្រប់គ្រាន់ ព្រមទាំងមានប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រាន់ សម្រាប់សម្រួលដល់ការអនុវត្តគោលនយោបាយរបស់ធនាគារ។
- តាមដានអំពីភាពជោគជ័យរបស់គណៈគ្រប់គ្រងក្នុងការអនុវត្តយុទ្ធសាស្ត្រ ផែនការ និងគម្រោងថវិកា ដែលបានអនុម័តរួច។
- ស្វែងយល់អំពីហានិភ័យចម្បងៗ ដែលទាក់ទងនឹងធុរកិច្ចរបស់ធនាគារ ព្រមទាំងធានាថាមានប្រព័ន្ធបច្ចេកវិទ្យាដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងលើហានិភ័យប្រកបដោយប្រសិទ្ធភាពក្នុងទស្សនវិស័យទទួលបានលទ្ធផល និងភាពជោគជ័យរយៈពេលវែងសម្រាប់ធនាគារ។
- តាមដានត្រួតពិនិត្យ និងសិក្សាលើការអភិវឌ្ឍដែលអាចជះឥទ្ធិពលដល់ផែនការយុទ្ធសាស្ត្រនានារបស់ធនាគារ។
- ពិនិត្យមើលឡើងវិញលើភាពគ្រប់គ្រាន់ និងសុចរិតភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងប្រព័ន្ធព័ត៌មានគ្រប់គ្រង រាប់បញ្ចូលទាំងប្រព័ន្ធនៃការប្រតិបត្តិតាមបញ្ញត្តិច្បាប់ បទបញ្ជា សារាចរ និង សេចក្តីណែនាំដែលមានជាធរមាន។
- បញ្ជៀសវិវាទផលប្រយោជន៍ និងធានាការផ្សព្វផ្សាយព័ត៌មានអំពីវិវាទផលប្រយោជន៍ដែលអាចកើតមាន។
- ប្រកាន់ខ្ជាប់ និងអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិស្តីពីធនាគារ ព្រមទាំងច្បាប់ វិធាន និងបទប្បញ្ញត្តិ ផ្សេងទៀត។

ក្រៅពីការទទួលខុសត្រូវសំខាន់ៗដែលបានរៀបរាប់ខាងលើ ក្រុមប្រឹក្សាភិបាលក៏ត្រូវប្រគល់ការទទួលខុសត្រូវជាក់លាក់មួយចំនួនឱ្យគណៈកម្មាធិការនានាផងដែរ។ ក្នុងខណៈដែលគណៈ-កម្មាធិការទាំងនេះ មានសិទ្ធិអំណាចពិនិត្យលើបញ្ហាជាក់លាក់ណាមួយ គណៈកម្មាធិការនោះក៏ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសេចក្តីសម្រេច/អនុសាសន៍របស់ខ្លួន ហើយការទទួលខុសត្រូវចុងក្រោយចំពោះបញ្ហាទាំងអស់នេះនៅតែជារបស់ក្រុមប្រឹក្សាភិបាលទាំងមូល។ តួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់ គណៈកម្មាធិការនានាមានបង្ហាញនៅទំព័រទី ៣២-៣៥។

ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល

ធនាគារអនុវត្តតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ ដែលជាគណៈកម្មាធិការមួយរបស់ស៊ីអាយអិមប៊ី ហ្គ្រុប ហូលឌីង ប៊ើហាដ (CIMB Group Holdings Berhad)។ គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេ ទទួលបន្ទុកកំណត់ និងបញ្ជូនបេក្ខភាពដែលសក្តិសមសម្រាប់តំណែងអភិបាលទៅក្រុមប្រឹក្សាភិបាល ដើម្បីសុំការអនុម័តយល់ព្រមលើការតែងតាំង មិនថាសម្រាប់បំពេញតំណែងដែលទំនេរ ឬ បន្ថែមលើតំណែង ដែលមានស្រាប់ ដើម្បីបំពេញតាមតម្រូវការដែលបានប្រែប្រួលរបស់ធនាគារ។ មុនពេលផ្តល់អនុសាសន៍លើការតែងតាំងអភិបាលទៅក្រុមប្រឹក្សាភិបាល គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេទទួលខុសត្រូវ ក្នុងការវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយលើបេក្ខភាពជាអភិបាល ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនានាដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ ធនាគារ ក៏ពិចារណាទៅលើប្រភេទធុរកិច្ចរបស់ធនាគារ ហើយផ្ទូរផ្ទង់ជាមួយសមត្ថភាព និងការចូលរួមចំណែកដែលរំពឹងទុកពីបេក្ខភាពដែលត្រូវទទួលតំណែងនេះផងដែរ។

នីតិវិធីនៃការតែងតាំងត្រូវធ្វើឡើងស្របតាមប្រកាស និងគោលការណ៍ ព្រមទាំងនីតិវិធីរបស់ក្រុមហ៊ុនមេស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប សម្រាប់បុគ្គលកាន់មុខងារដែលមានការទទួលខុសត្រូវសំខាន់របស់ក្រុមហ៊ុន (គោលការណ៍ស្តីពី លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប)។ គោលការណ៍នេះចែងអំពីនីតិវិធីផ្លូវការមួយសម្រាប់ការតែងតាំងអភិបាល ប្រធានក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ។ បេក្ខភាពនីមួយៗត្រូវឆ្លងកាត់ការវាយតម្លៃដែលត្រឹមត្រូវ ហើយគណៈកម្មាធិការ តែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេ ត្រូវធ្វើការបញ្ជាក់ថាបេក្ខភាពនោះថាមានលក្ខខណ្ឌសក្តិសម និងត្រឹមត្រូវ សម្រាប់មុខតំណែងដែលត្រូវទទួលការតែងតាំង។

គោលការណ៍ស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប ក៏ចែងអំពីលក្ខណៈវិនិច្ឆ័យមួយចំនួនសម្រាប់ធ្វើការវាយតម្លៃអំពីភាពសក្តិសមរបស់បេក្ខភាពដែលត្រូវតែងតាំងដូចខាងក្រោម៖

(i) សុចរិតភាព ភាពស្មោះត្រង់ និងកេរ្តិ៍ឈ្មោះបុគ្គល ដែលបេក្ខភាពនីមួយៗ ត្រូវមានដូចជាមានភាពស្មោះត្រង់ សុចរិតភាព ឧស្សាហ៍ព្យាយាម មានគំនិតឯករាជ្យ និងមិនលម្អៀង។
(ii) សមត្ថភាពដែលបេក្ខជនត្រូវមានដូចជាជំនាញ បទពិសោធន៍ការងារ សមត្ថភាព និងការប្តេជ្ញាចិត្ត ដែលចាំបាច់ ដើម្បីអនុវត្តតួនាទីរបស់ខ្លួន។
(iii) សុចរិតភាពផ្នែកហិរញ្ញវត្ថុ ពោលគឺបេក្ខជនត្រូវគ្រប់គ្រងឥណទាន ឬកិច្ចការហិរញ្ញវត្ថុរបស់ខ្លួនដោយប្រុងប្រយ័ត្នបំផុត។

នីតិវិធីសម្រាប់កំណត់អត្តសញ្ញាណ និងស្នើឈ្មោះបេក្ខជនសម្រាប់ការតែងតាំងតំណែងនេះមាន ០៥ ដំណាក់កាលដូចខាងក្រោម៖

ក្របខណ្ឌនៃការស្នើឈ្មោះបេក្ខជន

សំណើសុំតែងតាំងអភិបាលថ្មី និងសំណើសុំតែងតាំងអភិបាលចាស់ជាថ្មីម្តងទៀត គឺអាស្រ័យលើការពិនិត្យ និងអនុម័តយល់ព្រមជាមុនរបស់ធនាគារជាតិនៃកម្ពុជា។

ការតែងតាំង និងការបោះឆ្នោតជ្រើសតាំងអភិបាលជាថ្មីម្តងទៀត

ជារៀងរាល់ឆ្នាំ នៅក្នុងមហាសន្និបាតប្រចាំឆ្នាំ ១/៣ នៃចំនួនសមាជិកក្រុមប្រឹក្សាភិបាលត្រូវបញ្ចប់តំណែងរបស់ខ្លួន ប៉ុន្តែពួកគាត់នៅតែមានសិទ្ធិអាចឈរឈ្មោះឱ្យគេបោះឆ្នោតសាជាថ្មីបាននៅក្នុងមហាសន្និបាតប្រចាំឆ្នាំនោះ។ បន្ថែមពីលើនេះទៀត លក្ខន្តិកៈធនាគារតម្រូវថានៅក្នុងរយៈពេល ០៣ ឆ្នាំម្តង អភិបាលទាំងអស់ត្រូវបញ្ចប់ពីមុខតំណែងយ៉ាងហោចណាស់ឱ្យបានម្តង ប៉ុន្តែពួកគាត់នៅមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសសាជាថ្មីបាននៅក្នុងមហាសន្និបាតប្រចាំឆ្នាំ។ គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេ ត្រូវផ្តល់អនុសាសន៍លើសំណើសុំតែងតាំង និងបោះឆ្នោតជ្រើសរើសអភិបាលសាជាថ្មីជូនក្រុមប្រឹក្សាភិបាល មុននឹងដាក់ជូនភាគទុនិកអនុម័តនៅក្នុងមហាសន្និបាតប្រចាំឆ្នាំ។

កិច្ចប្រជុំ និងការផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ត្រូវជួបប្រជុំជាប្រចាំ ដើម្បីពិភាក្សាលើយុទ្ធសាស្ត្រអាជីវកម្ម ប្រតិបត្តិការហិរញ្ញវត្ថុ បញ្ហាដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិ និងអភិបាលកិច្ច ក៏ដូចជារបាយការណ៍ស្តីពីបញ្ហាដែលគណៈកម្មាធិការនីមួយៗបានពិភាក្សាគ្នាផងដែរ។ នៅរៀងរាល់ ០៣ខែម្តង ក្រុមប្រឹក្សាភិបាលពិនិត្យឡើងវិញលើប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ ការគ្រប់គ្រងហានិភ័យ និងរបាយការណ៍ស្តីពីការអនុវត្តបទប្បញ្ញត្តិ ព្រមទាំងធ្វើការអនុម័តលើលទ្ធផលប្រចាំត្រីមាសរបស់ធនាគារនៅក្នុងកិច្ចប្រជុំរបស់ខ្លួន។ ជារៀងរាល់ឆ្នាំ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវបានកំណត់កាលបរិច្ឆេទទុកមុនរួចជាស្រេច ដើម្បីអាចឱ្យអភិបាលទាំងអស់មានភាពងាយស្រួលក្នុងការរៀបចំធ្វើកាលវិភាគប្រជុំផ្ទាល់ខ្លួនរបស់អភិបាល។ ឯកសារសម្រាប់កិច្ចប្រជុំដែលមានសំណើ និងរបាយការណ៍ផ្សេងៗទៀតត្រូវបានចែកជូនក្រុមប្រឹក្សាភិបាល ឱ្យបានមុនពេលដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដើម្បីអាចឱ្យអភិបាលទាំងអស់មានពេលវេលាគ្រប់គ្រាន់ ក្នុងការធ្វើការវាយតម្លៃលើសំណើទាំងនេះ ហើយប្រសិនបើចាំបាច់ស្នើសុំព័ត៌មានបន្ថែម ដើម្បីជួយសម្រួលអភិបាលក្នុងការបំពេញកាតព្វកិច្ចប្រកបដោយប្រសិទ្ធភាព។ នីតិវិធីនានាត្រូវបានបង្កើតឡើងទាក់ទងនឹងទម្រង់ ខ្លឹមសារ បទបង្ហាញ និងការចែកជូនឯកសារសម្រាប់កិច្ចប្រជុំ។ ឯកសារសម្រាប់កិច្ចប្រជុំបញ្ជាក់យ៉ាងច្បាស់អំពីប្រវត្តិគោលបំណង បញ្ហាសំខាន់ៗ សនិទានភាព ផលប៉ះពាល់ និងព័ត៌មានផ្សេងៗទៀតដែលទាក់ទងនឹងសំណើនីមួយៗ ដើម្បីជួយឱ្យក្រុមប្រឹក្សាភិបាល អាចធ្វើសេចក្តីសម្រេចចិត្តបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព។

អភិបាល មានលទ្ធភាពទទួលបានគ្រប់ព័ត៌មានទាំងអស់របស់ធនាគារ។ តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដែលធ្វើឡើងជាទៀងទាត់ ក្រុមប្រឹក្សាភិបាលទទួលនូវព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពអំពីការអភិវឌ្ឍ និងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ ក៏ដូចជាទទួលបានផងដែរនូវឯកសារមួយច្បាប់ពេញលេញ រាប់បញ្ចូលទាំងរបាយការណ៍ជាទៀងទាត់ស្តីពីការវិវឌ្ឍនៃអាជីវកម្ម និងឯកសារផ្សេងៗសម្រាប់ពិភាក្សាទាក់ទងនឹងបញ្ហាជាក់លាក់ណាមួយ។ អភិបាលក៏ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចប្រជុំ ក្រុមប្រឹក្សាភិបាលតាមរយៈប្រព័ន្ធទូរស័ព្ទផងដែរ។ រាល់ការពិភាក្សាដេញដោលនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល រាប់បញ្ចូល ទាំងការខ្វែងគំនិតគ្នាត្រូវបានកត់ត្រាទុកទាំងស្រុងសម្រាប់ធ្វើជាកំណត់ហេតុនៃដំណើរការពិភាក្សារបស់អភិបាល។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវបានផ្ញើជូនគណៈគ្រប់គ្រងក្នុងរយៈពេលមួយថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកិច្ចប្រជុំត្រូវបានបញ្ចប់ ដើម្បីធានា ថាសេចក្តីសម្រេច និងការណែនាំផ្សេងៗត្រូវបានអនុវត្តទាន់ពេលវេលា។ សេចក្តីព្រាងកំណត់ហេតុត្រូវបានបញ្ជូនទៅអភិបាលទាំងអស់ ដើម្បីធ្វើការពិនិត្យ និងផ្តល់អនុសាសន៍ មុនពេលដាក់បញ្ជូនកំណត់ហេតុនោះទៅក្នុងរបៀបវារៈសម្រាប់អនុម័តយល់ព្រមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលបន្ទាប់។

នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អភិបាលប្រតិបត្តិ/អគ្គនាយក ត្រូវធ្វើការពន្យល់ឱ្យបានក្បោះក្បាយអំពីបញ្ហាសំខាន់ៗទាក់ទងនឹងធុរកិច្ច និងប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ។ លទ្ធផលសវនកម្មសំខាន់ៗដែលធ្វើឡើងដោយសវនករផ្ទៃក្នុងនៃក្រុមហ៊ុនមេ ក៏ត្រូវបញ្ជូនទៅក្រុមប្រឹក្សាភិបាលផងដែរ ដើម្បីធ្វើការពិភាក្សានិងណែនាំ។ បន្ថែមពីលើនេះទៀត នាយកនៃនាយកដ្ឋានប្រតិបត្តិត្រូវធ្វើសេចក្តីរាយការណ៍អំពីស្ថានភាពនៃការគោរពច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ និងនីតិវិធីផ្ទៃក្នុងដែលបានអនុម័តដោយធនាគារ។ គណៈគ្រប់គ្រងក៏ត្រូវបានអញ្ជើញឱ្យធ្វើបទបង្ហាញអំពីសំណើ និងឆ្លើយតបសំណួរផ្សេងៗ ដែលក្រុមប្រឹក្សាភិបាលចោទសួរ តាមការចាំបាច់ផងដែរ។ គណៈគ្រប់គ្រង ត្រូវចាត់វិធានការជាបន្ទាន់លើរាល់បញ្ហា ដែលលើកឡើងនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងត្រូវធ្វើបច្ចុប្បន្នភាពទៅក្រុមប្រឹក្សាភិបាលអំពីស្ថានភាពនៃបញ្ហាទាំងនេះ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកក្រោយ ឬ ប្រសិនបើយល់ថាបន្ទាន់ ត្រូវបញ្ជូនតាមការជូនដំណឹងជាលាយលក្ខណ៍អក្សរ។

អភិបាលណាម្នាក់ ដែលអាចជាប់ពាក់ព័ន្ធទទួលបានផលប្រយោជន៍ពីសំណើណាមួយ ឬកិច្ចការណាមួយ ដែលបានដាក់ជូនក្រុមប្រឹក្សាភិបាលសម្រេច ត្រូវប្រកាសប្រាប់អំពីផលប្រយោជន៍ដែលពាក់ព័ន្ធនឹងខ្លួន ហើយត្រូវដកខ្លួនចេញពីការពិភាក្សា និងការបោះឆ្នោតគាំទ្រសំណើ ឬកិច្ចការដែលបានស្នើនោះ។ នីតិវិធីនេះ ត្រូវបានកត់ត្រាទុកទាំងស្រុងនៅក្នុងកំណត់ហេតុនៃដំណើរការកិច្ចប្រជុំ។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសរុបចំនួន ០៤ លើក ត្រូវបានរៀបចំឡើងនៅឆ្នាំ ២០១២ ដោយមានវត្តមានរបស់អភិបាល ដូចមានរៀបរាប់ខាងក្រោម៖

ចំនួនកិច្ចប្រជុំ

អភិបាល	**បានចូលរួម**	**ចំនួនកិច្ចប្រជុំ**
Dato' Shaarani Ibrahim		
ប្រធានក្រុមប្រឹក្សាភិបាល/អភិបាលឯករាជ្យមិនប្រតិបត្តិ	៤	៤
Goh Nan Kioh		
អភិបាលឯករាជ្យមិនប្រតិបត្តិ	៣	៤
Dato' Wira Zainal Abidin Mahamad Zain		
អភិបាលឯករាជ្យមិនប្រតិបត្តិ	៤	៤
Yew Wan Kup		
អភិបាលមិនឯករាជ្យប្រតិបត្តិ/អគ្គនាយក	៤	៤
បណ្ឌិត ម៉ី កល្យាណ *		
អភិបាលឯករាជ្យមិនប្រតិបត្តិ	២	២
Peter England		
អភិបាលមិនឯករាជ្យមិនប្រតិបត្តិ	៤	៤

** តែងតាំងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២*

នៅដើមឆ្នាំហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលពិចារណាលើថវិកាប្រចាំឆ្នាំរបស់ធនាគារ ស្របជាមួយនឹងយុទ្ធសាស្ត្រ និងផែនការរបស់ធនាគារ ដែលបានបង្កើតឡើងនៅក្នុងកិច្ចប្រជុំពិភាក្សាថ្នាក់គ្រប់គ្រងប្រចាំឆ្នាំ។

ការបណ្តុះបណ្តាល និងការអភិវឌ្ឍរបស់អភិបាល

កម្មវិធីបណ្តុះបណ្តាលអភិបាល គឺជាធាតុដ៏សំខាន់មួយនៃដំណើរការតែងតាំងអភិបាលថ្មី ហើយក្រុមប្រឹក្សាភិបាល ត្រូវយកចិត្តទុកដាក់លើតម្រូវការក្នុងការអនុវត្តស្របតាមច្បាប់ និងបទប្បញ្ញត្តិថ្មីៗ បទដ្ឋានគណនេយ្យ ការប្រែប្រួលហានិភ័យអាជីវកម្ម និន្នាការទីផ្សារ និងការវិវឌ្ឍចុងក្រោយ បញ្ហាប្រឈមសំខាន់ៗនៅក្នុងទីផ្សារក្នុងស្រុក និងក្នុងតំបន់ និងក្នុងវិស័យធនាគារ។ ក្នុងគោលបំណងនេះ ក្រុមប្រឹក្សាភិបាលធ្វើការវាយតម្លៃលើតម្រូវការបណ្តុះបណ្តាល ដោយឈរលើមូលដ្ឋានវាយតម្លៃតាមដំណាក់កាល ហើយកំណត់អំពីចំណុចដែលអាចពង្រីកចំណេះដឹងរបស់អភិបាលទាក់ទងនឹងបញ្ហាដែលធនាគារកំពុងប្រឈម។

ខាងក្រោមនេះ គឺជាបញ្ជីវគ្គបណ្តុះបណ្តាលដែលអភិបាលបានចូលរួម ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅតំបន់អាស៊ីអាគ្នេយ៍ ដើម្បីអភិវឌ្ឍចំណេះដឹងទាន់ពេលវេលា៖

ចំនួនវគ្គបណ្តុះបណ្តាលដែលបានចូលរួម	ប្រភេទវគ្គ បណ្តុះបណ្តាល	ចំនួនម៉ោង ចូលរួម
អភិបាលកិច្ចធនាគារ		
អភិបាលកិច្ចធនាគារ ស៊ីអាយអិមប៊ី នាពេលបច្ចុប្បន្ន និងទិសដៅនាពេលខាងមុខ	វេទិកា	១ ថ្ងៃ
សន្និបាត ឆ្នាំ២០១២ ស្តីពីការធ្វើបច្ចុប្បន្នភាពនៃច្បាប់ បទប្បញ្ញត្តិ អភិបាលកិច្ច និងបញ្ហានាពេលបច្ចុប្បន្នសម្រាប់ អភិបាលនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងបណ្តាក្រុមហ៊ុនផ្សេងទៀត	វេទិកា	១ ថ្ងៃ
សន្និបាតស្តីពីការយល់ដឹងអំពីច្បាប់គ្រប់គ្រងអភិបាល និងបញ្ហាពាក់ព័ន្ធដទៃទៀត	វេទិកា	កន្លះថ្ងៃ
សន្និបាតស្តីពីតួនាទីជាអភិបាលកិច្ចឈានមុខរបស់ គណៈកម្មាធិការសវនកម្ម: តើអ្នកមានចំណេះដឹង គ្រប់គ្រាន់អំពីតួនាទីនេះ ដែរឬទេ?	វេទិកា	១ ថ្ងៃ
កម្មវិធីសិក្សារបស់អភិបាលស្តីពីគ្រឹះស្ថានហិរញ្ញវត្ថុ (ធានារ៉ាប់រង)	–	–
ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងលើការប្រែប្រួល		
ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី: កិច្ចពិភាក្សាថ្នាក់គ្រប់គ្រង ប្រចាំឆ្នាំខ្នាតតូច	វេទិកា	កន្លះថ្ងៃ
មហាសន្និបាតគណៈគ្រប់គ្រងប្រចាំឆ្នាំរបស់ក្រុមហ៊ុនមេ	វេទិកា	១ ថ្ងៃ
កិច្ចពិភាក្សា និងការជួបជុំពិសារអាហារពេលល្ងាច ជា លក្ខណៈឯកជន Dick Kovacevich	វេទិកា	–
វគ្គបណ្តុះបណ្តាលអំពី Pillar 2/ICAAP Basel II សម្រាប់គណៈគ្រប់គ្រងជាន់ខ្ពស់: វគ្គ១	វេទិកា	១ ថ្ងៃ
កិច្ចពិភាក្សាតុមូលស្តីពីធនាគារនៅទីក្រុងកូឡាឡាំពួរ IDC ឆ្នាំ ២០១២	វេទិកា	១ ថ្ងៃ
មហាសន្និបាតធនាគាររបស់ប្រទេសម៉ាឡេស៊ីលើកទី ១៦ ស្តីពីការកំណត់ទិសដៅនាពេលអនាគតសម្រាប់វិស័យ ធនាគារ និងហិរញ្ញវត្ថុ នាយុគសម័យថ្មី	វេទិកា	២ ថ្ងៃ
សន្និសីទអាស៊ាន ស៊ីអាយអិមប៊ី ឆ្នាំ ២០១២	វេទិកា	១ ថ្ងៃ
សន្និសីទធនាគារអាស៊ាន លើកទី១៩ ឆ្នាំ២០១២	វេទិកា	១ ថ្ងៃ
កិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិ លើកទី ១៤	វេទិកា	១ ថ្ងៃ
កិច្ចពិភាក្សាអំពីការវាស់វែងនៃការកែតម្រូវហានិភ័យ	វេទិកា	១ ថ្ងៃ
សន្និសីទស្តីពីកម្មសិទ្ធិអ្នស្ត្រាលី Baker Tilly	វេទិកា	១ ថ្ងៃ
កម្មវិធីជ្រើសរើស FIDE: កម្មវិធី ICAAP	វេទិកា	៤ ថ្ងៃ

ក្នុងអំឡុងឆ្នាំដែលស្ថិតក្រោមការត្រួតពិនិត្យ ការធ្វើបច្ចុប្បន្នភាពជាទៀងទាត់លើការវិវឌ្ឍ ផ្នែកច្បាប់ ការផ្សព្វផ្សាយ ព័ត៌មាន និងបទដ្ឋានគណនេយ្យ អភិបាលកិច្ចក្រុមហ៊ុន និងការ អនុវត្តល្អបំផុត ក៏ត្រូវបានផ្តល់ជូនសម្រាប់អភិបាលផងដែរ។

លេខាធិការក្រុមហ៊ុន

លេខាធិការក្រុមហ៊ុន ត្រូវបង្ហាញពីការគាំទ្រជាបន្តបន្ទាប់ក្នុងការផ្តល់យោបល់ និងជួយ ក្រុមប្រឹក្សាភិបាល លើបញ្ហាដែលទាក់ទងនឹងកិច្ចការរបស់ធនាគារ រាប់បញ្ចូលទាំងបញ្ហាដែល ទាក់ទងនឹងការអនុវត្តស្របតាមបទប្បញ្ញត្តិរបស់ក្រុមហ៊ុន អភិបាលកិច្ច ក្រុមហ៊ុន និងការអនុវត្ត ល្អបំផុត ប្រសិទ្ធភាពនៃសាលប្រជុំ និងកាតព្វកិច្ច និងការទទួលខុសត្រូវរបស់អភិបាល។ ក្នុងអំឡុងឆ្នាំ ដែលស្ថិតក្រោមការត្រួតពិនិត្យ ដំណើរការផ្សេងៗរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានពិនិត្យផ្ទៀងផ្ទាត់ ឡើងវិញជាមួយនឹងទស្សនៈលើកកម្ពស់ដំណើរការនៃការធ្វើសេចក្តីសម្រេច និងប្រសិទ្ធភាពនៃ មុខងារក្រុមប្រឹក្សាភិបាល។

លេខាធិការក្រុមហ៊ុនត្រូវធានាថា កិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងភាគទុនិក ត្រូវបានរៀបចំឡើងស្របតាមវិធានច្បាប់ និងការអនុវត្តល្អបំផុតរបស់ធនាគារ ហើយត្រូវធានាថា ការកត់ត្រាដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងភាគទុនិក ត្រូវបាន កត់ត្រាទុកទាំងស្រុងសម្រាប់ធ្វើជាកំណត់ហេតុ និងរក្សាទុកបានយ៉ាងល្អ។

លេខាធិការក្រុមហ៊ុន ក៏ត្រូវសម្របសម្រួលការទំនាក់ទំនង និងផ្សព្វផ្សាយសេចក្តីសម្រេច សំខាន់ៗ និងគោលការណ៍នានា រវាងក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងថ្នាក់គ្រប់គ្រង ប្រតិបត្តិជាន់ខ្ពស់ផងដែរ។ ក្រៅពីនេះ លេខាធិការក្រុមហ៊ុន ក៏ចូលរួមជួយការងារប្រធាន ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបៀបវារៈ និងរៀបចំដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងភាគទុនិក។

អភិបាលទាំងអស់ មានលទ្ធភាពពេញលេញក្នុងការស្នើយោបល់ពីលេខាធិការក្រុមហ៊ុន និង អាចស្វែងរកការពិគ្រោះយោបល់បែបវិជ្ជាជីវៈដោយឯករាជ្យពីប្រភពខាងក្រៅ ក្រោមបន្ទុកចំណាយ របស់ធនាគារ ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ នីតិវិធីមួយត្រូវបានអនុម័តឡើង ដើម្បីជួយសម្រួល អភិបាលក្នុងការស្វែងរកការពិគ្រោះយោបល់បែបវិជ្ជាជីវៈដោយឯករាជ្យនោះ។

គណៈកម្មាធិការនានា

ក្រុមប្រឹក្សាភិបាល ផ្ទេរការទទួលខុសត្រូវជាក់លាក់ដល់គណៈកម្មាធិការនានា ដែលរួមមាន គណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការហានិភ័យ។ គណៈកម្មាធិការទាំងនេះ ធ្វើប្រតិបត្តិការ តាមតួនាទី និងកាតព្វកិច្ច ដែលបានកំណត់យ៉ាងច្បាស់លាស់ ដូចមានចែងនៅក្នុងតួនាទី និង ភារកិច្ចរបស់គណៈកម្មាធិការនីមួយៗដែលបានអនុម័តយ៉ាងត្រឹមត្រូវ។

គណៈកម្មាធិការត្រូវ រាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីកិច្ចពិភាក្សា សេចក្តីសម្រេច និង អនុសាសន៍របស់ខ្លួន។ ប្រធានគណៈកម្មាធិការសវនកម្ម និងប្រធានគណៈកម្មាធិការហានិភ័យ ត្រូវវាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីបញ្ហាដែលបានលើកយកមកពិភាក្សា និងដោះស្រាយ នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការរបស់ខ្លួន។ ក្រុមប្រឹក្សាភិបាលបានទទួលស្គាល់ថា ខណៈដែល គណៈកម្មាធិការទាំងនេះមានសិទ្ធិអំណាចធ្វើការពិភាក្សាលើបញ្ហានានា ដែលបានប្រគល់ជូន រាល់សេចក្តីសម្រេច និង/ឬ អនុសាសន៍របស់គណៈកម្មាធិការទាំងនេះ ត្រូវបញ្ជូនទៅក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យ ដោយសារក្រុមប្រឹក្សាភិបាល គឺជាអ្នកទទួលខុសត្រូវរួមទៅលើភាពជោគជ័យ ធុរកិច្ច យុទ្ធសាស្ត្រ ការគ្រប់គ្រងហានិភ័យ សកម្មភាពប្រតិបត្តិការអាជីវកម្ម និងប្រតិបត្តិការហិរញ្ញវត្ថុ របស់ធនាគារ។ ព័ត៌មានលម្អិតអំពីគណៈកម្មាធិការនានា មានបង្ហាញនៅក្នុងផ្នែកខាងក្រោមជា បន្តបន្ទាប់។

គណៈកម្មាធិការសវនកម្ម

សមាជិកគណៈកម្មាធិការសវនកម្ម សុទ្ធតែជាអភិបាលឯករាជ្យមិនប្រតិបត្តិ ដែលប្រកបដោយចំណេះដឹង និងបទពិសោធន៍ ផ្នែកហិរញ្ញវត្ថុ។

ការទទួលខុសត្រូវចម្បងរបស់គណៈកម្មាធិការសវនកម្ម គឺធានាឱ្យមានការអនុវត្តអភិបាលកិច្ចរបស់ធនាគារបានល្អប្រសើរ ស្របពេលដែលធ្វើការពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ការផ្សព្វផ្សាយព័ត៌មាន ការគោរពបទប្បញ្ញត្តិច្បាប់ ការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងដំណើរការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។ គណៈកម្មាធិការសវនកម្ម ជួបប្រជុំជាប្រចាំ ដើម្បីពិនិត្យលើលទ្ធផលការងារប្រចាំត្រីមាស របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របាយការណ៍សវនកម្ម ដែលរាប់បញ្ចូល ទាំងការអនុវត្ត ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ក៏ដូចជាប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិ។ គណៈកម្មាធិការសវនកម្មបានជួបប្រជុំចំនួន ០៤ដង ក្នុងឆ្នាំ២០១២ ដែលមានវត្តមានសមាជិកចូលរួមដូចខាងក្រោម៖

ចំនួនកិច្ចប្រជុំដែលបានប្រារព្ធធ្វើឡើង

សមាជិក	**បានចូលរួម**	**ចំនួនកិច្ចប្រជុំ**
Goh Nan Kioh*		
ប្រធានគណៈកម្មាធិការសវនកម្ម/អភិបាលឯករាជ្យមិនប្រតិបត្តិ	២	២
បណ្ឌិត ម៉ី កល្យាណ**		
ប្រធានគណៈកម្មាធិការសវនកម្ម/អភិបាលឯករាជ្យមិនប្រតិបត្តិ	២	២
Dato' Shaarani Ibrahim		
អភិបាលឯករាជ្យមិនប្រតិបត្តិ	៤	៤
Dato' Wira Zainal Abidin Mahamad Zain		
អភិបាលឯករាជ្យមិនប្រតិបត្តិ	៤	៤

* *លាលែងតំណែងនៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២*

** *តែងតាំងនៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២*

លក្ខខណ្ឌយោងរបស់គណៈកម្មាធិការសវនកម្មមានដូចខាងក្រោម៖

ចំណុចគន្លឹះ	**ការទទួលខុសត្រូវ**
ការត្រួតពិនិត្យផ្ទៃក្នុង / ការគ្រប់គ្រងហានិភ័យ / អភិបាលកិច្ច	ពិនិត្យមើលឡើងវិញ លើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដំណើរការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ច ក្នុងសម្ព័ន្ធធនាគារ ស្របតាមលក្ខខណ្ឌតម្រូវនៅក្នុងប្រកាសស្តីពីអភិបាលកិច្ចនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។
សវនកម្មផ្ទៃក្នុង	ក. ធានាថាមុខងារសវនកម្មផ្ទៃក្នុង បានរៀបចំល្អប្រសើរ ដើម្បីធ្វើការត្រួតពិនិត្យ ឬអង្កេតក្នុងនាមគណៈកម្មាធិការសវនកម្ម ហើយមុខងារនេះត្រូវស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងផ្ទាល់ពីគណៈកម្មាធិការសវនកម្ម។ ខ. ពិនិត្យមើលឡើងវិញ លើភាពគ្រប់គ្រាន់នៃវិសាលភាពសវនកម្មផ្ទៃក្នុង មុខងារ សមត្ថភាព និងធនធាននៃ មុខងារសវនកម្មផ្ទៃក្នុង ហើយពិនិត្យមើលថាតើមុខងារនេះ បានទទួលសិទ្ធិសំខាន់ៗ ដើម្បីបំពេញការងារនេះ។ របាយការណ៍របស់សវនករផ្ទៃក្នុង និងគណៈកម្មាធិការសវនកម្ម មិនទាមទារឱ្យមានការពិនិត្យ និងកែសម្រួលពីអគ្គនាយកឡើយ។ គ. ពិនិត្យមើលឡើងវិញ លើលទ្ធផលនៃដំណើរការសវនកម្មផ្ទៃក្នុង ហើយប្រសិនបើចាំបាច់ត្រូវធានាចាត់វិធានការសមស្របចំពោះអនុសាសន៍របស់សវនករផ្ទៃក្នុង។ ឃ. គ្រប់គ្រងមុខងាររបស់សវនកម្មផ្ទៃក្នុង និងធានាការគោរពច្បាប់ និងបទប្បញ្ញត្តិដែលអនុវត្តចំពោះគ្រឹះស្ថាន ធនាគារ និងហិរញ្ញវត្ថុ។ ង. វាយតម្លៃសមិទ្ធកម្មការងារ និងធ្វើសេចក្តីសម្រេចចិត្ត អំពីកញ្ចប់ថវិកាសម្រាប់ប្រាក់បៀវត្ស របស់នាយកសវនកម្មផ្ទៃក្នុង។ ច. អនុម័តលើការតែងតាំង ការផ្ទេរ និងបណ្តេញចេញ ប្រធានសវនកម្មផ្ទៃក្នុង ឬ សមាជិកបុគ្គលិកជាន់ខ្ពស់ ដែលបំពេញមុខងារជាសវនករផ្ទៃក្នុង និងត្រូវទទួលការជូនដំណឹងអំពីការលាឈប់របស់បុគ្គលិកជាន់ខ្ពស់ ជាសវនករផ្ទៃក្នុង ហើយត្រូវផ្តល់ឱកាសឱ្យសមាជិក ដែលបានដាក់ពាក្យលាឈប់នោះ បញ្ជាក់ប្រាប់អំពីមូលហេតុនៃការលាឈប់នេះ។
សវនកម្មខាងក្រៅ	ក. ពិចារណាលើការតែងតាំងសវនករខាងក្រៅ ចំណាយសម្រាប់ការធ្វើសវនកម្ម និងបញ្ហាទាំងឡាយទាក់ទងនឹងមូលហេតុនៃការលាលែងតំណែង និងការបណ្តេញចេញ។ ខ. ពិភាក្សាជាមួយសវនករខាងក្រៅ មុននឹងចាប់ផ្តើមធ្វើសវនកម្មអំពីលក្ខណៈ និងវិសាលភាពការងារ សវនកម្ម ហើយធានាលើការសម្របសម្រួល ក្នុងករណីមានក្រុមហ៊ុនសវនកម្មច្រើនចូលរួម។ គ. វាយតម្លៃអំពីគោលដៅ ការបំពេញការងារ និងឯករាជ្យភាពរបស់សវនករខាងក្រៅ។ ឃ. អនុម័តលើការផ្តល់សេវា ដែលមិនទាក់ទងនឹងការងារសវនកម្មដោយសវនករខាងក្រៅ។ ង. ធានាថាមានការពិនិត្យច្បាស់លាស់លើលក្ខខណ្ឌ នៃការផ្តល់សេវាដែលមិនទាក់ទងនឹងការងារសវនកម្ម ដើម្បីជៀសវាងការប៉ះពាល់ដល់ការវិនិច្ឆ័យ ប្រកបដោយឯករាជ្យភាពរបស់សវនករខាងក្រៅ។ ច. ធានាថាគណនីធនាគារត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា ដោយមានការត្រួតពិនិត្យឡើងវិញ ជាប្រចាំលើភាពគ្រប់គ្រាន់នៃការធ្វើសំវិធានធន ដែលចាំបាច់ ព្រមទាំងចំពោះបំណុលអាក្រក់ និងសង្ស័យ។ ឆ. ពិភាក្សាលើបញ្ហា និងលក្ខខណ្ឌបម្រុងនានាដែលកើតចេញពីសវនកម្មអន្តរកាល និងចុងក្រោយ ព្រមទាំងបញ្ហាមួយចំនួនទៀតដែលសវនករចង់ធ្វើការពិភាក្សា (ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ប្រសិនបើចាំបាច់)

	ជ. ពិនិត្យមើលឡើងវិញ លើលិខិតគ្រប់គ្រងរបស់សវនករខាងក្រៅ និងការឆ្លើយតបរបស់គណៈគ្រប់គ្រង។ ឈ. ជួបប្រជុំជាមួយសវនករខាងក្រៅ យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ដើម្បីពិភាក្សាលើបញ្ហាគន្លឹះ និងស្នើសុំយោបល់ពីសវនករខាងក្រៅវិញ។
លទ្ធផលសវនកម្ម ការត្រួតពិនិត្យផ្ទៃក្នុង និងបញ្ហា នៃការគោរពច្បាប់ និងបទប្បញ្ញត្តិនានា	ពិនិត្យមើលឡើងវិញលើលទ្ធផល និងបញ្ហាទាក់ទងនឹងការគោរពច្បាប់ និងបទប្បញ្ញត្តិ ដែលចេញដោយអ្នកបញ្ញត្តិច្បាប់ និងធានាថា ថ្នាក់គ្រប់គ្រងបានចាត់វិធានការកែតម្រូវសមស្រប និងជាបន្ទាន់។
ផ្សេងៗ	ក. ពិនិត្យមើលឡើងវិញ លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងជំណាច់ឆ្នាំសម្រាប់ដាក់បញ្ជូនទៅក្រុម-ប្រឹក្សាភិបាល។ ខ. ពិនិត្យមើលឡើងវិញ លើរាល់ប្រតិបត្តិការពាក់ព័ន្ធនានាដែលអាចកើតមានឡើងនៅក្នុងសម្ព័ន្ធធនាគារ ដែលបានដាក់ជូនដោយគណៈគ្រប់គ្រង និងត្រូវជូនដំណឹងដល់ក្រុមប្រឹក្សាភិបាលអំពីប្រតិបត្តិការទាំងនេះ។

គណៈកម្មាធិការហានិភ័យ

ការទទួលខុសត្រូវចម្បងរបស់គណៈកម្មាធិការហានិភ័យ គឺត្រូវធានាថាមុខងារគ្រប់គ្រងហានិភ័យដែលត្រូវបានដាក់បញ្ចូលនៅក្នុងធនាគារ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ គណៈកម្មាធិការហានិភ័យ ត្រូវរាយការណ៍ទៅក្រុមប្រឹក្សាភិបាល នូវរាល់បញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យនៅក្នុងធនាគារ។

គណៈកម្មាធិការហានិភ័យបានជួបប្រជុំចំនួន ១២ដង ក្នុងឆ្នាំ២០១២ ដែលមានវត្តមានសមាជិកចូលរួមដូចខាងក្រោម៖

ចំនួនកិច្ចប្រជុំដែលបានប្រារព្ធធ្វើឡើង

សមាជិក	**បានចូលរួម**	**ចំនួនកិច្ចប្រជុំ**
Dato' Shaarani Ibrahim *ប្រធានគណៈកម្មាធិការ/អភិបាលឯករាជ្យមិនប្រតិបត្តិ*	១២	១២
Goh Nan Kioh*[1] *អភិបាលឯករាជ្យមិនប្រតិបត្តិ*	១	៨
Yew Wan Kup *អភិបាលមិនឯករាជ្យប្រតិបត្តិ/អគ្គនាយក*	១២	១២
ប៊ុន យីន *អគ្គនាយករង និងជានាយក សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម*	៦	១២
Khoo Lian Kim*[2] *តំណាងនាយកគ្រប់គ្រងហានិភ័យ*	៨	៨
Sasi Komanthakkal*[3] *តំណាងនាយកគ្រប់គ្រងហានិភ័យ*	៥	៥
ហេង ធីតា *នាយក សេវាកម្មហិរញ្ញវត្ថុបុគ្គល*	៧	១២
ហុង ស្រីនួន *នាយក រតនាគារ*	៩	១២
ដែន ជាវុទ្ធ *នាយក ព័ត៌មានវិទ្យា*	១២	១២
ហេង រ៉ូទ្វី *នាយក ហិរញ្ញវត្ថុ*	១១	១២
ហេង ឆូរ៉ង់ *ប្រធាន គ្រប់គ្រងហានិភ័យ*	១២	១២
លី សោភា *នាយក នីតិកម្ម និងលេខាធិការក្រុមហ៊ុន*	១០	១២

**[1] លាលែងតំណែងនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២*

***[2] លាលែងតំណែងនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២*

***[3] តែងតាំងនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២*

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការហានិភ័យមានដូចខាងក្រោម:

- *បែងចែកដើមទុនដែលមានហានិភ័យ (Capital-at-Risk) ទៅតាមប្រភេទជំនួញ និងហានិភ័យផ្សេងៗពីគ្នា ដើម្បីធានាថា ការបែងចែកហានិភ័យបានធ្វើគ្រប់គ្រាន់ អនុលោមតាមលក្ខខណ្ឌកំណត់ដោយបទប្បញ្ញត្តិច្បាប់ និងធានាថា ធនាគារមានដើមទុនបម្រុងគ្រប់គ្រាន់ ដើម្បីប្រឈមមុខនឹងស្ថានភាពវិបត្តិផ្សេងៗ។*
- *បង្កើនតម្លៃភាគទុនិកតាមរយៈការវាយតម្លៃលើប្រាក់ចំណេញ និងហានិភ័យពីដំណើរការប្រតិបត្តិការ ហើយធានាថា កម្រិតហានិភ័យដែលទទួលយកស្ថិតនៅក្នុងដែនកម្រិតដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារ។*
- *ពិនិត្យ និងជូនយោបល់ដល់ក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការអនុម័តលើគោលការណ៍ និងកម្រិតហានិភ័យដែលសមស្រប ដើម្បីរក្សាក្របខណ្ឌនៃការគ្រប់គ្រងហានិភ័យ ឱ្យស្របតាមផែនការអាជីវកម្មរបស់ធនាគារ ក្របខណ្ឌនៃ EWRM របស់ក្រុមហ៊ុនមេ និងស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលបានកំណត់។*
- *វាយតម្លៃ និងពិនិត្យលើសំណើសុំអនុម័តសម្រាប់ផលិតផលថ្មី ការវិនិយោគ អាជីវកម្ម យុទ្ធសាស្ត្រ និងផលិតផលដែល ត្រូវបានកែច្នៃ ដែលត្រូវអនុម័តជាគោលការណ៍ ឬ ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលដើម្បីធ្វើការអនុម័ត។*
- *ពិនិត្យ និងអនុម័តលើសំណើកែប្រែនីតិវិធី និងដំណើរការប្រតិបត្តិការ។*
- *ជំរុញលើការគោរពតាមគោលការណ៍ និងកម្រិតហានិភ័យ។*
- *ដាក់ឱ្យប្រើប្រាស់នូវវិធីសាស្ត្រដ៏សមស្របដើម្បីកំណត់និងវាស់វែងហានិភ័យគ្រប់ស្ថានភាព។*
- *បង្កើតយុទ្ធសាស្ត្រសម្រាប់វាយតម្លៃ ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យឱ្យស្ថិតក្នុងកម្រិតមួយដ៏សមស្រប។*
- *ពិភាក្សាសម្រេចលើវិធីសាស្ត្រ និងឧបករណ៍សម្រាប់ធ្វើការវាស់វែងទៅលើបរិមាណហានិភ័យផ្សេងៗ ដើម្បីសុំការអនុម័តពីក្រុមប្រឹក្សាភិបាល។*
- *ត្រួតពិនិត្យសមាសធាតុតារាងតុល្យការរបស់ធនាគាររួមមានឥណទាន និងប្រាក់បញ្ញើ។*
- *ធានានូវការប្រកាន់ខ្ជាប់នូវទ្រឹស្តីសន្ធនិយម (holistic approach) ក្នុងការគ្រប់គ្រងតារាងតុល្យការរបស់ធនាគារ តាមរយៈការគ្រប់គ្រងហានិភ័យអត្រាការប្រាក់ប្រកបដោយប្រសិទ្ធភាព ការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល ការគ្រប់គ្រងគម្លាតកម្រិតការប្រាក់ និងមូលធន។*
- *ធានាថាធនាគាររក្សាបាននូវគុណភាពទ្រព្យសកម្ម តាមរយៈការពិនិត្យតាមដានយ៉ាងហ្មត់ចត់លើដំណើរការ និងការអនុម័តលើឥណទានថ្មីៗ ព្រមទាំងការប្រមូលឥណទានដែលមិនដំណើរការ។*
- *ពិនិត្យឡើងវិញនូវផែនការបង្ការ និងការគ្រប់គ្រងនិរន្តរភាពនៃអាជីវកម្មសម្រាប់អនុវត្តនៅពេលចាំបាច់ និងស្នើសុំការអនុម័តពីក្រុមប្រឹក្សាភិបាល។*
- *ពិនិត្យឡើងវិញ និងអនុម័តលើលក្ខន្តិកៈ និងសមាសភាពនៃគណៈកម្មាធិការដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការហានិភ័យ រួមបញ្ចូលទាំងការតែងតាំង និងការដកចេញនូវសមាជិក និងអ្នកចូលរួមក្នុងគណៈកម្មាធិការទាំងនេះ។*

គណៈកម្មាធិការគ្រប់គ្រងនានា

គណៈកម្មាធិការគ្រប់គ្រងដូចមានរៀបរាប់ខាងក្រោម ត្រូវបានបង្កើតឡើងដើម្បីជួយការងាររបស់អភិបាលប្រតិបត្តិ/អគ្គនាយក និងគណៈគ្រប់គ្រង លើប្រតិបត្តិការអាជីវកម្មផ្សេងៗ និងជួយគាំទ្រដល់សកម្មភាពនានារបស់ធនាគារ៖

- គណៈកម្មាធិការគ្រប់គ្រង
- គណៈកម្មាធិការឥណទានកម្ពុជា
- គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម

គណៈកម្មាធិការគ្រប់គ្រង

គណៈកម្មាធិការគ្រប់គ្រង រាយការណ៍ជូនក្រុមប្រឹក្សាភិបាលនូវបញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ធនាគារ។

Yew Wan Kup *អគ្គនាយក*	ប្រធាន
ប៊ុន យីន *អគ្គនាយករង និងជានាយក សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម*	សមាជិក
ហេង ធីតា *នាយក សេវាកម្មហិរញ្ញវត្ថុបុគ្គល*	សមាជិក
ហុង ស្រីនួន *នាយក រតនាគារ*	សមាជិក
ហេង រុទ្ធី *នាយក ហិរញ្ញវត្ថុ*	សមាជិក
អ៊ុំ ចិន្តាភក្តី *នាយក ធនធានមនុស្ស*	សមាជិក
ដែន ដារ៉ុទ្ធ *នាយក ព័ត៌មានវិទ្យា*	សមាជិក
ហេង តូរ៉ង់ *ប្រធាន គ្រប់គ្រងហានិភ័យ*	សមាជិក
ប៉ុក នីវ៉ីល័យ *ប្រធាន ទីផ្សារ និងទំនាក់ទំនង*	សមាជិក
លី សោភា *នាយក នីតិកម្ម និងលេខាធិការក្រុមហ៊ុន*	សមាជិក

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងមានដូចខាងក្រោម៖

- ផ្តល់ប្រឹក្សាជូនអគ្គនាយក
- ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពប្រតិបត្តិការរបស់ផ្នែកអាជីវកម្មនីមួយៗ។
- ពិនិត្យរបាយការណ៍គ្រប់គ្រងហិរញ្ញវត្ថុ និងរបាយការណ៍គ្រប់គ្រងផ្សេងៗទៀតរបស់ធនាគារ។
- បង្កើតយុទ្ធសាស្ត្រ ផែនការអាជីវកម្ម និងផែនការថវិកាសម្រាប់ធនាគារ (រាប់បញ្ចូលទាំងចំណុចដែលទាក់ទងនឹង បច្ចេកវិទ្យាព័ត៌មាន)
- កំណត់ការងារដែលទាមទារឱ្យមានការសហការពីនាយកដ្ឋានច្រើន។
- ពិភាក្សាលីឡាប់ និងបទប្បញ្ញត្តិសំខាន់ៗ។
- ការងារផ្សេងៗទៀតតាមការណែនាំរបស់អគ្គនាយក។
- ការងារផ្សេងៗទៀតតាមការណែនាំរបស់ក្រុមប្រឹក្សាភិបាល/ប្រធាននាយកប្រតិបត្តិ របស់ក្រុមហ៊ុនមេ។

គណៈកម្មាធិការឥណទានកម្ពុជា

គណៈកម្មាធិការឥណទានកម្ពុជា ធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាភិបាលនូវរាល់បញ្ហាទាក់ទងនឹងការងារឥណទានរបស់ធនាគារ។

Yew Wan Kup *អគ្គនាយក*	ប្រធាន
ប៊ុន យីន *អគ្គនាយករង និងជានាយក សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម*	សមាជិក
ហេង ធីតា *នាយក សេវាកម្មហិរញ្ញវត្ថុបុគ្គល*	សមាជិក
គៀន វឌ្ឍនា ប្រធាន គ្រប់គ្រងឥណទាន	សមាជិក
John Chuah Keat Koong ទីប្រឹក្សាឥណទាន សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម	សមាជិក
Sue Kok Tseuy Shan ទីប្រឹក្សាឥណទាន សេវាកម្មហិរញ្ញវត្ថុបុគ្គល	សមាជិក
លី សោភា * នាយក នីតិកម្ម និងលេខាធិការក្រុមហ៊ុន	សមាជិក
ហេង រុទ្ធី * នាយក ហិរញ្ញវត្ថុ	សមាជិក

* *តែងតាំងនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២*

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការឥណទានកម្ពុជាមានដូចខាងក្រោម៖

- ត្រួតពិនិត្យឡើងវិញ និងអនុម័តលើឥណទាន និងបុរេប្រទានរបស់ធនាគារ ក្នុងកម្រិតកំណត់ឥណទានដែលក្រុមប្រឹក្សាភិបាលផ្តល់សិទ្ធិឱ្យ។
- ផ្តល់អនុសាសន៍សម្រាប់ការព្រមព្រៀង/ការយល់ព្រមពីគណៈកម្មាធិការឥណទានតំបន់ និងការសម្រេចរបស់ក្រុមប្រឹក្សាភិបាល លើរាល់សំណើឥណទានដែលហួសពីសិទ្ធិអំណាចសម្រេចរបស់គណៈកម្មាធិការឥណទានកម្ពុជា។
- អនុម័តលើប្រតិបត្តិការដែលគ្មានកម្រិតកំណត់ឥណទានដែលបានអនុម័តជាមុន ឬ ហួសពីកម្រិតកំណត់ឥណទានដែលបានអនុម័តជាមុនទៅតាមករណីនីមួយៗ។
- ធានាថាសមតុល្យឥណទានទាំងមូលរបស់ធនាគារ ស្របតាមគោលការណ៍ណែនាំរបស់អាជ្ញាធរ បញ្ញត្តិច្បាប់ និងស្របតាមគោលការណ៍ និងនីតិវិធីឥណទានដែលបានអនុម័ត។
- ត្រួតពិនិត្យឡើងវិញ និងអនុម័តលើវិធានការទារសំណងដែលនឹងត្រូវអនុវត្ត ស្របតាមលក្ខខណ្ឌពិន័យ និងការធ្វើសំវិធានធនចំពោះគណនីសង្ស័យ និងគណនីអាក្រក់ និងឥណទានដែលត្រូវលុបចេញពីបញ្ជី។
- វាយតម្លៃសមតុល្យហានិភ័យនៅពេលអនុម័តឥណទាន និងបុរេប្រទាន ដើម្បីធានាថាឥណទានដែលបានផ្តល់ គឺស្ថិតនៅក្នុងកម្រិតហានិភ័យរបស់ក្រុមហ៊ុនមេ។
- ត្រួតពិនិត្យឡើងវិញ និងវាយតម្លៃផលិតផលឥណទានផ្សេងៗរបស់ធនាគារ ដើម្បីធានាថាផលិតផលទាំងនោះត្រូវបាន អនុវត្តតាមបទដ្ឋាន និងគោលការណ៍ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល។
- ត្រួតពិនិត្យឡើងវិញ និងអនុម័តចំណាត់ថ្នាក់ឥណទានផ្ទៃក្នុងរបស់អ្នកខ្ចីម្នាក់ៗ តាមដែលអាចអនុវត្តបាន។
- ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍អំពីការកែប្រែ ឬ វិសោធនកម្មក្នុងគោលការណ៍ឥណទាន និងគោលការណ៍ណែនាំ សម្រាប់ការអនុម័តរបស់គណៈកម្មាធិការឥណទានតំបន់/គណៈកម្មាធិការហានិភ័យ និងក្រុមប្រឹក្សាភិបាល។
- បំពេញមុខងារដទៃទៀតតាមការណែនាំរបស់គណៈកម្មាធិការហានិភ័យ។

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម រាយការណ៍ទៅគណៈកម្មាធិការហានិភ័យ អំពីហានិភ័យសាច់ប្រាក់ងាយស្រួល និងបញ្ហានានាដែលទាក់ទងនឹងទ្រព្យសកម្ម និងទ្រព្យអកម្ម របស់ធនាគារ។

Yew Wan Kup *អគ្គនាយក*	ប្រធាន
Sasi Komanthakkal *តំណាងនាយកគ្រប់គ្រងហានិភ័យ*	សមាជិក
ប៊ុន យីន *អគ្គនាយករង និងជានាយក សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម*	សមាជិក
ហេង ធីតា *នាយក សេវាកម្មហិរញ្ញវត្ថុបុគ្គល*	សមាជិក
គឿន រ៉ូឌ្ឍនា *ប្រធាន គ្រប់គ្រងឥណទាន*	សមាជិក
ហេង រ៉ុទ្ធី *នាយក ហិរញ្ញវត្ថុ*	សមាជិក
ហេង ឆ្ងរ៉ង់ *ប្រធាន គ្រប់គ្រងហានិភ័យ*	សមាជិក
ហុង ស្រីនួន *នាយក រតនាគារ*	សមាជិក

តួនាទី និងការកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្មមានដូចខាងក្រោម៖

- គ្រប់គ្រង និងត្រួតពិនិត្យជារួមលើហានិភ័យសាច់ប្រាក់ងាយស្រួល និងហានិភ័យអត្រាការប្រាក់ របស់ធនាគារនៅក្នុងបញ្ជីធនាគារ (Banking Book) ដើម្បីធានាថាធនាគារអាចបំពេញ កាតព្វកិច្ចលំហូរសាច់ប្រាក់របស់ខ្លួនបានទាន់ពេលវេលា។
- ការបែងចែកប្រភពហិរញ្ញប្បទានឱ្យមានកាន់តែច្រើន ដើម្បីជៀសវាងការពឹងផ្អែកលើប្រភពហិរញ្ញប្បទានមិនបិតថេរ។
- ត្រួតពិនិត្យឡើងវិញ/ផ្តល់អនុសាសន៍អំពីហានិភ័យសាច់ប្រាក់ងាយស្រួល និងគោលការណ៍គ្រប់គ្រងលើហានិភ័យអត្រាការប្រាក់នៅក្នុងបញ្ជីធនាគារ (IRRBB) និងគោលការណ៍ជាក់លាក់ផ្សេងទៀតទាក់ទងនឹងហានិភ័យសាច់ប្រាក់ងាយស្រួល / គោលការណ៍គ្រប់គ្រងលើហានិភ័យអត្រាការប្រាក់នៅក្នុងបញ្ជីធនាគារ (IRRBB) មុននឹងស្នើសុំការអនុម័តយល់ព្រមពីគណៈកម្មាធិការហានិភ័យរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី ដោយមានការទទួលស្គាល់ពីគណៈកម្មាធិការគ្រប់គ្រង ហានិភ័យសាច់ប្រាក់ងាយស្រួលប្រចាំតំបន់ (RLRC) និងការអនុម័តយល់ព្រមពីក្រុមប្រឹក្សាភិបាលរបស់ ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី។
- ត្រួតពិនិត្យឡើងវិញលើហានិភ័យសាច់ប្រាក់ងាយស្រួល និងការអនុគ្រោះលើហានិភ័យអត្រាការប្រាក់នៅក្នុងបញ្ជីធនាគារ (IRRBB) និងធានាការប្រតិបត្តិតាមគោលការណ៍ផ្ទៃក្នុង ដូចជាការពិនិត្យតាមដានលើកម្រិតហានិភ័យ (Alert/MAT) ដែលបានអនុម័តរួច ឬ កម្រិតណាមួយដែលត្រូវបានកំណត់ទាក់ទងនឹងការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល និងផ្តល់អនុសាសន៍ទៅគណៈកម្មាធិការហានិភ័យដើម្បីធ្វើការអនុម័ត និងជូនដំណឹងទៅគណៈកម្មាធិការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួលប្រចាំតំបន់ ដើម្បីទទួលជ្រាបជាព័ត៌មាន។
- ត្រួតពិនិត្យឡើងវិញលើនីតិវិធីធ្វើប្រតិបត្តិការ វិធីសាស្ត្រ ឬ សេចក្តីសន្និដ្ឋាន ដែលប្រើប្រាស់សម្រាប់ការគ្រប់គ្រងហានិភ័យ សាច់ប្រាក់ងាយស្រួល និងការគ្រប់គ្រងលើហានិភ័យអត្រាការប្រាក់នៅក្នុងបញ្ជីធនាគារ (IRRBB) ដោយធ្វើការប្រឹក្សាជាមួយក្រុមការងារគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្មរបស់ក្រុមហ៊ុនមេ ដូចជាលើការសន្និដ្ឋានធ្វើឡើងនៅក្នុងរបាយការណ៍សាច់ប្រាក់ងាយស្រួល និងគម្លាតនៃការកំណត់តម្លៃឡើងវិញ/ហានិភ័យអត្រាការប្រាក់នៅក្នុងបញ្ជីធនាគារ។
- ធានាការប្រតិបត្តិតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក និងជូនដំណឹងទៅក្រុមការងារគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម របស់ក្រុមហ៊ុនមេ អំពីបញ្ហានានាដែលទាក់ទងនឹងហានិភ័យសាច់ប្រាក់ងាយស្រួល/ហានិភ័យអត្រាការប្រាក់ ដែលអាចកើត មានឡើង។
- ត្រួតពិនិត្យឡើងវិញនូវសមាសភាពក្នុងតារាងតុល្យការពាក់ព័ន្ធនឹងឥណទាន និងប្រាក់បញ្ញើ របស់ធនាគារ។
- ធានាថាទ្រឹស្តីសន្ធនិយម (holistic approach) ត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងតារាងតុល្យការរបស់ធនាគារ តាមរយៈការគ្រប់គ្រងដោយប្រសិទ្ធភាពលើហានិភ័យអត្រាការប្រាក់ ការគ្រប់គ្រងហានិភ័យប្រភពទុនសាច់ប្រាក់ងាយស្រួល គម្លាតនៃការប្រាក់ និងការគ្រប់គ្រងមូលធន។

គណនេយ្យភាព និងសវនកម្ម

ការធ្វើរបាយការណ៍ហិរញ្ញវត្ថុ

ដោយយោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ឆ្នាំសារពើពន្ធនីមួយៗត្រូវបានរៀបចំឡើងដោយយោងតាមសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យរបស់កម្ពុជា។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយផ្អែកលើទ្រឹស្តី On a going basis និងត្រូវផ្តល់នូវការពិនិត្យដ៏ជាក់លាក់ និងត្រឹមត្រូវលើស្ថានភាពអាជីវកម្មរបស់ធនាគារ ដោយគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២។

គោលការណ៍គណនេយ្យដ៏ត្រឹមត្រូវ ត្រូវបានអនុវត្តដើម្បីឱ្យមានភាពស្របគ្នាក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយមានការគាំទ្រនូវការវិនិច្ឆ័យ និងការប៉ាន់ប្រមាណប្រកបដោយភាពប្រុងប្រយ័ត្ន និងសមហេតុផល។ អភិបាលទាំងអស់ត្រូវទទួលខុសត្រូវទាំងស្រុងនៅក្នុងដំណាក់កាលនេះ ដើម្បីការពារនូវទ្រព្យសកម្មរបស់ធនាគារ និងត្រូវធានាថារបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារបង្ហាញពីសមតុល្យភាព និងការវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងការព្យាករណ៍នាថ្ងៃអនាគតប្រកបដោយភាពត្រឹមត្រូវ និងក្បោះក្បាយ ។

ក្រុមប្រឹក្សាភិបាល មានសេចក្តីពេញចិត្តនឹងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការបង្ហាញនូវសមតុល្យភាព និងការវាយតម្លៃ អំពីស្ថានភាពហិរញ្ញវត្ថុ និងការព្យាករណ៍នាថ្ងៃអនាគត ប្រកបដោយភាពត្រឹមត្រូវ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដូចមានបង្ហាញនៅក្នុងរបាយការណ៍របស់អភិបាលនៅក្នុងទំព័រ ៦០ ដល់ ១០៣ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុនៃរបាយការណ៍ប្រចាំឆ្នាំនេះ។

គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្ម ជួយក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ លទ្ធផលហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆមាសរបស់ធនាគារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវត្រួតពិនិត្យឡើងវិញ ដោយគណៈកម្មាធិការសវនកម្ម និងអនុម័តដោយក្រុមប្រឹក្សាភិបាល មុនពេលផ្តល់ជូនធនាគារជាតិ នៃកម្ពុជា។

ការត្រួតពិនិត្យផ្ទៃក្នុង

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវរួមលើការរក្សានូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យមានភាពល្អប្រសើរ ដែលរួមមានដូចជា ការត្រួតពិនិត្យលើហិរញ្ញវត្ថុ ការធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ការគោរពច្បាប់ និងបទប្បញ្ញត្តិនានា ក៏ដូចជាការគ្រប់គ្រងហានិភ័យ។ ទំហំ និងភាពស្មុគស្មាញនៃអាជីវកម្មរបស់ធនាគារទាមទារឱ្យមានជាចាំបាច់នូវការគ្រប់គ្រង និងការបែងចែកហានិភ័យត្រឹមត្រូវ។ លក្ខណៈនៃហានិភ័យទាំងនេះ មានន័យថាព្រឹត្តិការណ៍ទាំងឡាយអាចនឹងកើតមានឡើង ហើយបណ្តាលឱ្យមានការបាត់បង់ដោយមិនអាចដឹងមុន និងជៀសវាងបាន។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធត្រូវបានរៀបចំឡើង ដើម្បីផ្តល់នូវការធានាដ៏សមហេតុផលមួយ បើទោះបីជាវាមិនអាចធានាទាំងស្រុងចំពោះហានិភ័យដែលកើតចេញពីកំហុសធ្ងន់ធ្ងរ ការបោកបន្ទំ ឬ ការខាតបង់ដែលកើតមាន។

ក្រុមប្រឹក្សាភិបាលបានចាត់ទុកថាក្របខណ្ឌ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធី ត្រូវបានអនុវត្តដោយគណៈគ្រប់គ្រង របស់ធនាគារក្នុងឆ្នាំសារពើពន្ធរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ និងមានគ្រប់គ្រាន់ ស្របតាមតម្រូវការរបស់ធនាគារក្នុងបរិយាកាសអាជីវកម្មនាពេលបច្ចុប្បន្ន។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានរៀបចំឡើងសម្រាប់ផ្តល់នូវការការធានាដ៏សមស្របមួយ បើទោះបីជាវាមិនអាចធានាទាំងស្រុង ដើម្បីបង្កើតឱ្យបាននូវបទដ្ឋានជាក់លាក់មួយសម្រាប់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងជួយធនាគារក្នុងការគ្រប់គ្រងហានិភ័យលើបរាជ័យក្នុងការសម្រេចគោលដៅអាជីវកម្ម ប៉ុន្តែវាប្រសើរជាងការលុបចោលនូវប្រព័ន្ធ ត្រួតពិនិត្យនេះ។

សេចក្តីថ្លែងការណ៍អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលបង្ហាញពីស្ថានភាពត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារមានបង្ហាញនៅក្នុង ទំព័រទី ៣៩ ដល់ ៤២ នៃរបាយការណ៍ប្រចាំឆ្នាំនេះ។

នាយកដ្ឋានប្រតិបត្តិ សវនកម្ម និងគ្រប់គ្រងហានិភ័យ

របាយការណ៍របស់

គណៈកម្មាធិការសវនកម្ម

សេចក្តីសង្ខេប

គណៈកម្មាធិការសវនកម្មនៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ប្តេជ្ញាបំពេញតួនាទីរបស់ខ្លួនក្នុងការធានានូវការអនុវត្ត អភិបាលកិច្ចធនាគារកម្រិតខ្ពស់ ព្រមទាំងធានាត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យ ផ្ទៃក្នុងរបស់ធនាគារ។

១. សមាជិកចូលរួមកិច្ចប្រជុំ

ព័ត៌មានលម្អិតអំពីសមាជិកភាព និងកិច្ចប្រជុំគណៈកម្មាធិការសវនកម្មដែលបានរៀបចំឡើងកាលពីឆ្នាំ២០១២ មាន រៀបរាប់ដូចខាងក្រោម៖

សមាជិក	មុខតំណែង	បានចូលរួម	ចំនួនការប្រជុំ
Goh Nan Kioh*	អភិបាលឯករាជ្យមិនប្រតិបត្តិ	២	២
បណ្ឌិត ម៉ី កល្យាណ**	អភិបាលឯករាជ្យមិនប្រតិបត្តិ	២	២
Dato' Shaarani Ibrahim	អភិបាលឯករាជ្យមិនប្រតិបត្តិ	៤	៤
Dato' Wira Zainal Abidin Mahamad Zain	អភិបាលឯករាជ្យមិនប្រតិបត្តិ	៤	៤

* *លាលែងតំណែងនៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២*

** *តែងតាំងនៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២*

ប្រធានគណៈកម្មាធិការសវនកម្ម ធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីបញ្ហាទាំងឡាយណាដែលបានលើកឡើង ក្នុងកិច្ចប្រជុំគណៈកម្មាធិការសវនកម្មរបស់ខ្លួន។

២. សមាសភាព

គណៈកម្មាធិការសវនកម្មមានសមាជិកចំនួនបី (៣) រូប ដែលជាអភិបាលឯករាជ្យមិនប្រតិបត្តិ។ ប្រធានគណៈកម្មាធិការសវនកម្ម រួមមានលោក Goh Nan Kioh ដែលបានកាន់តំណែងនេះរហូតដល់ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២ ហើយបន្ទាប់មកបណ្ឌិត ម៉ី កល្យាណ ដែលជាអភិបាលឯករាជ្យមិនប្រតិបត្តិរបស់ធនាគារ ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការសវនកម្មជំនួសវិញនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២។

៣. សិទ្ធិអំណាច

គណៈកម្មាធិការសវនកម្ម គឺជាគណៈកម្មាធិការមួយដែលទទួលបានការផ្ទេរសិទ្ធិពីក្រុមប្រឹក្សាភិបាល។ នៅក្នុងការអនុវត្តតួនាទីរបស់ខ្លួន គណៈកម្មាធិការសវនកម្មនេះមានសិទ្ធិអំណាចពេញលេញក្នុងការស៊ើបអង្កេតលើបញ្ហានានា ដូចមានចែងនៅក្នុងតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម។ គណៈកម្មាធិការនេះ មានសិទ្ធិពេញលេញក្នុងការចូលរួម និងទាមទារឱ្យមានកិច្ចសហប្រតិបត្តិការពីគណៈគ្រប់គ្រង ព្រមទាំងមានឆន្ទានុសិទ្ធិពេញលេញក្នុងការអញ្ជើញអភិបាល ឬ មន្ត្រីប្រតិបត្តិណាម្នាក់ឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ព្រមទាំងមានសិទ្ធិទាមទារឱ្យធនាគារផ្តល់ធនធានចាំបាច់នានា ដើម្បីបំពេញការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ គណៈកម្មាធិការសវនកម្មមានសិទ្ធិពេញលេញ និងគ្មានដែនកំណត់ក្នុងការទទួលបានព័ត៌មានផ្សេងៗ ព្រមទាំងអាចទទួលយកការប្រឹក្សាយោបល់ពីអ្នកជំនាញឯករាជ្យក្នុងករណីចាំបាច់ ដោយរាល់ចំណាយដែលពាក់ព័ន្ធទាំងអស់ជាបន្ទុករបស់ធនាគារ។

៤. តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្មមានដូចខាងក្រោម៖

ចំណុចគន្លឹះ	ការទទួលខុសត្រូវ
ការត្រួតពិនិត្យផ្ទៃក្នុង / ការគ្រប់គ្រងហានិភ័យ / អភិបាលកិច្ច	ពិនិត្យមើលឡើងវិញ លើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដំណើរការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ច ក្នុងសម្ព័ន្ធធនាគារ ស្របតាមលក្ខខណ្ឌតម្រូវនៅក្នុងប្រកាសស្តីពីអភិបាលកិច្ចនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។
សវនកម្មផ្ទៃក្នុង	ក. ធានាថាមុខងារសវនកម្មផ្ទៃក្នុង បានរៀបចំល្អប្រសើរ ដើម្បីធ្វើការត្រួតពិនិត្យ ឬអង្កេតក្នុងនាមគណៈកម្មាធិការសវនកម្ម ហើយមុខងារនេះត្រូវស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងផ្ទាល់ពីគណៈកម្មាធិការសវនកម្ម។ ខ. ពិនិត្យមើលឡើងវិញ លើភាពគ្រប់គ្រាន់នៃវិសាលភាពសវនកម្មផ្ទៃក្នុង មុខងារ សមត្ថភាព និងធនធាននៃ មុខងារសវនកម្មផ្ទៃក្នុង ហើយពិនិត្យមើលថាតើមុខងារនេះ បានទទួលសិទ្ធិសំខាន់ៗ ដើម្បីបំពេញការងារនេះ។ របាយការណ៍របស់សវនករផ្ទៃក្នុង និងគណៈកម្មាធិការសវនកម្ម មិនទាមទារឱ្យមានការពិនិត្យ និងកែសម្រួលពីអគ្គនាយកឡើយ។ គ. ពិនិត្យមើលឡើងវិញ លើលទ្ធផលនៃដំណើរការសវនកម្មផ្ទៃក្នុង ហើយប្រសិនបើចាំបាច់ត្រូវធានាចាត់វិធានការសមស្របចំពោះអនុសាសន៍របស់សវនករផ្ទៃក្នុង។ ឃ. គ្រប់គ្រងមុខងាររបស់សវនកម្មផ្ទៃក្នុង និងធានាការគោរពច្បាប់ និងបទប្បញ្ញត្តិដែលអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ង. វាយតម្លៃសមិទ្ធកម្មការងារ និងធ្វើសេចក្តីសម្រេចចិត្ត អំពីកញ្ចប់ថវិកាសម្រាប់ប្រាក់បៀវត្ស របស់នាយកសវនកម្មផ្ទៃក្នុង។ ច. អនុម័តលើការតែងតាំង ការផ្ទេរ និងបណ្តេញចេញ ប្រធានសវនកម្មផ្ទៃក្នុង ឬ សមាជិកបុគ្គលិកជាន់ខ្ពស់ ដែលបំពេញមុខងារជាសវនករផ្ទៃក្នុង និងត្រូវទទួលការជូនដំណឹងអំពីការលាឈប់របស់បុគ្គលិកជាន់ខ្ពស់ ជាសវនករផ្ទៃក្នុង ហើយត្រូវផ្តល់ឱកាសឱ្យសមាជិក ដែលបានដាក់ពាក្យលាឈប់នោះ បញ្ជាក់ប្រាប់អំពីមូលហេតុនៃការលាឈប់នេះ។
សវនកម្មខាងក្រៅ	ក. ពិចារណាលើការតែងតាំងសវនករខាងក្រៅ ចំណាយសម្រាប់ការធ្វើសវនកម្ម និងបញ្ហាទាំងឡាយទាក់ទងនឹងមូលហេតុនៃការលាលែងតំណែង និងការបណ្តេញចេញ។ ខ. ពិភាក្សាជាមួយសវនករខាងក្រៅ មុននឹងចាប់ផ្តើមធ្វើសវនកម្មអំពីលក្ខណៈ និងវិសាលភាពការងារសវនកម្ម ហើយធានាលើការសម្របសម្រួល ក្នុងករណីមានក្រុមហ៊ុនសវនកម្មច្រើនចូលរួម។ គ. វាយតម្លៃអំពីគោលដៅ ការបំពេញការងារ និងឯករាជភាពរបស់សវនករខាងក្រៅ។

ឃ. អនុម័តលើការផ្តល់សេវា ដែលមិនទាក់ទងនឹងការងារសវនកម្មដោយសវនករខាងក្រៅ។

ង. ធានាថាមានការពិនិត្យច្បាស់លាស់លើលក្ខខណ្ឌ នៃការផ្តល់សេវាដែលមិនទាក់ទងនឹងការងារសវនកម្ម ដើម្បីជៀសវៀងការប៉ះពាល់ដល់ការវិនិច្ឆ័យ ប្រកបដោយឯករាជភាពរបស់សវនករខាងក្រៅ។

ច. ធានាថាគណនីធនាគារត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា ដោយមានការត្រួតពិនិត្យឡើងវិញ ជាប្រចាំលើភាពគ្រប់គ្រាន់នៃការធ្វើសំវិធានធន ដែលចាំបាច់ ព្រមទាំងចំពោះបំណុលអាក្រក់ និងសង្ស័យ។

ឆ. ពិភាក្សាលើបញ្ហា និងលក្ខខណ្ឌបម្រុងនានាដែលកើតចេញពីសវនកម្មអន្តរកាល និងចុងក្រោយ ព្រមទាំងបញ្ហាមួយចំនួនទៀតដែលសវនករចង់ធ្វើការពិភាក្សា (ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ប្រសិនបើចាំបាច់)។

ជ. ពិនិត្យមើលឡើងវិញ លើលិខិតគ្រប់គ្រងរបស់សវនករខាងក្រៅ និងការឆ្លើយតបរបស់គណៈគ្រប់គ្រង។

ឈ. ជួបប្រជុំជាមួយសវនករខាងក្រៅ យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ដើម្បីពិភាក្សាលើបញ្ហាគន្លឹះ និងស្នើសុំយោបល់ពីសវនករខាងក្រៅវិញ។

លទ្ធផលសវនកម្ម ការត្រួតពិនិត្យផ្ទៃក្នុង និងបញ្ហា នៃការគោរពច្បាប់ និងបទប្បញ្ញត្តិនានា

ពិនិត្យមើលឡើងវិញលើលទ្ធផល និងបញ្ហាទាក់ទងនឹងការគោរពច្បាប់ និងបទប្បញ្ញត្តិដែលចេញអ្នកបញ្ញត្តិច្បាប់ និងធានាថាថ្នាក់គ្រប់គ្រងបានចាត់វិធានការកែតម្រូវសមស្រប និងជាបន្ទាន់។

ផ្សេងៗ

ក. ពិនិត្យមើលឡើងវិញ លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងដំណាច់ឆ្នាំសម្រាប់ដាក់បញ្ជូនទៅក្រុម-ប្រឹក្សាភិបាល។

ខ. ពិនិត្យមើលឡើងវិញ លើរាល់ប្រតិបត្តិការពាក់ព័ន្ធនានាដែលអាចកើតមានឡើងនៅក្នុងសម្ព័ន្ធធនាគារ ដែលបានដាក់ជូនដោយគណៈគ្រប់គ្រង និងត្រូវជូនដំណឹង ដល់ក្រុមប្រឹក្សាភិបាលអំពីប្រតិបត្តិការទាំងនេះ។

5. សេចក្តីសង្ខេបសកម្មភាពផ្សេងៗនៅក្នុងឆ្នាំ២០១២

៥.១. គណៈកម្មាធិការសវនកម្ម

ក. បានពិនិត្យមើលឡើងវិញ និងអនុម័តយល់ព្រមលើផែនការសវនកម្មប្រចាំឆ្នាំ វិសាលភាពការងារ និងលក្ខខណ្ឌតម្រូវ ផ្នែកធនធានរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

ខ. បានពិនិត្យមើលឡើងវិញលើវិធីសាស្ត្ររបស់សវនកម្មផ្ទៃក្នុង ក្នុងការវាយតម្លៃកម្រិតហានិភ័យក្នុងវិស័យផ្សេងៗដែលអាចធ្វើសវនកម្មបាន និងធានាថាមុខងារសវនកម្ម ដោយផ្តោតសំខាន់ទៅលើវិស័យដែលមានកម្រិតហានិភ័យខ្ពស់។

គ. បានពិនិត្យមើលឡើងវិញលើភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យនានា ការធ្វើរបាយការណ៍ និងការគ្រប់គ្រងហានិភ័យ ដើម្បីធានាថាមានវិធីសាស្ត្រជាប្រព័ន្ធមួយក្នុងការកំណត់ វាយតម្លៃ និងកាត់បន្ថយហានិភ័យលើវិស័យនានា។

ឃ. បានពិនិត្យមើលឡើងវិញលើប្រសិទ្ធភាពនៃប្រតិបត្តិការ និងការប្រើប្រាស់ធនធានទាំងអស់នៅក្នុងធនាគារប្រកបដោយការសន្សំសំចៃ។

ង. បានពិនិត្យមើលឡើងវិញអំពីការតែងតាំងសវនករខាងក្រៅ ព្រមទាំងឯករាជភាព និងប្រសិទ្ធភាពការងាររបស់សវនករខាងក្រៅ។

ច. បានពិនិត្យមើលឡើងវិញលើផែនការសវនកម្មរបស់សវនករខាងក្រៅ វិសាលភាពការងារ និងលទ្ធផលនៃសវនកម្ម ប្រចាំឆ្នាំរបស់ធនាគារ។

ឆ. បានជួបជាមួយសវនករខាងក្រៅនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ ដោយពុំមានវត្តមានរបស់គណៈគ្រប់គ្រង និងអភិបាលប្រតិបត្តិ ដើម្បីពិភាក្សាបញ្ហាពាក់ព័ន្ធនានា និងស្នើសុំយោបល់កែតម្រូវពីសវនករខាងក្រៅ។

ជ. បានពិនិត្យមើលឡើងវិញនូវបញ្ហាពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុង ដែលរកឃើញដោយសវនករផ្ទៃក្នុង និងសវនករខាងក្រៅ ព្រមទាំងការឆ្លើយតបរបស់គណៈគ្រប់គ្រងចំពោះអនុសាសន៍របស់សវនករ និងការឯកភាពលើផែនការសកម្មភាពដែលត្រូវអនុវត្ត។

ឈ. បានពិនិត្យមើលឡើងវិញលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារប្រចាំត្រីមាស។

ញ. បានពិនិត្យមើលឡើងវិញលើប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិ និងភាពគ្រប់គ្រាន់នៃនីតិវិធីរបស់ធនាគារក្នុងការកំណត់ ត្រួតពិនិត្យ រាយការណ៍ និងពិនិត្យមើលឡើងវិញលើប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិនានា។

ដ. បានធានាចំពោះការប្រតិបត្តិតាមលក្ខខណ្ឌតម្រូវ វិធានច្បាប់ និងគោលការណ៍ផ្ទៃក្នុង ព្រមទាំងការវិវត្ត នៃសកម្មភាពការងារនានារបស់គណៈគ្រប់គ្រងក្នុងការអនុវត្តតាមអនុសាសន៍របស់សវនកម្មផ្ទៃក្នុង និងសវនកម្មខាងក្រៅ។

៥.២. មុខងារសវនកម្មផ្ទៃក្នុង

ក. ការធ្វើសវនកម្មផ្ទៃក្នុងសម្រាប់ធនាគារដោយមានការជួយគាំទ្រពីនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រុមហ៊ុនមេ។

ខ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង អនុវត្តការងារប្រកបដោយឯករាជភាព និងធានាលើភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលត្រូវអនុវត្តដោយគណៈគ្រប់គ្រង។

គ. នាយកដ្ឋានសវនកម្មផ្ទៃក្នុងជួយគណៈកម្មាធិការសវនកម្ម និងគណៈគ្រប់គ្រងក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពចំពោះការត្រួតពិនិត្យលើប្រសិទ្ធភាពនៃការចំណាយ ការវាយតម្លៃលើការគ្រប់គ្រងហានិភ័យ និងការផ្តល់យោបល់លើវិធានការកាត់បន្ថយហានិភ័យដែលបានរកឃើញ និងធានាដំណើរការអភិបាលកិច្ចត្រឹមត្រូវ។

ឃ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង ផ្តល់របាយការណ៍តាមកាលកំណត់ដល់គណៈកម្មាធិការសវនកម្ម និងគណៈគ្រប់គ្រង ដោយរាយការណ៍អំពីលទ្ធផលនៃការធ្វើសវនកម្មដែលបញ្ជាក់អំពីប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងហានិភ័យសំខាន់ៗ។

ង. នាយកដ្ឋានសវនកម្មផ្ទៃក្នុង ធ្វើការស៊ើបអង្កេតលើសកម្មភាពបោកបន្លំគួរឱ្យសង្ស័យ និងសកម្មភាពមិនប្រក្រតីផ្សេងទៀត។

៥.៣. របាយការណ៍សវនកម្មផ្ទៃក្នុង

ក. នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានបញ្ចប់ការធ្វើសវនកម្មរួមចំនួន ១៣លើក ជាមួយនឹងសវនករបស់ក្រុមហ៊ុនមេ និងការធ្វើសវនកម្មចំនួន ១៣ លើកផ្សេងទៀត ដែលធ្វើឡើងដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុងផ្ទាល់ ក្នុងអំឡុងឆ្នាំ២០១២ ដោយបានធ្វើសវនកម្មលើប្រតិបត្តិការសំខាន់ៗ ព្រមទាំងការអង្កេតដែលធ្លាប់បានធ្វើឡើង។

ខ. របាយការណ៍សវនកម្មដែលត្រូវបានចាត់ថ្នាក់ថាមាន “ហានិភ័យលើសពីកម្រិតមធ្យម” និង “ហានិភ័យកម្រិតធ្ងន់” តម្រូវឱ្យគណៈគ្រប់គ្រងមានវត្តមាននៅក្នុងកិច្ចប្រជុំគណៈកម្មាធិការសវនកម្មជាដាច់ខាត ដើម្បីឆ្លើយតប និងផ្តល់សេចក្តីពន្យល់លើបញ្ហាទាំងឡាយ ដែលនាយកដ្ឋានសវនកម្មផ្ទៃក្នុងរកឃើញ។

គ. រាល់បញ្ហាដែលនាយកដ្ឋានសវនកម្មផ្ទៃក្នុងរកឃើញ ត្រូវបានកត់ត្រាទុក និងតាមដានរហូតដល់បញ្ហាទាំងនោះត្រូវ បានដោះស្រាយចប់ និងត្រូវរាយការណ៍ប្រចាំត្រីមាសជូនគណៈកម្មាធិការសវនកម្មដោយនាយកដ្ឋានប្រតិបត្តិ។

ឃ. ស្ថានភាពអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្ម ក៏ត្រូវរាយការណ៍ជូនគណៈកម្មាធិការសវនកម្មប្រចាំត្រីមាសផងដែរ។

សេចក្តីថ្លែងការណ៍អំពី

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលផ្តោតសំខាន់ទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងប្តេជ្ញារក្សាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនេះឱ្យមានលក្ខណៈល្អប្រសើរ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនេះ បង្ហាញអំពីតម្រូវការចាំបាច់ចំពោះប្រតិបត្តិការអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល នីតិវិធីរៀបចំ និងគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុដ៏សមស្រប ព្រមទាំងការអនុវត្តស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមានផងដែរ។

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវជារួមលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងការគ្រប់គ្រងលើប្រព័ន្ធព័ត៌មានវិទ្យា។ ក្រុមប្រឹក្សាភិបាលក៏ទទួលស្គាល់ផងដែរថាការត្រួតពិនិត្យឡើងវិញលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺជាដំណើរការរួមគ្នាហើយត្រូវ អនុវត្តជាប់ជាប្រចាំនៅក្នុងធនាគារ ព្រមទាំងត្រូវធ្វើការផ្លាស់ប្តូរស្របនឹងបច្ចេកវិទ្យា បរិយាកាសអាជីវកម្ម និងបទប្បញ្ញត្តិច្បាប់ ក្នុងទស្សនៈធ្វើឱ្យប្រសើរឡើងនូវដំណើរការនៃការកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវបានបង្កើតឡើង ដើម្បីកំណត់ គ្រប់គ្រង និងត្រួតពិនិត្យហានិភ័យ ដែលរួមមានហានិភ័យប្រតិបត្តិការ ពោលគឺមិនមែនដើម្បីលុបបំបាត់ចោលនូវហានិភ័យដែលកើតចេញពីការបរាជ័យក្នុងការសម្រេចទិសដៅអាជីវកម្មនោះទេ។

ការគ្រប់គ្រងហានិភ័យ និងក្របខ័ណ្ឌនៃការត្រួតពិនិត្យ

ក្រុមប្រឹក្សាភិបាលទទួលស្គាល់ថាការគ្រប់គ្រងហានិភ័យ គឺជាផ្នែកមួយយ៉ាងសំខាន់នៃកម្មវត្ថុអាជីវកម្មរបស់ធនាគារ ហើយក៏ជាចំណុចសំខាន់សម្រាប់ធនាគារក្នុងការសម្រេចបានផលចំណេញជាបន្តបន្ទាប់ ព្រមទាំងការកើនឡើងជានិរន្តរ៍លើតម្លៃរបស់ភាគទុនិក។ ដើម្បីសម្រេចគោលដៅទាំងនេះ ធនាគារ ស៊ីអាយអិមបី ភីអិលស៊ី ដែលជាផ្នែកមួយនៃស៊ីអាយអិមបី ហ្គ្រុប បានអនុម័តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យទូទៅមួយ សម្រាប់ធនាគារទាំងមូល (EWRM) ដើម្បីគ្រប់គ្រងហានិភ័យ និងឱកាស។ ក្របខណ្ឌ EWRM ផ្តល់ជូនជាឧបករណ៍មួយដល់ក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងរបស់ខ្លួនក្នុងការប្រមើលមើលទុកជាមុន និងគ្រប់គ្រងលើហានិភ័យ ដែលមានស្រាប់ ព្រមទាំងហានិភ័យដែលអាចនឹងកើតមាន ដោយធ្វើការពិចារណាទៅលើការកែប្រែទម្រង់ហានិភ័យ ស្របតាមការផ្លាស់ប្តូរនៃយុទ្ធសាស្ត្រអាជីវកម្ម បញ្ញត្តិច្បាប់ និងសកម្មភាពការងារពេញមួយឆ្នាំ។

សុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន

ជាចម្បង ការគ្រប់គ្រងលើសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន គឺជាការគ្រប់គ្រងលើគ្រប់សកម្មភាពទាំងអស់ ដែលទាក់ទងនឹងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានរបស់ធនាគារ ស៊ីអាយអិមបី ភីអិលស៊ី។ ក្នុងការអនុវត្តផែនការមេនៃសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានរបស់ក្រុមហ៊ុនមេ (IT Securtity Blueprint) សុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាននេះថែរក្សា និងជម្រុញឱ្យមានប្រសិទ្ធភាពលើហេដ្ឋារចនាសម្ព័ន្ធ សុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានដើម្បីគាំទ្រដល់ផ្នែកអាជីវកម្ម។ តាមរយៈការវាយតម្លៃជាបន្តបន្ទាប់ និងការថែរក្សារចនាសម្ព័ន្ធសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានឱ្យមានភាពលូនសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន ធានាថានឹងអាចជំនះនូវរាល់បញ្ហាប្រឈមផ្នែកអាជីវកម្មនាថ្ងៃអនាគតឱ្យបាន។

ក្រៅអំពីសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន នាយកដ្ឋានប្រតិបត្តិតាមនៃបច្ចេកវិទ្យាព័ត៌មាន និងគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាព័ត៌មានរបស់ក្រុមហ៊ុនមេ ដើរតួនាទីជាអ្នកឃ្លាំមើលដើម្បីវាយតម្លៃបញ្ហាណាមួយដែលអាចនឹងមើលរំលង ដើម្បីរក្សាឱ្យបាននូវការគោរពតាមគោលការណ៍សុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានរបស់ក្រុមហ៊ុនមេ និងការអនុវត្តល្អប្រសើរបំផុតនៃវិស័យធនាគារ។ ការដាក់បញ្ចូលអោយមាននូវសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន គឺដើម្បីរក្សានូវស្តង់ដារកម្រិតខ្ពស់មួយ ដោយពឹងផ្អែកលើការអនុវត្តល្អប្រសើរបំផុតនៃវិស័យធនាគារ ដើម្បីធានាថាធនាគារ ស៊ីអាយអិមបី ភីអិលស៊ី អាចធ្វើប្រតិបត្តិការដោយមានហានិភ័យលើប្រព័ន្ធសុវត្ថិភាពតិចតួចបំផុត។

ដំណើរការនៃការត្រួតពិនិត្យផ្ទៃក្នុងសំខាន់ៗ

ដំណើរការសំខាន់ៗដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់ និងសុចរិតភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង រួមបញ្ចូលទាំងការអនុវត្តតាមបទប្បញ្ញត្តិច្បាប់ ដែលមានជាធរមានមានដូចខាងក្រោម៖

គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្ម (AC) មានសមាជិកជាអភិបាលឯករាជ្យមិនប្រតិបត្តិ។ គណៈកម្មាធិការសវនកម្ម គឺជាគណៈកម្មាធិការមួយដែលទទួលបានការផ្ទេរសិទ្ធិពីក្រុមប្រឹក្សាភិបាល ដើម្បីទទួលខុសត្រូវលើការត្រួតពិនិត្យ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ការផ្សព្វផ្សាយព័ត៌មាន ការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ការគ្រប់គ្រងហានិភ័យ និងដំណើរការនៃការគ្រប់គ្រងលើការត្រួតពិនិត្យផ្ទៃក្នុងនៅក្នុងធនាគារ។ គណៈគ្រប់គ្រង និងសវនករផ្ទៃក្នុង ព្រមទាំងសវនករខាងក្រៅ ផ្តល់របាយការណ៍ជូនគណៈកម្មាធិការសវនកម្មអំពីប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង។

រាល់បញ្ហាសំខាន់ៗ និងគួរឱ្យកត់សម្គាល់ទាំងអស់ដែលបានរកឃើញដោយសវនករ ត្រូវរាយការណ៍ជូនគណៈកម្មាធិការសវនកម្ម ដើម្បីធ្វើការពិនិត្យមើលឡើងវិញ និងពិភាក្សា។ គណៈកម្មាធិការសវនកម្មពិនិត្យមើលឡើងវិញ ហើយធានាអំពីការអនុវត្តផែនការកាត់បន្ថយ បញ្ហា ឬ ហានិភ័យរបស់គណៈគ្រប់គ្រង ដើម្បីការពារផលប្រយោជន៍របស់ក្រុមហ៊ុនមេ និងរក្សាឱ្យបានល្អនូវអភិបាលកិច្ចដ៏សមស្រប។ ការគ្រប់គ្រងផ្នែកអាជីវកម្មដែលត្រូវបានចាត់ថ្នាក់ថាមាន "ហានិភ័យលើសពីកម្រិតមធ្យម" ឬ "ហានិភ័យកម្រិតធ្ងន់" ត្រូវទទួលការពិគ្រោះយោបល់ពីគណៈកម្មាធិការសវនកម្ម។

គណៈកម្មាធិការសវនកម្ម ក៏ត្រូវធ្វើការពិនិត្យមើលឡើងវិញផងដែរនូវរាល់ប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិ សោហ៊ុយ ចំណាយលើសវនកម្មដែលស្នើដោយសវនករខាងក្រៅ និងសោហ៊ុយចំណាយមិនពាក់ព័ន្ធនឹងកិច្ចការសវនកម្មដែលស្នើដោយសវនករខាងក្រៅរបស់ធនាគារ។

ការធ្វើបទបង្ហាញនានាអំពីផែនការអាជីវកម្ម ការវិវឌ្ឍថ្មីៗ ប្រតិបត្តិការនានា ហានិភ័យនៃអាជីវកម្ម និងការត្រួតពិនិត្យ ដើម្បីកាត់បន្ថយហានិភ័យត្រូវបានធ្វើឡើងដោយផ្នែកអាជីវកម្មពាក់ព័ន្ធ និងផ្នែកគាំទ្រអាជីវកម្ម ប្រសិនបើគណៈកម្មាធិការសវនកម្មយល់ឃើញថាចាំបាច់។ គណៈកម្មាធិការសវនកម្មក៏ចូលរួមកិច្ចប្រជុំពិភាក្សាគណៈគ្រប់គ្រងប្រចាំឆ្នាំរបស់ធនាគារផងដែរ ដែលនៅក្នុងកិច្ចប្រជុំនេះ ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មនីមួយៗធ្វើការពិនិត្យមើលឡើងវិញនូវប្រតិបត្តិការនានារបស់ខ្លួន ដែលបានធ្វើឡើងសម្រាប់ឆ្នាំនេះ ព្រមទាំងធ្វើការបង្ហាញអំពីយុទ្ធសាស្ត្រ និងផែនការនានាសម្រាប់ឆ្នាំបន្ទាប់ផងដែរ។

គណៈកម្មាធិការហានិភ័យនានា

ក្រុមប្រឹក្សាភិបាលបានបង្កើតគណៈកម្មាធិការហានិភ័យចំនួន ២ ដែលមានឈ្មោះថា គណៈកម្មាធិការឥណទានកម្ពុជា (CCC) និងគណៈកម្មាធិការហានិភ័យ (RC)។ គណៈកម្មាធិការឥណទានកម្ពុជារាយការណ៍ជូនគណៈកម្មាធិការហានិភ័យ អំពីបញ្ហាពាក់ព័ន្ធនឹងឥណទានរបស់ធនាគារ ហើយគណៈកម្មាធិការនេះមានការទទួលខុសត្រូវ និងមុខងារដាច់ដោយឡែកពីគណៈកម្មាធិការហានិភ័យ ដូចដែលបានកំណត់ក្នុងតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការឥណទានកម្ពុជា។ គណៈកម្មាធិការហានិភ័យកំណត់កម្មវត្ថុ នៃគោលការណ៍ហានិភ័យរបស់ធនាគារ ហើយបំពេញតួនាទី និងកាតព្វកិច្ចជំនួសឱ្យក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យលើការគ្រប់គ្រងហានិភ័យ។ ការទទួលខុសត្រូវចំពោះការត្រួតពិនិត្យលើការគ្រប់គ្រងហានិភ័យប្រចាំថ្ងៃ ត្រូវបានប្រគល់សិទ្ធិជូនគណៈកម្មាធិការហានិភ័យ ដែលទទួលបន្ទុករាយការណ៍ដោយផ្ទាល់ទៅក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការហានិភ័យធ្វើការជួបប្រជុំ ជារៀងរាល់ខែ ឬ តាមការចាំបាច់។

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការហានិភ័យ នៅខែសីហា ឆ្នាំ២០១២ និងចាប់ផ្តើមកិច្ចប្រជុំលើកទី១ របស់ខ្លួននៅខែតុលា។ គណៈកម្មាធិការនេះរាយការណ៍អំពីហានិភ័យសាច់ប្រាក់ ងាយស្រួល ព្រមទាំងបញ្ហាទាក់ទងនឹង

ទ្រព្យសកម្ម និងទ្រព្យអកម្មរបស់ធនាគារទៅគណៈកម្មាធិការហានិភ័យ។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ធ្វើការប្រជុំជារៀងរាល់ខែ ដោយមានតួនាទីចម្បងក្នុងការពិនិត្យតាមដាន និងប្រើប្រាស់ យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុនៃតារាងតុល្យការ ជាមួយនឹងការទទួលខុសត្រូវជាក់លាក់ចំពោះការគ្រប់គ្រងលើថ្លៃដើម ឥណទាន ការរៀបចំអភិវឌ្ឍបន្ថែមលើការផ្តល់ប្រឹក្សា ដែលសមស្របជូនគណៈកម្មាធិការហានិភ័យ ក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងហានិភ័យសាច់ប្រាក់ងាយស្រួល និងហានិភ័យអត្រាការប្រាក់ ការរំបងចែកប្រភពហិរញ្ញប្បទាន និងការត្រួតពិនិត្យឡើងវិញ នូវសមាសភាពក្នុងតារាងតុល្យការពាក់ព័ន្ធនឹងឥណទាន និងប្រាក់បញ្ញើ។ សរុបសេចក្តីមក គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និង ទ្រព្យអកម្ម ត្រួតពិនិត្យមើលការអនុវត្តនៃដំណើរការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព សម្រាប់ការគ្រប់គ្រងលើអត្រាការប្រាក់ សាច់ប្រាក់ងាយស្រួលរបស់ធនាគារ និងហានិភ័យស្រដៀងគ្នាផ្សេងៗទៀត ដែលទាក់ទងនឹងតារាងតុល្យការបស់ធនាគារ និងកម្រិត ពាក់ព័ន្ធផ្សេងទៀត។

គណៈកម្មាធិការគ្រប់គ្រង

គណៈកម្មាធិការគ្រប់គ្រង គឺជាគណៈកម្មាធិការដែលបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលដើម្បីគ្រប់គ្រងបញ្ហាដែលកើតពីការធ្វើប្រតិបត្តិការប្រចាំថ្ងៃ។ កិច្ចប្រជុំគណៈកម្មាធិការនេះធ្វើឡើង ២សប្តាហ៍ម្តងក្នុងមួយខែ គឺនៅសប្តាហ៍ទី១ និងទី៣ នៃខែនីមួយៗ ឬ តាមការចាំបាច់។ សមាសភាពរបស់គណៈកម្មាធិការគ្រប់គ្រងរួមមាន សមាជិកមកពីនាយកដ្ឋាននានា រួមបញ្ចូលទាំងសវនករផ្ទៃក្នុងមួយរូប និងមន្ត្រីប្រតិបត្តិមួយរូបដែលត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំជាអចិន្ត្រៃយ៍។

គោលការណ៍ និងនីតិវិធីផ្ទៃក្នុង

រាល់គោលការណ៍ និងនីតិវិធីផ្ទៃក្នុងរបស់ផ្នែកអាជីវកម្មទាំងអស់ ត្រូវបានអនុម័តដោយក្រុម-ប្រឹក្សាភិបាល។ គោលការណ៍ និងនីតិវិធីទាំងអស់នេះត្រូវបានប្រើប្រាស់ជាមគ្គុទេសក៍សម្រាប់ការធ្វើប្រតិបត្តិការប្រចាំថ្ងៃ ដើម្បីធានាការប្រតិបត្តិតាម ការត្រួតពិនិត្យផ្ទៃក្នុង និងបទប្បញ្ញត្តិច្បាប់ដែលមានជាធរមាន។ គោលការណ៍ទាំងនេះ រៀបចំឡើងក្នុងគោលបំណងធានា ប្រសិទ្ធភាពនៃប្រតិបត្តិការឱ្យកាន់តែមានភាពប្រសើរឡើង ដោយធ្វើការពិចារណាផងដែរទៅលើបម្រែបម្រួលនៃវិស័យធនាគារ ដូចជា លក្ខខណ្ឌតម្រូវរបស់ច្បាប់ ហានិភ័យ និងវិធានការត្រួតពិនិត្យផ្ទៃក្នុងដើម្បីកាត់បន្ថយហានិភ័យ ព្រមទាំងផលិតផល និងសេវាកម្មថ្មីៗ ជាដើម។

សវនកម្មផ្ទៃក្នុង

ការធ្វើសវនកម្មដោយសវនករផ្ទៃក្នុងលើប្រតិបត្តិការរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ត្រូវបានធ្វើឡើងរួមគ្នាជាមួយ សវនករនៃក្រុមហ៊ុនមេ និងត្រូវរាយការណ៍ដោយឯករាជ្យទៅគណៈកម្មាធិការសវនកម្ម។ គណៈកម្មាធិការសវនកម្មមាន ឯករាជភាពគ្រប់គ្រាន់ពីផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មផ្សេងទៀតលើគ្រប់សកម្មភាព និងប្រតិបត្តិការទាំងអស់ ។

ការទទួលខុសត្រូវចម្បងរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង គឺផ្តល់ជូននូវការធានាដោយឯករាជ្យលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលត្រូវអនុវត្តដោយគណៈគ្រប់គ្រង។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងធ្វើការវាយតម្លៃលើស្ថានភាពនៃការត្រួតពិនិត្យ ការអនុវត្តការគ្រប់គ្រងហានិភ័យ ការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ប្រសិទ្ធភាព និងសមត្ថភាពរបស់គណៈគ្រប់គ្រង ព្រមទាំងការអនុវត្តយុទ្ធសាស្ត្ររបស់ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មផងដែរ។

វិសាលភាពការងាររបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង គ្របដណ្តប់លើគ្រប់ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មទាំងអស់។ ការជ្រើសរើសយកផ្នែកណាមួយមកធ្វើសវនកម្មត្រូវធ្វើឡើងដោយផ្អែកលើផែនការសវនកម្មប្រចាំឆ្នាំ ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការសវនកម្ម។ ផែនការសវនកម្មប្រចាំឆ្នាំត្រូវបានបង្កើតឡើង ផ្អែកតាមការវាយតម្លៃកម្រិតហានិភ័យ គោលដៅ និងយុទ្ធសាស្ត្ររបស់ធនាគារ។ ផ្នែកទាំងឡាយណាដែលត្រូវបានវាយតម្លៃថាមានហានិភ័យកម្រិតខ្ពស់ គឺជាកម្មវត្ថុនៃការធ្វើសវនកម្មប្រចាំឆ្នាំ ក្នុងខណៈផ្នែកដែលទទួលការវាយតម្លៃថាមានហានិភ័យកម្រិតមធ្យម ឬ ទាប គឺជាកម្មវត្ថុនៃការធ្វើសវនកម្មជាបន្តបន្ទាប់។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងក៏ធ្វើការស៊ើបអង្កេតផងដែរលើការសង្ស័យចំពោះការលួចបន្លំដែលប្រព្រឹត្តដោយបុគ្គលិក អតិថិជន និងតតិយជន ហើយផ្តល់អនុសាសន៍កែលម្អឱ្យកាន់ប្រសើរឡើង ដើម្បីបង្ការកុំឱ្យបញ្ហាដដែលកើតមានឡើងសាជាថ្មីម្តងទៀត និងធ្វើការចាត់វិធានការចំពោះបុគ្គលពាក់ព័ន្ធ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងមានសិទ្ធិទទួលបានគ្រប់ព័ត៌មានទាំងអស់ ដែលចាំបាច់ដោយគ្មានកម្រិតក្នុងក្របខណ្ឌនៃការងាររបស់ខ្លួនឡើយ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុម័តយកក្របខណ្ឌត្រួតពិនិត្យផ្ទៃក្នុង នៃគណៈកម្មាធិការ Committee of Sponsoring Organisations of the Tradeway Commission សម្រាប់ការផ្តល់ពិន្ទុ និងវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធរបស់ធនាគារ។ វិសាលភាពការងាររបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតឡើង ដោយយោងតាមស្តង់ដារអន្តរជាតិសម្រាប់ការប្រកបវិជ្ជាជីវៈសវនកម្មផ្ទៃក្នុងរបស់វិទ្យាស្ថានសវនករអន្តរជាតិ (IIA) និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា (NBC)។

របាយការណ៍សវនកម្ម គឺជាលទ្ធផលចុងក្រោយនៃការងារសវនកម្មដែលបង្ហាញអំពីវិសាលភាពការងារសវនកម្មដែលបានបំពេញ ការវាយតម្លៃទូទៅនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងជាមួយនឹងការអង្កេតយ៉ាងលម្អិតលើការធ្វើសវនកម្ម មតិយោបល់ និងអនុសាសន៍នានាដើម្បីធ្វើឱ្យកាន់តែប្រសើរឡើង។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងពិនិត្យមើលឡើងវិញ និងវាយតម្លៃរាល់អញ្ញត្តិកម្ម ឬ ការមិនប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ដែលបានលើកឡើងដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុង ហើយធានាថាគណៈគ្រប់គ្រងបានចាត់ វិធានការកែតម្រូវសមស្រប និងជាបន្ទាន់។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ធ្វើការបណ្តុះបណ្តាលដល់ថ្នាក់គ្រប់គ្រងសាខា និងបុគ្គលិករបស់ធនាគារជាប្រចាំអំពី អភិបាលកិច្ច និងបញ្ហានានានៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

ក្របខណ្ឌនៃការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់

ក្របខណ្ឌនៃការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ដាក់ចេញនូវយន្តការ និងមធ្យោបាយនានា ដើម្បីធានានូវការអនុវត្តស្របគ្នា និងប្រកបដោយប្រសិទ្ធភាពក្នុងការគ្រប់គ្រងហានិភ័យដែលកើតឡើងពីការមិនគោរពច្បាប់។ ទាំងនេះតម្រូវឱ្យធនាគារអនុម័ត និងអនុវត្តនូវគោលការណ៍ និងនីតិវិធីស្តីពីការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់របស់ក្រុមហ៊ុនមេ ហើយប្តេជ្ញាកាត់បន្ថយការទទួលខុសត្រូវរបស់ធនាគារចំពោះការមិនប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់។ ស្របតាមអភិបាលកិច្ចល្អ នាយកដ្ឋានប្រតិបត្តិធ្វើការរាយការណ៍ជូន ក្រុមប្រឹក្សាភិបាលដោយឯករាជ្យ។ អភិបាលកិច្ចសមស្របមួយក៏ត្រូវបានបង្កើតឡើង ដោយនៅក្នុងនោះមន្ត្រីប្រតិបត្តិតាមប្រចាំ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ត្រូវរាយការណ៍ជូននាយកដ្ឋានប្រតិបត្តិតាមបទប្បញ្ញត្តិរបស់ក្រុមហ៊ុនមេ បន្ថែមពីលើការរាយការណ៍ដោយផ្ទាល់ទៅក្រុមប្រឹក្សាភិបាលរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងកម្រិតមួយដែលអនុញ្ញាតដោយវិធានយុត្តាធិការកម្ពុជា។

គោលការណ៍ និងនីតិវិធីនៃការអនុម័តលើផលិតផលថ្មី

គោលការណ៍ និងនីតិវិធីនៃការអនុម័តលើផលិតផលថ្មី ត្រូវបានដាក់ឱ្យអនុវត្តសម្រាប់គ្រប់ផលិតផល និងសេវាកម្មថ្មីៗ ទាំងអស់របស់ធនាគារ។ ផលិតផលថ្មី គឺសំដៅទៅលើផលិតផល និង/ឬ សេវាកម្មទាំងឡាយណា ដែលផ្តល់ជូនដំបូងដោយធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ឬ ជាការបញ្ចូលផលិតផលច្រើនទៅជាផលិតផលតែមួយ ឬ បម្រែបម្រួលទម្រង់នៃផលិតផលដែលមានស្រាប់ និង/ឬ សេវាកម្មដែលមានការប្រែប្រួលខ្លាំងនូវទម្រង់ហានិភ័យ ដូចដែលបានកំណត់ដោយនាយកដ្ឋានគ្រប់គ្រងហានិភ័យ។

គ្រប់សំណើសុំការអនុម័តលើផលិតផលថ្មី ត្រូវឆ្លងកាត់ដំណើរការនៃការត្រួតពិនិត្យហានិភ័យ ឱ្យបានស៊ីជម្រៅ ដោយបុគ្គលពាក់ព័ន្ធនានា ទាំងនៅក្នុងធនាគារ និងនៅក្នុងក្រុមហ៊ុនមេ ដើម្បីធានាថាគ្រប់ផ្នែកសំខាន់ៗ និងផ្នែកដែលពាក់ព័ន្ធនឹងហានិភ័យ ត្រូវបានកំណត់ វាយតម្លៃ និងកាត់បន្ថយហានិភ័យមុនពេលដំណើរការផលិតផល និង/ឬ សេវាកម្មថ្មីៗនោះ។ បន្ទាប់មកសំណើសុំការអនុម័តលើផលិតផលថ្មីមួយរបស់ធនាគារ ត្រូវឆ្លងកាត់ការពិភាក្សាយ៉ាងហ្មត់ចត់ដោយគណៈកម្មាធិការនានារបស់ធនាគារ និងក្រុមហ៊ុនមេ មុននឹងដាក់ជូនក្រុមប្រឹក្សាភិបាលរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដើម្បីធ្វើការអនុម័តចុងក្រោយ។

ការគ្រប់គ្រងលើអញ្ញត្តិកម្ម និងការផ្សព្វផ្សាយ

ធនាគារ នៅតែបន្តសង្កត់ធ្ងន់លើសារៈសំខាន់នៃការប្រកាន់ខ្ជាប់នូវការគោរពតាមបទប្បញ្ញត្តិច្បាប់ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធីផ្សេងៗទៀត ដើម្បីរក្សាកេរ្តិ៍ឈ្មោះរបស់ធនាគារ។ អញ្ញត្តិកម្ម ត្រូវបានលើកឡើង និងចាត់ចែងឱ្យបានទាន់ពេលវេលា ប្រកបដោយតម្លាភាព។ ដើម្បីឈានទៅរកការសម្រេចគោលដៅនេះ ធនាគារបានបង្កើតនីតិវិធីគ្រប់គ្រងលើករណីអញ្ញត្តិកម្ម និងការផ្សព្វផ្សាយ ដើម្បីផ្សព្វផ្សាយករណីអញ្ញត្តិកម្មណាមួយដែលកើតមានឡើង រួមមាន ការមិនប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ការមិនគោរពកាតព្វកិច្ច ការលួចបន្លំ និងការមិនគោរពតាមដំណើរការផ្ទៃក្នុង។ នីតិវិធីនេះជួយឱ្យមានវិធានការកែលម្អទាន់ពេលវេលា និងពង្រឹងតម្លាភាព ព្រមទាំងការត្រួតពិនិត្យរបស់គណៈគ្រប់គ្រង។ ស្ថិតក្រោមនីតិវិធីនៃការគ្រប់គ្រងលើអញ្ញត្តិកម្ម និងការផ្សព្វផ្សាយ របាយការណ៍ស្តីពីបញ្ហាដែលកើតមានត្រូវធ្វើជូនក្នុងអំឡុងពេល ២៤ ម៉ោងបន្ទាប់ពីរកឃើញ ឬ បន្ទាប់ពីការជូនដំណឹងដំបូងបំផុតអំពីបញ្ហាដែលបានកើតឡើង។ បន្ទាប់មក ករណីអញ្ញត្តិកម្មទាំងនេះនឹងត្រូវបានចាត់ចែងដោះស្រាយដោយ ផ្អែកលើភាពធ្ងន់ធ្ងរ និងផលប៉ះពាល់របស់ករណីនេះចំពោះអាជីវកម្ម ប្រតិបត្តិការ និងកេរ្តិ៍ឈ្មោះរបស់ធនាគារ។ ករណីអញ្ញត្តិកម្មនេះ ត្រូវសង្ខេប និងរាយការណ៍ជូនគណៈកម្មាធិការហានិភ័យជារៀងរាល់ខែ។

ក្រមសីលធម៌

ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី មានស្តង់ដារក្រមសីលធម៌អប្បបរមាមួយសម្រាប់ឱ្យគ្រប់និយោជិតទាំងអស់របស់ខ្លួន អនុវត្ត ដែលរួមបញ្ចូលទាំងគ្រប់ទិដ្ឋភាពទាំងអស់នៃប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃផងដែរ។ គោលការណ៍ណែនាំអំពីក្រមសីលធម៌ ត្រូវបានអនុម័តយកតាមក្រមសីលធម៌របស់ក្រុមហ៊ុនមេ ហើយត្រូវបានដាក់បញ្ចូលនៅក្នុងកិច្ចសន្យាការងារដែលយល់ព្រម និងចុះហត្ថលេខាដោយគ្រប់និយោជិតទាំងអស់។

គោលការណ៍ និងនីតិវិធីស្តីពីធនធានមនុស្ស

គោលការណ៍ និងនីតិវិធីស្តីពីធនធានមនុស្សត្រូវបានបង្កើតឡើង និងប្រើប្រាស់នៅក្នុងក្រុមហ៊ុនមេទាំងមូល ដោយមានវិសាលភាពលើគ្រប់ទិដ្ឋភាពទាំងអស់នៃការគ្រប់គ្រងធនធានមនុស្សក្នុងធនាគារ។ គោលការណ៍នេះបានកំណត់យ៉ាងច្បាស់លាស់អំពី ការជ្រើសរើសនិយោជិត ការតម្លើងឋានៈ ការផ្ទេរកន្លែងការងារ និងការបញ្ឈប់និយោជិតនៅក្នុងក្រុមហ៊ុនមេទាំងមូល។ និយោជិតទទួលការវាយតម្លៃលើការងាររបស់ខ្លួនជារៀងរាល់ឆ្នាំ ហើយការវាយតម្លៃការងារនេះធ្វើឡើងដោយផ្អែកលើសូចនាករនៃការវាយតម្លៃលទ្ធផលការងារ និងការវាស់វែងសមត្ថភាពគន្លឹះ។ កម្មវិធីសិក្សា និងអភិវឌ្ឍន៍សមត្ថភាព ដែលរួមបញ្ចូលទាំង ជំនាញ/វគ្គបណ្តុះបណ្តាលបច្ចេកទេសត្រូវបានរៀបចំឡើង និងដាក់ឱ្យអនុវត្តក្នុងគោលដៅគាំទ្រ និងបង្កើនសមត្ថភាពនិយោជិតរបស់យើង ដើម្បីធានាថានិយោជិតទាំងអស់អាចបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ធនាគារបានធ្វើការត្រើនរំលឹកដល់និយោជិតរបស់ខ្លួនជារៀងៗ អំពីគោលការណ៍ពាក់ព័ន្ធនានាតាមរយៈ សារអេឡិចត្រូនិក ឬ ការជូនដំណឹងជាលាយលក្ខណ៍អក្សរ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធនានា។ វគ្គបណ្តុះបណ្តាលមួយ ក្នុងចំណោមវគ្គបណ្តុះបណ្តាលផ្សេងទៀតស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មត្រូវបានធ្វើឡើងជារៀងៗ ដើម្បីជាការបញ្ជាក់ឱ្យឃើញអំពីទស្សនាទានរបស់ក្រុមហ៊ុនមេ ដែលមិនអធ្យាស្រ័យចំពោះអំពើបោកបន្លំ។ ចំណុចនេះក៏ត្រូវបានធ្វើការសង្កត់ធ្ងន់ផងដែរនៅក្នុងកម្មវិធីបណ្តុះបណ្តាលណែនាំដំបូងរបស់ក្រុមហ៊ុនមេ។

ការគ្រប់គ្រងនិរន្តរភាពនៃធុរកិច្ច

ការទទួលស្គាល់អំពីសារៈសំខាន់នៃការគ្រប់គ្រងនិរន្តរភាពនៃធុរកិច្ច (BCM) និងការទទួលខុសត្រូវសំខាន់ៗ ព្រមទាំងសកម្មភាពដែលពាក់ព័ន្ធ និងការឆ្លើយតបចំពោះស្ថានភាពនៃវិបត្តិនានាដែលអាចកើតមានឡើង ធ្វើឱ្យធនាគារចាំបាច់ត្រូវតែបង្កើតឱ្យមានផែនការគ្រប់គ្រងនិរន្តរភាពនៃធុរកិច្ច

កិច្ចប្រជុំគណៈកម្មាធិការសវនកម្ម

សម្រាប់សហគ្រាសទាំងមូល ដែលមិនត្រឹមតែរួមបញ្ចូលនូវការគ្រប់គ្រងវិបត្តិនោះទេ។ ក្រុមការងារគ្រប់គ្រងនិរន្តរភាពនៃធុរកិច្ចរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី បានអនុវត្តដោយជោគជ័យនូវការសាកល្បងអំពីការដោះស្រាយវិបត្តិ និងការរៀបចំផែនការគ្រប់គ្រងនិរន្តរភាពនៃធុរកិច្ច។

សកម្មភាពរបស់ក្រុមការងារគ្រប់គ្រងនិរន្តរភាពនៃធុរកិច្ច ដែលបានបំពេញនៅឆ្នាំ២០១២ មានដូចខាងក្រោម៖

ក. សម្រេចផែនការគ្រប់គ្រងនិរន្តរភាពនៃធុរកិច្ចរួម សម្រាប់គ្រប់នាយកដ្ឋានទាំងអស់នៅការិយាល័យកណ្តាល ប៉ុន្តែ ផែនការនេះនៅពុំទាន់បានដាក់ជូនគណៈកម្មាធិការគ្រប់គ្រងហានិភ័យប្រតិបត្តិការរបស់ក្រុមហ៊ុនមេនៅឡើយ។

ខ. ការសាកល្បងដោះស្រាយវិបត្តិលើប្រព័ន្ធស្នូលរបស់ធនាគារ ត្រូវបានធ្វើឡើងប្រកបដោយជោគជ័យនៅត្រីមាសទី៤។

គ. ការសាកល្បងផែនការគ្រប់គ្រងនិរន្តរភាពនៃធុរកិច្ច នៅតាមបណ្តាទីតាំងផ្សេងៗទៀតដែលបានជ្រើសរើស សម្រាប់មុខងារសំខាន់នានាត្រូវបានធ្វើឡើងប្រកបដោយជោគជ័យនៅត្រីមាសទី៤។

ឃ. សម្រេចបាននូវការវាយតម្លៃលើទីតាំងដែលអាចបង្ក ឱ្យមានហានិភ័យ (Location Vulnerability Hazard Scorecard)

ង. ដាក់ជូនរបាយការណ៍ស្តីពីវិបត្តិ ដែលកើតមានដោយចៃដន្យទៅនាយកដ្ឋានគ្រប់គ្រងនិរន្តរភាពនៃអាជីវកម្មធុរកិច្ច របស់ក្រុមហ៊ុនមេ

ច. បានរៀបចំកម្មវិធីយល់ដឹងអំពីការគ្រប់គ្រងនិរន្តរភាពនៃធុរកិច្ចសម្រាប់គណៈគ្រប់គ្រង។

ឆ. បានតាក់តែងរួចរាល់នូវកម្រងសំណួរសម្រាប់ការវាយតម្លៃផ្ទាល់ខ្លួន។

ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ គឺជាផលវិបាកមួយដែលមិនអាចជៀសវាងបាននៅក្នុងការប្រកបអាជីវកម្ម។ ប៉ុន្តែធនាគារបានបង្កើតគោលការណ៍ និងនីតិវិធីដើម្បីធ្វើជាមគ្គុទេសក៍សម្រាប់ផ្អែកអាជីវកម្ម និងផ្អែកគាំទ្រអាជីវកម្មផ្សេងទៀតនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារ ការអនុវត្តដោយផ្អែកលើទម្លាប់អនុវត្តល្អប្រសើរបំផុតនៅក្នុងធនាគារ និងស្របតាមការណែនាំរបស់ក្រុមហ៊ុនមេ។ គោលការណ៍ និងនីតិវិធីគ្រប់គ្រងហានិភ័យរបស់ធនាគារ បានកំណត់យ៉ាងច្បាស់អំពីគោលការណ៍គ្រឹះនៃការកំណត់ ការវាយតម្លៃ ការគ្រប់គ្រង ការកាត់បន្ថយ និងការត្រួតពិនិត្យលើហានិភ័យដែលកើតមាន។

សកម្មភាពកំសាន្តរបស់បុគ្គលិកធនាគារ ស៊ីអាយអិមប៊ី ក្នុងរាជធានីភ្នំពេញ

ទិន្នន័យនៃហេតុការណ៍ដែលបណ្តាលឱ្យមានការបាត់បង់ (LED)៖

ដើម្បីធ្វើការពិនិត្យ និងតាមដានប្រកបដោយប្រសិទ្ធភាព ធនាគារបានអនុម័តលើប្រភេទនៃហេតុការណ៍ដែលនាំឱ្យមានការបាត់បង់កើតចេញពីប្រតិបត្តិការចំនួន ៧ប្រភេទ។ រាល់ឧប្បត្តិហេតុដែលបណ្តាលឱ្យមានការបាត់បង់ទាំងអស់ ត្រូវរាយការណ៍ជូន នាយកដ្ឋានគ្រប់គ្រងហានិភ័យ ដែលនាយកដ្ឋាននេះជាអ្នកប្រមូលផ្តុំ និងរាយការណ៍បន្តទៀតទៅគណៈកម្មាធិការហានិភ័យ ដើម្បីធ្វើការពិភាក្សា និងផ្តល់ការណែនាំនានាអំពីផែនការសកម្មភាពដ៏ល្អបំផុតមួយ ក្នុងការកាត់បន្ថយកុំឱ្យកើតមានឧប្បត្តិហេតុដែល បណ្តាលឱ្យមានការបាតបង់នេះកើតឡើងម្តងហើយម្តងទៀត។

ការប្រមូលទិន្នន័យនៃហេតុការណ៍ ដែលបង្កឱ្យមានការបាត់បង់ជួយសម្រួលដល់ការវិភាគនានា ក្នុងគោលបំណងគណនាមូលធនរបស់ធនាគារសម្រាប់ហានិភ័យប្រតិបត្តិការ ដូចបានលើកឡើងក្នុងកិច្ចព្រមព្រៀង Basel II ស្តីពីមូលធនដែលបានអនុវត្ត ដោយក្រុមហ៊ុនមេ។ ព័ត៌មានដែលប្រមូលបានដោយផ្នែកអាជីវកម្ម/ផ្នែកគាំទ្រអាជីវកម្ម ត្រូវបានប្រើប្រាស់ដើម្បីកំណត់អំពីមូលហេតុ ពិតប្រាកដនៃឧប្បត្តិហេតុ ហើយប្រសិនបើចាំបាច់ ត្រូវផ្តល់អនុសាសន៍ពង្រឹង និងកែលម្អការត្រួតពិនិត្យលើប្រតិបត្តិការ ឬ ដំណើរការការងារដែលមានស្រាប់។ ឧប្បត្តិហេតុធ្ងន់ធ្ងរណាមួយដែលជាលទ្ធផលនៃការបំពាន/ការមិនគោរពច្បាប់នឹងត្រូវលើកយកមកពិភាក្សា ហើយរាយការណ៍ជូនថ្នាក់លើភ្លាមៗ ដូចដែលបានបង្ហាញនៅក្នុងដំណើរការនៃគ្រប់គ្រង និងការផ្សព្វផ្សាយអំពីករណី អញ្ញត្តិកម្មរបស់ធនាគារ។

ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

កម្មវិធីបណ្តុះបណ្តាល និងបង្កើនការយល់ដឹងត្រូវបានធ្វើឡើងជាទៀងទាត់។ កម្មវិធីនេះត្រូវបានបំពេញបន្ថែមដោយច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយ ករណីសិក្សាលើប្រតិបត្តិការជាក់ស្តែងអំពីហានិភ័យនៃការសម្អាតប្រាក់ និងការផ្តល់ហិរញ្ញប្បទានភេរវកម្ម ដោយធ្វើការសង្កត់ធ្ងន់លើតួនាទី និងការទទួលខុសត្រូវរបស់និយោជិត។ ធនាគារ បាននិងបន្តចាត់វិធានការដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតមានចំពោះធនាគារ ស៊ីអាយអិមប៊ី ភីអីលស៊ី ពាក់ព័ន្ធនឹងសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហើយស្របពេលជាមួយគ្នានេះដើម្បីធានានូវការប្រតិបត្តិ តាមបទប្បញ្ញត្តិច្បាប់ និងគោលការណ៍ណែនាំរបស់អាជ្ញាធរពាក់ព័ន្ធផងដែរ។ កិច្ចសហប្រតិបត្តិការជាមួយបណ្តាធនាគារផ្សេងៗទៀត ក្នុងការផ្តួចផ្តើមគំនិតប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក៏ជាផ្នែកមួយនៃកម្មវិធីបណ្តុះបណ្តាល និងការបង្កើនការយល់ដឹងនេះផងដែរ។

សេចក្តីសន្និដ្ឋាន

ក្រុមប្រឹក្សាភិបាល មានជំនឿថាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលកំពុងអនុវត្តមានលក្ខណៈគ្រប់គ្រាន់ក្នុងការការពារផលប្រយោជន៍របស់ភាគទុនិក និងទ្រព្យសកម្មរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។ ក្រុមប្រឹក្សាភិបាលទទួលស្គាល់ថាធនាគារមានដំណើរការប្រកបដោយប្រសិទ្ធភាពសម្រាប់ធ្វើការកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យធំៗនៅក្នុងធនាគារ ហើយបានប្តេជ្ញាបន្តធ្វើការពិនិត្យមើលឡើងវិញនូវប្រតិបត្តិការ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ដែលរួមបញ្ចូលទាំងការត្រួតពិនិត្យ ផ្នែកហិរញ្ញវត្ថុ ប្រតិបត្តិការ និងការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ព្រមទាំងការគ្រប់គ្រងហានិភ័យផងដែរ។

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី

រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២

រចនាសម្ព័ន្ធ
របស់ធនាគារ



របស់ធនាគារ

ក្រុមប្រឹក្សាភិបាល

Dato' Shaarani Ibrahim
ប្រធានក្រុមប្រឹក្សាភិបាល
Goh Nan Kioh
Dato' Wira Zainal Abidin Mahamad Zain
Peter England
Yew Wan Kup
បណ្ឌិត ម៉ី កល្យាណ

គណៈកម្មាធិការសវនកម្ម

បណ្ឌិត ម៉ី កល្យាណ
ប្រធាន
Dato' Shaarani Ibrahim
Dato' Wira Zainal Abidin Mahamad Zain

គណៈកម្មាធិការហានិភ័យ

Dato' Shaarani Ibrahim
ប្រធាន
Yew Wan Kup
អគ្គនាយក
Sasi Komanthakkal
តំណាងនាយកគ្រប់គ្រងហានិភ័យ
ប៊ុន យ៉ីន
អគ្គនាយករង និងនាយក សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
ហេង ធីតា
នាយក សេវាកម្មហិរញ្ញវត្ថុបុគ្គល
ហុង ស្រីនួន
នាយក រតនាគារ
ដែន ដារ៉ុទ្ធ
នាយក ព័ត៌មានវិទ្យា
ហេង រ៉ុទ្ធី
នាយក ហិរញ្ញវត្ថុ
លី សោភា
នាយក នីតិកម្ម និងជាលេខាធិការក្រុមហ៊ុន
ហេង តូរ៉ង់
ប្រធាន គ្រប់គ្រងហានិភ័យ (លេខាធិការ)

អ្នកអញ្ជើញចូលរួម៖
ខៀវ ឡានីន
ប្រធាន សវនកម្ម
អ៊ិន រ៉ានសុភា
មន្ត្រីប្រតិបត្តិតាម
ទីប្រឹក្សាមកពីស៊ីអាយអ៊ីមប៊ី ហ្គ្រុប
តាមការអនុម័តពីក្រុមប្រឹក្សាភិបាល

គណៈកម្មាធិការឥណទានកម្ពុជា

Yew Wan Kup
អគ្គនាយក (ប្រធាន)
ប៊ុន យ៉ីន
អគ្គនាយករង និងនាយក សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
ហេង ធីតា
នាយក សេវាកម្មហិរញ្ញវត្ថុបុគ្គល
គឿន វ៉ូឡូនា
ប្រធាន គ្រប់គ្រងឥណទាន
John Chuah Keat Kong
ទីប្រឹក្សាឥណទាន សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
Sue Kok Tseuy Shan
ទីប្រឹក្សាឥណទាន សេវាកម្មហិរញ្ញវត្ថុបុគ្គល
ហេង រ៉ុទ្ធី
នាយក ហិរញ្ញវត្ថុ
លី សោភា
នាយក នីតិកម្ម និងលេខាធិការ ក្រុមហ៊ុន

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និង ទ្រព្យអកម្ម

Yew Wan Kup
អគ្គនាយក (ប្រធាន)
Sasi Komanthakkal
តំណាងនាយកគ្រប់គ្រងហានិភ័យ
ប៊ុន យ៉ីន
អគ្គនាយករង និងនាយក សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
ហេង ធីតា
នាយក សេវាកម្មហិរញ្ញវត្ថុបុគ្គល
ហេង រ៉ុទ្ធី
នាយក ហិរញ្ញវត្ថុ
ហេង តូរ៉ង់
ប្រធាន គ្រប់គ្រងហានិភ័យ
ហុង ស្រីនួន
នាយក រតនាគារ

គណៈកម្មាធិការគ្រប់គ្រង

Yew Wan Kup
អគ្គនាយក (ប្រធាន)
ប៊ុន យ៉ីន
អគ្គនាយករង និងនាយក សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
ហេង ធីតា
នាយក សេវាកម្មហិរញ្ញវត្ថុបុគ្គល
ហេង រ៉ុទ្ធី
នាយក ហិរញ្ញវត្ថុ
អ៊ុំ ចិន្តាភក្តី
នាយក ធនធានមនុស្ស
ដែន ដារ៉ុទ្ធ
នាយក ព័ត៌មានវិទ្យា
លី សោភា
នាយក នីតិកម្ម និងជា លេខាធិការក្រុមហ៊ុន (លេខាធិការ)
ប៉ុក នីវ៉ាល់យ
ប្រធាន ទីផ្សារ និង ទំនាក់ទំនង
ហុង ស្រីនួន
នាយក រតនាគារ
ហេង តូរ៉ង់
ប្រធាន គ្រប់គ្រងហានិភ័យ

អ្នកអញ្ជើញចូលរួម៖
ខៀវ ឡានីន
ប្រធាន សវនកម្ម
អ៊ិន រ៉ានសុភា
មន្ត្រីប្រតិបត្តិតាម

លេខាធិការក្រុមហ៊ុន

លី សោភា
Datin Rossaya Mohd Nashir

លេខចុះបញ្ជី

Co.1935E/2010

ការិយាល័យចុះបញ្ជី

អគារលេខ ២០អាបេ មហាវិថី ព្រះនរោត្តម កែងផ្លូវ១១៨
សង្កាត់ ផ្សារចាស់ រាជធានីភ្នំពេញ ១២២០៣
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ៩៨៨០៨៨
ទូរសារ៖ +៨៥៥ ២៣ ៩៨៨០៩៩
គេហទំព័រ៖ www.cimbbank.com.kh

សវនការ

PricewaterhouseCoopers (Cambodia) Ltd.
អគារលេខ ៣៥ មហាវិថីព្រះសីហនុ ខណ្ឌចំការមន
រាជធានីភ្នំពេញ ១២២១០
ប្រអប់សំបុត្រលេខ ១១៨៧
ទូរស័ព្ទ៖ +៨៥៥ ២៣ ២១៨០៨៦
ទូរសារ៖ +៨៥៥ ២៣ ២១១៥៩៤

ប្រវត្តិរូបសង្ខេបរបស់

ក្រុមប្រឹក្សាភិបាល

DATO' SHAARANI IBRAHIM
ប្រធានក្រុមប្រឹក្សាភិបាល/អភិបាលឯករាជ្យមិនប្រតិបត្តិ

- លោកមានអាយុ ៦៣ឆ្នាំ ជាជនជាតិម៉ាឡេស៊ី។
- ត្រូវបានតែងតាំងជាអភិបាលនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០។
- បានចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន ០៤លើក ក្នុងឆ្នាំ២០១២។
- ជាប្រធានគណៈកម្មាធិការហានិភ័យ។
- ជាសមាជិកគណៈកម្មាធិការសវនកម្ម។

Dato' Shaarani Ibrahim បានទទួលសញ្ញាបត្របរិញ្ញាបត្រជំនាញទំនាក់ទំនងអន្តរជាតិ ពីសាកលវិទ្យាល័យម៉ាឡាយ៉ា ក្នុងឆ្នាំ១៩៧៣។

ចាប់តាំងពីខែមករា ឆ្នាំ២០០៩ មក Dato' Shaarani Ibrahim ត្រូវបានតែងតាំងជាអភិបាលឯករាជ្យនៃធនាគារ ស៊ីអាយអិមប៊ីថៃ ហើយក៏ជាសមាជិកគណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការផងដែរ។ ចាប់ពីខែកញ្ញា ឆ្នាំ២០១០ Dato' Shaarani Ibrahim ក៏ត្រូវបានតែងតាំងជាអភិបាលឯករាជ្យនៃសម្ព័ន្ធជ្រាហ្គនអន្តរជាតិ (DGI) ប្រចាំនៅប្រទេសសិង្ហបុរី ដែលនៅទីនោះលោកក៏ជាប្រធានគណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ និងជាសមាជិកគណៈកម្មាធិការសវនកម្ម។ Dato' Shaarani Ibrahim ក៏ជាអភិបាលនៃសាកលវិទ្យាល័យពូត្រាម៉ាឡេស៊ី (UPM) ចាប់តាំងពីខែមករា ឆ្នាំ២០១១ មកផងដែរ។ ក្រៅពីនេះ លោកក៏ជាប្រធានគណៈកម្មាធិការសវនកម្ម និងជាសមាជិកគណៈកម្មាធិការវិនិយោគនៃសាកលវិទ្យាល័យនេះទៀតផង។

មុនពេលចូលបម្រើការងារក្នុងវិស័យឯកជន Dato' Shaarani ជាប្រធានការិយាល័យរដ្ឋបាល និងសេវាកម្មការទូតរបស់រដ្ឋាភិបាលម៉ាឡេស៊ី និងបានបម្រើការងារនៅក្នុងក្រសួងការបរទេសចាប់តាំងពីឆ្នាំ១៩៧៣ មកម្ល៉េះ ហើយលោកបានទទួលបន្ទុកការងារផ្សេងៗគ្នាជាច្រើនក្នុងអំឡុងពេល ៣៥ឆ្នាំកន្លងមកនេះ។

ក្នុងអំឡុងពេលបម្រើការងារនៅក្រសួងការបរទេស Dato' Shaarani ក៏បានបំពេញមុខងារជាឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំនៅសាធារណរដ្ឋអ៊ីយរ៉ាន់ គីសស្ថានពីឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៩ និងជាឯកអគ្គរាជទូតប្រទេសម៉ាឡេស៊ីប្រចាំនៅព្រះរាជាណាចក្រអេស្ប៉ាញ ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៥ និងជាឯកអគ្គរាជទូតប្រទេសម៉ាឡេស៊ីប្រចាំនៅព្រះ-រាជាណាចក្រថៃពីឆ្នាំ២០០៥ ដល់ ឆ្នាំ២០០៨ ផងដែរ។

DATO' WIRA ZAINAL ABIDIN MAHAMAD ZAIN
អភិបាលឯករាជ្យមិនប្រតិបត្តិ

- លោកមានអាយុ ៦៣ឆ្នាំ ជាជនជាតិម៉ាឡេស៊ី។
- ត្រូវបានតែងតាំងជាអភិបាល នៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០។
- បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន ០៤ដង ក្នុងឆ្នាំ ២០១២។
- ជាសមាជិកគណៈកម្មាធិការសវនកម្ម។

Dato' Wira Zainal បានទទួលសញ្ញាបត្របរិញ្ញាបត្រជំនាញទំនាក់ទំនងអន្តរជាតិពីសកលវិទ្យាល័យម៉ាឡាយ៉ា។ Dato' Wira Zainal គឺជាអភិបាលឯករាជ្យមិនប្រតិបត្តិនៃក្រុមហ៊ុនម៉ាឡាយ៉ាន ផ្លាវអ័រ ម៉ៀលបើហាដ (Malayan Flour Mills)។ មុនពេលកាន់តំណែងនេះ លោកគឺជាតំណាងស្ថិតិទីអចិន្ត្រៃយ៍អាស៊ានទីមួយរបស់ប្រទេសម៉ាឡេស៊ីប្រចាំសាធារណរដ្ឋតណ្ហូនេស៊ី ពីខែមីនា ឆ្នាំ២០០៩ ដល់ខែកក្កដា ឆ្នាំ២០០៩។

Dato' Wira Zainal បានបម្រើការងារនៅក្រសួងការបរទេសចាប់តាំងពីឆ្នាំ១៩៧៣ មកម្ល៉េះ ហើយលោកបានទទួលបន្ទុកលើការងារផ្សេងៗជាច្រើនក្នុងអំឡុងពេល ៣៩ឆ្នាំកន្លងមកនេះ នៅក្នុងវិស័យសាធារណៈ។ ចាប់តាំងពីខែមិថុនា ឆ្នាំ២០១០ មក លោកក៏ត្រូវបានតែងតាំងជាប្រេសិតពិសេសរបស់នាយករដ្ឋមន្ត្រីម៉ាឡេស៊ី ប្រចាំប្រទេសអាហ្ហ្គានីស្ថានផងដែរ។

នៅក្នុងអាជីពរបស់លោកក្នុងអំឡុងពេល ៤០ឆ្នាំ រហូតដល់បច្ចុប្បន្ន ដែលលោកបានបម្រើការងារឱ្យរដ្ឋាភិបាលម៉ាឡេស៊ី លោកធ្លាប់ទទួលបានការតែងតាំងជាឯកអគ្គរាជទូតម៉ាឡេស៊ី ប្រចាំប្រទេសប្រេស៊ីល វៀតណាម និងតណ្ហូនេស៊ី។ លោកក៏ធ្លាប់បំពេញមុខងារជាអគ្គនាយកទីមួយនៃមជ្ឈមណ្ឌលប្រឆាំងភេវរកម្មតំបន់អាស៊ីអាគ្នេយ៍របស់ប្រទេសម៉ាឡេស៊ី ដែលមានមូលដ្ឋាននៅកូឡាឡាំពួរផងដែរ។ លោកក៏ធ្លាប់ទទួលបានការតែងតាំងជាភារធារីម៉ាឡេស៊ីប្រចាំទីក្រុងតេអេរ៉ង់ ប្រទេសអ៊ីរ៉ង់ ជាអគ្គកុងស៊ុលម៉ាឡេស៊ីប្រចាំទីក្រុង អាប៊ីយដៃប៊ីនៃចក្រភពអារ៉ាប់រួម ជាអគ្គកុងស៊ុលម៉ាឡេស៊ីប្រចាំទីក្រុងជេដា ប្រទេសអារ៉ាប់ប៊ីសាអ៊ូឌីត និងជាអគ្គកុងស៊ុលម៉ាឡេស៊ីប្រចាំទីក្រុងវ៉ាន់ឃូវ៉ែ ប្រទេសកាណាដាផងដែរ។

GOH NAN KIOH
អភិបាលឯករាជ្យមិនប្រតិបត្តិ

- លោកមានអាយុ ៥៨ឆ្នាំ ជាជនជាតិម៉ាឡេស៊ី។
- ត្រូវបានតែងតាំងជាអភិបាលនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០។
- បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន ០៣ដង ក្នុងឆ្នាំ២០១២។
- ជាប្រធានគណៈកម្មាធិការសវនកម្ម។
- ជាសមាជិកគណៈកម្មាធិការហានិភ័យ។

បណ្ឌិត ម៉ី កល្យាណ
អភិបាលឯករាជ្យមិនប្រតិបត្តិ

- លោកមានអាយុ ៥៩ឆ្នាំ ជាជនជាតិខ្មែរ ។
- បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ ។
- បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន ០២ ដង ក្នុងចំណោមកិច្ចប្រជុំ ២ដង ដែលត្រូវចូលរួមនៅឆ្នាំ២០១២។
- ជាប្រធានគណៈកម្មាធិការសវនកម្ម។

លោក Goh Nan Kioh បានទទួលបរិញ្ញាបត្រសេដ្ឋកិច្ចពីសាកលវិទ្យាល័យម៉ាឡាយ៉ា។ លោក Goh Nan Kioh គឺជាសហគ្រិនដ៏មានកេរ្តិ៍ឈ្មោះ និងជោគជ័យម្នាក់ដែលបានវិនិយោគលើអាជីវកម្មជាច្រើននៅតាមបណ្តាប្រទេសនានា។

លោក Goh Nan Kioh គឺជាអភិបាលមិនឯករាជ្យមិនប្រតិបត្តិ ហើយជាប្រធានក្រុមហ៊ុនមេហ្គាហ្វើសឧរធ្លង់ស៊ីនបើហាដ (Mega First Corporation Berhad) នាពេលបច្ចុប្បន្ននេះ។ លោកក៏ជាប្រធាននាយកប្រតិបត្តិនៃសម្ព័ន្ធខេមប្រ្ហេ (Cambrew Group) ដែលជាក្រុមហ៊ុនផលិតស្រាបៀរ និងភេសជ្ជៈផ្សេងៗផងដែរ។ លោកក៏ជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ភើល រីវើ ថាយអើ លីមីតធីត (Pearl River Tyre (Holding) Limited) ជាក្រុមហ៊ុនផលិតសំបកកង់ ដែលបានចុះបញ្ជីចូលទីផ្សារមូលបត្រហុងកុងផងដែរ (Hong Kong Stock Exchange)។

បណ្ឌិត ម៉ី កល្យាណ បានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ពីសាកលវិទ្យាល័យកូបេ ប្រទេសជប៉ុន នៅឆ្នាំ១៩៨៤។ បន្ទាប់មក លោកបានទទួលការបណ្តុះបណ្តាលវគ្គជំនាញរយៈពេលខ្លីស្តីពីការអភិវឌ្ឍពីទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិ ធនាគារពិភពលោក និងសាកលវិទ្យាល័យហាវ៉ីដ (Harvard) ។

បច្ចុប្បន្ន លោកគឺជាទីប្រឹក្សាជាន់ខ្ពស់នៃស្ថាប័នជាច្រើនរបស់រាជរដ្ឋាភិបាលកម្ពុជា រួមទាំងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ដែលជាទីប្រឹក្សាសេដ្ឋកិច្ចរបស់នាយករដ្ឋមន្ត្រីផងដែរ។ មុនពេលចូលបម្រើតួនាទីទាំងនេះ លោកធ្លាប់បានបំពេញការងារជាអ្នកសេដ្ឋកិច្ចជាន់ខ្ពស់សម្រាប់កម្មវិធីសហប្រតិបត្តិការរបស់ UN/FAO-ធនាគារពិភពលោកប្រចាំនៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី អស់រយៈពេល ២០ឆ្នាំ។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយលើផ្នែកអភិវឌ្ឍសេដ្ឋកិច្ចក្នុងពិភពលោក ហើយលោកក៏បានធ្វើទស្សនកិច្ច និងបំពេញការងារនៅតាមបណ្តាប្រទេសចំនួនប្រហែលជា ១០០ នៅទូទាំងពិភពលោកផងដែរ។ នៅពាក់កណ្តាលទសវត្សឆ្នាំ១៩៨០ លោកក៏ជាមន្ត្រីហិរញ្ញវត្ថុរបស់សាជីវកម្ម Kanematsu Gosho ដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្ម នៅទីក្រុងអូសាកា និងទីក្រុងតូក្យូផងដែរ។

បណ្ឌិត ម៉ី កល្យាណ មានក្តីសប្បាយរីករាយដែលបានត្រឡប់មកប្រទេសកម្ពុជាវិញ បន្ទាប់ពីលោកបានរស់នៅបរទេសអស់រយៈពេល ៣៥ឆ្នាំមកហើយ។ ជាមួយនឹងបទពិសោធន៍ និងចំណេះដឹងដ៏ទូលំទូលាយដែលទទួលបានពីគ្រប់ទិសទីនៅជុំវិញពិភពលោក លោកមានកិត្តិយសយ៉ាងខ្លាំងក្នុងការចូលរួមចំណែកជួយអភិវឌ្ឍប្រទេសកម្ពុជា ទាំងក្នុងវិស័យឯកជន និងវិស័យសាធារណៈ។ លោកមាន ជំនឿថាការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ គឺជាគន្លឹះដ៏សំខាន់មួយដែលនាំប្រទេសកម្ពុជាឈានទៅរកការអភិវឌ្ឍ និងភាពជោគជ័យបាន។

PETER ENGLAND
អភិបាលមិនឯករាជ្យមិនប្រតិបត្តិ

- លោកមានអាយុ ៥២ឆ្នាំ ជាជនជាតិអូស្ត្រាលី។
- បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១។
- បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន ០៤ដង ក្នុងឆ្នាំ២០១២។

YEW WAN KUP
អភិបាលមិនឯករាជ្យប្រតិបត្តិ និងជាអគ្គនាយក

- លោកមានអាយុ ៥៤ឆ្នាំ ជាជនជាតិម៉ាឡេស៊ី។
- បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០។
- បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន ០៤ដង នៅឆ្នាំ២០១២។
- ជាសមាជិកគណៈកម្មាធិការហានិភ័យ ។

លោក Peter England បានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម (ឯកទេសរៀបចំផែនការហិរញ្ញវត្ថុបុគ្គល) ពីសាកលវិទ្យាល័យយ៉ូនលេនខាងត្បូង (University of Southern Queensland) ប្រទេសអូស្ត្រាលី ។

លោក Peter England គឺជានាយកសេវាកម្មហិរញ្ញវត្ថុបុគ្គលនៅ ស៊ីអាយអិមបី ហ្ស្គ្រុប។ លោកទទួលបន្ទុកលើការគ្រប់គ្រងទូទៅ និងការធ្វើប្រតិបត្តិការហិរញ្ញវត្ថុ នៃអាជីវកម្មរបស់ធនាគារ ស៊ីអាយអិមបី នៅប្រទេសម៉ាឡេស៊ី សម្រាប់អតិថិជនជាបុគ្គល និងសហគ្រាសខ្នាតតូច។ លោកក៏គ្រប់គ្រងលើការអភិវឌ្ឍផ្នែកសេវាកម្មហិរញ្ញវត្ថុបុគ្គលក្នុងប្រទេសសិង្ហបុរី និងប្រទេសកម្ពុជា ព្រមទាំងគ្រប់គ្រងលើផ្នែកធានារ៉ាប់រង និងសេវាកម្មធនាគារពិសេសសម្រាប់អតិថិជនបុគ្គលប្រចាំតំបន់ទាំងមូលផងដែរ។

លោក Peter ទទួលខុសត្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអាជីវកម្ម ការអភិវឌ្ឍផលិតផល ការគ្រប់គ្រងឥណទាន និងប្រតិបត្តិការធនាគារតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប។ ក្រុមការងាររបស់លោក Peter ទទួលខុសត្រូវក្នុងការរៀបចំផលិតផល និង សេវាកម្មរបស់ធនាគារ។

លោក Peter មានបទពិសោធន៍ការងារជាង ៣០ឆ្នាំ លើគ្រប់ផ្នែកនៃសេវាកម្មហិរញ្ញវត្ថុបុគ្គល និងការគ្រប់គ្រងទ្រព្យសម្បត្តិ ដែលក្នុងនោះរយៈពេល ១៦ឆ្នាំចុងក្រោយនេះ លោកបានបំពេញការងារនៅក្នុងតំបន់អាស៊ី។ មុនពេលចូលបម្រើការងារនៅ ស៊ីអាយអិមបី ហ្ស្គ្រុប លោកធ្លាប់ធ្វើជានាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល នៅស្ថាប័នធនាគារធំពីររបស់ប្រទេសម៉ាឡេស៊ី។

លោក Yew Wan Kup បានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតចំនួន ២ ពីសាកលវិទ្យាល័យម៉ាឡាយ៉ានៃប្រទេសម៉ាឡេស៊ី ដែលក្នុងនោះរួមមានអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម និងអនុបណ្ឌិតផ្នែកព័ត៌មានវិទ្យា។ លោក Yew ក៏ទទួលបានបរិញ្ញាបត្រ វិទ្យាសាស្ត្រផ្នែករៀបចំសំណង់ផ្ទះ អគារ (ស្ថាបត្យកម្ម) ពីសាកលវិទ្យាល័យសេនម៉ាឡេស៊ី (Universiti Sains Malaysia) នៃប្រទេសម៉ាឡេស៊ីផងដែរ ។

លោក គឺជាអគ្គនាយករបស់ធនាគារ ស៊ីអាយអិមបី ភីអិលស៊ី។ លោកបានចូលបម្រើការងារដំបូងនៅស៊ីអាយអិមបី ហ្ស្គ្រុប ក្នុងឆ្នាំ២០០៨ ដោយទទួលបន្ទុកគ្រប់គ្រងលើកម្មវិធី ពង្រីកបណ្តាញប្រតិបត្តិការបុត្រសម្ព័ន្ធនៅក្នុងតំបន់តំណ្ហូចិន។

លោក Yew បានចូលបង្កើត និងបម្រើការងារនៅក្នុងធនាគារ ស៊ីអាយអិមបី ភីអិលស៊ី នៅប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ២០១០ មកម្ល៉ះ ហើយក្នុងនាមជាអគ្គនាយក លោកបានចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំយុទ្ធសាស្ត្រ ដើម្បីធ្វើឱ្យមានកំណើនអាជីវកម្មសម្រាប់ធនាគារ។ លោក Yew ទទួលខុសត្រូវលើការគ្រប់គ្រងដឹកនាំប្រតិបត្តិការធនាគារទាំងមូលនៅក្នុងប្រទេសកម្ពុជា ។

លោក Yew មានតួនាទីជាអ្នករៀបចំគោលនយោបាយ ផែនការ និងដឹកនាំការធ្វើប្រតិបត្តិការប្រចាំថ្ងៃ រៀបចំយុទ្ធសាស្ត្រ ផលិតផល និងសេវាកម្ម ព្រមទាំងផែនការពង្រីកបណ្តាញសាខាចែកចាយបន្ថែមពីលើការលើកកម្ពស់ដំណើរការអភិវឌ្ឍ ប្រតិបត្តិការ អាជីវកម្មទាំងមូល។

មុននឹងមកកាន់តួនាទីបច្ចុប្បន្នរបស់លោកនៅធនាគារ ស៊ីអាយអិមបី ភីអិលស៊ី លោក Yew ធ្លាប់បម្រើការងារជាទីប្រឹក្សាឱ្យធនាគារ ស៊ីអាយអិមបី ថៃ ដោយធ្វើការចែករំលែកនូវបទពិសោធន៍ល្អៗលើការអនុវត្តប្រតិបត្តិការអាជីវកម្ម និងការរៀបចំ ប្រតិបត្តិការយុទ្ធសាស្ត្រស្នូល និងការគ្រប់គ្រងការចំណាយ និងការវិនិយោគប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។

លោក Yew មានបទពិសោធន៍ការងារជាង ៣០ឆ្នាំ ក្នុងវិស័យសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម។ មុនពេលចូលបម្រើការងារនៅក្នុងធនាគារ ស៊ីអាយអិមបី លោកធ្លាប់បម្រើការងារឱ្យធនាគារម៉ាឡេស៊ីមួយ ដោយទទួលបន្ទុកជាអ្នកគ្រប់គ្រងលើប្រតិបត្តិការក្រៅប្រទេសចំនួន ១២ទីតាំងនៅទូទាំងពិភពលោក។ នៅក្នុងធនាគារម៉ាឡេស៊ីមួយផ្សេងទៀតមុនពេលលោកចូលបម្រើការងារនៅ ស៊ីអាយអិមបី លោកក៏ជាអ្នកចូលរួមយ៉ាងសកម្ម ក្នុងការរៀបចំទិសដៅយុទ្ធសាស្ត្រគ្រប់គ្រងប្រតិបត្តិការរបស់ធនាគារដែលមានសាខាចំនួន ១៨០ និងមានបុគ្គលិកចំនួន ២.៣០០ នាក់ផងដែរ។

ប្រវត្តិរូបសង្ខេបរបស់

លេខាធិការក្រុមហ៊ុនរួម

DATIN ROSSAYA MOHD NASHIR

លេខាធិការក្រុមហ៊ុនរួម

Datin Rossaya Mohd Nashir គឺជាលេខាធិការធនាគាររបស់ស៊ីអាយអិមប៊ី ហ្គ្រុប។ លោកស្រី ក៏មានតួនាទីជាលេខាធិការរួម នៅក្នុងគណៈកម្មាធិការផ្សេងៗផងដែរ រួមមានដូចជា គណៈកម្មាធិការគ្រប់គ្រងរបស់ធនាគារ ស៊ីអាយអិមប៊ី ហ្គ្រុប ហើយលោកស្រី ក៏ជាអភិបាលនៃក្រុមហ៊ុនបុត្រសម្ព័ន្ធមួយចំនួនរបស់ធនាគារ ស៊ីអាយអិមប៊ី ហ្គ្រុប ផងដែរ។ លោកស្រីទទួលខុសត្រូវលើការគ្រប់គ្រង និងចាត់ចែងកិច្ចការរបស់ក្រុមប្រឹក្សាភិបាល ដោយគោរពតាមច្បាប់ បទប្បញ្ញត្តិ និងក្រមខ័ណ្ឌអភិបាលកិច្ច ព្រមទាំងជួយគាំទ្រដល់ក្រុមប្រឹក្សាភិបាល និងភាគីពាក់ព័ន្ធសំខាន់ៗរបស់ខ្លួនទាំងនៅក្នុងប្រទេសម៉ាឡេស៊ី និងប្រតិបត្តិការប្រចាំតំបន់របស់ក្រុមហ៊ុនមេ ផងដែរ។

លោកស្រីមានបទពិសោធន៍ធ្វើការងារជាលេខាធិការក្រុមហ៊ុនជាង ១៨ឆ្នាំមកហើយ។ លោកស្រីបានចាប់ផ្តើមអាជីពការងារដំបូង នៅក្រុមហ៊ុន ថាម អេនជីនេរីង ហ្គ្រុប (Time Engineering Group) ហើយក្រោយមកបានបម្រើការងារឱ្យក្រុមហ៊ុន តើម៉ូដាឡាន ណេសិនណល ប៊ីហាដ (Permodalan National Berhad) ក្នុងនាមជាលេខាធិការក្រុមហ៊ុនមួយរូបនៃក្រុមហ៊ុនបុត្រសម្ព័ន្ធមួយចំនួននៃក្រុមហ៊ុននេះ។ លោកស្រីបានចូលរួមបម្រើការងារឱ្យធនាគារស៊ីអាយអិមប៊ី ហ្គ្រុប ចាប់តាំងពីឆ្នាំ ២០០២ នៅក្នុងផ្នែកសេវាកម្មនីតិកម្មក្រុមហ៊ុន មុនពេលបង្កើតនាយកដ្ឋានលេខាធិការក្រុមហ៊ុនក្នុងឆ្នាំ ២០០៤ ។

លោកស្រីមានអាយុ ៤៤ឆ្នាំ ហើយបានទទួលបរិញ្ញាបត្រនីតិសាស្ត្រ ជំនាញនីតិពាណិជ្ជកម្មពីសាកលវិទ្យាល័យ Conventry នៃចក្រភពអង់គ្លេស។ ក្នុងចំណោមសកម្មភាពសង្គមរបស់លោកស្រី លោកស្រី Datin Rossaya បានបម្រើការងារក្នុងវេទិកាពិភាក្សាអំពីទម្លាប់អនុវត្តក្រុមហ៊ុនរបស់គណៈកម្មការក្រុមហ៊ុនប្រទេសម៉ាឡេស៊ី ជាតំណាងអ្នកការពារអត្ថប្រយោជន៍ឱ្យក្រុមហ៊ុនដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាលក្រោមកិច្ចឧបត្ថម្ភរបស់កាហ្សាណា ណេសិនណល ប៊ីហាដ (Khazanah Nasional Berhad) ហើយលោកស្រីក៏ជាសមាជិកនៃវិទ្យាស្ថានលេខាធិការ និងរដ្ឋបាលជំនាញនៃប្រទេសម៉ាឡេស៊ីផងដែរ។ លោកស្រី មានចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការតស៊ូមតិជំរុញការចូលរួមរបស់ស្ត្រីក្នុងក្រុមប្រឹក្សាភិបាល ហើយនាពេលថ្មីៗនេះ លោកស្រីបានចូលរួមក្នុងក្រុមវិជ្ជាជីវៈមួយ "ស្ត្រី និងតួនាទីស្ត្រីក្នុងក្រុមប្រឹក្សាភិបាល" ដែលរៀបចំឡើងដោយអង្គភាពផ្តល់ និងគ្រប់គ្រងប្រតិបត្តិការ និងវិទ្យាស្ថាន NAM សម្រាប់ការផ្តល់អំណាចដល់ស្ត្រី។

លី សោភា

លេខាធិការក្រុមហ៊ុនរួម

លោកស្រី លី សោភា គឺជាលេខាធិការក្រុមហ៊ុនរួមរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។ លោកស្រី គឺជាលេខាធិការមួយរូបនៃក្រុម-ប្រឹក្សាភិបាល និងគណៈកម្មាធិការសវនកម្មរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។ លោកស្រី ក៏ជាលេខាធិការនៃគណៈកម្មាធិការគ្រប់គ្រង និងជាសមាជិកក្នុងគណៈកម្មាធិការផ្សេងៗទៀត របស់ធនាគារផងដែរ រួមមានគណៈកម្មាធិការហានិភ័យ និងគណៈកម្មាធិការតណទានកម្ពុជាជាដើម។

មុនពេលចូលបម្រើការងារក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រី សោភា ធ្លាប់បម្រើការងារជាជំនួយការនាយកប្រតិបត្តិជាន់ខ្ពស់នីតិកម្ម នៅក្នុងធនាគារដ៏ធំមួយក្នុងប្រទេសកម្ពុជា។ ក្នុងពេលតែមួយក្រៅពីការបន្តការសិក្សា លោកស្រីបានបម្រើការងារផ្នែកនីតិកម្ម និងលេខាធិការក្រុមហ៊ុនអស់រយៈពេល ០៦ឆ្នាំ នៅកន្លែងការងារពីមុនរបស់លោកស្រី។

លោកស្រី លី សោភា បានទទួលបរិញ្ញាបត្រនីតិសាស្ត្រពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅឆ្នាំ២០០៤ ហើយក្នុងឆ្នាំដដែលនេះ លោកស្រីក៏ទទួលបានបរិញ្ញាបត្រគណនេយ្យពីវិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រង (បច្ចុប្បន្នជាសាកលវិទ្យាល័យពុទ្ធិសាស្ត្រ) ផងដែរ ។ នៅឆ្នាំ២០០៧ លោកស្រីថែមទាំងបានទទួលសញ្ញាបត្រអនុបណ្ឌិតជំនាញនីតិឯកជនពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផងដែរ។

Step up
CIMB BANK

ប្រវត្តិរូបសង្ខេបរបស់

គណៈកម្មាធិការគ្រប់គ្រង

ប៊ុន យីន
អគ្គនាយករងធនាគារ
នាយក សេវាកម្មហិរញ្ញវត្ថុពាណិជ្ជ

លោក ប៊ុន យីន គឺជាអគ្គនាយករងធនាគារស៊ីអាយអ៊ីមប៊ីកីអ៊ីលស៊ី។ លោកជានាយក នាយកដ្ឋានសេវាកម្ម ហិរញ្ញវត្ថុពាណិជ្ជដែលមានភារកិច្ចគ្រប់គ្រងចំណែកទីផ្សារអតិថិជន សហគ្រាសធុនតូចនិងមធ្យម និងសហគ្រាសនានារបស់ធនាគារផងដែរ។ នៅក្នុងនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជ លោកត្រូវទទួលខុសត្រូវ ចំពោះយុទ្ធសាស្ត្រផ្នែកលក់ការវិភាគឥណទាន និងការគ្រប់គ្រងអតិថិជន ព្រមទាំងអភិវឌ្ឍផលិតផលនិងសេវាកម្មធុរកិច្ចសំខាន់ៗផងដែរ។ ក្នុងឋានៈជាអគ្គនាយករងនៃធនាគារស៊ីអាយអ៊ីមប៊ី កីអ៊ីលស៊ី លោក ប៊ុន យីន ចូលរួមយ៉ាងសកម្មក្នុងការរក្សាទំនាក់ទំនងដ៏ល្អជាមួយអតិថិជនក្នុងតំបន់ ក៏ដូចជាអាជ្ញាធរមូលដ្ឋានផងដែរ។ លោកបានដឹកនាំយ៉ាងសកម្ម រាល់ទស្សនវិស័យធុរកិច្ចរបស់ធនាគារ ដោយបង្កើតប្រភពទុនប្រកបដោយគុណភាព និងធានាតុល្យភាពឥណទានទៀតផង។

ជាមួយនឹងបទពិសោធន៍ផ្នែកធនាគារពាណិជ្ជជាង ៣០ឆ្នាំ លោក ប៊ុន យីន ត្រូវបានទទួលស្គាល់ថាជាបុគ្គលដ៏សំខាន់មួយរូប ក្នុងវិស័យធនាគារកម្ពុជានៅប្រទេសកម្ពុជា។ លោកមានបទពិសោធន៍យ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្នុងវិស័យធនាគារ ហើយបានបង្កើតបណ្តាញយ៉ាងទូលំទូលាយតាមសហគ្រាស និងក្នុងវិស័យធនាគារក្នុងប្រទេសកម្ពុជា។ លោកបានដឹកនាំប្រកបដោយជោគជ័យក្នុងវិស័យនានារួមទាំងការគ្រប់គ្រងឥណទាន ហិរញ្ញប្បទានពាណិជ្ជកម្ម ប័ណ្ណឥណទាន ព្រមទាំងបានចូលរួមចំណែកក្នុងតួនាទីជាទីប្រឹក្សាដ៏សំខាន់ នៅក្នុងដំណាក់កាលបង្កើតធនាគារស៊ីអាយអ៊ីមប៊ី កីអ៊ីលស៊ី នៅប្រទេសកម្ពុជាផងដែរ។

ហេង ធីតា
នាយក សេវាកម្មហិរញ្ញវត្ថុបុគ្គល

លោកស្រី ហេង ធីតា ទទួលបន្ទុកគ្រប់គ្រងទូទៅលើផ្នែកសេវាកម្មហិរញ្ញវត្ថុបុគ្គលរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ហើយភារៈកិច្ចរបស់លោកស្រីរួមមាន ការអភិវឌ្ឍន៍ផលិតផល ការលក់ និងការចែកចាយ ក៏ដូចជាការគ្រប់គ្រងឥណទានទៅលើអតិថិជនបុគ្គល។ លើសពីនេះ លោកស្រី ធីតា ជាអ្នកបង្កើតយុទ្ធសាស្ត្រអាជីវកម្ម និងទទួលខុសត្រូវទៅលើសេវាកម្មហិរញ្ញវត្ថុ Preferred Banking និងសេវាកម្មហិរញ្ញវត្ថុបែបបច្ចេកវិទ្យា (Technology Banking)។

លោកស្រីធីតា ចាប់ផ្តើមអាជីពការងារជាបុគ្គលិកផ្នែកលក់នៅក្នុងក្រុមហ៊ុននាំចេញ/នាំចូល និងបន្ទាប់មកបម្រើការងារផ្នែកទំនាក់ទំនងអតិថិជននៅក្នុងក្រុមហ៊ុនផ្សាយពាណិជ្ជកម្មអស់រយៈពេល ៤ឆ្នាំ មុននឹងលោកស្រីចេញទៅបន្តការសិក្សានៅប្រទេសជប៉ុន។ នៅពេលលោកស្រីវិលត្រលប់មកក្នុងប្រទេសកម្ពុជាវិញ លោកស្រីបានចូលបម្រើការងារជាអ្នកផ្តល់ប្រឹក្សាដល់ធនាគារពិភពលោក ក្នុងកម្មវិធីមេគង្គអភិវឌ្ឍឯកជន (Mekong Private Development Facility) ផ្នែកជំនួយបច្ចេកទេស ដល់សហគ្រាសខ្នាតតូច និងមធ្យម។

មុនចូលបម្រើការងារក្នុងធនាគារស៊ីអាយអ៊ីមប៊ី លោកស្រី ធីតា ធ្លាប់បម្រើការងារក្នុងធនាគារធំមួយកន្លែងនៅប្រទេសកម្ពុជា អស់រយៈពេល ៧ឆ្នាំ ដែលក្នុងអំឡុងពេលនោះលោកស្រី បម្រើការងារក្នុងមុខតំណែងជាអ្នកគ្រប់គ្រងលើផ្នែកផ្សេងៗចាប់ពីប្រធានផ្នែកទីផ្សារ ប្រធានផ្នែកគាំទ្រសេវាកម្មហិរញ្ញវត្ថុបុគ្គល ហើយបន្ទាប់មកជាប្រធានផ្នែកគ្រប់គ្រងបណ្តាញសាខា។

លោកស្រី ធីតា ទទួលបានបរិញ្ញាប័ត្រពីសកលវិទ្យាល័យជាតិគ្រប់គ្រង (NUM) នៅទីក្រុងភ្នំពេញ និងបន្ទាប់មកទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកទីផ្សារ និងអាជីវកម្មនៅសាកលវិទ្យាល័យអន្តជាតិនៃប្រទេសជប៉ុន។

ហុង ស្រីនួន
នាយក រតនាគារ

ភារកិច្ចចម្បងរបស់កញ្ញា ហុង ស្រីនួន គឺត្រូវចាត់ចែងមូលនិធិលើតារាងតុល្យការរបស់ធនាគារ និងទិញ-លក់រូបិយវត្ថុអន្តរជាតិ ព្រមទាំងផលិតផលវិនិយោគផ្សេងៗដែលផ្សារភ្ជាប់នឹងទីផ្សារ។

អំឡុងពេលបម្រើកិច្ចការងារ កញ្ញាត្រូវរក្សាទំនាក់ទំនងជាប្រចាំជាមួយអតិថិជន ទាំងបុគ្គល និងជាក្រុមហ៊ុន។ ទន្ទឹមនឹងនោះ កញ្ញា ស្រីនួន បានបង្កើន និងក្លាយទៅជាអ្នកជំនាញ លើផ្នែកផលិតផលវិនិយោគ ផ្សារភ្ជាប់នឹងទីផ្សារតារាងតុល្យការ និស្សន្ទវត្ថុ ទីផ្សាររូបិយវត្ថុ និងការគ្រប់គ្រងមូលនិធិរបស់ធនាគារ។

មុននឹងចូលបម្រើការងារនៅក្នុងធនាគារស៊ីអាយអ៊ីមប៊ី កីអ៊ីលស៊ី កញ្ញា ស្រីនួន គឺជាអ្នកវិភាគហិរញ្ញវត្ថុ ក្នុងនាយកដ្ឋានហិរញ្ញវត្ថុនៃធនាគារពហុជាតិមួយនៅកម្ពុជា។ បទពិសោធន៍ការងារ និងទេពកោសល្យរបស់កញ្ញា ស្រីនួន បានជួយឱ្យកញ្ញា មានចំណេះដឹងជ្រៅជ្រះលើផ្នែកទីផ្សារហិរញ្ញវត្ថុ និងការអភិវឌ្ឍយុទ្ធសាស្ត្រ ការវិភាគហិរញ្ញវត្ថុ ការធ្វើផែនការថវិកា និងការគ្រប់គ្រងការផ្លាស់ប្តូរផងដែរ។

កញ្ញា ស្រីនួន បានបញ្ចប់ការសិក្សាអនុបណ្ឌិតផ្នែកគណនេយ្យពីសាកលវិទ្យាល័យមែលបិន ប្រទេសអូស្ត្រាលី បរិញ្ញាបត្រអប់រំពីវិទ្យាស្ថានភាសាបរទេស និងបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។ ហើយបច្ចុប្បន្នកញ្ញាកំពុងបន្តការសិក្សាយកសញ្ញាបត្រពីមជ្ឈមណ្ឌលផ្តល់អាជ្ញាប័ណ្ណចក្រភពអង់គ្លេសនៅប្រទេសកម្ពុជា ដើម្បីក្លាយជាសមាជិក ACCA (សមាគមគណនេយ្យករជំនាញ) ដែលជាស្ថាប័នសកលសម្រាប់គណនេយ្យជំនាញ។

លោក ហេង រ៉ុទ្ធី
នាយក ហិរញ្ញវត្ថុ

លោក ហេង រ៉ុទ្ធី ជានាយក នាយកដ្ឋានហិរញ្ញវត្ថុ។ លោកជាសមាជិកដ៏សំខាន់មួយរូបក្នុងគណៈគ្រប់គ្រងរបស់ធនាគារ ស៊ីអាយអិមប៊ី។ ភារកិច្ចចម្បងរបស់លោករួមមានការគ្រប់គ្រងមុខងារហិរញ្ញវត្ថុ និងរៀបចំផែនការ ចាត់ចែង ដឹកនាំ និងគ្រប់គ្រងបុគ្គលិកក្រោមបង្គាប់ក្នុងការរៀបចំ អនុវត្ត និងថែរក្សាគោលការណ៍ និងនិតិវិធីអនុវត្តផ្សេងៗសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ រៀបចំផែនការថវិកា គណនេយ្យពន្ធដារ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងការគ្រប់គ្រងយុទ្ធសាស្ត្ររបស់ធនាគារ។

លោក រ៉ុទ្ធី ក៏ត្រូវត្រួតពិនិត្យប្រព័ន្ធ និងរបាយការណ៍គណនេយ្យ ការគ្រប់គ្រងហិរញ្ញវត្ថុ និងការរៀបចំផែនការអាជីវកម្ម ព្រមទាំងដើរតួនាទីជាអ្នកសម្របសម្រួលជាមួយក្រុមហ៊ុនមេ នៅប្រទេសម៉ាឡេស៊ីផងដែរ។ មុនពេលចូលបម្រើការងារនៅ ធនាគារស៊ីអាយអិមប៊ី ភីអិលស៊ី លោកធ្លាប់មានបទពិសោធន៍រយៈពេល ៨ឆ្នាំ ផ្នែកការងារគ្រប់គ្រងហិរញ្ញវត្ថុ ហើយលោកធ្លាប់ជានាយករងនាយកដ្ឋានហិរញ្ញវត្ថុ នៅធនាគារដ៏ធំមួយនៅកម្ពុជា។

លោក ហេង រ៉ុទ្ធី ទទួលបានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្មក្នុងវិស័យហិរញ្ញវត្ថុ ហើយបច្ចុប្បន្នលោកកំពុងបន្តការសិក្សាថ្នាក់គណនេយ្យករជាន់ខ្ពស់ (ACCA: Association of Chartered Certified Accountants) នៅមជ្ឈមណ្ឌលដែលទទួលបានអាជ្ញាប័ណ្ណពីចក្រភពអង់គ្លេសនៅក្នុងប្រទេសកម្ពុជា។

អ៊ុំ ចិន្តាភក្តី
នាយក ធនធានមនុស្ស

លោកស្រី អ៊ុំ ចិន្តាភក្តី ទទួលបានបរិញ្ញាប័ត្រគ្រប់គ្រងពាណិជ្ជកម្មពីវិទ្យាស្ថានជាតិគ្រប់គ្រង។ មុនចូលបម្រើការនៅធនាគារ ស៊ីអាយអិមប៊ី លោកស្រីធ្លាប់បម្រើការងារក្នុងតួនាទី ជាអ្នកគ្រប់គ្រងផ្នែកធនធានមនុស្ស នៅក្នុងវិស័យជាច្រើនតាំងពីឆ្នាំ ២០០២។ ជានាយក ធនធានមនុស្ស លោកស្រីមានតួនាទីទទួលខុសត្រូវផ្នែកសេវាកម្មធនធានមនុស្ស ដែលរួមមានការស្វែងរក គ្រប់គ្រង និងរក្សាបុគ្គលិកដែលមានជំនាញ និងទេពកោសល្យខ្ពស់។

ក្នុងនាមជាផ្នែកមួយនៃគណៈគ្រប់គ្រង លោកស្រីជានាថានាយកដ្ឋានធុរកិច្ចទាំងអស់ដើរទន្ទឹមគ្នា ក្នុងគោលបំណងអភិវឌ្ឍន៍ធនធានមនុស្ស ការថែរក្សាបុគ្គលិកសំខាន់ៗដែលមានទេពកោសល្យ ក៏ដូចជារក្សានូវវប្បធម៌ដែលមានសមិទ្ធផលការងារខ្ពស់។ លើសពីនេះទៅទៀត លោកស្រីក៏ធ្វើការគ្រប់គ្រងទៅលើប្រាក់បំណាច់របស់បុគ្គលិក ទំនាក់ទំនងបុគ្គលិក ព្រមទាំងសកម្មភាពសម្រាកកំសាន្ត និងការបង្កើនភាពស្និទ្ធស្នាលរបស់បុគ្គលិកផងដែរ។ ការជម្រុញអោយបុគ្គលិកមានសមត្ថភាពខ្ពស់ គឺជាតួនាទីដ៏សំខាន់មួយរបស់លោកស្រី ហើយលោកស្រីក៏ធានាថា បុគ្គលិកគ្រប់រូបសុទ្ធតែទទួលបានការបណ្តុះបណ្តាលអោយមានវប្បធម៌រៀនសូត្រពីគ្នាតាមរយៈកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍនៅក្នុងប្រទេស និងតំបន់។

លី សោភា
នាយក នីតិកម្ម និងលេខាធិការក្រុមហ៊ុន

លោកស្រី លី សោភា មានតួនាទីជានាយកនីតិកម្ម និងលេខាធិការនៃធនាគារស៊ីអាយអិមប៊ីភីអិលស៊ី ចាប់តាំងពីថ្ងៃចាប់ផ្តើមប្រតិបត្តិការដំបូងរបស់ធនាគារនៅខែវិច្ឆិកា ឆ្នាំ២០១០ មកម្លេះ។

លោកស្រី សោភា ទទួលបន្ទុកលើការងារនីតិកម្ម និងលេខាធិការរបស់ធនាគារ។ លោកស្រី គឺជាលេខាធិការរួមមួយរូបនៃក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការសវនកម្មរបស់ធនាគារស៊ីអាយអិមប៊ី ភីអិលស៊ី។ លោកស្រីក៏ជាលេខាធិការនៃគណៈកម្មាធិការគ្រប់គ្រង និងជាសមាជិកក្នុងគណៈកម្មាធិការផ្សេងៗទៀតរបស់ធនាគារផងដែរ រួមមាន គណៈ-កម្មាធិការហានិភ័យ និងគណៈកម្មាធិការឥណទានកម្ពុជាជាដើម។

មុនពេលចូលបម្រើការងារក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រី សោភា ធ្លាប់បម្រើការងារជាជំនួយការនាយកប្រតិបត្តិជាន់ខ្ពស់ នីតិកម្ម នៅក្នុងធនាគារដ៏ធំមួយក្នុងប្រទេសកម្ពុជា។ ក្នុងពេលតែមួយក្រៅពីការបន្តការសិក្សា លោកស្រីបានបម្រើការងារផ្នែកនីតិកម្ម និងលេខាធិការក្រុមហ៊ុន អស់រយៈពេល ០៦ឆ្នាំ នៅកន្លែងការងារពីមុនរបស់លោកស្រី។ បន្ទាប់ពីចូលបម្រើការងារនៅក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រី សោភា ក៏ទទួលបន្ទុកលើការងារប្រតិបត្តិតាមរបស់ធនាគារផងដែរ រហូតដល់ការងារប្រតិបត្តិតាមនេះ ត្រូវបានផ្តាច់ចេញនៅខែកក្កដា ឆ្នាំ២០១២។

លោកស្រី លី សោភា បានទទួលបរិញ្ញាបត្រនីតិសាស្ត្រពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅឆ្នាំ២០០៤ ហើយក្នុងឆ្នាំដដែលនេះ លោកស្រីក៏ទទួលបានបរិញ្ញាបត្រគណនេយ្យពីវិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រង (បច្ចុប្បន្នជាសាកលវិទ្យាល័យពុទ្ធិសាស្ត្រ) ផងដែរ ។ នៅឆ្នាំ២០០៧ លោកស្រីថែមទាំងបានទទួលសញ្ញាបត្រអនុបណ្ឌិតជំនាញនីតិឯកជនពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផងដែរ។

ដែន ដាវុទ្ធ
នាយក ព័ត៌មានវិទ្យា

លោក ដែន ដាវុទ្ធ ចូលបម្រើការងារនៅក្នុងធនាគារស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី ជានាយក នាយកដ្ឋានព័ត៌មានវិទ្យា។

លោកត្រួតពិនិត្យលើការគ្រប់គ្រងព័ត៌មានវិទ្យា ដឹកនាំបច្ចេកវិទ្យារបស់ធនាគារ និងអនុវត្តយុទ្ធសាស្ត្របច្ចេកវិទ្យា ផ្សេងៗដើម្បីធានាថាការតម្លើងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា គឺស្របតាមទិសដៅរបស់នាយកដ្ឋានព័ត៌មានវិទ្យា និងប្រតិបត្តិការ របស់ក្រុមហ៊ុនមេ។

លោកក៏គ្រប់គ្រងផ្នែកប្រតិបត្តិការព័ត៌មានវិទ្យា និងថែទាំហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាផងដែរ ដើម្បីទ្រទ្រង់ដល់នាយកដ្ឋានហិរញ្ញវត្ថុ បុគ្គល នាយកដ្ឋានពាណិជ្ជ ព្រមទាំងសេវាកម្មអេឡិចត្រូនិចផ្សេងៗទៀត ។

លោក ដែន ដាវុទ្ធ បានទទួលបរិញ្ញាបត្រចំនួន ២ គឺបរិញ្ញាបត្រវិស្វកម្ម និងវិទ្យាសាស្ត្រកុំព្យូទ័រ និងអក្សរសាស្ត្រអង់គ្លេសលើជំនាញទំនាក់ទំនងអាជីព ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ប៉ុក នីវីល័យ
ប្រធាន ទីផ្សារ និងទំនាក់ទំនង

ក្នុងនាមជានាយកទីផ្សារ និងទំនាក់ទំនង លោកស្រី ប៉ុក នីវីល័យ ទទួលបន្ទុកលើរាល់សកម្មភាពទីផ្សាររបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី ក៏ដូចជាទទួលខុសត្រូវក្នុងការកំណត់ទិសដៅ និងអនុវត្តនូវសកម្មភាពទំនាក់ទំនងទាំងខាងក្នុង និងខាងក្រៅរបស់ធនាគារ ដែលរួមមានការគ្រប់គ្រងស្លាកសញ្ញា និងទីផ្សារទំនាក់ទំនងសាធារណៈ ការគ្រប់គ្រងបណ្តាញសារព័ត៌មាន ការទំនាក់ទំនងផ្ទៃក្នុង ការរៀបចំព្រឹត្តការណ៍នានា និងការឧបត្ថម្ភផ្សេងៗ ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ព្រមទាំងសកម្មភាពទំនួលខុសត្រូវសាធារណៈ។

លោកស្រី នីវីល័យ បានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យបៀលប្រាយ ប្រទេសកម្ពុជា។ មុននឹងចូលបម្រើការងារនៅក្នុងធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី លោកស្រីមានបទពិសោធន៍ជាង ១០ឆ្នាំ ក្នុងផ្នែកលក់ និងទីផ្សារ ព្រមទាំងធ្លាប់បម្រើការងារក្នុងវិស័យផ្សេងៗជាច្រើន ចាប់ពីផ្នែកផ្សព្វផ្សាយពាណិជ្ជកម្ម និងវិស្វកម្ម រហូតដល់ផ្នែកទូរគមនាគមន៍។

ហេង តូរ៉ង់
ប្រធាន គ្រប់គ្រងហានិភ័យ

លោក ហេង តូរ៉ង់ មានតួនាទីជាជំនួយការនាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យ និងជាលេខាធិការនៃគណៈកម្មាធិការហានិភ័យចាប់តាំងពីចូលបម្រើការងារនៅក្នុងធនាគារស៊ី អាយអ៊ីមប៊ី ភីអ៊ីលស៊ី កាលពីខែកញ្ញាឆ្នាំ២០១០មក។

ភារកិច្ចរបស់លោក រួមមានការវិភាគវាយតម្លៃ និងពិនិត្យតាមដានស្ថានភាពហានិភ័យឥណទាន ទីផ្សារ និងសន្ទនិយភាព ព្រមទាំងបញ្ហាហានិភ័យប្រតិបត្តិការ ដែលកើតមានឡើងនៅក្នុងដំណើរការប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ។ លោកក៏ជាអ្នកតំណាងឱ្យនាយកដ្ឋានគ្រប់គ្រងហានិភ័យនៅក្នុងកិច្ចប្រជុំ គណៈកម្មាធិការរបស់ធនាគារ និងកិច្ចការទំនាក់ទំនងទូទៅជាប្រចាំ ជាមួយផ្នែកគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុនមេ ដោយបានរៀបចំរបាយការណ៍អំពីបញ្ហាហានិភ័យផ្សេងៗ សម្រាប់ដាក់ជូនគណៈកម្មាធិការ ហានិភ័យ ដើម្បីធ្វើការពិចារណា និង/ឬសម្រាប់សុំការអនុម័តពីក្រុមប្រឹក្សាភិបាលរបស់ធនាគារ។

មុនពេលចូលបម្រើការងារនៅក្នុងធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី លោក ហេង តូរ៉ង់ ធ្លាប់ធ្វើជាប្រធានផ្នែកគ្រប់គ្រងហានិភ័យសាច់ប្រាក់ និងទីផ្សារនៅធនាគារធំមួយនៅក្នុងប្រទេសកម្ពុជា។ ក្រៅពីជំនាញផ្នែកគ្រប់គ្រងហានិភ័យនេះ លោកក៏មានបទពិសោធន៍រយៈពេល ៣ឆ្នាំ ផ្នែកគ្រប់គ្រងសាច់ប្រាក់នៅនាយកដ្ឋានរតនាគារផងដែរ។

លោក ហេងតូរ៉ង់ បានទទួលបរិញ្ញាបត្រគណនេយ្យពីវិទ្យាស្ថានជាតិគ្រប់គ្រង និងសញ្ញាបត្រថ្នាក់អនុបណ្ឌិត ផ្នែកហិរញ្ញវត្ថុពីសាកលវិទ្យាល័យបញ្ញាសាស្ត្រនៃកម្ពុជាកាលពីឆ្នាំ២០១១។ បច្ចុប្បន្នលោកកំពុងបន្តការសិក្សា យកសញ្ញាបត្រពីមជ្ឈមណ្ឌលគ្រប់គ្រងអាជ្ញាប័ណ្ណចក្រភពអង់គ្លេសនៅប្រទេសកម្ពុជា ដើម្បីក្លាយជាសមាជិក ACCA (សមាគមគណនេយ្យករជំនាញ) ដែលជាស្ថាប័នសកលសម្រាប់គណនេយ្យជំនាញ។

បណ្តាញ សាខា

សាខានរោត្តមខាងជើង
ផ្ទះលេខ ២០ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ

សាខានរោត្តមខាងត្បូង
ផ្ទះលេខ ២១៦ មហាវិថីព្រះនរោត្តម
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ

សាខាមហាវិថីព្រះសីហនុ
ផ្ទះលេខ ៥៧អេហ្ វ មហាវិថីព្រះសីហនុ
សង្កាត់ចតុមុខ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ

សាខាមហាវិថីម៉ៅសេទុង
ផ្ទះលេខ ១៨៧ មហាវិថីម៉ៅសេទុង
សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន
រាជធានីភ្នំពេញ

សាខាអូឡាំពិក
ផ្ទះលេខ ២០១ ផ្លូវវ៉ាហារឡាលនេរហ៉ារុ
សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក
រាជធានីភ្នំពេញ

សាខាក្រុងព្រះសីហនុ
ផ្ទះលេខ ៩០ ផ្លូវឯកភាព
សង្កាត់លេខ៤ ខណ្ឌមិត្តភាព
ខេត្តព្រះសីហនុ

សាខាក្រុងសៀមរាប
ផ្ទះលេខ ៣៨-៤០ ផ្លូវស៊ីវ៉ាន
សង្កាត់ស្វាយដើមគរ ខណ្ឌសៀមរាប
ខេត្តសៀមរាប

សាខាផ្សារហេងលី
ផ្ទះលេខ១២Z ផ្លូវ២៧១
សង្កាត់ទឹកល្អក់ III ខណ្ឌទួលគោក
រាជធានីភ្នំពេញ

សាខាទួលគោក
ផ្ទះលេខ ១៥0F២DE0E0១ ផ្លូវ ២៨៩
សង្កាត់បឹងកក់ I ខណ្ឌទួលគោក
រាជធានីភ្នំពេញ

សាខាក្រុងបាត់ដំបង
ផ្ទះលេខ ៩៨-៩៩ ភូមិព្រៃកមហាទេព
សង្កាត់ស្វាយពរក្រុងបាត់ដំបង
ខេត្តបាត់ដំបង

សាខាក្រុងកំពង់ចាម
ភូមិ៤ សង្កាត់វាលវង់
ក្រុងកំពង់ចាមខេត្តកំពង់ចាម

មជ្ឈមណ្ឌល CIMB Preferred
សាខានរោត្តមខាងជើង
ផ្ទះលេខ ២០ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ

សាខានរោត្តមខាងត្បូង
ផ្ទះលេខ ២១៦ មហាវិថីព្រះនរោត្តម
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ

សាខាអូឡាំពិក
ផ្ទះលេខ ២០១ ផ្លូវវ៉ាហារឡាលនេរហ៉ារុ
សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក
រាជធានីភ្នំពេញ

សាខាក្រុងសៀមរាប
ផ្ទះលេខ ៣៨-៤០ ផ្លូវស៊ីវ៉ាន
សង្កាត់ស្វាយដើមគរ ខណ្ឌសៀមរាប
ខេត្តសៀមរាប

ទីតាំងម៉ាស៊ីន ATMs
Naga World
ផ្លូវសម្តេចតេជោ
រាជធានីភ្នំពេញ

T&C សម្តេចប៉ាន
ផ្ទះលេខ ៣៥-៣៧ ផ្លូវសម្តេចប៉ាន(២១៤)
រាជធានីភ្នំពេញ

U-Care មាត់ទន្លេ
មហាវិថី សម្តេចសុធារស
រាជធានីភ្នំពេញ

អាគារពាណិជ្ជកម្ម HSC (Linex)
អាគារលេខ ៣៧ABCD មហាវិថីសហព័ន្ធរុស្សី
សង្កាត់មនោរម្យ ខណ្ឌ៧មករា
រាជធានីភ្នំពេញ

មជ្ឈមណ្ឌលពាណិជ្ជកម្ម បុណ្ណា
មហាវិថីព្រះនរោត្តម
រាជធានីភ្នំពេញ

សណ្ឋាគារ និងភោជនីយដ្ឋាន Royal Inn
ផ្ទះលេខ ១២៨D៦.៧ មហាវិថីសុធារស
រាជធានីភ្នំពេញ

Brown Coffee
ផ្ទះលេខ ០១ ផ្លូវលេខ ៩៨ ឈៀងវិថីព្រះស៊ីសុវត្ថិ
រាជធានីភ្នំពេញ

U-Care កម្ពុជាក្រោម
ផ្ទះលេខ ៨៩៩E0 ផ្លូវ ១២៨
សង្កាត់ទឹកល្អក់ I
រាជធានីភ្នំពេញ

វិទ្យាស្ថាន ELT
ផ្ទះលេខ ២២A ផ្លូវ ២៧៣
សង្កាត់បឹងកក់ I ខណ្ឌទួលគោក
រាជធានីភ្នំពេញ

The Place
ផ្ទះលេខ ១២៣ ផ្លូវ ៩៣
សង្កាត់ប៉ឹងកេងកង I ខណ្ឌចំការមន
រាជធានីភ្នំពេញ

របាយការណ៍
ហិរញ្ញវត្ថុ

មាតិកា

៦០ របាយការណ៍ក្រុមប្រឹក្សាភិបាល

៦២ របាយការណ៍សវនករឯករាជ

៦៣ របាយការណ៍ហិរញ្ញវត្ថុ

៦៧ កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

៩៧ កំណត់សម្គាល់ស្តីពីការអនុវត្តតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា

ប្រពៃណីតម្បាញសូត្រ ដែលមានអាយុកាលរាប់រយឆ្នាំមកហើយនៅ
ក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើឡើងដោយថ្វីដៃតម្បាញដ៏ចំណាន
ដើម្បីបង្កើតបានជាក្រណាត់សូត្រដ៏ប្រណីត ដូចគ្នានេះដែរ នៅឯ
ធនាគារ ស៊ីអាយអ៊ីមប៊ី យើងមានជំនាញសម្រាប់ជួយឲ្យជំនួញរបស់
អតិថិជនយើងមានភាពរីកចម្រើន។

ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី (ហៅកាត់ថា "ធនាគារ") សូមដាក់ជូនរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដែលបានធ្វើសវនកម្មរួចហើយ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ។

អំពីធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចាប់ផ្តើមដំណើរការអាជីវកម្មនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ហើយធនាគារគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលកាន់កាប់ទាំងស្រុងដោយ CIMB Bank Berhad ជាធនាគារដែលមានអាជ្ញាប័ណ្ណចុះបញ្ជីអាជីវកម្មនៅប្រទេសម៉ាឡេស៊ី ។ ក្រុមហ៊ុន CIMB Group Holdings Berhad ដែលបានចុះបញ្ជីជាក្រុមហ៊ុនសាជីវកម្មនៅប្រទេសម៉ាឡេស៊ីគឺជាក្រុមហ៊ុនមេធំជាងគេ ។

សកម្មភាពអាជីវកម្មចម្បងៗ

សកម្មភាពអាជីវកម្មចម្បងៗរបស់ធនាគារ គឺការផ្តល់សេវាកម្មផ្នែកធនាគារជាច្រើនប្រភេទ និងសេវាកម្មដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

លទ្ធផលប្រតិបត្តិការ និងភាគលាភ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ត្រូវបានបង្ហាញក្នុងរបាយការណ៍លទ្ធផលនៅលើទំព័រទី៨ ។

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ មិនមានការប្រកាស ឬការបង់ភាគលាភទេ ។

ទ្រព្យសកម្មរយៈពេលខ្លី និងទ្រព្យសកម្មរយៈពេលវែង

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មរយៈពេលខ្លី និងទ្រព្យសកម្មរយៈពេលវែងក្រៅពីបំណុល ដែលទំនងជាមិនអាចទទួលបានមកវិញនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ទៅតាមតម្លៃនៅក្នុងបញ្ជីរបស់ធនាគារ ត្រូវបានកាត់បន្ថយឱ្យស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បាននៅលើទីផ្សារជាក់ស្តែង ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើការយល់ដឹងដ៏សុក្រឹតបំផុត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ និងកាលៈទេសៈណាមួយ ដែលបណ្តាលឱ្យតម្លៃទ្រព្យសកម្មរយៈពេលខ្លី និងទ្រព្យសកម្មរយៈពេលវែងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានតម្លៃមិនត្រឹមត្រូវជាសារវន្តនោះឡើយ ។

បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ :

ក. មិនមានបន្ទុកណាមួយលើទ្រព្យសកម្មរបស់ធនាគារដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ការិយបរិច្ឆេទមក និង

ខ. មិនមានបំណុលយថាភាពណាមួយរបស់ធនាគារដែលបានកើតឡើងចាប់តាំងពីដំណាច់ការិយបរិច្ឆេទមក ក្រៅពីដំណើរការអាជីវកម្មធនាគារធម្មតានោះទេ ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់ធនាគារ ដែលត្រូវបានទាមទារឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងរយៈពេល ១២ខែបន្ទាប់ពីដំណាច់ការិយបរិច្ឆេទ ដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃផុតកំណត់សងនោះទេ ។

ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានកំហុសឆ្គងជាសារវន្តនោះឡើយ ។

គណនីដែលមានលក្ខណៈមិនធម្មតា

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារសម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានរងនូវការប៉ះពាល់ជាសារវន្តពីគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតានោះទេ ។ តាមយោបល់របស់ក្រុមប្រឹក្សាភិបាលក្នុងចន្លោះពេលរវាងដំណាច់ការិយបរិច្ឆេទហិរញ្ញវត្ថុមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតា ដែលទំនងជាមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះ ត្រូវបានធ្វើឡើងនោះទេ ។

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលនៅបម្រើការក្នុងអំឡុងការិយបរិច្ឆេទ និងរហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម :

- លោក Dato' Shaarani Ibrahim (ប្រធានក្រុមប្រឹក្សាភិបាល)
- លោក Dato' Wira Zainal Abidin Bin Mahamad Zain
- លោក Goh Nan Kioh
- បណ្ឌិត ម៉ី កល្យាណ
- លោក Peter William England
- លោក Yew Wan Kup

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងគិតត្រឹមដំណាច់ការិយបរិច្ឆេទនេះ ធនាគារពុំបានចូលរួមជាភាគីក្នុងកិច្ចព្រមព្រៀងណាមួយ ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ឱ្យទទួលបានផលប្រយោជន៍ ដោយការទិញយកភាគហ៊ុន ឬលិខិតបំណុលពីសាមីធនាគារ ឬក្រុមហ៊ុនដទៃទៀតទេ ។

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់របស់ធនាគារ បានទទួល ឬមានសិទ្ធិនឹងបានទទួលនូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងរវាងធនាគារ និងសមាជិកក្រុមប្រឹក្សាភិបាល ឬរវាងធនាគារ និងក្រុមហ៊ុន ដែលសមាជិកក្រុមប្រឹក្សាភិបាលជាសមាជិក ឬជាមួយក្រុមហ៊ុន ដែលសមាជិកក្រុម-ប្រឹក្សាភិបាល មានផលប្រយោជន៍ផ្ទែកហិរញ្ញវត្ថុជាសារវន្ត ក្រៅពីប្រតិបត្តិការផ្សេងៗ ដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ តម្រូវឱ្យក្រុមប្រឹក្សាភិបាល :

១. ប្រើប្រាស់គោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន បន្ទាប់ពីនោះ ត្រូវអនុវត្តគោលការណ៍ទាំងនោះឱ្យបានស៊ីសង្វាក់គ្នា។
២. អនុវត្តតាមគោលការណ៍ណែនាំ ដែលចេញដោយធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញឱ្យមានភាពត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
៣. រក្សាទុកបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។
៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្ទែកលើមូលដ្ឋាននិរន្តរភាពនៃអាជីវកម្ម លើកលែងតែមានករណីមិនសមរម្យ ក្នុងការសន្ទតថា ធនាគារអាចនឹងបន្តប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង
៥. ត្រួតពិនិត្យ និងដឹកនាំធនាគារ ដោយចូលរួមលើរាល់ការសម្រេចចិត្តសំខាន់ៗទាំងអស់ ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ធនាគារបានអនុវត្តតាមតម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។

ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំជាក្រុមប្រឹក្សាភិបាល បានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយ ដែលបានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ព្រមទាំងលទ្ធផលប្រតិបត្តិការ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា។

ចុះហត្ថលេខាដោយអនុលោម ទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

YEW WAN KUP

អគ្គនាយក

កាលបរិច្ឆេទ : ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣

សវនករឯករាជ

ជូនភាគទុនិកទាំងអស់របស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី (ហៅកាត់ថា "ធនាគារ") រួមមានតារាងតុល្យការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របាយការណ៍លទ្ធផលរបាយការណ៍បម្រែបម្រួលមូលធន និងរបាយ-ការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ឆ្នាំថ្ងៃ ទី៣១ ខែធ្នូ ឆ្នាំ២០១២ ព្រមទាំងសេចក្ដីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់ផ្សេងៗទៀត។

ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើ របាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមគោលការណ៍ណែនាំផ្សេងៗ ចេញដោយធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំ របាយការណ៍ហិរញ្ញវត្ថុមិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្ដាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញមតិលើ របាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដោយផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារស្តីពីសវនកម្មអន្តរជាតិនៃកម្ពុជា។ ស្តង់ដារទាំងនោះ តម្រូវឱ្យយើងខ្ញុំប្រតិបត្តិតាមក្រមសីលធម៌ ធ្វើផែនការសវនកម្ម និងធ្វើសវនកម្ម ដើម្បី ទទួលបានការធានាអះអាង ដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុពុំមានលក្ខណៈខុសឆ្គងជាសារវន្ត។

ការធ្វើសវនកម្មរួមមានការអនុវត្តនីតិវិធី ដើម្បីទទួលបាននូវភស្តុតាងសវនកម្ម អំពីចំនួនទឹកប្រាក់ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការជ្រើសរើសនីតិវិធីទាំងនេះ គឺអាស្រ័យលើការវិនិច្ឆ័យរបស់សវនករ រាប់ទាំងការវាយតម្លៃលើហានិភ័យនៃភាពខុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្ដាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង។ ក្នុងការវាយតម្លៃហានិភ័យទាំងនេះ សវនករ បានពិចារណាទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាព ដែលទាក់ទងទៅនឹងការរៀបចំ និងការបង្ហាញយ៉ាងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីរៀបចំ នីតិវិធីសវនកម្ម ដែលមានលក្ខណៈសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ ប៉ុន្តែពុំមានគោលបំណងបញ្ចេញមតិ ទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាពនោះទេ។ សវនកម្មក៏រាប់ទាំងការវាយតម្លៃនូវភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ដែលគណៈគ្រប់គ្រងបានធ្វើឡើង ក៏ដូចជាការវាយតម្លៃលើការបង្ហាញជាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងទទួលបានគឺមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ដែលជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

មតិយោបល់

តាមទស្សនៈរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ បានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ដោយអនុលោមទៅតាមគោលការណ៍ណែនាំផ្សេងៗរបស់ ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា។

ជ. PricewaterhouseCoopers (Cambodia) Ltd.

BENILDA C. FERNANDO

នាយក

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទ : ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២

តារាងតុល្យការ

	កំណត់សម្គាល់	២០១២ ដុល្លារអាមេរិក	២០១២ ពាន់រៀល	២០១១ ដុល្លារអាមេរិក	២០១១ ពាន់រៀល
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ		៧.៤៨៦.៩៤៤	២៩.៩១០.៣៤១	២.៩៧៧.១៨០	១២.០២៤.៨៣០
សមតុល្យនៅធនាគារកណ្តាល	៤	៥៥.៣៨១.៦៣៨	២២១.២៤៩.៦៤៤	៣២.៤២៦.២៥៥	១៣០.៩៦៩.៦៤៤
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ	៥	១១.៩២០.១៣៦	៤៧.៦២០.៩៤៣	៦.៥៨៩.៥៥៤	២៦.៦១៥.២០៩
ឥណទាន និងបុរេប្រទានអតិថិជន	៦	៨៣.៧៣៦.២៦១	៣៣៤.៥២៦.៣៦៣	៤១.៩៤២.៨២៩	១៦៩.៤០៧.០៨៦
ទឹកប្រាក់ត្រូវទារក្រុមហ៊ុនពាក់ព័ន្ធ	១២	៣៤.៨៧៥	១៣៩.៣២៦	១.៩០២	៧.៦៨២
ទ្រព្យសកម្មផ្សេងៗ	៧	១.០៥៣.៩៣១	៤.២១០.៤៥៥	៥០៦.៦៥៣	២.០៤៦.៣៧២
ទ្រព្យសម្បត្តិ និងបរិក្ខារ	៨	៤.៩០៧.០២៥	១៩.៦០៣.៥៦៥	៤.១៣៧.៣៩៩	១៦.៧១០.៩៥៥
ទ្រព្យសកម្មអរូបី	៩	១.០៦៥.៥៤៨	៤.២៥៦.៨៦៤	៩១៧.៩០៩	៣.៧០៧.៤៣៤
ទ្រព្យសកម្មសរុប		១៦៥.៥៨៦.៣៥៨	៦៦១.៥១៧.៥០១	៨៩.៤៩៩.៦៨១	៣៦១.៤៨៩.២១២
បំណុល និងមូលធន					
បំណុល					
ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ	១០	២៣.៤៤៥.៥០១	៩៣.៦៦៤.៧៧៦	៣.០៣១.២៤៥	១២.២៤៣.១៩៩
ប្រាក់បញ្ញើរបស់អតិថិជន	១១	៩៨.៣៦៣.២៣០	៣៩២.៩៦១.១០៤	៤៩.៦៣៤.៥៩៤	២០០.៤៧៤.១២៥
ទឹកប្រាក់ជំពាក់ក្រុមហ៊ុនពាក់ព័ន្ធ	១២	៤៤.៥៥៤	១៧៧.៩៩៣	៣៨៤.៥២៨	១.៥៥៣.១០៩
ទឹកប្រាក់ជំពាក់អ្នកផ្គត់ផ្គង់	១៣	៦៤៩.៤៧៣	២.៥៩៤.៦៤៥	៩៣៥.៨៣៤	៣.៧៧៩.៨៣៤
បំណុលពន្ធលើប្រាក់ចំណេញ		៦.៦៣០	២៦.៤៨៧	៣.១៦៩	១២.៨០០
បំណុលផ្សេងៗ	១៤	១១.៨៦៧.២៧៨	៤៧.៤០៩.៧៧៦	២.២៣៤.៨២០	៩.០២៦.៤៣៧
បំណុលសរុប		១៣៤.៣៧៦.៦៦៦	៥៣៦.៨៣៤.៧៨១	៥៦.២២៤.១៩០	២២៧.០៨៩.៥០៤
មូលធនភាគទុនិក					
ដើមទុន	១៥	៣៧.000.000	១៤៧.៨១៥.000	៣៧.000.000	១៤៩.៤៤៣.000
ខាតបង្គរ		(៥.៧៩០.៣០៨)	(២៣.១៣២.២៨០)	(៣.៧២៤.៥០៩)	(១៥.០៤៣.២៩២)
មូលធនភាគទុនិកសរុប		៣១.២០៩.៦៩២	១២៤.៦៨២.៧២០	៣៣.២៧៥.៤៩១	១៣៤.៣៩៩.៧០៨
បំណុល និងមូលធនភាគទុនិកសរុប		១៦៥.៥៨៦.៣៥៨	៦៦១.៥១៧.៥០១	៨៩.៤៩៩.៦៨១	៣៦១.៤៨៩.២១២

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២

របាយការណ៍លទ្ធផល

	កំណត់ សម្គាល់	សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ដុល្លារអាមេរិក	 ពាន់រៀល	សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ដុល្លារអាមេរិក	 ពាន់រៀល
ចំណូលការប្រាក់	១៦	៥.៣៩៨.៩០១	២១.៥៦៨.៦០៩	១.៦០១.១៣៤	៦.៤៦៦.៩៨០
ចំណាយការប្រាក់	១៦	(១.៧៤១.៧៥៣)	(៦.៩៥៨.៣០៣)	(៤៩៥.៩៥៨)	(២.០០៣.១៧៤)
ចំណូលការប្រាក់សុទ្ធ		៣.៦៥៧.១៤៨	១៤.៦១០.៣០៦	១.១០៥.១៧៦	៤.៤៦៣.៨០៦
ចំណូលកម្រៃនិងជើងសារ	១៧	៨០៦.០៧៧	៣.២២០.២៧៨	១៥៣.៤៩២	៦១៩.៩៥៤
ចំណាយផ្នែកបុគ្គលិក	១៨	(២.១៥០.៥៥៥)	(៨.៥៩១.៤៦៧)	(១.៥២៤.៣៧០)	(៦.១៥៦.៩៣០)
ចំណាយរំលស់ទ្រព្យសម្បត្តិនិងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី	៨ & ៩	(១.៨៥០.១៦៣)	(៧.៣៩១.៤០១)	(១.២១៨.១៤៧)	(៤.៩២០.០៩៦)
ចំណាយទូទៅ និងចំណាយរដ្ឋបាល	១៩	(២.១២១.៩៨០)	(៨.៤៧៧.៣១១)	(១.៣៥៨.៦៩២)	(៥.៤៨៧.៧៥៨)
ចំណូលប្រតិបត្តិការផ្សេងៗ		៧៨.៧០៥	៣១៤.៤២៧	១២.៦៥៤	៥១.១១១
សវិធានធនបំណុលសង្ស័យ	៦ (ក)	(៤២២.០២១)	(១.៦៨៥.៩៧៤)	(៤២៣.៨០០)	(១.៧១១.៧២៨)
ខាតមុនបង់ពន្ធលើប្រាក់ចំណេញ		(២.០០២.៧៨៩)	(៨.០០១.១៤២)	(៣.២៥៣.៦៨៧)	(១៣.១៤១.៦៤១)
ចំណាយពន្ធលើប្រាក់ចំណេញ	២០	(៦៣.០១០)	(២៥១.៧២៥)	(១៨.៥៧២)	(៧៥.០១២)
ខាតសុទ្ធក្នុងឆ្នាំ		(២.០៦៥.៧៩៩)	(៨.២៥២.៨៦៧)	(៣.២៧២.២៥៩)	(១៣.២១៦.៦៥៣)

របាយការណ៍បម្រែបម្រួលមូលធន

	ដើមទុន ដុល្លារអាមេរិក	ខាតបង្គរ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១			
គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១១	៣៧.000.000	(៤៥២.២៥0)	៣៦.៥៤៧.៧៥0
ខាតសុទ្ធក្នុងឆ្នាំ	-	(៣.២៧២.២៥៩)	(៣.២៧២.២៥៩)
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១	៣៧.000.000	(៣.៧២៤.៥0៩)	៣៣.២៧៥.៤៩១
សមមូលជាពាន់រៀល	១៤៩.៤៤៣.000	(១៥.0៤៣.២៩២)	១៣៤.៣៩៩.៧0៨
សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២			
គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១២	៣៧.000.000	(៣.៧២៤.៥0៩)	៣៣.២៧៥.៤៩១
ខាតសុទ្ធក្នុងឆ្នាំ	-	(២.0៦៥.៧៩៩)	(២.0៦៥.៧៩៩)
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២	៣៧.000.000	(៥.៧៩0.៣0៨)	៣១.២0៩.៦៩២
សមមូលជាពាន់រៀល	១៤៧.៨១៥.000	(២៣.១៣២.២៨0)	១២៤.៦៨២.៧២0

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២

របាយការណ៍លំហូរសាច់ប្រាក់

	កំណត់សម្គាល់	សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ដុល្លារអាមេរិក	ពាន់រៀល	សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ដុល្លារអាមេរិក	ពាន់រៀល
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ					
សាច់ប្រាក់បានពីប្រតិបត្តិការ	២១	៣១.៨៤៥.១៧៨	១២៨.៩៥២.២៤២	៤.៧៧៣.២៧៨	១៩.២៧៨.៩៩១
ការប្រាក់បានទទួល		៥.២០៩.៨៣២	២០.៨១៣.២៧៩	១.៤១៥.៥៩៨	៥.៧១៧.៦០០
ការប្រាក់បានបង់		(១.៤៣២.៣០៤)	(៥.៧២២.០៥៤)	(៣៥៤.៧០៥)	(១.៤៣២.៦៥៣)
ពន្ធលើប្រាក់ចំណេញបានបង់		(៥៩.៥៤៩)	(២៣៧.៨៩៨)	(១៥.៥៣១)	(៦២.៧៣០)
សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ		៣៥.៥៦៣.១៥៧	១៤៣.៨០៥.៥៦៩	៥.៨១៨.៦៤០	២៣.៥០១.២០៨
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ					
ទុនបម្រុងកាតព្វកិច្ចនៅធនាគារកណ្តាល		(៦.៣០០.០០០)	(២៥.១៦៨.៥០០)	(៥.៩៨៥.០០០)	(២៤.១៧៣.៤១៥)
ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ	៨	(២.០៤២.៩៧១)	(៨.១៦១.៦៦៩)	(៣.២៩៧.១១៣)	(១៣.៣១៧.០៣៩)
ការទិញទ្រព្យសកម្មអរូបី	៩	(៧២៤.៤៥៧)	(២.៨៩៤.២០៦)	(៣០៥.៦១២)	(១.២៣៤.៣៦៧)
សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ		(៩.០៦៧.៤២៨)	(៣៦.២២៤.៣៧៥)	(៩.៥៨៧.៧២៥)	(៣៨.៧២៤.៨២១)
កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ		២៦.៤៩៥.៧២៩	១០៧.៥៨១.១៩៤	(៣.៧៦៩.០៨៥)	(១៥.២២៣.៦១៣)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ		៣២.០៣៧.៩៨៩	១២៩.៤០១.៤៣៨	៣៥.៨០៧.០៧៤	១៤៥.១២៦.០៧១
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(៣.១៤០.៤២៩)	-	(៥០១.០២០)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ	២២	៥៨.៥៣៣.៧១៨	២៣៣.៨៤២.២០៣	៣២.០៣៧.៩៨៩	១២៩.៤០១.៤៣៨

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២

១. ព័ត៌មានទូទៅ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ក្រោមអាជ្ញាប័ណ្ណចុះបញ្ជីពាណិជ្ជកម្មលេខ Co.១៩៣៥E/ ២០១០ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ ចេញដោយក្រសួងពាណិជ្ជកម្ម ហើយធនាគារ បានចាប់ផ្តើមប្រតិបត្តិការនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។ ធនាគារត្រូវបានកាន់កាប់ ទាំងស្រុងដោយ CIMB Bank Berhad ជាធនាគារដែលមានអាជ្ញាប័ណ្ណចុះបញ្ជីពាណិជ្ជកម្ម នៅប្រទេសម៉ាឡេស៊ី ។ ធនាគារ CIMB Group Holdings Berhad ដែលបានចុះបញ្ជី ជាក្រុមហ៊ុនសាជីវកម្មនៅប្រទេសម៉ាឡេស៊ី ជាក្រុមហ៊ុនមេធំបំផុត ។

សកម្មភាពចម្បងៗរបស់ធនាគារ គឺការផ្តល់សេវាកម្មផ្នែកធនាគារជាច្រើនប្រភេទ និងសេវាកម្ម ដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ធនាគារ បានទទួលអាជ្ញាប័ណ្ណប្រតិបត្តិផ្នែកធនាគារ ចេញដោយធនាគារជាតិនៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០ ។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារលេខ ២0AB កែងមហាវិថីព្រះនរោត្តម និងផ្លូវលេខ ១១៨ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

ក្រុមប្រឹក្សាភិបាលបានអនុម័តឱ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ ។

២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗដែលបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ នេះ ត្រូវបានបង្ហាញដូចខាងក្រោម ។

២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំដោយអនុលោមទៅតាមគោលការណ៍ណែនាំផ្សេងៗចេញដោយធនាគារកណ្តាល និងស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS") ។ ក្នុងការអនុវត្តស្តង់ដារគណនេយ្យកម្ពុជា ធនាគារក៏បានប្រើប្រាស់ស្តង់ដារ របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនៃកម្ពុជា (ហៅកាត់ថា "CFRS") គឺ CFRS 7 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ : ការលាតត្រដាងព័ត៌មាន" ។ គោលការណ៍គណនេយ្យដែលបាន ប្រើប្រាស់ អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យដែលត្រូវបានគេទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ ។ របាយការណ៍ ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់ដោយអនុលោមទៅតាមយុត្តាធិការ ណាផ្សេង ក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ ។

ដូចនេះរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ សម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាបអំពី គោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដោយប្រើប្រាស់វិធីសាស្ត្រថ្លៃដើម ។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលអនុលោមទៅតាម CAS តម្រូវឱ្យប្រើប្រាស់ ការប៉ាន់ស្មាន និងការសន្មត ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ম និងបំណុល និងការលាតត្រដាង ទ្រព្យសកម្ম និងបំណុលយថាភាព គិតត្រឹមកាលបរិច្ឆេទរបាយការណ៍ ហិរញ្ញវត្ថុ និងប៉ះពាល់ ដល់ចំនួននៃចំណូល និងចំណាយដែលបានរាយការណ៍នៅក្នុង ការិយបរិច្ឆេទ ដែលបានរាយការណ៍នេះ ។ ទោះបីជាការប៉ាន់ស្មានទាំងនេះផ្អែកទៅលើ ការយល់ដឹងដ៏សុក្រឹតបំផុតរបស់គណៈគ្រប់គ្រងទៅលើព្រឹត្តិការណ៍ និងសកម្មភាព បច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់ស្តែងចុងក្រោយអាចនឹងខុសពីការប៉ាន់ស្មានទាំងនេះ ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់បំផុត ឬផ្នែកដែល ការសន្មត និងការប៉ាន់ស្មាន មានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវ បានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣ នៃរបាយការណ៍ហិរញ្ញវត្ថុ ។

២.២ ស្តង់ដារគណនេយ្យថ្មីៗ និងបំណែកស្រាយ

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានប្រកាសឱ្យប្រើប្រាស់ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទៅលើស្តង់ដារទាំងអស់ដែលបានបោះផ្សាយ ដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ រួមទាំងបំណែកស្រាយផ្សេងៗ និង វិសោធនកម្មដែលអាចកើតឡើងនៅកាលៈទេសៈណាមួយ ទៅលើស្តង់ដារនីមួយៗ ដោយការបន្ថែមពាក្យ "កម្ពុជា" នៅពីមុខស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិ (ហៅកាត់ថា "IFRS") ។ អង្គភាពដែលមានទំនួលខុសត្រូវសាធារណៈ ត្រូវ រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនស្របទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទ គណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ឬការិយបរិច្ឆេទគណនេយ្យ បន្ទាប់ពីនេះ ។ យោងតាមប្រកាសលេខ ០៨៦ ស.ហ.វ-ក.ជ.ត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ បានអនុម័តពន្យារការអនុវត្ត CIFRS សម្រាប់ត្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ រហូតដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ។

CIFRS ត្រូវមានការត្រួតពិនិត្យបន្តបន្ទាប់ទៀត ហើយអាចមានការកែសម្រួល ផ្សេងៗទៀត តាមរយៈគោលការណ៍ណែនាំក្នុងការបកស្រាយពីក្រុមប្រឹក្សាស្តង់ដារ អន្តរជាតិគណនេយ្យ (ហៅកាត់ថា "IASB") ដូចនេះស្តង់ដារនេះ អាចមានការកែប្រែ បន្ថែមទៀតនាពេលអនាគត ។

ធនាគារត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន អនុលោមតាម CIFRS សម្រាប់ ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ។ ការអនុវត្ត CIFRS នឹងបណ្តាលឱ្យមាន ផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ។ ធនាគារនឹងធ្វើការវាយតម្លៃអំពី ផលប៉ះពាល់ទាំងស្រុងក្នុងការអនុវត្ត CIFRS ហើយព័ត៌មានអំពី CIFRS នឹងត្រូវធ្វើ បច្ចុប្បន្នកម្មតាមការចាំបាច់ ប្រសិនបើមានការកែប្រែណាមួយកើតឡើង ។

២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

២.៣ រូបិយប័ណ្ណ

ក. រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយប័ណ្ណនៃប្រតិបត្តិការសេដ្ឋកិច្ចចម្បង ដែលធនាគារធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល") ។ របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងជារូបិយប័ណ្ណសម្រាប់បង្ហាញរបស់ធនាគារ ។

អនុលោមតាមប្រកាសលេខ ធ៧-០៧-១៦៤ប្រ.ក. ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ របស់ធនាគារកណ្តាល តារាងតុល្យការ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាប្តូរប្រាក់មធ្យមភាគផ្លូវការដែលកំណត់ដោយធនាគារកណ្តាលនាកាលបរិច្ឆេទរាយការណ៍ ដែល ១ ដុល្លារអាមេរិក ស្មើនឹង ៣.៩៩៥ រៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ : ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៣៩ រៀល) ។ តួលេខដែលបានប្តូរនេះ មិនត្រូវបានធ្វើសវនកម្មទេ ហើយមិនគួរបកស្រាយថាតួលេខនេះ ជាតួលេខសម្រាប់បង្ហាញដូចតួលេខជាប្រាក់ដុល្លារអាមេរិកនោះទេ ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់រៀល តាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ ។

ខ. ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ ។ ចំណេញ និងខាត ដែលបណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានាដែលកំណត់ជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរនាដំណាច់ឆ្នាំ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

២.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ គណនីសាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សមតុល្យដែលមានកាលកំណត់ដើមបីខែ ឬតិចជាង គិតពីថ្ងៃទទួលបានរាប់ទាំងសាច់ប្រាក់ក្នុងដៃ សមតុល្យមិនជាប់កម្រិត (non-restricted balance) នៅធនាគារកណ្តាល និងសមតុល្យនៅធនាគារផ្សេងៗ ។

២.៥ ឥណទាន និងបុរេប្រទានអតិថិជន

ឥណទាន និងបុរេប្រទានអតិថិជនទាំងអស់ត្រូវបានកត់ត្រាក្នុងតារាងតុល្យការ តាមចំនួនប្រាក់ដើម និងការប្រាក់ ដែលនៅមិនទាន់ទូទាត់ ដកចំនួនដែលបានជម្រះចេញពីបញ្ជី និងសវិធានធនលើឥណទានបាត់បង់ ។

ឥណទាន និងបុរេប្រទានត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលមិនមានភាពភាពជាក់លាក់ថានឹងអាចប្រមូលបានមកវិញ ។ ឥណទាន និងបុរេប្រទានដែលប្រមូលបានមកវិញ បន្ទាប់ពីបានជម្រះចេញពីបញ្ជីរួចហើយ ឬបានកត់ត្រាសវិធានធនរួចហើយ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

២.៦ សវិធានធនលើឥណទានបាត់បង់

ធនាគារបានអនុវត្តតាមការធ្វើចំណាត់ថ្នាក់ និងសវិធានធនឥណទាន ដែលតម្រូវដោយប្រកាសលេខ ធ៧-០៩-០៧៤ប្រ.ក. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ចេញដោយធនាគារកណ្តាល ។ ប្រកាសនេះ តម្រូវឱ្យធនាគារពាណិជ្ជទាំងឡាយធ្វើចំណាត់ថ្នាក់ឥណទាន បុរេប្រទាន និងទ្រព្យសកម្មស្រដៀងៗគ្នារបស់ពួកគេជាប្រាំចំណាត់ថ្នាក់ ហើយកម្រិតចាំបាច់អប្បបរមានៃការធ្វើសវិធានធនជាក់លាក់ នឹងត្រូវបានធ្វើអាស្រ័យតាមចំណាត់ថ្នាក់ដែលពាក់ព័ន្ធ ដោយមិនគិតដល់ទ្រព្យសកម្មដែលត្រូវបានដាក់ជាវត្ថុបញ្ចាំ ដូចមានបង្ហាញខាងក្រោម :

	អត្រាសវិធានធន គិតជា %
សវិធានធនទូទៅ :	
ឥណទានធម្មតា	១
សវិធានធនជាក់លាក់ :	
ក្រោមការយាំមើល	៣
ក្រោមស្តង់ដារ	២០
សង្ស័យ	៥០
បាត់បង	១០០

ការធ្វើចំណាត់ថ្នាក់ឥណទាន និងសវិធានធន ត្រូវផ្តោតការយកចិត្តទុកដាក់លើកត្តាពីរ គឺកត្តាហួសកាលកំណត់សង និងកត្តាគុណភាពឥណទាន ។

២.៧ កិច្ចសន្យាពាក់ព័ន្ធនឹងឥណទានផ្សេងៗ

នៅក្នុងដំណើរការធម្មតានៃអាជីវកម្ម ធនាគារចុះកិច្ចសន្យាដែលពាក់ព័ន្ធនឹងឥណទានផ្សេងៗ រួមមានកិច្ចសន្យា ឥណទាន លិខិតឥណទាន និងការធានាផ្សេងៗ ។ គោលការណ៍គណនេយ្យ និងវិធីសាស្ត្រសវិធានធនមានលក្ខណៈស្រដៀងគ្នា ចំពោះឥណទានផ្សេងៗដូចបានរៀបរាប់ខាងលើ ។ ធនាគារនឹងកត់ត្រាសវិធានធនជាក់លាក់ ចំពោះកិច្ចសន្យាពាក់ព័ន្ធនឹងឥណទានផ្សេងៗទាំងនោះ នៅពេលដែលធនាគារគិតថាវាទំនងជាមានការបាត់បង់ ។

២.៨ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ ។ ថ្លៃដើម រួមមានចំណាយផ្ទាល់ផ្សេងៗក្នុងការទិញទ្រព្យសកម្មទាំងនោះ ។

២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

២.៨ ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

ចំណាយនាពេលបន្ទាប់មកទៀតពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិ និងបរិក្ខារណាមួយ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃចុះបញ្ជីនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យសកម្ម ដាច់ដោយឡែកតាមការសមស្រប តែនៅពេលដែលមានភាពប្រាកដថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះ នឹងហូរចូលមកក្នុងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះ អាចត្រូវបានវាស់វែងគួរឱ្យជឿជាក់បានតែប៉ុណ្ណោះ។ រាល់ចំណាយលើការជួសជុល និងថែទាំ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផលក្នុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង។

ទ្រព្យសកម្មកំពុងសាងសង់ មិនត្រូវបានដករំលស់ទេ។ ការដករំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រា ជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផលតាមមូលដ្ឋានរំលស់ថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យសកម្មនោះ តាមអត្រាប្រចាំឆ្នាំខាងក្រោម :

	%
ការកែលម្អទ្រព្យជួល	២០
បរិក្ខារការិយាល័យ	១០-២០
បរិក្ខារកុំព្យូទ័រ	២០-៣៣
យានយន្ត	២០

ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មណាមួយ លើសពីតម្លៃប៉ាន់ស្មានដែលអាចប្រមូលមកវិញបាន វាត្រូវបានកត់ត្រាបន្ថយភ្លាមឱ្យនៅស្មើនឹងចំនួនដែលអាចប្រមូលមកវិញបាន។

ចំណេញ ឬខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់បានពីការ លក់ និងតម្លៃយោង ហើយត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល។

២.៩ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមាន អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ ដែលបានទិញ និងចំណាយ ដែលពាក់ព័ន្ធផ្សេងៗ ត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលកើតឡើង ក្នុងការទិញកម្មវិធីនោះនិងយកវាមកប្រើប្រាស់។ ថ្លៃដើមនេះ ត្រូវបានធ្វើរំលស់រយៈពេលបីឆ្នាំដោយប្រើវិធីសាស្ត្ររំលស់ថេរ។

ចំណាយលើការថែទាំកម្មវិធីកុំព្យូទ័រ ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលមានប្រតិបត្តិការនោះកើតឡើង។

២.១០ ចំណូល និងចំណាយការប្រាក់

ចំណូលការប្រាក់បានពីឥណទាន និងបុរេប្រទានអតិថិជន ប្រាក់បញ្ញើនៅធនាគារកណ្តាល និងនៅធនាគារផ្សេងៗ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ លើកលែងតែមានការសង្ស័យខ្លាំងចំពោះការប្រមូលប្រាក់មកវិញ ដែលក្នុងករណីនេះ ការប្រាក់នឹងត្រូវបានព្យួរ រហូតដល់បានទទួលសាច់ប្រាក់ជាក់ស្តែង។ គោលការណ៍ក្នុងការព្យួរការប្រាក់គឺអនុលោមស្របទៅតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល ស្តីពីការព្យួរការប្រាក់លើឥណទានមិនដំណើរការ និងសិទ្ធានធនលើឥណទានបាត់បង់។

ចំណាយការប្រាក់លើប្រាក់បញ្ញើរបស់ធនាគារ និងប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ។

២.១១ ចំណូលកម្រៃ និងជើងសារ

ចំណូលកម្រៃ និងជើងសារ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ នៅពេលដែលបានបំពេញសេវាកម្មជូនអតិថិជន។ ចំណូលកម្រៃ និងជើងសារ រួមមានចំណូលបានមកពីសេវាកម្មផ្ទេរប្រាក់ចេញ-ចូល សេវា ATM និងសេវាផ្សេងៗទៀត។ កម្រៃលើការផ្តល់ឥណទានត្រូវបានគេកត់ត្រាជាចំណូល នៅពេលផ្តល់ឥណទានឱ្យអតិថិជន។

២.១២ ភតិសន្យាប្រតិបត្តិ

ភតិសន្យាដែលភាគីម្ចាស់ទ្រព្យនៅមានចំណែកហានិភ័យ និងផលកម្មសិទ្ធិជាសារវន្ត ត្រូវបានចាត់ថ្នាក់ជា ភតិសន្យាប្រតិបត្តិ។ ការទូទាត់ភតិសន្យាប្រតិបត្តិត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យានោះ។

២.១៣ សិទ្ធានធន

សិទ្ធានធន ត្រូវបានកត់ត្រានៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចដែលធនាគារបានបង្កើតឡើងនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល និងនៅពេលដែលមានភាពប្រាកដថា នឹងមានតម្រូវការឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់អាចប៉ាន់ស្មានបានយ៉ាងគួរឱ្យជឿជាក់។

នៅពេលដែលមានកាតព្វកិច្ចប្រហាក់ប្រហែលគ្នាជាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចទាំងនោះ ត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់កាតព្វកិច្ចទាំងមូល។

សិទ្ធានធនត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ន នៃការទូទាត់កាតព្វកិច្ចដែលរំពឹងទុកដោយប្រើអត្រាអប្បហារមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការវាយតម្លៃសមរម្យបច្ចុប្បន្ននៃតម្លៃពេលវេលាទឹកប្រាក់ និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសិទ្ធានធនដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់។

២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

២.១៤ ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ ត្រូវបានគណនាតាមច្បាប់ពន្ធដារដែលបានអនុម័តជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំក្នុងព្រះរាជាណាចក្រកម្ពុជា គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ។

ពន្ធពន្យារលើប្រាក់ចំណេញត្រូវបានធ្វើសំវិធានធនពេញលេញ ដោយប្រើវិធីសាស្ត្របំណុលលើសម្បៃងបណ្តោះអាសន្នដែលកើតមានរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលទាំងនោះ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា ទៅតាមទំហំនៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតដែលមានធ្យៀបនឹងលម្អៀងបណ្តោះអាសន្ន ដែលអាចប្រើប្រាស់បាន។

២.១៥ ប្រតិបត្តិការភាគីពាក់ព័ន្ធ

ភាគីដែលចាត់ទុកថាជាភាគីពាក់ព័ន្ធ គឺជាភាគីដែលមានលទ្ធភាពគ្រប់គ្រង ឬមានឥទ្ធិពលជាសារវន្តលើភាគីមួយ ទៀត ក្នុងការសម្រេចចិត្តលើផ្នែកប្រតិបត្តិការ និងហិរញ្ញវត្ថុ។

អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ភាគីពាក់ព័ន្ធត្រូវបានឱ្យនិយមន័យថា ជាភាគីដែលកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលយ៉ាងហោចណាស់ ១០% នៃដើមទុន ឬសិទ្ធិបោះឆ្នោតរួមទាំងបុគ្គលទាំងឡាយណា ដែលចូលរួមនៅក្នុងអភិបាលកិច្ច ការដឹកនាំ ការគ្រប់គ្រង ឬការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។

២.១៦ តួលេខគត់

តួលេខទាំងឡាយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានកាត់ខ្ទង់គត់ចំពោះតួលេខជាប្រាក់ដុល្លារអាមេរិក និងកាត់ខ្ទង់ពាន់រៀលចំពោះប្រាក់រៀល។

៣. ការប៉ាន់ស្មានគណនេយ្យ និងការវិនិច្ឆ័យសំខាន់ៗ

ធនាគារធ្វើការប៉ាន់ប្រមាណ និងការសន្មត ដែលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងបំណុល ដែលបានរាយការណ៍។ ការប៉ាន់ប្រមាណ និងការវិនិច្ឆ័យត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដោយផ្អែកលើបទពិសោធន៍នាពេលកន្លងមក និងកត្តាផ្សេងៗ ដូចជាការរំពឹងទុកអំពីហេតុការណ៍នាពេលអនាគត ដែលគេជឿថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។

ក. ការខាតបង់បណ្តាលមកពីការថយចុះតម្លៃនៃឥណទាន និងបុរេប្រទាន

ធនាគារបានអនុវត្តតាមការធ្វើចំណាត់ថ្នាក់ និងសំវិធានធនលើឥណទានតាមប្រកាសលេខ ធ៧-០៩-០៧៤ប្រ.ក. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន សម្រាប់ស្ថាប័នធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ដែលចេញដោយធនាគារកណ្តាល។ ធនាគារកណ្តាល តម្រូវឱ្យធនាគារពាណិជ្ជទាំងឡាយធ្វើចំណាត់ថ្នាក់ សំវៀតឥណទាន បុរេប្រទាន និងទ្រព្យសកម្មប្រហាក់ប្រហែលរបស់ខ្លួនជាប្រាំថ្នាក់ ហើយកម្រិតអប្បបរមានៃសំវិធានធនជាក់លាក់ ត្រូវបានធ្វើឡើងអាស្រ័យតាមចំណាត់ថ្នាក់ពាក់ព័ន្ធ ដោយមិនគិតដល់ទ្រព្យសកម្មដែលត្រូវបានដាក់ជាវត្ថុបញ្ចាំ។ ក្នុងការធ្វើចំណាត់ថ្នាក់ឥណទាន ធនាគារពិចារណាទៅលើកត្តាពាក់ព័ន្ធទាំងអស់ដែលអាចមានផលប៉ះពាល់ដល់លទ្ធភាព ក្នុងការសងប្រាក់នៃភាគីដៃគូរបស់ខ្លួន។

ខ. ពន្ធលើប្រាក់ចំណេញ

ពន្ធត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ននៃបទប្បញ្ញត្តិពន្ធដារ ប៉ុន្តែបទប្បញ្ញត្តិទាំងអស់នេះ មានការផ្លាស់ប្តូរពីមួយគ្រាទៅមួយគ្រា ហើយការសម្រេចជាចុងក្រោយលើចំនួនពន្ធ នឹងធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យ ចុងក្រោយដោយអគ្គនាយកដ្ឋានពន្ធដារ។

នៅពេលដែលលទ្ធផលពន្ធចុងក្រោយ ខុសគ្នាពីចំនួនពន្ធដែលបានកត់ត្រាពីដំបូង ភាពលម្អៀងនេះនឹងធ្វើឱ្យប៉ះពាល់ដល់ពន្ធលើប្រាក់ចំណេញ និងសំវិធានធនពន្ធពន្យារក្នុងឆ្នាំដែលការកំណត់ពន្ធបានធ្វើឡើង។

៤. សមតុល្យនៅធនាគារកណ្តាល

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
គណនីចរន្ត	៣៤.១២៦.៦៣៨	១៣៦.៣៣៥.៩១៩	១២.៤៧១.២៥៥	៥០.៣៧១.៣៩៩
ប្រាក់បញ្ញើមានកាលកំណត់ (ក)	៥.000.000	១៩.៩៧៥.000	១0.000.000	៤0.៣៩0.000
ទុនបម្រុងកាតព្វកិច្ច (ខ)	១២.៥៥៥.000	៥0.១៥៧.២២៥	៦.២៥៥.000	២៥.២៦៣.៩៤៥
ប្រាក់តម្កល់ធានាលើដើមទុន	៣.៧00.000	១៤.៧៨១.៥00	៣.៧00.000	១៤.៩៤៤.៣00
	៥៥.៣៨១.៦៣៨	២២១.២៤៩.៦៤៤	៣២.៤២៦.២៥៥	១៣0.៩៦៩.៦៤៤

៤. សមតុល្យនៅធនាគារកណ្តាល (ត)

(ក) *ប្រាក់បញ្ញើមានកាលកំណត់*

ប្រាក់បញ្ញើមានកាលកំណត់នៅធនាគារកណ្តាល គឺជាប្រាក់បញ្ញើរយៈពេលខ្លីដែលមានកាលកំណត់តិចជាង៣ខែ ។

(ខ) *ប្រាក់បម្រុងកាតព្វកិច្ច*

ប្រាក់បម្រុងកាតព្វកិច្ចគឺជាប្រាក់បម្រុងអប្បបរមា ធ្យៀបនឹងប្រាក់បញ្ញើនិងប្រាក់កម្ចី តាមសមតុល្យមធ្យមប្រចាំថ្ងៃ ដែលសមមូលនឹង ៨% ជាប្រាក់រៀល និង ១២.៥% ជារូបិយប័ណ្ណផ្សេងៗ ហើយប្រាក់បម្រុងកាតព្វកិច្ចនេះរក្សាទុកនៅធនាគារកណ្តាល ។

ប្រាក់បម្រុងកាតព្វកិច្ច ៨% មិនមានការប្រាក់ទេ ។ ប្រាក់បម្រុងកាតព្វកិច្ច ៣២% (៤%/១២.៥%) នៃប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបរទេសផ្សេងៗទាំងអស់ មានការប្រាក់គិតតាមអត្រា ៥0% នៃអត្រា SIBOR មួយខែ ដែលត្រូវបានគណនាតាមមូលដ្ឋានប្រចាំខែ ។

(គ) *ប្រាក់តម្កល់ធានាលើដើមទុន*

យោងតាមប្រកាសលេខ ធ៧-០១-១៣៦ប្រ.ក. ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ចេញដោយធនាគារកណ្តាល ស្តីពីប្រាក់តម្កល់ធានាលើដើមទុន តម្រូវឱ្យធនាគារតម្កល់ប្រាក់ចំនួន ១0% នៃដើមទុនចុះបញ្ជីនៅធនាគារកណ្តាល ។ ប្រាក់តម្កល់នេះមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារបានទេ ហើយនឹងត្រូវប្រគល់ឱ្យធនាគារវិញ នៅពេលដែលធនាគារស្ម័គ្រចិត្តបញ្ឈប់ប្រតិបត្តិការរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

(ឃ) *អត្រាការប្រាក់*

គណនីចរន្ត គឺជាគណនីដែលមិនមានការប្រាក់ ។ អត្រាការប្រាក់ប្រចាំឆ្នាំលើសមតុល្យនៅធនាគារកណ្តាល ត្រូវបានសង្ខេបដូចខាងក្រោម :

	២០១២	២០១១
ប្រាក់បញ្ញើមានកាលកំណត់	0,១0% - 0,១៤%	0,១0% - 0,១៣%
ទុនបម្រុងកាតព្វកិច្ច	0,១0% - 0,១២%	0,0៥% - 0,១១%
ប្រាក់តម្កល់ធានាលើដើមទុន	0,១៨% - 0,២0%	0,0៥% - 0,១0%

៥. ប្រាក់បញ្ញើនៅធនាគារផ្សេងៗ

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ការដាក់ប្រាក់	៧.៨00.000	៣១.១៦១.000	-	-
គណនីចរន្ត	៤.១២0.១៣៦	១៦.៤៥៩.៩៤៣	៦.៥៨៩.៥៥៤	២៦.៦១៥.២0៩
	១១.៩២0.១៣៦	៤៧.៦២0.៩៤៣	៦.៥៨៩.៥៥៤	២៦.៦១៥.២0៩

គណនីចរន្តមិនមានការប្រាក់ទេ ។ ក្នុងឆ្នាំ២០១២ ការដាក់ប្រាក់នៅធនាគារផ្សេងៗ គឺដាក់នៅធនាគារ CIMB Bank Berhad នៅប្រទេសម៉ាឡេស៊ី ។ ការដាក់ប្រាក់នេះ មានកាលកំណត់រយៈពេលខ្លី ហើយទទួលបានការប្រាក់ប្រចាំឆ្នាំពី 0,១ ទៅ 0,៣% ។

៦. ឥណទាន និងបុរេប្រទានអតិថិជន

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ឥណទានពាណិជ្ជ :				
ឥណទានរយៈពេលខ្លី	១.០០៥.៤២៤	៤.០១៦.៦៦៩	-	-
ឥណទានរយៈពេលវែង	៥១.៧១៧.៣៩៥	២០៦.៦១០.៩៩៣	២៩.៧០៨.៥១៦	១១៩.៩៩២.៦៩៦
ឥណទានវិបារូបនី	៣១.៨៥៩.២៦៣	១២៧.២៧៧.៧៥៦	១២.៦៥៨.១១៣	៥១.១២៦.១១៨
ឥណទាន និងបុរេប្រទានអតិថិជន សរុប-ដុល	៨៤.៥៨២.០៨២	៣៣៧.៩០៥.៤១៨	៤២.៣៦៦.៦២៩	១៧១.១១៨.៨១៤
សវិធានធនបំណុលសង្ស័យ	(៨៤៥.៨២១)	(៣.៣៧៩.០៥៥)	(៤២៣.៨០០)	(១.៧១១.៧២៨)
	៨៣.៧៣៦.២៦១	៣៣៤.៥២៦.៣៦៣	៤១.៩៤២.៨២៩	១៦៩.៤០៧.០៨៦

រាល់បណ្តាឥណទានទាំងអស់ត្រូវបានផ្តល់ជូនអតិថិជនជាឯកត្តជន និងសហគ្រាសនានាដែលធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា។

(ក) សវិធានធនបំណុលសង្ស័យ

បម្រែបម្រួលសវិធានធនបំណុលអាក្រក់និងសង្ស័យ មានដូចខាងក្រោម :

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
នាដើមឆ្នាំ	៤២៣.៨០០	១.៧១១.៧២៨	-	-
សវិធានធនក្នុងឆ្នាំ	៤២២.០២១	១.៦៨៥.៩៧៤	៤២៣.៨០០	១.៧១១.៧២៨
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(១៨.៦៤៧)		
នាចុងឆ្នាំ	៨៤៥.៨២១	៣.៣៧៩.០៥៥	៤២៣.៨០០	១.៧១១.៧២៨

(ខ) វិភាគតាមចំណាត់ថ្នាក់ឥណទាន

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ឥណទានធម្មតា-មានការធានា	៨៤.៥៨២.០៨២	៣៣៧.៩០៥.៤១៨	៤២.៣៦៦.៦២៩	១៧១.១១៨.៨១៤
	៨៤.៥៨២.០៨២	៣៣៧.៩០៥.៤១៨	៤២.៣៦៦.៦២៩	១៧១.១១៨.៨១៤

(គ) អត្រាការប្រាក់

ឥណទាន និងបុរេប្រទានអតិថិជនទាំងនេះ មានអត្រាការប្រាក់ប្រចាំឆ្នាំក្នុងចន្លោះពី ៦% ទៅ ១១% (២០១១ : ៨% ទៅ ១២%)។

៧. ទ្រព្យសកម្មផ្សេងៗ

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ការប្រាក់ត្រូវទទួល	៣៧៦.២៣៤	១.៥០៣.០៥៥	១៨៧.១៦៥	៧៥៥.៩៥៩
ប្រាក់កក់ (*)	២៥២.៥៣៧	១.០០៨.៨៨៥	២០៦.៨០៤	៨៣៥.២៨១
ប្រតិបត្តិការផ្ទេរប្រាក់ចូលដែលនៅមិនទាន់ទូទាត់	២១១.៥៤៨	៨៤៥.១៣៤	-	-
សម្ភារការិយាល័យ	១២.៨៣០	៥១.២៥៦	១៩.៤៧៨	៧៨.៦៧២
ផ្សេងៗ	២០០.៧៨២	៨០២.១២៥	៩៣.២០៦	៣៧៦.៤៦០
	១.០៥៣.៩៣១	៤.២១០.៤៥៥	៥០៦.៦៥៣	២.០៤៦.៣៧២

(*) ប្រាក់កក់នេះគឺជាប្រាក់កក់លើការជួលការិយាល័យ ដែលអាចបង្វិលមកវិញបាននៅដំណាច់កិច្ចសន្យាភតិសន្យា។ រយៈពេលនៃភតិសន្យា គឺមានរយៈពេលលើសពី១ឆ្នាំ ហើយប្រាក់កក់នេះមិនមានការប្រាក់ទេ។

៨. ទ្រព្យសម្បត្តិ និងបរិក្ខារ

	ការកែលម្អ ទ្រព្យជួល ដុល្លារអាមេរិក	បរិក្ខារ ការិយាល័យ ដុល្លារអាមេរិក	បរិក្ខារ កុំព្យូទ័រ ដុល្លារអាមេរិក	យានយន្ត ដុល្លារអាមេរិក	ទ្រព្យសកម្ម កំពុងដំណើរការ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១						
តម្លៃចុះបញ្ជីសុទ្ធដើមគ្រា	-	៤៤.៥៣៨	៤.២០៨	២៤៨.២៦៤	១.២៧៩.៤១៧	១.៥៧៦.៤២៧
ការទិញបន្ថែម	២.៤៥៧.៤៥២	៤២៩.៥៤៩	១.០៧៧.១២២	១៥៤.០១២	(៨២១.០២២)	៣.២៩៧.១១៣
រំលស់	(២៨៧.៣៨៥)	(៤៨.៧៨៣)	(៣៣៤.៥៥១)	(៦៥.៤២២)	-	(៧៣៦.១៤១)
តម្លៃចុះបញ្ជីសុទ្ធចុងគ្រា	២.១៧០.០៦៧	៤២៥.៣០៤	៧៤៦.៧៧៩	៣៣៦.៨៥៤	៤៥៨.៣៩៥	៤.១៣៧.៣៩៩
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១						
ថ្លៃដើម	២.៤៥៧.៤៥២	៤៧៤.៤២៥	១.០៨១.៥៦៦	៤១៤.៤១២	៤៥៨.៣៩៥	៤.៨៨៦.២៥០
រំលស់បង្គរ	(២៨៧.៣៨៥)	(៤៩.១២១)	(៣៣៤.៧៨៧)	(៧៧.៥៥៨)	-	(៧៤៨.៨៥១)
តម្លៃចុះបញ្ជីសុទ្ធ	២.១៧០.០៦៧	៤២៥.៣០៤	៧៤៦.៧៧៩	៣៣៦.៨៥៤	៤៥៨.៣៩៥	៤.១៣៧.៣៩៩
តម្លៃចុះបញ្ជីសុទ្ធ សមមូលជាពាន់រៀល	៨.៧៦៤.៩០១	១.៧១៧.៨០៣	៣.០១៦.២៤០	១.៣៦០.៥៥៣	១.៨៥១.៤៥៨	១៦.៧១០.៩៥៥

៨. ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

	ការកែលម្អ ទ្រព្យជួល ដុល្លារអាមេរិក	បរិក្ខារ ការិយាល័យ ដុល្លារអាមេរិក	បរិក្ខារ កុំព្យូទ័រ ដុល្លារអាមេរិក	យានយន្ត ដុល្លារអាមេរិក	ទ្រព្យសកម្ម កំពុងដំណើរការ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២						
តម្លៃចុះបញ្ជីសុទ្ធដើមគ្រា	២.១៧០.០៦៧	៤២៥.៣០៤	៧៤៦.៧៧៩	៣៣៦.៨៥៤	៤៥៨.៣៩៥	៤.១៣៧.៣៩៩
ការទិញបន្ថែម	៥៣៧.០៦៣	៣០៧.០៣៩	១៦៧.៨៥០	១៣.៣៦៨	១.០១៧.៦៥១	២.០៤២.៩៧១
ការផ្ទេរចូល/(ចេញ)	៥៦២.២៧០	៣.៦៣០	៤៩១.០៩៣	១៣.២៥០	១.០៧០.២៤៣)	-
រំលស់	(៦២៥.១៦៦)	(១១៤.២០៩)	(៤៤៥.១៥៨)	(៨៨.៨១២)	-	(១.២៧៣.៣៤៥)
តម្លៃចុះបញ្ជីសុទ្ធចុងគ្រា	២.៦៤៤.២៣៤	៦២១.៧៦៤	៩៦០.៥៦៤	២៧៤.៦៦០	៤០៥.៨០៣	៤.៩០៧.០២៥
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២						
ថ្លៃដើម	៣.៥៥៦.៧៨៥	៧៨៥.០៩៤	១.៧៤០.៥០៩	៤៤១.០៣០	៤០៥.៨០៣	៦.៩២៩.២២១
រំលស់បង្គរ	(៩១២.៥៥១)	(១៦៣.៣៣០)	(៧៧៩.៩៤៥)	(១៦៦.៣៧០)	-	(២.០២២.១៩៦)
តម្លៃចុះបញ្ជីសុទ្ធ	២.៦៤៤.២៣៤	៦២១.៧៦៤	៩៦០.៥៦៤	២៧៤.៦៦០	៤០៥.៨០៣	៤.៩០៧.០២៥
តម្លៃចុះបញ្ជីសុទ្ធ សមមូលជាពាន់រៀល	១០.៥៦៣.៧១៥	២.៤៨៣.៩៤៧	៣.៨៣៧.៤៥៣	១.០៩៧.២៦៧	១.៦២១.១៨៣	១៩.៦០៣.៥៦៥

៩. ទ្រព្យសកម្មអរូបី

	កម្មវិធីកុំព្យូទ័រ ដុល្លារអាមេរិក	ទ្រព្យសកម្ម កំពុងដំណើរការ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១			
តម្លៃចុះបញ្ជីសុទ្ធដើមគ្រា	១.០៩៤.៣០៤	-	១.០៩៤.៣០៤
ការទិញបន្ថែម	៣០៥.៦១២	-	៣០៥.៦១២
រំលស់	(៤៨២.០០៦)	-	(៤៨២.០០៦)
តម្លៃចុះបញ្ជីសុទ្ធចុងគ្រា	៩១៧.៩១០	-	៩១៧.៩១០
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១			
ថ្លៃដើម	១.៤៤៤.៦៤៥	-	១.៤៤៤.៦៤៥
រំលស់បង្គរ	(៥២៦.៧៣៦)	-	(៥២៦.៧៣៦)
តម្លៃចុះបញ្ជីសុទ្ធ	៩១៧.៩០៩	-	៩១៧.៩០៩
តម្លៃចុះបញ្ជីសុទ្ធ សមមូលជាពាន់រៀល	៣.៧០៧.៤៣៤	-	៣.៧០៧.៤៣៤

៩. ទ្រព្យសកម្មអរូបី (ត)

	កម្មវិធីកុំព្យូទ័រ ដុល្លារអាមេរិក	ទ្រព្យសកម្ម កំពុងដំណើរការ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២			
តម្លៃចុះបញ្ជីសុទ្ធដើមគ្រា	៩១៧.៩០៩	-	៩១៧.៩០៩
ការទិញបន្ថែម	៤៧១.៥៧៧	២៥២.៨៨0	៧២៤.៤៥៧
ការផ្ទេរចូល/(ចេញ)	២៥២.៨៨0	(២៥២.៨៨0)	-
រំលស់	(៥៧៦.៨១៨)	-	(៥៧៦.៨១៨)
តម្លៃចុះបញ្ជីសុទ្ធចុងគ្រា	១.0៦៥.៥៤៨	-	១.0៦៥.៥៤៨
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២			
ថ្លៃដើម	២.១៦៩.១0២	-	២.១៦៩.១0២
រំលស់បង្គរ	(១.១0៣.៥៥៤)	-	(១.១0៣.៥៥៤)
តម្លៃចុះបញ្ជីសុទ្ធ	១.0៦៥.៥៤៨	-	១.0៦៥.៥៤៨
តម្លៃចុះបញ្ជីសុទ្ធ សមមូលជាពាន់រៀល	៤.២៥៦.៨៦៤	-	៤.២៥៦.៨៦៤

១0. ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ

	៣១ ធ្នូ ២0១២		៣១ ធ្នូ ២0១២	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
គណនីចរន្ត	២៣៦.១២៦	៩៤៣.៣២៣	១៩.៩៩៥	៨0.៧៦0
ប្រាក់បញ្ញើមានកាលកំណត់	២៣.២0៩.៣៧៥	៩២.៧២១.៤៥៣	៣.0១១.២៥0	១២.១៦២.៤៣៩
	២៣.៤៤៥.៥0១	៩៣.៦៦៤.៧៧៦	៣.0៣១.២៤៥	១២.២៤៣.១៩៩

ប្រាក់បញ្ញើមានកាលកំណត់គឺជាប្រាក់បញ្ញើដែលមានរយៈពេលខ្លី ដែលមានកាលកំណត់សងតិចជាង៣ខែ។ ប្រាក់បញ្ញើមានកាលកំណត់ មានអត្រាការប្រាក់ពី 0,៥% ទៅ ១,៥% ក្នុងមួយឆ្នាំ (២0១១ : 0,៥% ទៅ ១,៥%)។

១១. ប្រាក់បញ្ញើរបស់អតិថិជន

	៣១ ធ្នូ ២0១២		៣១ ធ្នូ ២0១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
គណនីចរន្ត	៣៤.១៥៧.៨៤៤	១៣៦.៤៦0.៥៨៧	១១.៤៨៩.៧៣១	៤៦.៤0៧.0២៤
គណនីសន្សំ	៧.៤៤៧.៨៤៨	២៩.៧៥៤.១៥៣	៤.៧0២.៩៨0	១៨.៩៩៥.៣៣៦
ប្រាក់បញ្ញើមានកាលកំណត់	៥៦.៧៥៧.៥៣៨	២២៦.៧៤៦.៣៦៤	៣៣.៤៤១.៨៨៣	១៣៥.0៧១.៧៦៥
	៩៨.៣៦៣.២៣0	៣៩២.៩៦១.១0៤	៤៩.៦៣៤.៥៩៤	២00.៤៧៤.១២៥

១១. ប្រាក់បញ្ញើរបស់អតិថិជន (ត)

ប្រាក់បញ្ញើមានកាលកំណត់ គឺជាប្រាក់បញ្ញើដែលមានរយៈពេលខ្លី ដែលមានកាលកំណត់សងតិចជាង១២ខែ ។

គណនីសន្សំ និងប្រាក់បញ្ញើមានកាលកំណត់ ទទួលបានការប្រាក់ប្រចាំឆ្នាំ ដូចខាងក្រោម :

	២០១២	២០១១
គណនីសន្សំ	០,៥% ទៅ ១,៥០%	០,៥% ទៅ ១,៥%
ប្រាក់បញ្ញើមានកាលកំណត់	២% ទៅ ៥%	២,២៥% ទៅ ៤,៧៥%
គណនីចរន្ត	អតិបរមា ១,៧៥%	-

១២. ទឹកប្រាក់ត្រូវទារ/ជំពាក់ក្រុមហ៊ុនពាក់ព័ន្ធ

ទឹកប្រាក់ដែលធនាគារ CIMB Bank Berhad ជំពាក់ ភាគច្រើនពាក់ព័ន្ធនឹងចំនួនទឹកប្រាក់ ដែលធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ទូទាត់ជំនួសធនាគារ CIMB Bank Berhad ទាក់ទិននឹងអត្ថប្រយោជន៍នានារបស់បុគ្គលិកហាត់ការពីធនាគារ CIMB Bank Berhad និងក្រុមហ៊ុនផ្សេងៗ។ ទឹកប្រាក់ជំពាក់នេះមិនមានការប្រាក់ និងមិនមានកាលកំណត់សងថេរទេ ។

ទឹកប្រាក់ជំពាក់ក្រុមហ៊ុនពាក់ព័ន្ធ គឺជាប្រាក់ជំពាក់ធនាគារ CIMB Bank Berhad ពាក់ព័ន្ធនឹងចំនួនទឹកប្រាក់ ដែលធនាគារ CIMB Bank Berhad ទូទាត់ជំនួសធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ទាក់ទិនទៅនឹងការបណ្តុះបណ្តាលនៅ ប្រទេសម៉ាឡេស៊ី ។ ទឹកប្រាក់ជំពាក់នេះមិនមានការប្រាក់ទេ ហើយត្រូវសងវិញតាមតម្រូវការ ។

១៣. ទឹកប្រាក់ជំពាក់អ្នកផ្គត់ផ្គង់

ទឹកប្រាក់ជំពាក់អ្នកផ្គត់ផ្គង់ភាគច្រើន គឺថ្លៃការងារសំណង់ និងប្រាក់តម្កល់របស់អ្នកសាងសង់ ។ ទឹកប្រាក់នេះ ត្រូវទូទាត់សងក្នុងរយៈពេលតិចជាង១២ខែ ។

១៤. បំណុលផ្សេងៗ

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
មូលប្បទានបត្ររបស់ធនាគារ និង គណនីត្រូវទទួលផ្សេងៗ (*)	១០.២៩០.៤០៥	៤១.១១០.១៦៨	១.៧៥២.២៥១	៧.០៧៧.៣៤២
ប្រតិបត្តិការផ្ទេរប្រាក់ចេញដែលនៅមិនទាន់ទូទាត់ (**)	៥៤៣.៥៣០	២.១៧១.៤០២	-	-
បង្ការការប្រាក់ត្រូវបង់	៤៥៣.០៧៩	១.៨១០.០៥១	១៤៣.៦៣០	៥៨០.១២២
បង្ការប្រាក់រង្វាន់ត្រូវបង់	២៨០.០០០	១.១១៨.៦០០	១៨៥.០០០	៧៤៩.៨០៥
ការវិនិយោគក្នុងរូបិយប័ណ្ណទ្វេ	៩៤.៩៥៨	៣៧៩.៣៥៧	-	-
បង្ការពន្ធត្រូវបង់	៣២.៤៤៩	១២៩.៦៣៤	៣៦.៨៣៧	១៤៨.៧៨៥
បំណុលផ្សេងៗ	១៧២.៨៥៧	៦៩០.៥៦៤	១១៧.១០២	៤៧០.៣៨៣
	១១.៨៦៧.២៧៨	៤៧.៤០៩.៧៧៦	២.២៣៤.៨២០	៩.០២៦.៤៣៧

(*) មូលប្បទានបត្ររបស់ធនាគារ និងគណនីត្រូវទទួលផ្សេងៗ គឺជាមូលប្បទានផ្ទាត់ទាត់ដែលនៅមិនទាន់ទូទាត់ ហើយដែលត្រូវទូទាត់នៅនាយកដ្ឋានផ្ទាត់ទាត់ របស់ធនាគារកណ្តាល បន្ទាប់ពីកាលបរិច្ឆេទតារាងតុល្យការ ។

(**) ប្រតិបត្តិការផ្ទេរប្រាក់ចេញដែលនៅមិនទាន់ទូទាត់ គឺជាសាច់ប្រាក់ផ្ទេរចេញដែលត្រូវទូទាត់ បន្ទាប់ពីកាលបរិច្ឆេទតារាងតុល្យការ ជាមួយធនាគារជាដៃគូ ។

បំណុលទាំងនេះ ត្រូវបានរំពឹងថានឹងត្រូវទូទាត់សងក្នុងរយៈពេលតិចជាង១ឆ្នាំ ។

១៥. ដើមទុន

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ដើមទុនចុះបញ្ជីរបស់ធនាគារមានចំនួន ៣៧ លានភាគហ៊ុន (៣១ ធ្នូ ២០១១ : ៣៧ លានភាគហ៊ុន) ដែលមានតម្លៃចារិក ១ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន។ ភាគហ៊ុនទាំងអស់ត្រូវបានបង់ គ្រប់ចំនួនទាំងស្រុង។

បន្ទាប់មកទៀតក្នុងខែមករា ឆ្នាំ២០១៣ ក្រុមប្រឹក្សាភិបាលនិងភាគទុនិកបានអនុម័តបន្ថែមដើមទុនទៀត។ ចំពោះព័ត៌មានលម្អិតបន្ថែម សូមយោងទៅកំណត់សម្គាល់ ២៦។

១៦. ចំណូលការប្រាក់សុទ្ធ

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	**ពាន់រៀល**	**ដុល្លារអាមេរិក**	**ពាន់រៀល**
ចំណូលការប្រាក់ :				
ឥណទាន និងបុរេប្រទានអតិថិជន	៥.៣៦៣.៨៣៩	២១.៤២៨.៥៣៦	១.៥៦៨.៤០៥	៦.៣៣៤.៧៨៨
ឥណទាន និងបុរេប្រទានបុគ្គលិក	៣.២៥៦	១៣.០០៨	-	-
ការដាក់ប្រាក់នៅធនាគារកណ្តាល និងធនាគារផ្សេងៗ	៣១.៨០៦	១២៧.០៦៥	៣២.៧២៩	១៣២.១៩២
ចំណូលការប្រាក់សរុប	៥.៣៩៨.៩០១	២១.៥៦៨.៦០៩	១.៦០១.១៣៤	៦.៤៦៦.៩៨០
ចំណាយការប្រាក់ :				
គណនីចរន្ត (*)	(១០៩.៩៥៩)	(៤៣៩.២៨៦)	-	-
ប្រាក់បញ្ញើមានកាលកំណត់	(១.៥៧៣.៦១៤)	(៦.២៨៦.៥៨៨)	(៤៦៩.៣៦១)	(១.៨៩៥.៧៤៩)
ប្រាក់បញ្ញើសន្សំ	(៥៨.១៨០)	(២៣២.៤២៩)	(២៦.៥៩៧)	(១០៧.៤២៥)
ចំណាយការប្រាក់សរុប	(១.៧៤១.៧៥៣)	(៦.៩៥៨.៣០៣)	(៤៩៥.៩៥៨)	(២.០០៣.១៧៤)
ចំណូលការប្រាក់សុទ្ធ	៣.៦៥៧.១៤៨	១៤.៦១០.៣០៦	១.១០៥.១៧៦	៤.៤៦៣.៨០៦

(*) គណនីចរន្តរបស់អតិថិជនពិសេសគឺជាគណនីដែលមានការប្រាក់។

១៧. ចំណូលកម្រៃសេវា និងជើងសារ

	សម្រាប់រយៈពេលឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២		សម្រាប់រយៈពេលឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១	
	ដុល្លារអាមេរិក	**ពាន់រៀល**	**ដុល្លារអាមេរិក**	**ពាន់រៀល**
កម្រៃបានមកពីការផ្ទេរប្រាក់	៣៩៨.៤៤៨	១.៥៩១.៨០០	១២០.៨០៣	៤៨៩.៦១៥
កម្រៃបានមកពីសេវាឥណទាន	២១០.១៦៣	៨៣៩.៦០១	-	-
កម្រៃកិច្ចសន្យាឥណទាន	៧៩.៥៦០	៣១៧.៨៤២	១៩.៨៤៩	៧៨.២៩៨
កម្រៃហិរញ្ញប្បទានពាណិជ្ជកម្ម	៣៦.០០២	១៤៣.៨២៩	-	-
កម្រៃ និងជើងសារលើសេវាផ្សេងៗ	៨១.៩០៤	៣២៧.២០៦	១២.៨៤០	៥២.០៤១
	៨០៦.០៧៧	៣.២២០.២៧៨	១៥៣.៤៩២	៦១៩.៩៥៤

១៨. ចំណាយផ្នែកបុគ្គលិក

	សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២		សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់ឈ្នួលវត្សរ៍ និងប្រាក់ឈ្នួល	១.៦០៦.២២៦	៦.៤១៦.៨៧៣	១.០៦៨.២៩៦	៤.៣១៤.៨៤៨
អត្ថប្រយោជន៍រយៈពេលខ្លីផ្សេងៗ	២៦៦.១៦៤	១.០៦៣.៣២៥	២៧១.០៧៤	១.០៩៤.៨៦៨
ប្រាក់រង្វាន់ និងប្រាក់លើកទឹកចិត្ត	២៧៨.១៦៥	១.១១១.២៦៩	១៨៥.000	៧៤៧.២១៤
	២.១៥0.៥៥៥	៨.៥៩១.៤៦៧	១.៥២៤.៣៧0	៦.១៥៦.៩៣0

១៩. ចំណាយទូទៅ និងចំណាយរដ្ឋបាល

	សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២		សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណាយការជួល	៤៨៥.0៧៤	១.៩៣៧.៨៧១	២៩៩.៥៤៧	១.២0៩.៨៧0
ចំណាយផ្សាយពាណិជ្ជកម្ម និងទំនាក់ទំនង សាធារណ	២៧៣.១៧៩	១.0៩១.៣៥0	៩6.៥២៧	៣៨៩.៨៧៣
ចំណាយទឹក-ភ្លើង	១6៤.៤៧២	6៥៧.06៧	៧៨.៣0៤	៣១6.២៧0
សោហ៊ុយធ្វើដំណើរ និងការស្នាក់នៅ	១៥៧.១6៨	6២៧.៨៨6	៨៩.៨៨6	៣6៤.៣0៨
ចំណាយសេវាធនាគារ	១៤១.៨១៧	៥66.៥៥៩	២៧.៥៩១	១១១.៨២6
ចំណាយទំនាក់ទំនង	១៣១.១១៥	៥២៣.៨0៤	៩៩.0១២	៣៩៩.៩0៩
ចំណាយកម្រៃអាជ្ញាប័ណ្ណ	១២៨.៤៨២	៥១៣.២៨6	១២0.២0២	៤៨៧.១៧៩
ចំណាយជួសជុល និងថែទាំ	១១៨.៥0១	៤៧៣.៤១១	១0៥.6១0	៤២6.៥៥៩
អត្ថប្រយោជន៍ក្រុមប្រឹក្សាភិបាល	១១១.៨៧៣	៤៤6.៩៣៣	៩6.១66	៣៨៨.៤១៤
ចំណាយសម្ភារការិយាល័យ	៧៧.06៣	៣0៧.៨6៧	១06.១៩៤	៤២៨.៩១៨
ចំណាយហិរញ្ញប្បទានពាណិជ្ជកម្ម	៥៨.១0៤	២៣២.១២៥	-	-
កម្រៃផ្នែកច្បាប់ និងវិជ្ជាជីវៈ	៣៨.៧6៣	១៥៤.៨៥៨	៣0.៤៤២	១២២.៩៥៥
ចំណាយផ្សេងៗ	២៣6.៣6៩	៩៤៤.២៩៤	២0៩.២១១	៨៤១.6៧៧
	២.១២១.៩៨0	៨.៤៧៧.៣១១	១.៣៥៨.6៩២	៥.៤៨៧.៧៥៨

២0. ចំណាយពន្ធលើប្រាក់ចំណេញ

	សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២		សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ (ពន្ធអប្បបរមា)	6៣.0១0	២៥១.៧២៥	១៨.៥៧២	៧៥.0១២

២០. ចំណាយពន្ធលើប្រាក់ចំណេញ (ត)

(ក) **ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញ**

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញ ដែលបានគណនាតាមអត្រាពន្ធ២០%លើចំនួនពន្ធលើប្រាក់ចំណេញ ត្រូវបាន បង្ហាញនៅក្នុងរបាយការណ៍លទ្ធផលដូចខាងក្រោម :

	សម្រាប់រយៈពេលឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២		សម្រាប់រយៈពេលឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១	
	ដុល្លារអាមេរិក	**ពាន់រៀល**	**ដុល្លារអាមេរិក**	**ពាន់រៀល**
ខាតមុនបង់ពន្ធលើប្រាក់ចំណេញ	(២.០០២.៧៨៩)	(៨.០០១.១៤២)	(៣.២៥៣.៦៨៧)	(១៣.១៤១.៦៤១)
ពន្ធលើប្រាក់ចំណេញគណនាតាមអត្រា ២០%	(៤០០.៥៥៨)	(១.៦០០.២២៨)	(៦៥០.៧៣៧)	(២.៦២៨.៣២៨)
ផលប៉ះពាល់ពន្ធទាក់ទិននឹង :				
ចំណាយដែលមិនអាចកាត់កងតាមច្បាប់ពន្ធ	២៦.៥៧៥	១០៦.១៦៧	១៨.៣៤៦	៧៤.០៩៩
ពន្ធលើប្រាក់ចំណេញតាមអត្រា២០%	-	-	-	-
ពន្ធអប្បបរមា	៦៣.០១០	២៥១.៧២៥	១៨.៥៧២	៧៥.០១២

(ខ) **ពន្ធអប្បបរមា**

ពន្ធលើប្រាក់ចំណេញរបស់ធនាគារត្រូវបានគណនាដោយផ្អែកលើពន្ធអប្បបរមា។ ពន្ធអប្បបរមា ត្រូវបានគណនាតាមអត្រា ១% នៃផលរបរប្រចាំឆ្នាំ រួមបញ្ចូលរាល់ពន្ធទាំងអស់ ។ ពន្ធលើប្រាក់ចំណេញ ត្រូវបង់តាមអត្រាណាមួយដែល ខ្ពស់ជាង រវាងអត្រាពីរខាងក្រោមនេះ :

- ២០% លើប្រាក់ចំណេញជាប់ពន្ធ ឬ
- ពន្ធអប្បបរមា ១%នៃផលរបរសរុប រួមបញ្ចូលអាករលើតម្លៃបន្ថែម ។

(គ) **បញ្ហាពន្ធផ្សេងៗ**

លិខិតប្រកាសពន្ធរបស់ធនាគារ ត្រូវត្រួតពិនិត្យដោយអគ្គនាយកដ្ឋានពន្ធដារតាមការិយបរិច្ឆេទ។ ដោយសារការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពន្ធដារទៅលើប្រតិបត្តិការផ្សេងៗ អាចមានការបកស្រាយខុសៗគ្នា ហេតុនេះចំនួនពន្ធដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អាចមានការផ្លាស់ប្តូរនៅពេលក្រោយ អាស្រ័យលើការកំណត់ចុងក្រោយដោយអគ្គនាយកដ្ឋានពន្ធដារ ។

២១. សាច់ប្រាក់បានពីប្រតិបត្តិការ

		សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២		សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ខាតមុនបង់ពន្ធលើប្រាក់ចំណេញ	(២.០០២.៧៨៩)	(៨.០០១.១៤២)	(៣.២៥៣.៦៨៧)	(១៣.១៤១.៦៤១)
និយ័តកម្ម :				
សវិធានធនលើបំណុលសង្ស័យ	៤២២.០២១	១.៦៨៥.៩៧៤	៤២៣.៨០០	១.៧១១.៧២៨
រំលស់ទ្រព្យសម្បត្តិនិងបរិក្ខារ (កំណត់សម្គាល់៨)	១.២៧៣.៣៤៥	៥.០៨៧.០១៣	៧៣៦.១៤១	២.៩៧៣.២៧៣
រំលស់ទ្រព្យសកម្មអរូបី (កំណត់សម្គាល់៩)	៥៧៦.៨១៨	២.៣០៤.៣៨៨	៤៨២.០០៦	១.៩៤៦.៨២៣
ចំណូលការប្រាក់សុទ្ធ	(៣.៦៥៧.១៤៨)	(១៤.៦១០.៣០៦)	(១.១០៥.១៧៦)	(៤.៤៦៣.៨០៦)
ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទ្រព្យសកម្ម និងបំណុលប្រតិបត្តិការ	(៣.៣៨៧.៧៥៣)	(១៣.៥៣៤.០៧៣)	(២.៧១៦.៩១៦)	(១០.៩៧៣.៦២៣)
បម្រែបម្រួលទ្រព្យសកម្មនិងបំណុលប្រតិបត្តិការ				
តណាទាននិងបុរេប្រទានអតិថិជន	(៤២.២១៥.៤៥៣)	(១៦៦.៧៨៦.៦០៤)	(៤២.៣៦៦.៦២៩)	(១៧១.១១៨.៨១៤)
ទ្រព្យសកម្មផ្សេងៗ	(៣៥៨.២០៩)	(១.៤៣១.០៤៥)	(២២០.៤៥៤)	(៨៩០.៤១៤)
ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ	២០.៤១៤.២៥៦	៨១.៤២១.៥៧៧	៣.០១១.២៥៥	១២.១៦២.១៧៩
ប្រាក់បញ្ញើរបស់អតិថិជន	៤៨.៧២៨.៦៣៦	១៩៤.៦៧០.៩០១	៤៦.៦២៣.៤៧១	១៨៨.៣១២.១៩៩
ទឹកប្រាក់ត្រូវទារ/ជំពាក់ក្រុមហ៊ុនពាក់ព័ន្ធ	(៣៧២.៩៤៧)	(១.៤៨៩.៩២៣)	(១.០៨៧.១៣១)	(៤.៣៩០.៩២២)
ទឹកប្រាក់ជំពាក់អ្នកផ្គត់ផ្គង់	(២៨៦.៣៦១)	(១.១៤៤.០១២)	(២០៨.៣១២)	(៨៤១.៣៧២)
បំណុលផ្សេងៗ	៩.៣២៣.០០៩	៣៧.២៤៥.៤២១	១.៧៣៧.៩៩៤	៧.០១៩.៧៥៨
សាច់ប្រាក់បានពីប្រតិបត្តិការ	៣១.៨៤៥.១៧៨	១២៨.៩៥២.២៤២	៤.៧៧៣.២៧៨	១៩.២៧៨.៩៩១

២២. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

		សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២		សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
សាច់ប្រាក់ក្នុងដៃ	៧.៤៨៦.៩៤៤	២៩.៩១០.៣៤១	២.៩៧៧.១៨០	១២.០២៤.៨៣០
សមតុល្យនៅធនាគារកណ្តាល :				
គណនីចរន្ត	៣៤.១២៦.៦៣៨	១៣៦.៣៣៥.៩១៩	១២.៤៧១.២៥៥	៥០.៣៧១.៣៩៩
ប្រាក់បញ្ញើមានកាលកំណត់ (កាលកំណត់តិចជាង៣ខែ)	៥.000.000	១៩.៩៧៥.000	១0.000.000	៤0.៣៩0.000
សមតុល្យនៅធនាគារផ្សេងៗ :				
គណនីចរន្ត	៤.១២0.១៣៦	១៦.៤៥៩.៩៤៣	៦.៥៨៩.៥៥៤	២៦.៦១៥.២0៩
ប្រាក់បញ្ញើ	៧.៨00.000	៣១.១៦១.000	-	-
	៥៨.៥៣៣.៧១៨	២៣៣.៨៤២.២0៣	៣២.0៣៧.៩៨៩	១២៩.៤0១.៤៣៨

២៣. កិច្ចសន្យា និងបំណុលយថាហេតុ

ក. កិច្ចសន្យាពន្យារឥណទាន

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ធនាគារមានចំនួនទឹកប្រាក់ក្នុងកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុក្រៅតារាងតុល្យការរបស់ធនាគារ ដែលត្រូវពន្យារឥណទានជូនអតិថិជនដូចខាងក្រោម :

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
កិច្ចសន្យាឥណទាន	៥.000.៩១0	១៩.៩៧៨.៦៣៥	៥.៤៥៥.៦00	២២.0៣៥.១៦៨
លិខិតឥណទាន	៧.២២៧.១៥៤	២៨.៨៧២.៤៨0	-	-
លិខិតទទួលស្គាល់ឥណទាន	៤៤៧.៤២២	១.៧៨៧.៤៥១	-	-
ចំណែកឥណទានវិបារូបនីដែលមិនបានប្រើប្រាស់	១១.៩៣៤.៣២៣	៤៧.៦៧៧.៦២១	៩.៣២៣.៥៤0	៣៧.៦៥៧.៧៧៨
	២៤.៦0៩.៨0៩	៩៨.៣១៦.១៨៧	១៤.៧៧៩.១40	៥៩.៦៩២.៩4៦

ខ. កិច្ចសន្យាភតិសន្យាប្រតិបត្តិ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ធនាគារមានកិច្ចសន្យាភតិសន្យាដែលមិនអាចលុបចោលបាន ទាក់ទិននឹងភតិសន្យាលើការជួលអគារ ។

ចំណាយភតិសន្យាអប្បបរមាសរុបនាពេលអនាគត ដែលត្រូវបង់ក្រោមប្រតិបត្តិការភតិសន្យាដែលធនាគារមិនអាចលុបចោលបានមានដូចខាងក្រោម :

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
មិនលើសពី១ឆ្នាំ	៤១៧.៦៧២	១.៦៦៨.៦00	៣៤៥.១២0	១.៣៩៣.៩40
លើសពី១ឆ្នាំ តែមិនលើសពី៥ឆ្នាំ	២៥២.៥៧៨	១.00៩.04៩	៤៨៣.៨៥៥	១.៩៥4.២៨៨
	៦៧0.២៥0	២.៦៧៧.៦4៩	៨២៨.៩៧៥	៣.៣4៨.២២៨

២4. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ

ក. ភាគីពាក់ព័ន្ធ និងទំនាក់ទំនង

ធនាគារត្រូវបានកាន់កាប់ទាំងស្រុងដោយ CIMB Bank Berhad ដែលមានអាជ្ញាប័ណ្ណចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសម៉ាឡេស៊ី ។ ក្រុមហ៊ុន CIMB Group Holdings Berhad ជាក្រុមហ៊ុនមេដែលបានចុះបញ្ជីជាក្រុមហ៊ុនសាជីវកម្ម នៅប្រទេសម៉ាឡេស៊ី ។

ថ្នាក់គណៈគ្រប់គ្រងសំខាន់ៗរបស់ធនាគារ រួមមានសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ ជាអ្នកដែលធ្វើការការសម្រេចចិត្តសំខាន់ៗពាក់ព័ន្ធទៅនឹងគោលដៅយុទ្ធសាស្ត្ររបស់ធនាគារ ព្រមទាំងអ្នកគ្រប់គ្រងជាន់ខ្ពស់ (រួមមាន សមាជិកក្រុមគ្រួសារជិតដិតរបស់ពួកគេផងដែរ) ។

២៤. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ (ត)

ខ. សមតុល្យភាគីពាក់ព័ន្ធ

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទឹកប្រាក់ដែលធនាគារជំពាក់ :				
ក្រុមហ៊ុនមេ :				
ទឹកប្រាក់ជំពាក់ CIMB Bank Berhad (កំណត់សម្គាល់ ១២)	៤៤.៥៥៤	១៧៧.៩៩៣	៣៨៤.៥២៨	១.៥៥៣.១០៩
ប្រាក់បញ្ញើរបស់គណៈគ្រប់គ្រងជាន់ខ្ពស់	១៧៦.៦៦៧	៧០៥.៧៨៥	៦.៨៤៣	២៧.៦៣៩
	២២១.២២១	៨៨៣.៧៧៨	៣៩១.៣៧១	១.៥៨០.៧៤៨
ទឹកប្រាក់ដែលក្រុមហ៊ុនពាក់ព័ន្ធជំពាក់ :				
ប្រាក់បញ្ញើនៅ :				
ក្រុមហ៊ុនមេ :	៩.២៤៥.០៩២	៣៦.៩៣៤.១៤២	៦.៥៧០.៧៤១	២៦.៥៣៩.២២៣
ក្រុមហ៊ុនញាតិសម្ព័ន្ធ :	១.៩៦៧.៣១២	៧.៨៥៩.៤១១	១៨.៨១៣	៧៥.៩៨៦

គ. ប្រតិបត្តិការភាគីពាក់ព័ន្ធ

	សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២		សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណាយ :				
ចំណាយការប្រាក់ដែលបង់/ត្រូវបង់លើប្រាក់បញ្ញើ				
របស់គណៈគ្រប់គ្រងជាន់ខ្ពស់	១.២៩៨	៥.១៨៦	៣០៧	១.២៤០

ឃ. លាភការគណៈគ្រប់គ្រងសំខាន់ៗ

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល	១១១.៨៧៣	៤៤៦.៩៣៣	៩៦.១៦៦	៣៨៨.៤១៤
ប្រាក់ឈ្នួលវត្ស និងអត្ថប្រយោជន៍រយៈពេលខ្លី	២៩០.៨៣៦	១.០០២.០៩០	៣១៥.៣៨៦	១.២៧៣.៨៤៤
	៣៦២.៧០៩	១.៤៤៩.០២៣	៤១១.៥៥២	១.៦៦២.២៥៨

២៥. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

សកម្មភាពរបស់ធនាគារប្រឈមនឹងហានិភ័យហិរញ្ញវត្ថុផ្សេងៗមួយចំនួនដូចជា ហានិភ័យឥណទាន ហានិភ័យទីផ្សារ (រួមមាន ហានិភ័យរូបិយវត្ថុបរទេស និងហានិភ័យអត្រាការប្រាក់) ហានិភ័យសាច់ប្រាក់ងាយស្រួល និងហានិភ័យប្រតិបត្តិការ។ សកម្មភាពអាជីវកម្មហិរញ្ញវត្ថុជាចម្បងទទួលយកនូវហានិភ័យ ហើយហានិភ័យប្រតិបត្តិការ គឺជាផលវិបាកដែលមិនអាចជៀសរួចក្នុងដំណើរការអាជីវកម្ម។ ធនាគារមិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិទស្សន៍ ដើម្បីគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ខ្លួននោះទេ។

២៥. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ធនាគារកាន់កាប់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដូចខាងក្រោម :

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្មហិរញ្ញវត្ថុ				
សាច់ប្រាក់ក្នុងដៃ	៧.៤៨៦.៩៤៤	២៩.៩១០.៣៤១	២.៩៧៧.១៨០	១២.០២៤.៨៣០
សមតុល្យនៅធនាគារកណ្តាល	៥៥.៣៨១.៦៣៨	២២១.២៤៩.៦៤៤	៣២.៤២៦.២៥៥	១៣០.៩៦៩.៦៤៤
ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ	១១.៩២០.១៣៦	៤៧.៦២០.៩៤៣	៦.៥៨៩.៥៥៤	២៦.៦១៥.២០៩
ឥណទាន និងបុរេប្រទានអតិថិជន (*)	៨៤.៥៨២.០៨២	៣៣៧.៩០៥.៤១៨	៤២.៣៦៦.៦២៩	១៧១.១១៨.៨១៤
ទឹកប្រាក់ត្រូវទារក្រុមហ៊ុនពាក់ព័ន្ធ	៣៤.៨៧៥	១៣៩.៣២៦	១.៩០២	៧.៦៨២
ទ្រព្យសកម្មផ្សេងៗ	៨៤០.៣១៩	៣.៣៥៧.០៧៤	៣៩៣.៩៦៩	១.៥៩១.២៤១
	១៦០.២៤៥.៩៩៤	៦៤០.១៨២.៧៤៦	៨៤.៧៥៥.៤៨៩	៣៤២.៣២៧.៤២០
បំណុលហិរញ្ញវត្ថុ				
ប្រាក់បញ្ញើរបស់ធនាគារ	២៣.៤៤៥.៥០១	៩៣.៦៦៤.៧៧៦	៣.០៣១.២៤៥	១២.២៤៣.១៩៩
ប្រាក់បញ្ញើរបស់អតិថិជន	៩៨.៣៦៣.២៣០	៣៩២.៩៦១.១០៤	៤៩.៦៣៤.៥៩៤	២០០.៤៧៤.១២៥
ទឹកប្រាក់ជំពាក់ក្រុមហ៊ុនពាក់ព័ន្ធ	៤៤.៥៥៤	១៧៧.៩៩៣	៣៨៤.៥២៨	១.៥៥៣.១០៩
ទឹកប្រាក់ជំពាក់អ្នកផ្គត់ផ្គង់	៦៤៩.៤៧៣	២.៥៩៤.៦៤៥	៩៣៥.៨៣៤	៣.៧៧៩.៨៣៤
បំណុលផ្សេងៗ	១១.៣៨១.៧៥០	៤៥.៤៧០.០៩១	២.១៩៧.៩៨៣	៨.៨៧៧.៦៥៣
	១៣៣.៨៨៤.៥០៨	៥៣៤.៨៦៨.៦០៩	៥៦.១៨៤.១៨៤	២២៦.៩២៧.៩២០
ទ្រព្យសកម្មហិរញ្ញវត្ថុ-សុទ្ធ	២៦.៣៦១.៤៨៦	១០៥.៣១៤.១៣៧	២៨.៥៧១.៣០៥	១១៥.៣៩៩.៥០០

(*) មិនរាប់បញ្ចូលសវិធានធនទូទៅចំពោះឥណទានបាត់បង់ ។

២៥.១ ហានិភ័យឥណទាន

ធនាគារត្រូវប្រឈមមុខនឹងហានិភ័យឥណទាន ជាហានិភ័យដែលកើតឡើងដោយភាគីដៃគូរបស់ធនាគារ នឹងធ្វើឱ្យមានការខាតបង់ដល់ធនាគារ ដោយការខកខានក្នុងការបំពេញកាតព្វកិច្ចតាមកិច្ចសន្យា ។ ហានិភ័យឥណទាន គឺជាហានិភ័យដែលសំខាន់ជាងគេបង្អស់ក្នុងអាជីវកម្មធនាគារ ។ ហានិភ័យឥណទាន ភាគច្រើនកើតមកពីសកម្មភាពនៃការផ្តល់ឥណទាន និងបុរេប្រទាន ។ ឧបករណ៍ហិរញ្ញវត្ថុក្រៅខ្លង់តារាងតុល្យការក៏មានហានិភ័យឥណទានដែរ ដូចជាកិច្ចសន្យា ឥណទានជាដើម ។ ការគ្រប់គ្រងហានិភ័យឥណទាន ត្រូវបានធ្វើឡើងដោយគណៈកម្មាធិការឥណទានរបស់ធនាគារ ។

ហានិភ័យឥណទាន ត្រូវបានគ្រប់គ្រងតាមរយៈការវិភាគជាប្រចាំទៅលើលទ្ធភាពរបស់អ្នកខ្ចីប្រាក់ និងអ្នកខ្ចីប្រាក់ ដែលមានសក្តានុពល ក្នុងការបំពេញកាតព្វកិច្ចសងការប្រាក់ និងប្រាក់ដើម ។ ហានិភ័យឥណទានក៏ត្រូវបានគ្រប់គ្រង តាមរយៈការទទួលវត្ថុបញ្ចាំ និងការធានាជាបុគ្គល ។

(ក) ការវាស់វែងហានិភ័យឥណទាន

ធនាគារបានបង្កើតគោលការណ៍ហានិភ័យឥណទានស្នូល (Core Credit Risk Policy) ដែលរៀបចំឡើងដើម្បីអភិបាលសកម្មភាពក្នុងការធានារ៉ាប់រងហានិភ័យ ។ ការបន្តឥណទានត្រូវបានអភិបាលដោយកម្មវិធីឥណទាន ដែលបានរៀបចំគម្រោងសម្រាប់ផលិតផល ឬសំព្យៃតឥណទានពិសេស រាប់ទាំងទីផ្សារគោលដៅ កាលកំណត់ និងលក្ខខណ្ឌ ឯកសារសំអាង និងនីតិវិធី នៅក្រោមផលិតផលឥណទាន ដែលនឹងត្រូវបានវាស់វែងនិងផ្តល់ឱ្យ ។

ធនាគារក៏អះអាងផងដែរថា ខ្លួនមានការបែងចែកតួនាទីច្បាស់លាស់ រវាងកាតព្វកិច្ចអ្នកលើកសំណើឥណទាន (loan originators) អ្នកវាយតម្លៃឥណទាន (evaluators) និងកម្រិតការអនុម័តឥណទាន (approving authorities) ។

២៥. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

២៥.១ ហានិភ័យឥណទាន (ត)

(ខ) ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍គ្រប់គ្រងហានិភ័យ

ធនាគារគ្រប់គ្រងកម្រិតឥណទាន និងត្រួតពិនិត្យការប្រមូលផ្តុំហានិភ័យឥណទាន នៅពេលដែលពួកគេរកឃើញ ជាពិសេសទៅលើដៃគូជាបុគ្គល និងជាក្រុម ព្រមទាំងវិស័យផ្សេងៗ។

ធនាគាររៀបចំរចនាសម្ព័ន្ធតាមកម្រិតនៃហានិភ័យឥណទាន ដោយដាក់កម្រិតលើចំនួនទឹកប្រាក់នៃហានិភ័យ ដែលអាចទទួលយកបានទាក់ទងនឹងអ្នកខ្ចីឯកត្តជន ឬអ្នកខ្ចីជាក្រុម និងតាមវិស័យផ្សេងៗ។ ហានិភ័យនេះត្រូវបានត្រួតពិនិត្យតាមមូលដ្ឋានរង្វិល ហើយនឹងត្រូវត្រួតពិនិត្យឡើងវិញប្រចាំឆ្នាំ ឬញឹកញាប់ជាងនេះតាមការចាំបាច់។ ការដាក់កំណត់លើកម្រិតហានិភ័យឥណទានតាមផលិតផល និងតាមវិស័យអាជីវកម្ម ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ហានិភ័យធំៗត្រូវបានកំណត់និយមន័យដោយធនាគារកណ្តាល ថាជាហានិភ័យឥណទានទូទៅចំពោះអ្នកទទួលផលឯកត្តជន ដែលលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។ យោងតាមលក្ខខណ្ឌនៃប្រកាសលេខ ធ៧-០៦-២២៦ប្រ.ក. របស់ធនាគារកណ្តាល ធនាគារចាំបាច់ត្រូវរក្សាគ្រប់ពេលវេលានូវអនុបាតអតិបរមា ចំនួន ២០% រវាងហានិភ័យឥណទានទូទៅរបស់ធនាគារ ធៀបនឹងអ្នកទទួលផលឯកត្តជនណាមួយ និងមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។ ហានិភ័យឥណទានធំៗសរុប មិនត្រូវលើសពី ៣០០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារទេ។

ធនាគារប្រើប្រាស់គោលការណ៍ និងការអនុវត្តជាច្រើនដើម្បីកាត់បន្ថយហានិភ័យឥណទាន រួមទាំងការតម្រូវឱ្យអ្នកខ្ចីប្រាក់ដាក់វត្ថុបញ្ចាំលើឥណទាន និងបុរេប្រទានដែលធនាគារផ្តល់ឱ្យ។

(គ) គោលការណ៍សវិធានធន និងការថយចុះតម្លៃ

ធនាគារត្រូវអនុវត្តតាមការចាត់ថ្នាក់ឥណទាន និងសវិធានធន អនុលោមតាមប្រកាសពាក់ព័ន្ធដូចមានបញ្ជាក់នៅក្នុងកំណត់សម្គាល់ ២.ខ នៃរបាយការណ៍ហិរញ្ញវត្ថុ។

ឥណទាន និងបុរេប្រទាន ដែលហួសកាលកំណត់សងតិចជាង ៩០ថ្ងៃ មិនត្រូវបានចាត់ទុកថាមានការថយចុះតម្លៃទេ លើកលែងតែមានព័ត៌មានបញ្ជាក់ផ្សេងពីនេះ។

(ឃ) ហានិភ័យអតិបរមានៃឥណទាន មុនរាប់បញ្ចូលវត្ថុបញ្ចាំ ឬមុនការបង្កើនឥណទានផ្សេងៗ

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	**ពាន់រៀល**	**ដុល្លារអាមេរិក**	**ពាន់រៀល**
ហានិភ័យឥណទានពាក់ព័ន្ធនឹងទ្រព្យសកម្មក្នុងតារាងតុល្យការ :				
សមតុល្យនៅធនាគារផ្សេងៗ	១១.៩២០.១៣៦	៤៧.៦២០.៩៤៣	៦.៥៨៩.៥៥៤	២៦.៦១៥.២០៩
ឥណទាន និងបុរេប្រទានអតិថិជន (*)	៨៤.៥៨២.០៨២	៣៣៧.៩០៥.៤១៨	៤២.៣៦៦.៦២៩	១៧១.១១៨.៨១៤
ទឹកប្រាក់ក្រុមហ៊ុនពាក់ព័ន្ធជំពាក់	៣៤.៨៧៥	១៣៩.៣២៦	១.៩០២	៧.៦៨២
ទ្រព្យសកម្មផ្សេងៗ	៨៤០.៣១៩	៣.៣៥៧.០៧៤	៣៩៣.៩៦៩	១.៥៩១.២៤១
ហានិភ័យឥណទានពាក់ព័ន្ធនឹងខ្ទង់ក្រៅតារាងតុល្យការ :				
កិច្ចសន្យាឥណទាន	៥.០០០.៩១០	១៩.៩៧៨.៦៣៥	៥.៤៥៥.៦០០	២២.០៣៥.១៦៨
លិខិតឥណទាន	៧.២២៧.១៥៤	២៨.៨៧២.៤៨០	-	-
លិខិតទទួលស្គាល់ឥណទាន	៤៤៧.៤២២	១.៧៨៧.៤៥១	-	-
ចំណែកឥណទានវិបារូបនីដែលមិនទាន់បានប្រើ	១១.៩៣៤.៣២៣	៤៧.៦៧៧.៦២១	៩.៣២៣.៥៤០	៣៧.៦៥៧.៧៧៨
	១២១.៩៨៧.២២១	៤៨៧.៣៣៨.៩៤៨	៦៤.១៣១.១៩៤	២៥៩.០២៥.៨៩២

(*) មិនរាប់បញ្ចូលសវិធានធនទូទៅចំពោះឥណទានបាត់បង់។

២៥. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

២៥.១ ហានិភ័យឥណទាន (ត)

(ឃ) ហានិភ័យអតិបរមានៃឥណទាន មុនរាប់បញ្ចូលវត្ថុបញ្ចាំ ឬមុនការបង្កើនឥណទានផ្សេងៗ (ត)

តារាងខាងលើនេះបង្ហាញពីស្ថានភាពអាក្រក់បំផុតនៃហានិភ័យឥណទានរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ និង ២០១១ ដោយមិនគិតលើវត្ថុបញ្ចាំ ឬការបង្កើនឥណទានផ្សេងទៀតឡើយ។ ចំពោះទ្រព្យសកម្មក្នុងតារាងតុល្យការ ហានិភ័យដែលបានបង្ហាញខាងលើគឺផ្អែកទៅលើតម្លៃយោងសុទ្ធ ដោយមិនរាប់បញ្ចូលសវិធានធនទូទៅ។

ដូចបានបង្ហាញខាងលើ ៦៥% នៃហានិភ័យឥណទានអតិបរមាសរុប បានមកពីឥណទាន និងបុរេប្រទានអតិថិជន។

គណៈគ្រប់គ្រងមានជំនឿថាខ្លួនមានលទ្ធភាពបន្តការគ្រប់គ្រង និងទ្រទ្រង់ហានិភ័យឥណទានរបស់ធនាគារ ដែលបណ្តាលមកពីឥណទាន និងបុរេប្រទាន ឱ្យស្ថិតនៅក្នុងកម្រិតអប្បបរមាតាមវិធីដូចខាងក្រោម :

- ឥណទាន និងបុរេប្រទានស្ទើរតែទាំងអស់របស់ធនាគារ ត្រូវបានធានាដោយវត្ថុបញ្ចាំ ហើយឥណទានដែលបានផ្តល់គឺត្រឹមតែ៦0% ទៅ៧0%នៃតម្លៃវត្ថុបញ្ចាំប៉ុណ្ណោះ ។
- សំពៀតឥណទានស្ទើរតែទាំងអស់ មិនត្រូវបានចាត់ទុកថាហួសកាលកំណត់សង និងថយចុះតម្លៃទេ។
- ធនាគារមាននីតិវិធីវាយតម្លៃឥណទានយ៉ាងសមរម្យ ក្នុងការផ្តល់ឥណទាន និងបុរេប្រទានជូនអតិថិជន។

(ង) ឥណទាន និងបុរេប្រទាន

ឥណទាន និងបុរេប្រទានត្រូវបានសង្ខេបដូចខាងក្រោម :

	៣១ ធ្នូ ២០១២		៣១ ធ្នូ ២០១១	
	ដុល្លារអាមេរិក	**ពាន់រៀល**	**ដុល្លារអាមេរិក**	**ពាន់រៀល**
ឥណទាន និងបុរេប្រទានដែលមិនហួសកំណត់សង និងមិនថយចុះតម្លៃ	៨៤.៥៨២.0៨២	៣៣៧.៩0៥.៤១៨	៤២.៣៦៦.៦២៩	១៧១.១១៨.៨១៤
ដក :				
សវិធានធនលើបំណុលសង្ស័យ	(៨៤៥.៨២១)	(៣.៣៧៩.0៥៥)	(៤២៣.៨00)	(១.៧១១.៧២៨)
ឥណទាន និងបុរេប្រទានសុទ្ធ	៨៣.៧៣៦.២៦១	៣៣៤.៥២៦.៣៦៣	៤១.៩៤២.៨២៩	១៦៩.40៧.0៨៦

អនុលោមទៅតាមគោលការណ៍របស់ធនាគារកណ្តាល ផលដែលរំពឹងថានឹងអាចប្រមូលបានមកវិញពីវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់) មិនត្រូវបានគិតបញ្ចូលក្នុងការធ្វើសវិធានធនឥណទានទេ។ សវិធានធនលើឥណទានបាត់បង់ សរុបមានចំនួន ៨៤៥.៨២១ ដុល្លារអាមេរិក គឺជាសវិធានធនទូទៅ១%នៃឥណទាន និងបុរេប្រទានដែលនៅមិនទាន់ទូទាត់ទាំងអស់។

i. ឥណទាន និងបុរេប្រទានដែលមិនទាន់ផុតកំណត់សង និងមិនទាន់ថយចុះតម្លៃ

ឥណទាន និងបុរេប្រទានដែលមិនទាន់ផុតកំណត់សង មិនត្រូវបានចាត់ទុកថាថយចុះតម្លៃទេ លុះត្រាតែមាន ព័ត៌មានផ្សេងបញ្ជាក់ផ្ទុយពីនេះ។

ii. ឥណទាន និងបុរេប្រទានដែលផុតកំណត់ ប៉ុន្តែមិនទាន់ថយចុះតម្លៃ

ឥណទាន និងបុរេប្រទានដែលផុតកំណត់សងតិចជាង ៩0ថ្ងៃ មិនត្រូវបានចាត់ទុកថាថយចុះតម្លៃទេ លុះត្រាតែមានព័ត៌មានផ្សេងបញ្ជាក់ផ្ទុយពីនេះ។

